អភិធម្មត្ថវិភាវិនី

សម្តេចព្រះធម្មលិខិត ឧត្តមប្រីក្សា

ព្រះនាម ល្វី - ឯម រដ្ឋបញ្ញោ

ប្រែនិងរៀបរៀង

តាមគម្ពីរបាលី អដ្ឋកថាដីកា យោជនាអភិធម្ម

ឆ្នាំ ព.ស. ២៤៨៩ - គ.ស. ១៩៤៦

គណៈធម្មត្ថទីបនីសម្តេចសង្ឃនាយកជុំវិញព័រគណៈ

បានអនុញ្ញាតហើយ

បោះពុម្ពលើកទី ២

ក្នុងឆ្នាំ ព.ស. ២៥០៨ - គ.ស. ១៩៦៥

ការផ្សាយរបស់បណ្ណាគារ ជីន - ថោ - ហួត

លេខ ១៤០ វិថីព្រះភគ្នាទេវ ភ្នំពេញ

ផ្សាយចេញពី

www.haotrai.com

ចែកជាឆមួយជាយ





អនិច្ចសុត្តាធិប្បាយ

សម្តេចព្រះធម្មលិខិត ឧត្តមប្រីក្សា

ព្រះនាម ល្វី - ឯម រដ្ឋបណ្ឌិត

ប្រែនិងរៀបរៀង

តាមគម្ពីរបាលី អដ្ឋកថាដីកា យោជនាអភិធម្ម

ព.ស. ២៤៨៥ - គ.ស. ១៩៤២

គណៈធម្មត្ថិនិងសម្តេចសង្ឃនាយកទាំងពីរគណៈ

បានគន្ថាភរហើយ

បោះពុម្ពលើកទី ២

ក្នុងព.ស. ២៥០៨ — គ.ស. ១៩៦៥

ការផ្សាយរបស់បណ្ណាគារ ជីង - ហ្គោ - ហួត

លេខ ១៤០ វិថីព្រះសង្ឃរាជ ភ្នំពេញ



ឆាយាលក្ខណ៍ សម្តេចព្រះធម្មលិខិត ល្វី-ឯម

ជាតៈ ថ្ងៃបន្ទុះកើត ខែពិសាខ ឆ្នាំរោងទោស័ក ព.ស. ២៤២២

មតៈ ថ្ងៃអង្គារ ៨កើត ខែពិសាខ ឆ្នាំរកាធឫស័ក ព.ស. ២៥០០

ជីវប្រវត្តិសង្ខេប

នៃសម្តេចព្រះធម្មលិខិត ល្វី-ដម ឧត្តមប្រឹក្សាគណៈមហា-ធិកាបរ អតីតចៅអធិការវត្តលង្កា សង្កាត់លេខ៦ក្រុងភ្នំពេញ

សម្តេចជាបុត្រ នៃចិត្តានាម ល្វីដោ-មាន់ និងលោកស្រី ច្រាក់ កើតនៅថ្ងៃចន្ទ ៥ កើត រោចពិសាខ ឆ្នាំរកាធោស័ក ព.ស ២៤២២ គ.ស ១៨៧៨ នៅក្រុងភ្នំពេញ បានសិក្សារៀនអក្សរសាស្ត្រខ្មែរបេះ ចប់ លុះដល់អាយុ ១៥ ឆ្នាំបានបួសជាសាមណេររៀនសូត្រព្រះវិន័យ-ជាកម្មវត្ថុណ្ណាសោម លុះដល់ព.ស. ២៤៤៣ គ.ស. ១៩០០ បាន ទទួលសម្រេចជាកិត្តិយសសំណាក់សម្តេចព្រះមហាសង្ឃរាជព្រះនាម ជិល-ខៀង ជាព្រះឧបជ្ឈាយ៍ មានឈ្មោះហៅថា "វជីរប្បញ្ញោ" នៅសំ-ណាក់អស្រ័យនឹងព្រះតេជគុណព្រះមហាវិមលធម្ម នាម ជោ ចាន-ហ្វានីទី១ នៃសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ ។

លុះដល់ ព.ស. ២៤៤៩ គ.ស. ១៩០២ មានទុបាសកម្នាក់ឈ្មោះ ចញ្ញា-ចាប នៅឃុំស៊ីធរ បានបួលមកគាន់សំណាក់សម្តេចព្រះមហា សង្ឃរាជនិងព្រះតេជព្រះគុណព្រះមហាវិមលធម្ម សុំនិមន្តទៅធ្វើជាចៅ-អធិការ នៅវត្តស៊ីធរ ឃុំស៊ីធរ ស្រុកទ្រាំងកណ្តាល នៃក្រុកណ្តាល

កំស្រាប់តែស្រដាំកចិត្តគ្រប់គ្នា ។ លោកកំពុងរៀនពីរលោចេញចាកអាចារ្យវត្ត
ស៊ុជរនោះ ពី ព.ស.២៤៥៤ គ.ស.១៩១១ ត្រឡប់មកធ្វើជាចៅអធិការ
វត្តលង្កានេះ ប៉ុន្តែនៅមានព្រះទ័យប្រកបដោយមេត្តាករុណា មិនបាន
កាត់អាល័យចោះបង់ចោលកន្លែងដែលវត្តស៊ុជរនោះឡើយ តែងបាន
ជួយចំនុកចំរុងជាជកចរហូតដល់អស់ព្រះជន្មាយុ ។

ចៅអធិការ ល្អ ឯម ដែលបានទទួលហាន:ជានៅសិកាធិបតី
ចៅគាវាសវត្តលង្កានេះ ពីព.ស.២៤៥៤ គ.ស. ១៩១១ កាលគ្រានោះ
មានតែកុំសង្ឃប្រហែល ១៨ អង្គប៉ុណ្ណោះ ចាត់ការរៀបចំសូចយកព្រះ
បដិមាករអង្គធំដែលកប់នៅក្នុងរណ្តៅដី ដែលគេចាក់កន្ទិរហារលើតទៀត
ដំកល់លើបល្ល័ង្កជាដំបូង ។

លុះដល់ ព.ស. ២៤៦០ គ.ស. ១៩១៣ ចៅអធិការ ល្អ ឯម
បានទទួលហាន:ជាព្រះគ្រូ នៃសបញ្ញា, ដល់ព.ស. ២៤៦៧ គ.ស
១៩១៤-១៥ បានទទួលសមណស័ក្តិជា ព្រះញាណាភរវិជ្ជា ផង
ជាសាស្ត្រាចារ្យនៃសាលាបាលីជាន់ខ្ពស់ផង ។

លុះដល់ ព.ស. ២៤៧២ គ.ស. ១៩២៨ បានឡើងជាចាងហ្វាង
សាលាបាលីជាន់ខ្ពស់ បានតាំងធម្មសភា ១ ខ្នង, ដល់ ព.ស.២៤៧៣

កំស្រាប់តែស្រដាំកចិត្តគ្រប់គ្នា ។ លោកកំពុងរៀនពីរលោចេញចាកអាចារ្យវត្ត
ស៊ុជរនោះ ពី ព.ស.២៤៥៤ គ.ស.១៩១១ ត្រឡប់មកធ្វើជាចៅអធិការ
វត្តលង្កានេះ ប៉ុន្តែនៅមានព្រះទ័យប្រកបដោយមេត្តាករុណា មិនបាន
កាត់អាល័យចោះបង់ចោលកន្លែងដែលវត្តស៊ុជរនោះឡើយ តែងបាន
ជួយចំនុកចំរុងជាជកចរហូតដល់អស់ព្រះជន្មាយុ ។

ចៅអធិការ ល្អ ឯម ដែលបានទទួលហាន:ជានៅសិកាធិបតី
ចៅគាវាសវត្តលង្កានេះ ពីព.ស.២៤៥៤ គ.ស. ១៩១១ កាលគ្រានោះ
មានតែកុំសង្ឃប្រហែល ១៨ អង្គប៉ុណ្ណោះ ចាត់ការរៀបចំសូចយកព្រះ
បដិមាករអង្គធំដែលកប់នៅក្នុងរណ្តៅដី ដែលគេចាក់កន្ទិរហារលើតទៀត
ដំកល់លើបល្ល័ង្កជាដំបូង ។

លុះដល់ ព.ស. ២៤៦០ គ.ស. ១៩១៣ ចៅអធិការ ល្អ ឯម
បានទទួលហាន:ជាព្រះគ្រូ នៃសបញ្ញា, ដល់ព.ស. ២៤៦៧ គ.ស
១៩១៤-១៥ បានទទួលសមណស័ក្តិជា ព្រះញាណាភរវិជ្ជា ផង
ជាសាស្ត្រាចារ្យនៃសាលាបាលីជាន់ខ្ពស់ផង ។

លុះដល់ ព.ស. ២៤៧២ គ.ស. ១៩២៨ បានឡើងជាចាងហ្វាង
សាលាបាលីជាន់ខ្ពស់ បានតាំងធម្មសភា ១ ខ្នង, ដល់ ព.ស.២៤៧៣

គ.ស. ១៩៣០ បានឡើងទាំងជាអធិបតីក្រុមជំនុំប្រែព្រះត្រៃបិដក, គ.ស.១៩៣២ បានឡើងសមណសក្តិជាព្រះស៊ីរសម្ថតវង្ស, នៅថ្ងៃពុធ ១៤ កេីតខែផល្គុន ឆ្នាំរកាបញ្ចស័ក ព.ស.២៤៧៧ គ.ស. ១៩៣៤ បានកសាងកំផែងវត្តព័ទ្ធពីទីទុបចារៈខាងជើង រហូតដល់ទីទុបចារៈខាងកើតទុកជាកំណាត់ព្រំដែន ។ ដល់ព.ស. ២៤៨៥ គ.ស. ១៩៤២ បានសមណស័ក្តិជាព្រះធម្មលិខិត សង្ឃមន្ត្រីសម្រាប់ឯក, បានសាងធម្មកុដិ ១ ខ្នងពី ព.ស. ២៤៨០ គ.ស. ១៩៤៧ ដោយការរួមចំណែកជាមួយនឹងពុទ្ធបរិស័ទនៅស្រុកជិតឆ្ងាយ សម្រាប់សង្ឃគង់នៅក្នុងសាសនា, ដល់ ព.ស ២៤៨៤ គ.ស. ១៩៥១ បានឡើងជាទីសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សាគណៈមហានិកាយ, លុះដល់ ព.ស. ២៤៩៧ សម្តេចបានប្រជុំគ្នាសង្ឃក្នុងវត្តនិងឧបាសកឧបាសិកា ចាត់ការរុះរើវិហារចាស់ហើយកសាងវិហារថ្មី នៅថ្ងៃពុធ ១៥ កេីតខែកត្តិកត្រូវនឹងថ្ងៃទី ១០ ខែវិច្ឆិកា ១៩៥៤ ។

ការកសាងវិហារថ្មីនេះ អស់រយៈកាលជាង ៣ ឆ្នាំ មិនទាន់ហើយស្រេច តំសម្តេចមានភាពជាទម្ងន់ ព្រំនឹងភាពជានោះពុំបានតំណាងឧបាសកឧបាសិកាមុខ នៅថ្ងៃអង្គារ ៨ កេីត ខែវិសាខ ឆ្នាំរកនព្វស័ក ព.ស. ២៥០០ ត្រូវនឹងថ្ងៃទី ៧ ឧសភា គ.ស. ១៩៥៧

គោលមាំង ៥ ទង្គិច ៨០ នាទី ភ្លឺ, អស់កិច្ចជីវិតប្បវត្តិរបស់សម្តេចត្រឹមប៉ុណ្ណេះ ។

បើគិតដល់គុណសម្បត្តិនិងគុណធម៌ របស់សម្តេចព្រះធម្មលិខិត ធម្មប្រឹក្សា គណៈមហានិកាយ ដែលបានចំរើនព្រះពុទ្ធសាសនាអស់រយៈកាល ៦៣ ឆ្នាំ ឃើញថាច្រើនហួសពិស្តារដែលនាំមករៀបរាប់ថ្លែងជីវប្បវត្តិនោះ ឲ្យសព្វគ្រប់ក្នុងទំនេះបាន ព្រោះហេតុនោះពួកពុទ្ធបរិស័ទជាទីស្នេហាទាំងឡាយ បានកសាងរូបសំណាកស្ថិតសិទ្ធដោយស្ថានដ៏ឧត្តុងជាអនុស្សាវរីយ៍ នៅទីវត្តលង្កានេះទុកជាទីគោរពតទៅ ។

ព្រះពុទ្ធវង្ស កៅ-សុឹម
បៀអធិការវត្តលង្កា ជាសិស្សផ្ទាល់
បានរៀបរៀង

សេចក្តីអធិប្បាយ

សៀវភៅ "អតិធម្មត្ថាធិប្បាយ" ដែលជាស្នាព្រះហស្តរបស់ព្រះសពសម្តេចព្រះធម្មលិខិត ល្អី-ឯម ១ក្តមប្រឹក្សាគណមហានិកាយ អតីតចៅអធិការវត្តលង្កា ក្រុងភ្នំពេញ ឲ្យចំពោះចៅកែ ជឹង-ចាំ-ហួត ផ្ទះលេខ ១៤០ ជាពាណិជ្ជករ ក្រុងភ្នំពេញ ចោះជាថ្មីចំនួន ២០០០ ក្បាល ជាលើកទី ២ ហើយមិនបានអនុញ្ញាតបន្តាប់នេះឲ្យចោះតទៅទៀតទេ ។

ចៅកែរូបនេះ បានបួលមកសុំអនុញ្ញាតចោះពុម្ពសៀវភៅនេះ ចំពោះព្រះរោសធម្ម ចៅអធិការវត្តលង្កា ជាសិស្សផ្ទាល់របស់សម្តេច ដោយបានជឿថា "ព្រះសពសម្តេចកាលនៅព្រះជន្មនៅ មានចំណងចង់ចោះពុម្ពសៀវភៅនេះជាលើកទី ២ ចំណងនេះមិនទាន់បានសំរេច ក៏ព្រះអង្គលោកអនិច្ចធម្មទៅ សៀវភៅនេះក៏ទ្រឹងជកាបមកដល់សព្វថ្ងៃនេះ, ទើបតែឥឡូវនេះ ចៅកែ ជឹង-ចាំ-ហួត សុំអនុញ្ញាតចោះពុម្ពជាថ្មី ដើម្បីជាប្រយោជន៍ឲ្យសមតាមចំណងរបស់ពុទ្ធសាសនិក អ្នកត្រូវការសិក្សាប្រតិបត្តិក្នុងព្រះពុទ្ធសាសនា" ។

ដូច្នេះ ការចោះពុម្ពសៀវភៅនេះ មិនបានអនុញ្ញាតឲ្យប៉ះពាល់ជាកំសេចក្តីបន្ថែមបំពេញនោះឡើយ ត្រូវដំកល់ទុកសេចក្តីដើមឲ្យនៅដូចដើមជាដែល ។

សូម ។ ខ្ញុំសូមសុំសេចក្តីសុខ ចំពោះព្រះសពសម្តេចព្រះធម្មលិខិត ។ តែមប្រឹក្សា សូមឲ្យបានប្រកបដោយសេចក្តីសុខចំរើនក្នុងទេវលោកកុំបីឃ្លៀងឃ្លាត ។

ភ្នំពេញ ថ្ងៃ ១៦ - ៨ - ៦៨

ព្រះយោសធម្ម

ប្រោះពុម្ពលើកទី ១

ក្នុង គ.ស. ១៩៤៨

លោកអ្នកឧកញ៉ា ឃឹម - ទិត អតីតរដ្ឋមន្ត្រី

ជាអ្នកចាត់ចែងប្រោះពុម្ព

ដោយសេចក្តីឧបត្ថម្ភរបស់សម្តេចក្រុមព្រះមុនីវង្ស

បញ្ជីមាតិការឿង

បញ្ញា		ទំព័រ	បន្ទាត់
	អារម្ភកថា	១	១
	នមស្សការ	៥	១
	អភិធម្មត្ថាធិប្បាយ		
	អភិធម្មុប្បត្តិហេតុកថា	៦	៤
ទី ១	សូរអំពីពាក្យថាអភិធម្ម		៩
- ២	សូរអំពីអភិធម្មអ្នកណាសំដែងទុកមក . . .		១៣
- ៣	ព្រះអរហំសម្មាសម្ពុទ្ធព្រាស់បានប៉ុន្មានវស្សាសំដែងអភិធម្ម	៧	៧
- ៤	ព្រះជិនស្រីសំដែងអភិធម្មថ្វាយព្រះសិរិមហាមាយា	៨	៥
- ៥	អំពីព្រះសិរិមហាមាយាបិតនៅឋានណា . . .	៩	៨
- ៦	អំពីសិរិមហាមាយាបិតនៅឋានតុសិតជាដើម		១៥
- ៧	អំពីព្រះអនាវរញ្ញាណប្រកបដោយកតញ្ញូធម៌ .	១០	១១
- ៨	អំពីហេតុទី ៤ នៃសព្រះពុទ្ធមាតាចុះមកដោយផ្លូវផ្ទាយ	១៥	១៦
- ៩	អំពីឧណានិសង្សព្រះសិរិមហាមាយាស្តាប់ព្រះអភិធម្ម	១៧	១៣
- ១០	អំពីព្រះសម្មាសម្ពុទ្ធឆង់លើផែនឋិបណ្តាកម្ពលសណាសន	២០	១០
- ១១	អំពីកិច្ចព្រះអរហំសម្មាសម្ពុទ្ធក្នុងវស្សន្តរទូរបីទៀ	២១	៦
- ១២	សូរបញ្ជាក់អំពីព្រះសម្មាសម្ពុទ្ធមានបិណ្ឌបាតជាដើម	២២	២
- ១៣	អំពីព្រះទសពលញ្ញាណយាងចុះមកកាន់ជម្ពុទ្វីប	២៤	៦
- ១៤	អំពីសម្មាសម្ពុទ្ធសំដែងចរមត្តអភិធម្មចែកជាការណៈ	២៥	១០
- ១៥	អំពីព្រះសម្មាសម្ពុទ្ធយាងទៅបិណ្ឌបាតនគរកុរុទ្វីប	២៨	៣
- ១៦	អំពីព្រះសម្មាសម្ពុទ្ធ សំដែងអភិធម្មកំណត់ ៨០ ថ្ងៃ	៣០	១៥
- ១៧	អំពីព្រះធីមានព្រះភាគសំដែងអភិធម្មក្នុងហានភាវត្តិង្ស	៣៣	១៦

បញ្ហា		ទំព័រ	បន្ទាត់
ទី	๑๘ អំពីសំដែងអភិធម្មក្នុងឋានសួគ៌មានតែពួកទេវតា	๓๔	๖
-	๑๙ អំពីសំដែងអភិធម្មក្នុងវស្សន្តរដូវជាមួយគ្នាមិនមុនក្រោយ	๓๕	๑๑
-	๒๐ អំពីការល្បែងយល់ទេវនិស្ស័យភិក្ខុទាំង ๕๐๐ អង្គ .	๓๗	๑๔

អភិធម្មត្ថវិភាវិនីបរមត្ថកថា

-	๒๑ អំពីរួមចូលកន្លែងមិនកំណត់ឲ្យឈ្មោះគម្ពីរធម្មសង្គណីជាដើម	๔๐	๑๑
-	๒๒ អំពីកុសលតិកមាតិកា	๔๓	๔
-	๒๓ ពាក្យជាធម៌និងធម្មសព្ទ	๔๖	๑๑
-	๒๔ សេចក្តីជួលត្រង់ពាក្យជាអកុសលធម៌ . . .	๔๘	๑
-	๒๕ អំពីហេតុបណ្តាលឲ្យកើតជាកុសលកម្មជាដើម . .	๕๒	๒
-	๒๖ ពាក្យថាចិត្តច្បាទ្រូកបដោយលក្ខណៈ ๔ យ៉ាង .	๕๓	๓
-	๒๗ ចិត្តសព្វប្រែ អធិប្បាយន័យបម្ពេ	๕๕	๑๒
-	๒๘ ការរឹតរឹនចិត្តឲ្យចំរើនទៅតាមថ្នាក់ខាងខ្ពស់ . .	๕๘	๔
-	๒๙ ការជួលអំពីចេតសិកនីយៈ	๖๐	๕
-	๓๐ អំពីចិត្ត ๔ យ៉ាង ចំនួនដោយសង្កេចនឹងពិស្តារ .	๖๒	๗
-	๓๑ អំពីការមិនរួមចិត្ត ๕๔	๖๓	๑๑
-	๓๒ ពាក្យថាអកុសលចិត្តជាដើម អធិប្បាយ . . .	๖๔	๒
-	๓๓ ចិត្តប្រកបដោយហេតុ ព្រមទាំងអធិប្បាយ .	๖๖	๗
-	๓๔ អំពីកុសលចិត្តនឹងអកុសលចិត្តសម្បយោគដោយហេតុ	๖๗	๑๑
-	๓๕ អំពីព្រះសយម្ភូញាណទ្រង់ត្រាបច្បាស់នូវភាវៈចិត្តនៃសត្វ	๗๒	๔
-	๓๖ អំពីសោភណចិត្ត๓๐ចែកទៅតាមពួកតាមក្រុម .	๗๓	๑๑
-	๓๗ អំពីអកុសលវិបាក អហេតុកចិត្តទាំង ๗ . .	๗๔	๖
-	๓๘ អំពីកុសលវិបាក អហេតុកចិត្តទាំង ๘ . . .	๗๐	๑๔

បញ្ជា		ទំព័រ	បន្ទាត់
ទី ៣៩	អំពីអហេតុកកិរិយាចិត្តទាំង ៣	៨៣	១៣
- ៤០	សេចក្តីសង្ស័យពីអារម្មណ៍ដែលមានឈ្មោះផ្សេងគ្នាទាំង ៤	៨៩	១៦
- ៤១	សេចក្តីសង្ស័យពីអារម្មណ៍ទាំង ៦ ក្នុងកាមាវចរចិត្ត .	៩៤	១៤
- ៤២	អំពីសោភណចិត្ត ៥៩	១០៤	៩
- ៤៣	អំពីចិត្តតែមួយឈ្មោះផ្សេងគ្នាជា ៣ យ៉ាង . .	១០៥	១៣
- ៤៤	អំពីកាមាវចរកុសលចិត្ត ៤ ផ្សេងដោយវេទនាប៉ុន្មាន .	១១០	១
- ៤៥	អំពីកាមាវចរកុសលចិត្ត ៨ ផ្សេងគ្នាដោយវេទនា ២ .	១១១	៥
- ៤៦	បុគ្គលធ្វើបុណ្យដោយកុសលចិត្តជាញាណសម្បយុត្តជាដើម	១២០	៤
- ៤៧	កាមាវចរកុសលចិត្តប្រកបដោយសោមនស្សនឹងឧបេក្ខាវេទនា	១២១	១៦
- ៤៨	សប្បុរសទ្យទានចំពោះបុគ្គល-សង្ឃដោយកាមាវចរកុសលចិត្ត ៨	១២៦	២
- ៤៩	ពាក្យថាបុណ្យជាអសំខ្យេយ្យ ចែកនឹងឧបមាទ្វិបម្តេច .	១៣២	៦
- ៥០	អំពីក្រុមាវចរកុសលចិត្តទាំង ៥	១៣៤	១៤
- ៥១	អំពីភាវនាសមថកម្មដ្ឋាននឹងវិបស្សនាកម្មដ្ឋាន . .	១៣៩	១៤
- ៥២	អំពីចរិតទាំង ៦	១៥៧	៩
- ៥៣	កម្មដ្ឋាន ៤០ អនុលោមតាមចរិតទាំង ៦ . . .	១៦០	១០
- ៥៤	អំពីភាវនា ៣ ឥទ្ធិបាទ ៣ សមាធិ ៣ . .	១៦១	១៥
- ៥៥	អំពីបាលីសូមអាពធនាមុន ដែលពុំទាន់ភាវនាកម្មដ្ឋានណាមួយ	១៦៥	៣
- ៥៦	អំពីវសី ទាំង ៥	១៦៧	២
- ៥៧	អំពីណោកុត្តរសោភណចិត្ត ៨ សំដែងដោយធម្មាធិដ្ឋាន . .	១៧០	១
- ៥៨	បុគ្គលភេទ ចែក - អធិប្បាយ	១៧៥	៩
- ៥៩	ព្រះអរិយបុគ្គល ៤ ពួក លះបង់សំយោជនធម៌ជាដើម .	១៧៦	១០
- ៦០	បុថុជ្ជនបុគ្គលទាំង ២ ពួក	១៨០	៤

បញ្ជា	ទំព័រ	បន្ទាត់
ទី ៦១ អំពីបុគ្គលទី ២-៣-៤ ដែលផ្សេងគ្នា . . .	១៨២	១១
- ៦២ អំពីសកិទាគាមីបុគ្គលទី ២ ផ្សេងដោយឈ្មោះ ៥ យ៉ាង	១៨៦	១២
- ៦៣ ធម៌ ៥២ ឈ្មោះថាចេតសិកចែកតាមពួកមាន ៣ . .	១៨៩	១១
- ៦៤ អំពីអញ្ញសមានាចេតសិកពួកទី ១	១៩០	៥
- ៦៥ អំពីអកុសលចេតសិកពួកទី ២	១៩៤	៤
- ៦៦ អំពីសោភណចេតសិកពួកទី ៣	១៩៧	៨
- ៦៧ ពាក្យថារួចសព្ទ-ប្រែ-អធិប្បាយ	២០៤	៨
- ៦៨ អំពីសភាវធម៌ ២យ៉ាងគឺឧហេតុកនិងឧបាទាយ . .	២០៦	៤
- ៦៩ ឧហេតុករូបចំនួន-ប្រែ-អធិប្បាយ	២០៨	៣
- ៧០ អំពីឧបាទាយរូប ២៤	២១០	៣
- ៧១ អំពីរូប ២៨ មានឈ្មោះផ្សេង ៦ ក្នុងគ្នា ៦ . .	២១៣	១
- ៧២ អំពីរូបកលាបៈសំណុំរូបទាំង ២១ ពួក . . .	២១៧	១៤
- ៧៣ អំពីរូបទាំង ៤ មានកម្មជរូបជាដើម . . .	២២២	១០
- ៧៤ អំពីសព្វនៃសត្វកើតក្នុងភពទាំង៣មានរូបតិចច្រើនផ្សេងៗគ្នា	២២៥	៦
- ៧៥ អំពីអនុបាទិន្នករូប	២២៦	១១
- ៧៦ អំពីកំណើតសត្វទាំង ៤ យ៉ាង	២៣២	១
- ៧៧ អំពីកាយកោដ្ឋាសចំណែកកាយទាំង៣កំណាត់ . .	២៣៩	១១
- ៧៨ បកិណ្ណកសង្គហៈក្នុងចិត្ត ៨៩ ដួងមានវេទនា ៥ . .	២៤១	៤
- ៧៩ ក្នុងហេតុសង្គហចិត្ត ៨៩	២៤៣	៦
- ៨០ ចិត្តនិងចេតសិកញ៉ាំងកិច្ចទាំង ១៤ ឲ្យសម្រេច . .	២៤៥	១១
- ៨១ អំពីហេតុជាទីតៅនៃចិត្តឧប្បាទមានបដិសន្ធិចិត្តជាដើម .	២៤៨	៤
- ៨២ ទ្វារសង្គហៈ សួរអំពីទ្វារនិងវិថីចិត្ត . . .	២៥០	១

ឋញ្ញា		ទំព័រ	បន្ទាត់
ទី ៨៣	សួរក្នុងអារម្មណ៍សង្គហៈ	២៥២	១៤
- ៨៤	សេចក្តីសង្ស័យអំពីវត្ថុនិងវិញ្ញាណធាតុ . .	២៦០	៨
- ៨៥	សួរក្នុងវិសយប្បវត្តិសង្គហៈ . . .	២៦៤	១
- ៨៦	អំពីអារម្មណ៍ប្រព្រឹត្តទៅក្នុងទ្វារ ៥ . .	២៦៤	១៤
- ៨៧	អំពីឧណចិត្តធំទាំង ១៧	២៦៥	៨
- ៨៨	អំពីអារម្មណ៍ ៤ មានអតិមហគ្គតារម្មណ៍ជាដើម .	២៧០	១
- ៨៩	បញ្ចាក់សេចក្តីអំពីអារម្មណ៍ទាំង ៤ . .	២៧៦	៦
- ៩០	វិភូតារម្មណ៍និងអវិភូតារម្មណ៍ . . .	២៧៩	១២
- ៩១	ជវនសម្ភវេចសំចុប្បដ្ឋិន-សេក្ខនិងអសេក្ខបុគ្គល .	២៨០	១៥
- ៩២	បដិសន្ធិចតុក្កៈប្រជុំបដិសន្ធិទាំង ៤ . .	២៨៧	១០
- ៩៣	កម្មចតុក្កៈប្រជុំកម្ម ៤ ដោយអាការមាន ៤ ។ .	២៩៤	៤
- ៩៤	កុសលកម្មនិងអកុសលកម្មឲ្យផលជាអហេតុកបដិសន្ធិ	៣០៤	៥
- ៩៥	ទុក្ខដ្ឋកម្មនិងទមកកម្មឲ្យផលផ្សេង ។ ភ្លា .	៣០៦	៩
- ៩៦	អំពីរឿងព្រះនិព្វានមាន ១-២- . . .	៣០៩	៨
- ៩៧	អំពីហានព្រះនិព្វាន	៣២៣	៤
- ៩៨	ភាក្យថា ទីបំផុតលោក - ភពមាន ៣ .	៣២៥	១១
- ៩៩	ហានព្រះនិព្វានស្ថិតទៅទីបំផុតលោក-ភពណា ៣បមា	៣២៧	៤
- ១០០	ព្រះទីឈាស្រពារសត់ទន្លូលកាន់ព្រះនិព្វានយ៉ាងណាបំ	៣២៩	៩
- ១០១	អំពីសោកុត្តរមហានគរ - លោកិយមហានគរ .	៣៣១	២
- ១០២	អំពីសោយសុខក្នុងព្រះនិព្វានទត្តមជាសុខជាសោកិយ	៣៣៤	១០
- ១០៣	អំពីឈ្មោះព្រះនិព្វាន	៣៣៧	៩
- ១០៤	បុគ្គលទៅកាន់មហានគរ គឺព្រះនិព្វានដោយយានដំនិះអ្វី	៣៤៥	៣

អារម្ភកថា

ការដែលបានផ្តើមផ្សាកើតសៀវភៅអក្ខរក្រមធម្មក្នុងឆ្នាំនេះឡើង ដោយសារយើងបានសិក្សារៀនគម្ពីរព្រះអភិធម្មសង្គ្រោះបាលី ព្រមទាំងអដ្ឋកថានិងគម្ពីរព្រះអភិធម្មសង្គ្រោះបាលី ព្រមទាំងមហាដីកា, អនុដីកា, និស្សយ និងនោជនា លោកសំដែងប្រាប់ពន្យល់ធម្មសន្ទនិងអត្ថសំខាន់ចំពោះបេរមត្តព្រះអភិធម្ម មានចិត្ត ចេតសិក រូប និងនិព្វានជាដើម នោះយើងបានរៀនតាំងជញ្ជឹងពិនិត្យពិចារណាមើល ធម្មសន្ទនិងអត្ថសន្សំសមគ្នា, ចំពោះបេរមត្តព្រះអភិធម្មតាមពុទ្ធកាសិត តាំងពីយើងបួសជាសាមណេរបាន ៤ វស្សាដកចេញមកដល់ឥឡូវនេះបាន ៤៦ ឆ្នាំហើយ ក៏នៅតែពុំទាន់អស់សេចក្តីព្យាយាមនៅឡើយ រីឯតែងមានទុស្សាហ៍ព្យាយាមក្សៀវក្សាខ្ជាំឯឡើងថែមទៀត ដោយយើងតាំងចិត្តជាតណ្ហាលះ មិនបានប្រើសព្ទខ្ជាំឯជានិបញ្ញា មិនបានប្រើបញ្ញាខ្ជាំឯជាឯសព្ទ តែយកសតិជាធំចាប់ចង មានោជាខ្សែព្រញ្ចប់នឹមតាំងសង្ឃឹមថា តែសព្ទនិងបញ្ញាឲ្យនឹងនៅស្មើគ្នា មិនឲ្យស្លឿនម្ខាង។ឬថាយកមនោជាខ្សែចងព្រញ្ចប់សេះតាំងគួ តែសព្ទនិងបញ្ញាឲ្យត្រាប់ទៅស្មើគ្នា មិនឲ្យរៀបរៃរៀបទៅម្ខាង ។ ដើម្បីនឹងរក្សាផ្លូវត្រង់តាមសេចក្តីពិតសមគួរដល់ពុទ្ធដីកា ។

មួយទៀត យើងខំប្រឹងព្យាយាមរៀនរៀង ។ មក តាំងពីតាយុ

១៦ ឆ្នាំ ដែលបានបួសជាសាមណេរ ដកចេញបាន ១ បសម្បទាជាកិច្ច-
ការៈក្នុងព្រះពុទ្ធសាសនាកំណត់អាយុ ៦៣ ឆ្នាំគត់ កិច្ចដែលទំប្រើដំប្រែន
ព្យាយាមរៀន គឺមើលសាស្ត្រាបាលីសុទ្ធ ហើយទំត្រង់រិះគិតរំពឹងសញ្ញឹង
ពិចារណារឿយ ។ ដោយច្រើនជង្គឹណាស់ កំណត់សង្កេតយកសេចក្តី
អត្ថសេចមេត្តព្រះអភិធម្មឲ្យសមគ្នាតាមបាលី អដ្ឋកថា មហាដីកា
អនុដីកា និស្ស័យ និង យោជនា ដើម្បីរក្សាកេនតីសេចក្តីចិត្តអត្ថស
ព្រះអភិធម្មដែលច្រឡំប្រឡែងឃ្លាតសេចក្តីទៅផ្សេង ។ ឲ្យបានជាកេនតី
ឲ្យបានអត្ថសម្បត្តិពេញចំបូណិ ដោយអត្ថសេសមគួរដល់ពុទ្ធភាសិតោ-
វាទជាប្រក្រតីវិញ ដូចជាអ្នករៀនវិជ្ជាពេទ្យចេះយ៉ាងវិសេស ដើម្បីនឹង
រក្សាមនុស្សមានកេនឲ្យជាកេនប៉ុណ្ណោះឯង ។ កំគាលដែលពាជការ
បានតាំងឲ្យមានព្រះពាជបណ្ណាល័យខ្ពើងជាដំបូងនោះ យើងមានសេចក្តី
សោមនស្សត្រេកអរជាក្រៃលែង បានទំប្រើនប្រែនព្យាយាមរៀបរៀង
សេចក្តីបរមេត្តព្រះអភិធម្ម ៤ យ៉ាងគឺ ចិត្ត ១ ចេតសិក ១ រូប ១
និងនិព្វាន ១ ប្រមាណជាមួយឆ្នាំទើបចប់ ហើយបានយកទៅប្រគេន
ព្រះតេជព្រះគុណ ព្រះសេតព្រះមហាវិមលធម្ម ព្រះនាម (ថោង) ចាង-
ហ្វាងសាលាបាលីជាន់ខ្ពស់ សូមឲ្យលោកពិនិត្យផ្ទៀងផ្ទាត់ឲ្យ លោកក៏

មានព្រះទ័យរីករាយបានផ្សឿនផ្សាត់ដកបដសល់ចប់ រួចបានបញ្ជូនទៅព្រះ
ពជបណ្ណាល័យសុំឲ្យប្តឹងពជការតាមក្រសួងសូមអនុញ្ញាតបោះពុម្ព ពនិតារ
កំបានអនុញ្ញាតឲ្យជាស្រេច ទុកក្នុងមន្ទីរព្រះពជបណ្ណាល័យ មាន
សេចក្តីបំណងនឹងបោះពុម្ពផ្សាយទៅដោយពិតតែបែរជាអាក់ខានបោះពុម្ព
ទៅវិញ សៀវភៅច្បាប់នោះក៏បាត់ទៅរកពុំឃើញ ហេតុដែលអាក់ខាន
បោះពុម្ពមិនបាត់សៀវភៅច្បាប់ទៅដូច្នោះ ក៏យើងមិនបានទោមនស្សតួច
ចិត្តអ្វីឡើយ យើងនឹតតែមានសេចក្តីសោមនស្សត្រេកអរច្រើនឡើង
ដោយហេតុដែលយើងបានពិនិត្យសេចក្តីនោះ ថែមទៀតដោយការពិនិ
តរឿយ ៗ ទៅឃើញថាសៀវភៅច្បាប់នោះនៅមានចំណុចឃ្លាតឃ្លាតអត្ថ-
សេទ្ធរដោយអនេក ៗ ពុំទាន់បានត្រឹមត្រូវត្រួតត្រាន់ពេញលេញនៅឡើយ
ហេតុនឹងហើយបានជាយើងមានសទ្ធាចាត់ចាយាមខ្លាំងឡើង មិនបាន
តិតរសេចក្តីលំបាកខ្លាយហត់ ទោះបីថាស់ជាត្រូវបង្កើនកំទំអត់ទ្រាំរៀប
រៀងសៀវភៅអភិធម្មត្ថវិភាយនេះ ឲ្យកើតឡើងដើម្បីរក្សាអត្ថរសឲ្យ
ត្រឹមត្រូវសមគួរតាមពុទ្ធគាសិត តែថាពុំបានអធិប្បាយហួសហែ តាម
របៀបបរិច្ឆេទចំនួន ៩ ក្នុងគម្ពីរអភិធម្មត្ថសង្គហឲ្យសព្វគ្រប់ចំនួនឡើយ
ទេ ព្រោះសេចក្តីវែងពិស្តារពេកមានចំនួនលោកអ្នកច្រើន សៀម-ខ្មែរបាន

ប្រៀបរៀបរៀនសេចក្តីបរមត្ថព្រះអភិធម្ម ៧ បរិច្ឆេទចុះពុម្ពផ្សាយទៅដោយ
ច្រើនសព្វគ្រប់ហើយ ; ក៏ក្នុងបរិច្ឆេទទាំង ៧ នោះ យើងពិនិត្យជ្រើសរើស
ដកស្រង់ យកតែសេចក្តីបរមត្ថដែលមានអត្ថរស ដ៏ល្អិតជ្រាលជ្រៅក្រៃ
ពេកពាំទ្យែកំចាំដឹងច្បាស់ កុលបុត្រកុលធីតាប្រើនតែភ័ន្តច្រឡំ នាំទ្យែ
ពាល់គំនិតគិតពុំយល់ ខ្មោរហើយគិតតែយកសេចក្តីស្មានៗ ទៅដោយ
មិនបានច្បាស់លាស់ យើងនឹងដឹកកាយអត្ថរសទាំងឡាយដ៏ជ្រាលជ្រៅនោះយកមកអធិប្បាយ ទ្យែកជាយសេចក្តីខ្លីៗ ដូចជាខ័ន្ធធីតៈ
ហើយអុជប្រទីបទ្យែមានពន្លឺខ្លាំង ដើម្បីជាប្រយោជន៍ដល់សាធុជនដែល
មានសទ្ធាមុតមាំនឹងសិក្សាបានដឹង អត្ថរស បរមត្ថ ព្រះអភិធម្ម ដោយងាយ
តែការដែលនឹងអធិប្បាយនោះ យើងកំណត់ទ្យែមានពាក្យសួរប្រស្នា
ពាក្យឆ្លើយតបប្រស្នា ដូចកិកូតាវុបៈ តិមហាវោ អនុត្តរោជាធម្មកថិកត្តេ
ធម្មសាកច្ឆា សាកសួរធម្មិកាថិ ជាដើមតគ្នាទៅវិញទៅមក ដើម្បីនឹងដឹក
រំលើងអត្ថរសយកសេចក្តីពិតជាវត្ថុប្រតិបត្តិក្នុងព្រះពុទ្ធសាសនា យើង
បានតំណាត់អ្នកសួរប្រស្នាថា ធម្មកថិ អ្នកឆ្លើយតបប្រស្នាថាអត្ថកថិ តែថា
ធម្មកថិ ជាអ្នកសួរប្រស្នាបញ្ជាក់សេចក្តី អត្ថកថិ ជាអ្នកឆ្លើយតបប្រស្នា
អធិប្បាយតាមពាក្យសួរដោយពិត ដូចមានសំដែងសេចក្តីទៅខាងមុខ ។

ធម្មស្សការ

ធម៌ រតនត្តយំ

ខ្ញុំព្រះករុណាសូមបង្ហាញកាយ វាចា ចិត្ត ថ្វាយបង្គំនឹងព្យាយកចំពោះ
ប្រជុំនៃព្រះរតនៈគឺព្រះពុទ្ធ ១ ព្រះធម៌ ១ ព្រះសង្ឃ ១ ដែលជាកែវដ៏
ឧត្តមខ្ពង់ខ្ពស់បំផុតនឹងកែវគ្រប់ប្រភេទក្នុងលោកនេះ យកមកប្រៀបផ្ទឹមឲ្យ
ត្រឹមស្មើពុំបាននៅឡើយ ដោយឥស្សរិយសិរី ដោយសេចក្តីគោរព ។

តស្សាធុភាវេន សព្វន្តរាយោ ធស្សតុ សូមឲ្យសេចក្តី
អន្តរាយទាំងអស់វិនាសបាត់បង់ សាបសូន្យអស់ទៅ ដោយអំណាច
គាថុភាពនៃគុណព្រះរតនៈត្រៃនោះឯង ។

ចប់ធម្មស្សការ ។

អតិធម្មត្ថាធិប្បាយកថា

អភិធម្មប្បត្តិហេតុកថា

សំដែងហេតុព្រះអភិធម្មដែលកើតឡើងក្នុងលោកជាដំបូងកំណត់ឲ្យមានពាក្យសួរពាក្យឆ្លើយ គឺថាសួរបញ្ជាក់សេចក្តីបរមត្ថ អត្ថព្រះអភិធម្មដ៏ជ្រាលជ្រៅ ជីកតាស់កកាយសេចក្តីដ៏កំចាំងជ្រាលជ្រៅនោះឲ្យកក់ឡើង ដើម្បីជាប្រយោជន៍ដល់អ្នកសិក្សា បានស្តាប់បានរៀនដឹងអត្ថសព្រះអភិធម្មដោយងាយ ដូចយើងបានកំណត់ទុកក្នុងអារម្ភកថារួចហើយ នឹងសំដែងតទៅខាងក្រោយនេះ៖

១-ធម្មវិទី សួរប្រស្នាអត្ថាទិថា លោក ពាក្យថាអភិធម្ម ។ នោះអធិប្បាយបានដូចម្តេចខ្លះ ?

អត្ថវិទី ឆ្លើយតបប្រស្នាថា ពាក្យថា អភិធម្ម។នោះ អធិប្បាយថា ធម៌ក្រៃលែងកំបាន, ថាធម៌មានគុណានុភាពដ៏ល្អិត គឺមនុស្សនិងទេវតាព្រមទាំងពួកព្រហ្មគប្បីនោរពបូជាកំបាន, ថាធម៌សំដែងច្រាប់ពន្យល់បរមត្ថមានអត្ថរសដ៏ជ្រាលជ្រៅក្រៃលែង ជាហេតុបណ្តាលឲ្យកើតឡើងជាបុណ្យនិងបាបក្នុងសន្តានសត្វសត្វកំបាន, សេចក្តីដែលបានអធិប្បាយមកជាសង្ខេបប៉ុណ្ណេះជាដើម បានឈ្មោះថាព្រះអភិធម្មដោយពិត ។

២-ធម្មវិទី ពោលថា អើអត្ថាទិ លោកអធិប្បាយពាក្យថាព្រះ

អភិធម្មមកនេះយើងស្តាប់បានហើយ ចុះព្រះអភិធម្មនោះ អ្នកណាគឺសមណៈឬព្រាហ្មណ៍ មនុស្សឬទេវតា យក្សឬព្រហ្ម សំដែងតែងតាំងទុកមក?

អត្ថវាទី ឆ្លើយអធិប្បាយតបថា ព្រះអភិធម្មនោះនឹងថា សមណៈ ព្រាហ្មណ៍ មនុស្ស ទេវតា យក្ស ព្រហ្ម ឬអ្នកច្រើនណាមួយសំដែងតែងតាំងទុកមកក៏ទេ, ព្រះអភិធម្មនេះពិតជាអង្គព្រះអរហំសម្មាសម្ពុទ្ធទ្រង់សំដែងតែងតាំងទុកមកដោយព្រះអង្គឯងពិត ។

៣-ធម្មវាទី ពោលថា អើអត្ថវាទី ប្រស្នានេះយើងស្តាប់បានហើយ ចុះព្រះអរហំសម្មាសម្ពុទ្ធកាលព្រះអង្គទ្រង់សំដែងព្រះអភិធម្មនោះ ព្រះអង្គបានត្រាស់ជាអង្គសព្វញ្ញុតញ្ញាណទៅបានប៉ុន្មានវស្សាហើយ? ដល់វស្សាជាតំរាប់ប៉ុន្មានទើបទ្រង់សំដែង? ព្រះអង្គទ្រង់សំដែងនៅកន្លែងណា? ច្រើនខួបប៉ុន្មានឆ្នាំរួច?

អត្ថវាទី ឆ្លើយតបថា ព្រះសព្វញ្ញុសម្មាសម្ពុទ្ធព្រះអង្គបានត្រាស់តញ្ញាណទៅ ៦ វស្សាហើយ ដល់វស្សាជាតំរាប់ ៧ ព្រះអង្គទ្រង់សំដែងយមកបាដិហារ្យផ្តាញ់ពួកតិរ្ថិយគាំនឹងឲ្យមានពួកនិគ្រន្ថជាដើម ឲ្យបាក់បបួរបង្អាប់ឈ្មោះបុណ្យសម្ភារព្រះចាំមើព្រះអង្គហើយ ទ្រង់យាងទៅគង់ចាំវស្សានៅឯបណ្ឌុកម្ពលសិលាសនៈក្រោមម្លប់ដើមបាវិច្ឆត្តកព្រឹក្សក្នុងហានគារវត្តិ-

សពិភពដែលជាទី ប្រជុំនៃទេវតាទាំងមួយម៉ឺនលោកធាតុបួលមកប្រជុំក្នុងទីនោះ ទើបព្រះអង្គទ្រង់សំដែងធម្មទេសនាព្រះអភិធម្មប្បាវតារចំពោះព្រះសិរីមហាមាយាទេវីបុត្រជាពុទ្ធមាតាព្រះអង្គ ក្នុងទីប្រជុំនៃទេវតាទាំងមួយម៉ឺនលោកធាតុនោះឯង ។

៤- ធម្មវិទី ខ្ញុំសូមថា តើសេតុផលទី លោកអធិប្បាយរឿងនេះមកយើងស្តាប់បានសព្វគ្រប់ហើយ, បុរេអង្គសម្តេចព្រះមុនីន្ទ្រជនស្រីជាម្ចាស់ទ្រង់ត្រាស់សំដែងធម្មទេសនាព្រះអភិធម្មប្បាវតារចំពោះព្រះសិរីមហាមាយាទេវីបុត្រជាពុទ្ធមាតារបស់ព្រះអង្គនោះ តើនិមិត្តវត្ថុអ្វី? ទ្រង់តំណាងពាក្យណាយល់ឃើញដូចម្តេចខ្លះ?

អត្ថវិទី វិសជ្ជនាតបថា ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងធម្មទេសនាព្រះអភិធម្មប្បាវតារចំពោះព្រះសិរីមហាមាយាទេវីបុត្រជាពុទ្ធមាតានោះ និមិត្តមាតុគុណវត្ថុ គឺព្រះអង្គទ្រង់សំដែងតបស្នងសងគុណទឹកដោះសម្តេចព្រះមេរបស់ព្រះអង្គ ដែលព្រះអង្គនៅជាព្រះពោធិសត្វនៅឡើយ តែងខ្លួលសោយរសទឹកដោះនៃព្រះមាតារបស់ព្រះអង្គមកច្រើនជាតិណាស់ហើយ, ព្រោះព្រះអង្គបានត្រាស់កន្លងទៅ ៦ សង្ឃាហើយទ្រង់តំណាងពាក្យណាយល់ឃើញប្លាស់ថា ព្រះសម្មាសម្ពុទ្ធទាំងឡាយត្រប់ព្រះអង្គ ក្នុងវេលាវ

ជាគំរប់ ៧ តែធំយាងទៅនធំចាំសង្ឃនៅនាដែនថ្មបណ្តុកម្ពុលសិលាសនៈ
ក្រោមដើមចាំប្តូតកព្រឹក្សព្ធជ៌ឋានតាវត្តឹសទេវលោក ហើយតែធំលើក
បរមត្តព្រះអភិធម្មមកសំដែងតបស្នងសងគុណព្រះពុទ្ធមាតា ជាធម្មតា
រៀងមក ត្រង់ព្រះអង្គចាំនតស់, ឯព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើងចាំន
ឡាយត្រង់យល់ហេតុដូច្នេះហើយ ចានជាព្រះអង្គត្រង់យាងទៅចាំព្រះ
សង្ឃឯឋានតាវត្តឹសពិភពកន្លែងសង្ឃជាគំរប់៧ដូចព្រះសម្មាសម្ពុទ្ធចាំនឡាយ
នោះឯង ។

៥ - ធម្មវាទី ពោលថា អើអត្តាវ៉ ប្រស្នានេះលោកសួនាមក
យើងស្តាប់ចានហ្នឹយ, ចុះព្រះសិរីមហាមាយាទេវបុត្រជាពុទ្ធមាតាត្រង់
តន់នៅឋានណា ។

អត្ថវាទី សួនាតបថា ព្រះសិរីមហាមាយាទេវបុត្រជាពុទ្ធមាតា
ត្រង់តន់ទៅឋានតុសិត ដែលជាឋានមនោរម្យជាទីតម្រេកត្រេកអរនៃ
លោកអ្នកមានបុណ្យវាសនាធំ ។ មានសព្វញ្ញុពោធិសត្វជាដើម តែងទៅ
កើតសោយសុខជាទីក្នុងឋានតុសិតនោះឯង ។

៦ - ធម្មវាទី ពោលថា អើអត្តាវ៉ ប្រស្នានេះយើងស្តាប់ចានហើយ
តែយើងនៅមានសង្ស័យតទៅទៀតថា បើព្រះសិរីមហាមាយាទេវបុត្រ

ជាពុទ្ធមាតាគង់ឯហានតុសិតឆ្ងាយពីទន្លឹងចាំដ៏ហានយោមមួយខៀតផង បើ
ឆ្ងាយដល់ម្លេះ ដូចម្តេចព្រះសិរីមហាមាយាទេវបុត្រជាពុទ្ធមាតានឹងស្តាប់
បរមត្តព្រះអភិធម្មបាន ឬមួយព្រះពុទ្ធមាតាយាងចុះមកស្តាប់ឯហានតាវត្តឹ-
សទេវលោកចំពោះព្រះភ័ក្ត្រឬដូចម្តេច ?

អត្ថវាទី សៃដួងតាបថា ព្រះសិរីមហាមាយាទេវបុត្រជាពុទ្ធមាតា
ព្រះអង្គគង់ឯហានតុសិតពិតមែនហើយ តែថាកាលព្រះអរហំសម្មាសម្ពុទ្ធ
ទ្រង់សំដែងព្រះអភិធម្មនោះ ព្រះសិរីមហាមាយាទេវបុត្រជាពុទ្ធមាតា
ក៏ព្រះអង្គទ្រង់យាងចុះមកគាន់ហានតាវត្តឹសពិតព តែងស្តាប់ព្រះអភិធម្ម
ចំពោះព្រះភ័ក្ត្រព្រះជ័មានព្រះភាគ ក្នុងកណ្តាលដំខ្ទុំនៃទេវតាចាំដ៏មួយ
ម៉ឺនហោកដាតុដោយពិត ។

ពុ - ធម្មវាទី ពោលថា សាធុ ប្រពៃហើយអត្ថាធិ៍ ប្រស្នាដែល
លោកសៃដួងមកនេះ ចុះសម្តេចព្រះអនាវរណញាណជាម្ចាស់ ព្រះអង្គ
ប្រកបដោយអតញ្ញូតាធម៌មានព្រះហឫទ័យជ្រាបច្បាស់ថា ព្រះពុទ្ធមាតា
ទេសព្រះអង្គមានឧបការគុណច្រើនជ័ក្រៃលែង រកវាស់ពុំបាននិងពុំត្រូវ
កំណាត់ពុំសល់ ធំលើសយ៉ាងណាស់ជាអនន្តគុណ ដូចម្តេចក៏ព្រះអង្គ
ពុំបានយាងទៅគាន់ហានតុសិតពិតព សំដែងព្រះអភិធម្មតបស្នងសងគុណ

សម្តេចព្រះអនន្តគុណជាពុទ្ធមាតាឯហ៊ានតុសិតវែមដ្ឋឯទៅ ដូចម្តេចទើប
ព្រះអង្គយាងទៅកាន់ហ៊ានតាវត្តឯង្ស្រពិកឥត តដំរលើផែនបណ្តុកមួលសិលា-
សនះក្រោមដើមចាប៉ែតត្រកួរជាហ៊ានខាងក្រោមវិញ ឲ្យព្រះពុទ្ធមាតា
នឿយព្រួយលំបាកព្រះអង្គយាងចុះមកអំពីស្ថានតុសិត រំលងពាំងស្ថាន
យាមមួយទៀតផង ទើបបានមកដល់ស្ថានតាវត្តឯង្ស្រពិកឥត តើព្រះអង្គ
ទ្រង់ឈ្លងយល់ដោយហេតុមានប៉ុន្មានប្រការនិងហេតុអ្វីខ្លះ ?

អត្ថរាធិ៍ ឆ្លើយតបថា សម្តេចព្រះបរមគ្រូជាម្ចាស់ ព្រះអង្គទ្រង់
ឈ្លងយល់ដោយហេតុ ៤ ប្រការគឺ:

ហេតុទី ១ ព្រះអង្គទ្រង់ពិចារណាគុណព្រះមាតាព្រះអង្គ និងគុណព្រះ
ត្រៃបិដក តែទ្រង់យកគុណព្រះវិនយបិដកពីម៉ឺនមួយពាន់ព្រះធម្មក្ខន្ធមក
ថ្លឹងប្រៀបផ្ទឹមនឹងគុណព្រះមាតាព្រះអង្គ ឃើញថាពុំស្មើនឹងគុណព្រះមា-
តាព្រះអង្គទេ ទើបព្រះអង្គទ្រង់យកគុណព្រះសុត្តន្តបិដកពីម៉ឺនមួយ
ពាន់ព្រះធម្មក្ខន្ធ មកថ្លឹងប្រៀបផ្ទឹមនឹងគុណព្រះមាតាព្រះអង្គទៀត ក៏
ឃើញថាពុំស្មើនឹងគុណព្រះមាតាទៀត ហើយព្រះអង្គទ្រង់យកគុណ
ព្រះអភិធម្មបិដកបួនម៉ឺនពីរពាន់ព្រះធម្មក្ខន្ធ មកថ្លឹងប្រៀបផ្ទឹមនឹងគុណ
ព្រះមាតា ឃើញថាមានគុណធំជ្រុលយ៉ាងស្មើៗគ្នាទើបព្រះអង្គទ្រង់យាង

ទៅតដ៏លើដែនថ្មបណ្តែកម្ពស់សិលាសន:ក្រោមដើមចាំបច្ចត្តកព្រឹក្សនាហាន តាវត្តដ៏ឆ្ងាយនេះ ទៅទីពាក់កណ្តាល ឲ្យព្រះពុទ្ធមាតាយាងចុះមកកាន់ទី ពាក់កណ្តាល សម្តែងសេចក្តីឲ្យឃើញច្បាស់លាស់ថាគុណវិសេសព្រះ អភិធម្មបិដក ខ្ពង់គុណព្រះមាតាបស់ព្រះអង្គស្មើៗគ្នាដោយពិត ។

ហេតុទី ២ ព្រះអង្គទ្រង់រំពឹងពិចារណាឃើញថាហានតុសិតគ្មានទី តាសន:ដ៏សមគួរ ក្រៅអំពីទីប្រាសាទវិមានរបស់ទេវបុត្រ-ទេវកញ្ញា ដែលជាបន្ទាះខំនេរធំទូលាយ ល្មមដល់ទីប្រជុំទេវតាចំនួនមួយម៉ឺនលោក-ធាតុ ខ្ពង់ចូលមកអង្គុយប្រជុំស្តាប់ព្រះអភិធម្ម ព្រមទាំងគ្មានទីដ៏សមគួរ ដល់ពុទ្ធាសន: ល្មមព្រះសម្មាសម្ពុទ្ធគង់ចាំវស្សាខ្ពង់ធ្វើសម្តែងបរមត្ថត្រៃអភិ-ធម្មនោះបានឡើយ ។

ហេតុទី ៣ ព្រះអង្គទ្រង់ពិចារណាឃើញថា ហានតាវត្តដ៏ឆ្ងាយពិតប្រ-កបដោយសួនច្បារមានដើមឈើគួច-ធំមានពណ៌ល្អផ្សេងៗ ជាទីតម្រេក យ៉ាងវិសេស មានទាំងដើមចាំបច្ចត្តកព្រឹក្សមានសណ្ឋានដូចធ្លុតត្រួត ដុះ ឡើងក្នុងកណ្តាលទេវនគរ សំណុំដើមមូលដុំវិញ ១៥យោជន៍, ប្រវែងពី តល់ទៅដល់ប្រតាបមែកខាងលើ ៥០យោជន៍, បែកមែកចេញទៅជាប្រាំ លួតទៅកាន់ទិសទាំងប្រាំ គឺទិសខាងលើ ទិសខាងកើត ខាងលិច

ខាងត្បូង ខាងជើង ហាបសិបយោជន៍ដូចគ្នា, កំពស់ពីតល់ទៅដល់
ចុងខាងលើ១០០យោជន៍, បែកមែកចេញទៅកាន់ទិសទាំងបួន ម្ខាង ។
ហាសិបយោជន៍ ត្រូវជា១០០យោជន៍, ចើកប់ប៉ាមែល្អាលសាខាមួល
ជោយជុំវិញប្រមាណ ៣០០ យោជន៍តត់, រំយោលផ្កាសំយុងចុះមកជុំវិញ
រឿងបញ្ចេញតូវស្មើផ្សាយទៅកាន់ទិសទាំងបួន ៤០០ យោជន៍ ជោយ
ជុំវិញ ផ្កាមានក្លិនក្រអូបផ្សាយទៅបណ្តាយ ៗល់ ១០០ យោជន៍, ឯ
ខាងក្រោមជើមមានសិលាសនៈផែនថ្មដ៏ខន់ដូចសំពត់កម្ពល មានពណ៌
ក្រហមល្មឿនដូចផ្កាជយត្រីកូរ បណ្តាយ ៦០ យោជន៍ ទទឹង ៤០
យោជន៍ កម្រាស់ ១៤ យោជន៍, មានការគ្រុងចុះនឹងចាំងខ្លឹងជាប្រក្រតី
ក្នុងពេលដែលអគ្គិយចុះនឹងក្រោកខ្លឹងជាធម្មតា សមគួរដល់ពុទ្ធាសនៈ
ល្មមដល់ព្រះសម្មាសម្ពុទ្ធត្រាច់ព្រះអគ្គិនធំចាំសព្វ សំដែងចរមគ្គ
ព្រះអភិធម្មជោយសុទ្ធក្សេមក្សាន្ត ព្រមទាំងមានទីកន្លែងដ៏ធំ
ទូលាយល្មមទៅតាំងមួយម៉ឺនលោកធាតុ ចូលមកអគ្គិយប្រជុំស្តាប់
ធម្មទេសនា បរមត្ថព្រះអភិធម្មជោយស្រួល ទើបបានជាព្រះសម្មាសម្ពុទ្ធ
ជាម្ចាស់នៃយើងទាំងឡាយ ព្រះអគ្គិត្រង់យោងទៅនធំចាំសព្វលើថ្មបណ្តុំ-

កម្ពុលសិលាសនៈនោះឯង ។

ហេតុនេះ ព្រះអង្គទ្រង់ពិចារណាស្រាបចប្បាស់ថា បើតថាគតទៅគង់ចាំសង្ឃឯឋានតុសិត ទីឯកាត់សេចក្តីសង្ស័យនៃទេវតាពាន់មួយម៉ឺនលោកធាតុពុំបានទេ ព្រះពុទ្ធមាតាតថាគតស្តាប់ព្រះអភិធម្មកថាទៀតក៏មានផលានិសង្សតិចពុំគេញបរិបូណ៌ឡើយ បើតថាគតទៅគង់លើផែនថ្មបណ្ឌុកម្ពលសិលាសនៈក្នុងឋានតាវត្តិង្សពិតមែន ទេវតាពាន់មួយម៉ឺនលោកធាតុ ទីឯបួលមកប្រជុំស្តាប់ព្រះធម្មទេសនាក្នុងទីនោះ ទីឯកើតមានសេចក្តីសង្ស័យក្នុងចិត្តផ្សេង ៗ គ្នា ទេវតាពួកខ្លះបួលចិត្តថាព្រះតថាគតដែលព្រះអង្គទ្រង់យាងមកនេះ ដើម្បីទីឯសំដែងព្រះធម្មទេសនាប្រោរព្ធចំពោះយើងតាំងខ្លាយដោយពិត, ទេវតាពួកខ្លះទៀតបួលចិត្តថាព្រះតថាគតដែលព្រះអង្គទ្រង់យាងមកនេះ ព្រះអង្គពុំបានប្រោរព្ធចំពោះយើងតាំងខ្លាយទេ, មុខជាព្រះអង្គទ្រង់ប្រោរព្ធចំពោះបុគ្គលណាមួយដទៃដោយពិត, ទេវតាតាំងខ្លាយតិតុសាគ្នាដូច្នេះហើយ ក៏កើតសេចក្តីសង្ស័យគ្រប់ ៗ គ្នាពុំជាប់ស្រេច; កាលបើទេវតាពាន់មួយម៉ឺនលោកធាតុមានសេចក្តីសង្ស័យដូច្នេះហើយ, តថាគតក៏ទីឯប្រារព្ធសួរកែព្រះពុទ្ធមាតាថ្វាយសំតថាគតចំពោះសម្តេចសក្កទេវរាជថា បពិត្រមហាពាជ ព្រះមាតា

តថាគតគង់នៅឯណា ? សម្តេចព្រះសក្កទេវរាជនឹងក្រាបទូលតថាគត
ថា ព្រះពុទ្ធមាតាបស់ព្រះអង្គគង់នៅឋានតុសិត តថាគតនឹងបង្គាប់
សម្តេចសក្កទេវរាជថា បើដូច្នោះ ចូរមហាពាជទៅអញ្ជើញព្រះពុទ្ធមាតា
តថាគតចុះមកកន្លែងឋាននេះ, សម្តេចអម្ចាស្ត្រាធិរាជនឹងទៅអញ្ជើញពុទ្ធមាតា
របស់តថាគតឡើយដោយចុះមកគាន់ឋានតាវត្តឹង្សពិភពនេះដោយពិត; កាល
បើទេវតាទាំងមួយម៉ឺននោះបានជាតុ បានស្តាប់ពាក្យតថាគតពោលដូច្នោះ
ហើយ ក៏សាបនឹងគាត់សេចក្តីសង្ស័យរបស់ខ្លួនៗជាប់ស្រេចមួយរំពេចឥត
មានសង្ស័យឡើយ ចូលចិត្តជាក់ច្បាស់ថា ទុហ្ម! ព្រះសម្ចាសម្ពុទ្ធព្រះ
អង្គទ្រង់ប្រោរឮចំពោះព្រះមាតាបស់ព្រះអង្គទេតើ! ឯព្រះពុទ្ធមាតាបស់
តថាគតដែលមានប្រាថ្នានឹងស្តាប់ព្រះអភិធម្មទេសនា ហើយយាងចុះមក
ដោយផ្លូវឆ្ងាយមានសេចក្តីខ្វែយព្រួយលំបាកនោះសោត នឹងបានសោយ
នូវផលានិសង្សដ៏ប្រើនវៃក្រៃលែង ពាប់តាមដំហាន ក្នុងមួយដំហានបាន
បុណ្យមួយកន្តេាកល់ៗដំហានដោយពិត ។ ព្រះសម្ចាសម្ពុទ្ធជាម្ចាស់នៃ
យើងទាំងឡាយ ព្រះអង្គពិចារណាជ្រាបហេតុ ៤ ប្រការនេះហើយ បានជា
ព្រះអង្គទ្រង់យាងទៅគង់ចាំសង្គ្រាក្នុងឋានតាវត្តឹង្សពិភពនោះឯង ។

๘ - ធម្មវិចិ ពោលថា សាធុ ! តើ! អត្ថាធិប្បាយណាស់ហើយ

លោកជាឧបមាចំពោះធ្វើវិធានសង្កត់ដែរតែមែន ចេះវិសជ្ជនាដ៏ពិតសំរេចក្តី
ដ៏កំប៉ាំងដ៏ក្រាស់ជ្រៅផ្សែងណាសេចក្តីពាក់ព្រឹនស្តាប់បានដោយងាយ តែ
ត្រង់ហេតុទី ៤ សេចក្តីនៅទីបំផុតខាងចុង លោកវិសជ្ជនាថា ព្រះពុទ្ធមាតា
ដែលត្រូវយាងចុះមកដោយផ្លូវឆ្ងាយ ទៀតព្រោះលំបាកនោះនឹងបាន
សោយនូវផលានិសង្សដ៏ច្រើនវិសេសដែរ ពាក់តាមដំហានក្នុងមួយជំហាន
បានបុណ្យមួយអនន្តកល្បជំហាននោះ យើងមិនទាន់ចូលចិត្តស្តាប់បាន
នៅទេ ព្រោះព្រះសិរីមហាយាមាទេវបុត្រជាទេវតាមានមហិទ្ធានុភាព
ច្រើន គាចហោះហើរទៅតាមអាកាសបាន ទើបពាក់តាមដំហានដូចម្តេច
វិញ? ចើជាជាតិមនុស្សទៅតំណាចឈានដើរដើរទៅតាមផែនដីល្មមពាក់
ផានិសង្សតាមកាលៃនដំហានដែលឈានដើរទៅ ថាបានបុណ្យមួយអនន្ត
ទៅបាន ចុះចើព្រះសិរីមហាយាមាទេវបុត្រហោះទៅតាមអាកាសទេ, ទើប
ពាក់ផានិសង្សថាបានបុណ្យមួយអនន្ត ពីរអនន្តដោយដំហានដូចម្តេចបាន?

អ្នកវិទី វិសជ្ជនាតបថា ៩ ធម្មតាទីពាក់បានដូចគ្នាទេ ពោះបើមនុស្ស
សត្វដើរទៅតាមផែនដីក៏គង់ពាក់ដំហានបានដែរ មនុស្សដែលហែលទឹកក៏
គង់ពាក់ដំហានបានដែរ, សត្វហើរទៅលើអាកាសក៏គង់ពាក់ដំហានបានដែរ,
ទេវតាទាំងឡាយដែលមានឫទ្ធិហោះទៅតាមអាកាស ក៏គង់ពាក់ដំហាន

ចានដូចគ្នាដែរ, ឯមនុស្សដើរកាត់តាមកាវៈដំហានដែលឈានដើរ គឺឈាន
ទៅមួយកាវៈហៅថាមួយដំហាន តីរកាវៈហៅថាតីរដំហាន មនុស្សហែល
ឡើងកាត់តាមកាវៈជើងដែលខាងស្តាំហែលឆ្ងាយទៅខាងមុខ គឺជើងខាងស្តាំ
មួយកាវៈ ហៅថាមួយដំហាន, តីរកាវៈ ហៅថាតីរដំហាន, សត្វហើរទៅ
លើអាកាសកាត់តាមកាវៈខនះស្មាប គឺខនះស្មាបហើរមួយកាវៈ ហៅថាមួយ
ដំហាន, តីរកាវៈ ហៅថាតីរដំហាន, ពួកទេវតាទាំងឡាយដែលហោះ
ទៅតាមអាកាស កាត់តាមកាវៈជើងដែលផ្ទាស់ប្តូរ គឺកាវៈកន្លះជើងឆ្លើ
ក្បាលជង្គង់ខាងស្តាំឡើងខ្ពស់ឡើង សណ្តកជើងឆ្លងត្រង់ទៅ ហៅថាមួយ
ដំហាន កាវៈកន្លះជើងឆ្លើក្បាលជង្គង់ខាងឆ្វេងឡើងខ្ពស់ឡើង សណ្តកជើង
ខាងស្តាំត្រង់ទៅ ហៅថាមួយដំហាន, ឯព្រះសិរីមហាមាយាទេវបុត្រជា
ពុទ្ធមាតាដែលពាក្យថាបានបុណ្យច្រើនគ្រាលែង មួយដំហានបានបុណ្យ
មួយអនន្តៗដូច្នះគឺកាត់តាមកាវៈ ដៃជើងដែលផ្ទាស់ប្តូរហោះដូច្នោះឯង ។

๙- ធម្មរាជិ បានស្តាប់ហើយពោលថា អើអែតភាពខ្ញុំលោកវិសជ្ជនា
មកចុំណ្តោះនេះ យើងស្តាប់បានចូលចិត្តហើយរឿងនេះ, តែយើងមាន
សង្ស័យតទៅទៀត, ចុះព្រះសិរីមហាមាយាទេវបុត្រជាពុទ្ធមាតា, បើបាន
ស្តាប់ព្រះអភិធម្មបានផលានិសង្សដ៏ច្រើនគ្រាលែង ពាក់តាមកាវៈដំហាន

ដែលថ្នាស់ប្លែកដើងហោះ មួយវារៈ ហៅថាមួយដំហាន បានបុណ្យមួយអនន្ត, ពីរវារៈ ហៅថាពីរដំហាន បានបុណ្យពីរអនន្ត, ហើយហោះចុះតាំងពីឋានតុសិតរំលងឋានយាមមួយទៀត ទើបបានមកដល់ឋានតាវត្តឹង្សពិភព ឃើញថាឆ្ងាយពន់ពេកណាស់ ចេកចំតាមវារៈដំហានច្រើនជាងសែនកោដិដំហាន បានបុណ្យច្រើនជាងសែនកោដិអនន្ត ជាអានេកពាក្យពុំអស់យ៉ាងនេះហើយ កាលណាឡើយនឹងប្លែចផុតចាកសង្ខារទុក្ខបានមុនជានឹងសោយជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ នឹងមរណទុក្ខជាដើម នឹងស្លាប់កើតៗ សោយសុខវេទនាប្រឡំជាមួយទុក្ខវេទនា ដេកគ្រាំនៅក្នុងសង្ខារភព ឥតមានទីបំផុតជាតិទុក្ខជាដើមឡើយ ឯជាតិកំណើតក៏កាន់តែច្រើនឡើងៗ ដោយបុណ្យជាអនន្តៗ បានកម្លាំងនាំឲ្យមានជាតិកំណើតកាន់តែឆ្ងាយរៀងទៅៗ រកទីបំផុតជាតិឥតមាន តាក់ទានបានសម្រេចព្រះនិព្វានទៅ ឬដូចម្តេច ?

អត្ថវិធី វិសជ្ជនាតបថា បតិត្រធម្មកថី មិនមែនដូច្នោះទេ ព្រោះព្រះសម្មាសម្ពុទ្ធត្រាស់ព្រះអង្គ ដែលទ្រង់សំដែងសរសើរផលានិសង្សបុណ្យស្តាប់ព្រះធម៌ទេសនាថាជាបុណ្យដ៏ឧត្តមខ្ពង់ខ្ពស់នោះ ទោះបីបុគ្គលណាមួយមានប្រាថ្នាខ្ពង់ស្តាប់ព្រះធម៌ទេសនា ហើយឈានដើរដើរទៅ

កាន់ទីព្រះវិហារ ដែលជាទីប្រជុំគ្នាស្តាប់ព្រះធម៌ទេសនា បុគ្គលទាំងនោះ
ទទឹងបានបុណ្យច្រើន តាមការៈនៃជំហាន. ដែលឈានដើរទៅ មួយ
ជំហាន បានបុណ្យមួយអនន្តៗនោះ ទទឹងថែរជាបានគុណឡើងថាបុណ្យ
នោះនាំឲ្យមានជាតិកំណើតវិលស្តាប់វិលកើត រហូតសុទ្ធវេទនាប្រឡំ
ទៅដោយកងទុក្ខទាំងពួង មានជាតិទុក្ខជារដើម ដេកគ្រាំនៅក្នុងសង្សារ-
ភព ឲ្យមានជាតិកំណើតកាន់តែច្រើនឡើង ។ រីឯទៅ : រកទីបំផុត
ជាតិគ្មានជួបច្បោះគំរេ, ឯព្រះសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់ព្រះអង្គ- ដែលទ្រង់
សំដែងធម៌ទេសនាសរសើរថា បុគ្គលមានក្រាថ្នាចង់ស្តាប់ធម៌ទេសនា
សូមឲ្យតែឈានដើរដើរទៅមួយជំហាន បានបុណ្យមួយអនន្ត, ពីរជំហាន
បានបុណ្យពីរអនន្ត, មិនមែនឲ្យគុណឡើងចំរើនជាតិឲ្យកាន់តែមានច្រើន
ឡើងរៀងទៅ ។ រកទីបំផុតជាតិគ្មានជួបច្បោះទេ តើព្រះអង្គឲ្យគុណថយជាតិ
ឲ្យខ្លីចុះមកតិចទេតើ! សេចក្តីអធិប្បាយថា ចើបុគ្គលបានឈានដើរ
ទៅប្រឹងនឹងស្តាប់ធម៌ទេសនា ឈានដើរទៅមួយជំហានបានបុណ្យមួយ
អនន្តនោះតើ ថយជាតិកំណើតខ្លីតិចចុះមក មួយអនន្តជាតិដែរ ឈានដើរ
ទៅពីរជំហាន បានបុណ្យពីរអនន្ត ជាតិកំណើតក៏កាន់តែខ្លីថយចុះតិចមក
ពីរអនន្តជាតិដែរ ដូនកាលបានសំរេចមគ្គផលកន្លងបច្ចុប្បន្នជាតិនេះទៅ

កំតង់មានខ្លះ បើពុកជាពុំបានសំរេចមគ្គផលក្នុងជាតិនេះ កំតង់
បានជាវាសនាជាមិយាំង ៗ ត្តមកទៀតទៅខាងមុខទៀត បើបានជួបប្រទះនឹង
ពុទ្ធុប្បាទ កាលដែលព្រះសម្មាសម្ពុទ្ធបានត្រាស់ប្បាសាទៅនឹងក្នុងលោក
ជាខាងក្រោយនឹងបានស្តាប់ព្រះធម៌ទេសនា ក្នុងទីចំពោះព្រះភ័ក្ត្រព្រះ
សម្មាសម្ពុទ្ធអង្គនោះ ហើយគាចបានត្រាស់ជីនូវមគ្គផលមួយ ៗ ពេញ
បានយ៉ាងយូរឡើយ ។

ឯព្រះសិរីមហាមាយាទេវបុត្រ ជាពុទ្ធមាតាដែលយាងចុះមកស្តាប់
ព្រះអភិធម្មនោះ សំដែងថាបានបុណ្យច្រើនអនន្តនោះគឺគុណថយជាតិឲ្យ
ខ្ពស់តិចចុះមក ដូចសេចក្តីអធិប្បាយមកខាងលើនេះដែរ ។

១០- ធម្មរាជី បានស្តាប់រឿងនេះហើយយល់ព្រមទើបសួរតទៅ
ទៀតថា ព្រះសម្មាសម្ពុទ្ធ កាលដែលព្រះអង្គឥតរំលើផែនថ្មបណ្តាកម្ពល-
សិលាសនៈក្រោមដើមជាទីប្តូនកព្រឹក្ស សំដែងបរមត្ថព្រះអភិធម្មប្រាប់ព្ធ
ចំពោះសម្តេចព្រះសិរីមហាមាយាទេវបុត្រជាពុទ្ធមាតា ក្នុងកណ្តាលជំនុំនៃ
ទេវតាចាំងមួយម៉ឺនលោកជាតុនោះអស់រយៈកាលចំនួនប៉ុន្មានខែ ប៉ុន្មាន
ថ្ងៃ ទើបចប់? ដែលព្រះអង្គទ្រង់សំដែងព្រះអភិធម្មនោះទៀត មានពេល
ព្រះអង្គឈប់សម្រាកខ្លះដែរឬទេដូចម្តេច ?

អគ្គវិទី វិសជ្ជនាតបថា កាលដែលអគ្គព្រះសម្មាសម្ពុទ្ធទ្រង់សំដែងបរមត្ថព្រះអភិធម្មនោះ កំណត់បាន១ បើគិតជាថ្ងៃវិញបាន៩០ (១) ថ្ងៃតត់; ដែលព្រះអគ្គទ្រង់សំដែងនោះសោត កំគ្មានកាលវេលាឈប់សម្រាកទេ តែព្រះអគ្គទ្រង់សំដែងតអនុសន្ធិអភិធម្មកថា ហូរហែតាមរបៀបបរមត្ថព្រះអភិធម្មជាប់គ្នាមិនដាច់ ជានិរន្តរកាល ជាបវដ្តច្បាស់ដោយពិត ។

๑๑- ធម្មវិទី បានស្តាប់ហើយ សួរតទៅទៀតថា អើ! អត្តវាទី បើដូច្នោះ កន្លងអស់វស្សន្តរដូវបាន ๑ ๙๐ ថ្ងៃនោះ ព្រះអរហំសម្មាសម្ពុទ្ធព្រះអង្គពុំបានយកអាសុណ សោយឈើស្នូន លុបព្រះភ័ក្ត្រ ពុំបានយាងទៅចិណ្ឌបាត ឆ្លើកគ្គកិច្ច ពុំបានផ្តុំសំពកព្រះអង្គ កិច្ចទាំង៤នេះគ្មានសោះទេឬដូចម្តេច ?

អគ្គវិទី វិសជ្ជនាតបថា បពិត្រធម្មវាទី មិនមែនដូច្នោះទេ ឯព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអគ្គទ្រង់សំដែងព្រះអភិធម្មនោះ កំព្រះអគ្គទ្រង់សំដែងជានិរន្តរកាល អស់កាលជាប់មិនដាច់ ពេលអាសុណរះកំព្រះអគ្គចុះមកកាន់ផម្ពូទីប យកអាសុណ សោយឈើស្នូន លុបព្រះភ័ក្ត្រ ពេលចិណ្ឌបាត កំព្រះអគ្គយាងទៅចិណ្ឌបាត ពេលសោយចង្ហាន់ កំព្រះអគ្គ

---

๑ ក្នុងបាលីជា๙๐ថ្ងៃ ប៉ុន្តែបើតាមទំនៀមរដោះខែស្រាពណ៌ជាបក្ខទាតយើញបានតែ๙๙ថ្ងៃទេ

សោយបង្ហាន់ ពេលផ្ទុំ កំព្រះអង្គទ្រង់ផ្ទុំដោយពិត ។

១២- ធម្មវាទី ស្តាប់ហើយសួរបញ្ជាក់តទៅទៀតថា អើតែត្រង់ប្រស្នាដែលលោកដោះស្រាយមកនេះ យើងស្តាប់មិនទាន់ចុងនៅឡើយទេ ព្រោះសេចក្តីខាងដើមនឹងខាងចុងឃ្លាងចេញពីគ្នា ឯខាងដើមលោកវិសជ្ជនាថា ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងព្រះអភិធម្មជានិន្នៈកាល អស់កាលគ្មានបន្ទោះដកបដល់ចប់, ដល់ខាងចុងលោកវិសជ្ជនាថា ព្រះសម្មាសម្ពុទ្ធដល់ពេលអុណោះ ព្រះអង្គទ្រង់យាងចុះមកកាន់ជម្ពូទ្វីប យកអុណោសោយឈើស្តួន់ លាបព្រះឆ័ត្រ យាងទៅបិណ្ឌបាត សោយបង្ហាន់ហើយផ្ទុំសម្រាកព្រះអង្គផង ឃើញថាចាក់ស្រេះ ព័ន្ធសេចក្តីគ្នាស្តាប់ពុំបាន ប្រសិនបើព្រះសម្មាសម្ពុទ្ធតែមួយព្រះអង្គ ទ្រង់សំដែងព្រះអភិធម្មតែមានសម្រាកសោះ ហើយមានព្រះពុទ្ធអង្គឯណាទៀត ចុះមកយកអុណោ សោយឈើស្តួន់ លុបព្រះឆ័ត្រ បិណ្ឌបាត សោយបង្ហាន់ហើយផ្ទុំសម្រាកព្រះអង្គផង ឬមានព្រះពុទ្ធច្រើនព្រះអង្គជាន់វេនផ្ទាស់ប្តូរគ្នាទៅ ឬដូចម្តេច ?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ព្រះសម្មាសម្ពុទ្ធមិនមានច្រើនព្រះអង្គទេ គឺមានតែមួយព្រះអង្គពិត តែថាព្រះអង្គជាបុគ្គលឯក

ថ្ងៃកសុក្កវ្រណាសំ ប្រសើរជាងអត្តនិកាយទាំងឡាយមានមនុស្សទាំង
ទេវតាជាដើម ទាំងរាប់ចូលនឹងណាមួយដទៃមកប្រៀបផ្ទឹមនឹងព្រះអង្គពុំ
បានទេឡើយ ព្រោះអង្គជាព្រះពុទ្ធតែមួយព្រះអង្គទេ តែបើព្រះអង្គប្រាថ្នាចង់
ធ្វើឲ្យ ៧ជាព្រះពុទ្ធច្រើនព្រះអង្គក៏បាន ព្រោះព្រះអង្គប្រកបដោយឫទ្ធិ
ពាំង ១០ មានមនោមយិទ្ធិជាដើម សម្រេចតាមព្រះហឫទ័យព្រះអង្គ បើ
ព្រះអង្គមានប្រាថ្នាយ៉ាងណា ក៏អាចធ្វើបានតាមប្រាថ្នាយ៉ាងនោះ ពុំបាន
ខើសភាល់ឡើយ កាលដែលព្រះអង្គទ្រង់សំដែងព្រះអភិធម្មប្បាវចរ
ចំពោះព្រះពុទ្ធមាតា តទំាំងក្នុងកណ្តាលវស្សាទុំនៃទេវតាពាំងមួយម៉ឺនលោ
កោះ ព្រះអង្គទ្រង់តិចាណារមិលមើលគោល កាលបើបានជ្រាបច្បាស់
ថា ពេលនេះអាណាជតរៈហើយ ហើយព្រះអង្គនិម្មិតជាពុទ្ធនិម្មិតឲ្យ
សំដែងព្រះអភិធម្មជំនួសព្រះអង្គតទៅ ឯព្រះសម្មាសម្ពុទ្ធក៏ទ្រង់យាងចុះ
មកតាន់ដម្ពូថ្ម ឃកអាណា សោយឈើស្នូនំ លុបព្រះភ័ក្ត្រ ក្រោបទៅ
ចិណ្ឌបាតធ្វើតត្តកិច្ច. ស្រេចហើយយាងឡើងទៅតាន់ហានតាវត្តិង្សភាព
វិញ ទ្រង់សំដែងព្រះអភិធម្ម តអំពីពុទ្ធនិម្មិតសំដែងនោះរហូតទៅ ព្រះ
អង្គទ្រង់ចំណាយពាំងនេះតែកន្លះៗថ្ងៃ ត្រូវ ៤០ ថ្ងៃគត់ ទេវតាចង់ឮឃកពុ
ងុនដឹងទេ; លុះដល់ពេលអួរព្រះអង្គផ្ទំហើយ ទ្រង់និម្មិតជាពុទ្ធនិម្មិត ឲ្យ

សំដែងព្រះអភិធម្មជំនួសព្រះអង្គ ហើយព្រះអង្គទ្រង់ផ្ទៀ ដល់ពេលព្រះអង្គតើនឡើង ទើបទ្រង់សំដែងព្រះអភិធម្មតាមពុទ្ធដំណើរសំដែងនោះទៀតៗ ព្រះអង្គទ្រង់ធ្វើយ៉ាងនេះតែពាល់ ๑ ថ្ងៃ ជាធម្មតាពុំដែលជាច់ឡើយ មិនតែប៉ុណ្ណោះ កំពុងកិច្ចតាំង ๙ ក្នុងរវាងត្រមាស ๙๐ ថ្ងៃនេះ ព្រះអង្គពុំលះបង់ឡើយ ទ្រង់បំពេញបានគ្រប់សព្វគាំងអស់ដោយពិត ។

๑๓ - ធម្មវិទី បានស្តាប់ហើយ ពោលថាសាធុ ៗ ប្រពៃណាស់ហើយ ម្រះស្នាដែលលោកដោះស្រាយមកនេះ យើងស្តាប់បានចូលចិត្តហើយ តែនៅមានសេចក្តីសង្ស័យតទៅទៀត ចុះព្រះទសពលញ្ញាណជាម្ចាស់ តើព្រះអង្គទ្រង់យាងចុះមកកាន់ជម្ពូទ្វីបយកអ្វីណា សោយឈើស្ទូង់លុបព្រះកត្រុ ក្នុងទីកន្លែងប្រទេសណា ? គ្រាប់ទៅបិណ្ឌបាតក្នុងស្រុកភូមិប្រទេសណា ? គ្រឡប់មកតង់ធ្វើកត្តកិច្ច សោយចង្ហាន់ក្នុងទីណាកន្លែងប្រទេសណា ?

អត្ថវិទី វិសជ្ជនាតបថា ព្រះសយម្ភូញ្ញាណជាម្ចាស់ ដែលព្រះអង្គទ្រង់យាងចុះមកកាន់ជម្ពូទ្វីបនោះ ទ្រង់គង់ទៀបមាត់ស្រះអនោតត្តក្នុងប្រទេសហិមពាន្ត ទ្រង់យកអ្វីណារះច្បាស់តេញស្ទើហើយ ទ្រង់សោយឈើស្ទូង់ទំព្វដែលទេវតាថ្វាយព្រះអង្គ ទំលុបលាងព្រះកត្រុ

ដោយទឹកស្រះអនោតត្តជ៏ត្រជាក់ឆ្ងាល្អវិសេស ស្រេចហើយព្រះអង្គ
ត្រាច់ទៅបិណ្ឌបាតឯទុត្តរកុរុទ្វីប ដោយពុទ្ធានុភាពតែមួយរំពេចបានដល់
ទៅទុត្តរកុរុទ្វីប ហើយទ្រង់យាងទៅបិណ្ឌបាត តាមលំដាប់ច្រកផ្លូវក្នុង
ទុត្តរកុរុទ្វីបនោះ បានបង្ហាន់ល្មមមួយចំអែតហើយ ក៏ព្រះអង្គយាងត្រឡប់
មកកាន់ច្រកទ្វេសហ៊ិមពានព្តវិញ តង់លើបុប្ផាសនៈក្រោមដើមទុលោក-
ព្រឹក្ស មានសណ្ឋានដូចមណ្ឌបដ៏ធំទូលាយសាទាល្អ ក្នុងទីជិតស្រះ
អនោតត្តនោះ ហើយទ្រង់ធ្វើកត្តកិច្ច សោយបង្ហាន់ សម្រេចកិច្ច ហើយ
ទើបទ្រង់យាងទៅកាន់ហានតាវត្តិឆ្នៃកតវិញ, ដែលព្រះសម្មាសម្ពុទ្ធទ្រង់
ធ្វើយ៉ាងនេះ តទ្រង់ធ្វើពល់ៗថ្ងៃអស់ត្រមាសចំនៃរដូវពិត ។

១៤- ធម្មវិធី ទទួលថាសាធុអត្តកថីប្រពៃហើយប្រស្នានេះ, តែ
នៅមានសេចក្តីចាក់ចងគ្នាគួរឲ្យមានសេចក្តីសង្ស័យតទៅទៀត អើអត្ត-
កថី ក្នុងវិភាលគោជនសិក្ខាបទ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតឲ្យភិក្ខុ
ទទួលបង្ហាន់ឆាន់បាន តាំងពីពេលអរុណរះភ្លឺឡាស់ជាប់ដល់ថ្ងៃជិតត្រង់
ទើបឆាន់បានប្រកាបក្តី តែដល់ថ្ងៃរសៀលជ្រេតត្រង់សូម្បីតែមួយចំរៀក
សក់ ហើយភិក្ខុទទួលបង្ហាន់ឲ្យកន្លងផុតទីដែនខ្លួនឯង ត្រូវគាបក្តីភ្លក
ឆាន់ត្រូវគាបក្តីបាចិត្តិយពល់ៗមាំត់ ឬព្រះសម្មាសម្ពុទ្ធព្រះអង្គយតអរុណា

វេកង់ជម្ពូទីប ថៃត្រង់កង់ឫទ្ធិវេហាទីប យប់ឯខត្តវេទីប ហើយព្រះអង្គ
យាងទៅចិណ្ឌបាតឯខត្តវេទីប ខ្ញុំលចិណ្ឌបាតកង់វេលាយប់ដូចេះ
មិនតាស់ខុសនឹងវិកាលកោជនសិក្ខាបទនោះទេឬដូចម្តេច? មួយវិញទៀត
ព្រះអង្គយកអរុណកង់ជម្ពូទីបហើយ ដូចម្តេចក៏ព្រះអង្គមិនយាងទៅ
ចិណ្ឌបាតកង់ជម្ពូទីបដែលអរុណរះត្រូវគ្នានោះ? ក៏ព្រះអង្គត្រឡប់ជាទៅ
ចិណ្ឌបាតឯខត្តវេទីបកង់វេលាយប់វិញ តើព្រះអង្គខ្ជិនល្ងង់ឃ្លង់
ប្រយោជន៍ដូចម្តេចខ្លះ?

អត្ថវិទី វិសជ្ជនាថា បពិត្រធម្មាភី ព្រះសម្មាសម្ពុទ្ធព្រះអង្គបាន
ត្រាស់ដឹងអភិសម្ពោធិញ្ញាណកង់ជម្ពូទីបពិត វិកាលកោជនសិក្ខាបទ
ក៏ព្រះអង្គបញ្ញត្តកង់ជម្ពូទីបដែរ ព្រះអង្គពុំបានបញ្ញត្តហាមកង់ខត្តវេទីប
ញ្ញត្តទេ កង់ជម្ពូទីបនោះទេ បើព្រះអង្គបានយកអរុណរះកង់ជម្ពូទីបហើយ ទើបខ្ជិនយាង
ទៅចិណ្ឌបាតខ្ញុំលចិណ្ឌបាតឯខត្តវេទីបនោះ បានឈ្មោះថាព្រះអង្គខ្ញុំលចិណ្ឌ
ចិណ្ឌបិណ្ឌបាតកង់វេលាព្រឹកដោយពិត មិនបានតាស់ខុសអ្វីកង់វិកាល
កោជនសិក្ខាបទនោះទេ មួយវិញទៀត ព្រះអរហំសម្មាសម្ពុទ្ធព្រះអង្គ
ប្រកបដោយមេត្តាគុណ មានជួនព្រះហឫទ័យស្រឡាញ់រាប់អានសត្វ
ក្រៃប្រយោជន៍ដែលកែបកឱ្យសត្វសោតាបាំងអស់ស្មើៗគ្នា ពុំរើសមុខ

ព្រះអង្គប្រកបដោយគុណាគុណ មានជួងព្រះហ្ឫទ័យទន់ត្រជាក់គាណិត
គាស្រូវផ្សាយទៅកាន់សព្វសត្វដែលជាប់នៅក្នុងចំណងទាំង ៧ ប្រការ
នឹងដែនទៅក្នុងតំនរភ្នំទាំង ១១ ប្រការ នេះពេលកាលជាប់ជាន់ក្នុងអា-
ស្រ័យហេតុនេះហើយបានជាអង្គព្រះសព្វញ្ញូសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់យាងទៅ
បិណ្ឌបាតប្រោសមនុស្សដែលនៅក្នុងនគរកុរុទ្ធីបនោះ ដើម្បីឲ្យបានបុណ្យ
ច្រើនជាវាសនាធម៌តទៅខាងមុខទៀត នឹងបានសោយសុខរួចផុតពីទុគ-
សង្គ្រាមទុក្ខ កំពុងដែលព្រះអង្គទ្រង់យាងទៅបិណ្ឌបាតឯនគរកុរុទ្ធីបនោះ
ព្រះអង្គទ្រង់បញ្ចេញឆព្ភណ្ណរង្សីស្មើទាំង ៦ ពណ៌ ផ្សាយទៅក្នុងនគ-
រកុរុទ្ធីបទាំងមូលជាភ្លឺស្វាងរុងរឿងត្រជាក់សប្បាយវិសេស ជាងពន្លឺព្រះអា-
ទិត្យព្រះចន្ទ្រដោយពិត មនុស្សទាំងឡាយដែលបានជ្រះថ្លាយកចង្ហាន់មក
ជាក់ជាត្រូវថ្វាយព្រះអង្គ ក៏បានសោយចំណែនបុណ្យតាមទេយ្យទាន
របស់ខ្លួនៗនោះទៅ មនុស្សទាំងឡាយដែលនៅឆ្ងាយនឹងយកចង្ហាន់មក
ជាក់ជាត្រូព្រះអង្គមិនបានទេ ក៏គង់កើតសេចក្តីជ្រះថ្លាខ្ពស់ជាយកវាចាចិត្ត
នមស្សការថ្វាយបង្គំចំពោះព្រះអង្គ នឹងបានសោយចំណែកបុណ្យតាម
កិច្ចដែលនមស្សការនោះឯង ឯមនុស្សទាំងឡាយនោះនឹងបានបុណ្យ
ច្រើនជាអសង្ខ្យេយ្យ កើតជាវាសនាធម៌តទៅខាងមុខទៀត នឹងបាន

សោយសុខដរាបដល់ព្រះនិព្វាន តុំបានឃ្លៀងឃ្លាតឡើយ ឯព្រះសម្ម-
សម្ពុទ្ធជាម្ចាស់នៃយើងទាំងឡាយ បានជាព្រះអង្គទ្រង់យាងទៅចំណាកាត
ឯខន្ធកុរុទ្ធបានោះ ព្រោះព្រះអង្គទ្រង់ឈ្វេងយល់ប្រយោជន៍ ដូចបាន
អធិប្បាយមកខាងលើនេះ ដែលព្រះអង្គទ្រង់យាងទៅចំណាកាតឯខន្ធ-
កុរុទ្ធបានោះទៀត គឺព្រះអង្គយាងទៅពល់ៗថ្ងៃអស់ត្រមាសចាំទៀតុំដែល
ជាប់ឡើយ ។

๑๕ - ធម្មវិទី ខ្ញុំសូមថា សាធុ អត្ថវិទី ប្រស្នានេះប្រពៃណាស់
ហើយ យើងនឹងសួរប្រស្នាដទៃតទៅទៀត ឱព្រះសម្ចាសម្ពុទ្ធទ្រង់
សំដែងបរមត្ថព្រះអភិធម្មនោះ ចែកជាឋកវណ:គឺគម្ពីរមានប៉ុន្មានគម្ពីរ ?
គឺគម្ពីរឈ្មោះអ្វីខ្លះ ? គឺគម្ពីរនីមួយ ។ មានធម្មក្ខន្ធប៉ុន្មាន ? មានឆាណវារ:
ប៉ុន្មាន ? មានគណ្ឋ:ប៉ុន្មាន ? មានអក្ខរ:ប៉ុន្មាន ? អស់រយ:កាលប៉ុន្មាន ?
ទេវតាបានសំរេចមគ្គផលប៉ុន្មានគោដ ? ឬក៏មគម្ពីរទាំងអស់ត្រូវជាធម្មក្ខន្ធ
ប៉ុន្មាន ? ឆាណវារ:ប៉ុន្មាន ? គណ្ឋ:ប៉ុន្មាន ? អក្ខរ:ប៉ុន្មាន ? អស់រយ:កាល
ប៉ុន្មាន ? ទេវតាបានសំរេចមគ្គផលប៉ុន្មានគោដ ?

អត្ថវិទី វិសជ្ជនាថា បពិត្រធម្មវិទីកាលព្រះសម្ចាសម្ពុទ្ធទ្រង់សំ-
ដែងបរមត្ថព្រះអភិធម្មនោះ ចែកជាគម្ពីរមាន ๗ គឺ ធម្មសង្គណី ๑ វិភង្គ ๑

ជាតុកថា ១ បុគ្គលប្ញត្តិ ១ កថាវត្ថុ ១ យមក: ១ មហាបដ្ឋាន ១ ។

គម្ពីរធម្មសង្គណីព្រះអង្គទ្រង់សំដែង ១៣០០ ធម្មក្ខន្ធ, ២៤ ភាណវារ:, ៥៩០០ គណ្ឌ:, ១ សែន ៧ ម៉ឺន ៦ ពាន់អក្ខរ:, ទ្រង់សំដែង ១២ ថ្ងៃទើបចប់, ខេវតាបានសំរេច ៧ គោដិ ។

គម្ពីរវិភង្គ ព្រះអង្គទ្រង់សំដែង ៦៥០០ ធម្មក្ខន្ធ, ៣៤ ភាណវារ:, ៨៥០០ គណ្ឌ:, ២ សែន ៧ ម៉ឺន ២ ពាន់អក្ខរ:, ទ្រង់សំដែង ១២ ថ្ងៃទើបចប់, ខេវតាបានសម្រេច ៧ គោដិ ។

គម្ពីរធាតុកថា ព្រះអង្គទ្រង់សំដែង ៧០០០ ធម្មក្ខន្ធ, ១១ ភាណវារ: ២៧៥០ គណ្ឌ:, ៨ ម៉ឺន ៨ ពាន់អក្ខរ:, ទ្រង់សំដែង ៦ ថ្ងៃទើបចប់, ខេវតាបានសម្រេច ៦ គោដិ ។

គម្ពីរបុគ្គលប្ញត្តិ ព្រះអង្គទ្រង់សំដែង ៩៦០០ ធម្មក្ខន្ធ, ១១ ភាណវារ:, ២៧៥០ គណ្ឌ:, ៨ ម៉ឺន ៨ ពាន់អក្ខរ:, ទ្រង់សំដែង ៧ ថ្ងៃទើបចប់, ខេវតាបានសម្រេច ៦ គោដិ ។

គម្ពីរកថាវត្ថុ ព្រះអង្គទ្រង់សំដែង ៧១០០ ធម្មក្ខន្ធ, ៣៤ ភាណវារ: ៨៥០០ គណ្ឌ:, ២ សែន ៧ ម៉ឺន ២ ពាន់អក្ខរ:, ទ្រង់សំដែង ១២ ថ្ងៃទើបចប់, ខេវតាបានសម្រេច ៧ គោដិ ។

គម្ពីរយមក: ព្រះអង្គទ្រង់សំដែង ៥១០០ ធម្មក្ខន្ធ, ១២០ ភាណ-
វារៈ, ៣០០០០ គណ្ឌៈ, ៨ សែន ៦ម៉ឺនអក្ខរៈ,. ទ្រង់សំដែង ១៨ ថ្ងៃទើប
ចប់, ទេវតាបានសម្រេច ៧ កោដិ ។

គម្ពីរមហាបដ្ឋាន ព្រះអង្គទ្រង់សំដែង ៨៤០០ ធម្មក្ខន្ធ, ១៨៦ភា-
ណវារៈ, ៨៥៥០០ គណ្ឌៈ, ១ លាន ៨ សែន ៥ម៉ឺន ៦ ពាន់អក្ខរៈ, ទ្រង់
សំដែង ៤៣ ថ្ងៃទើបចប់, ទេវតាបានសម្រេច ៤០ កោដិ ។ បូកបញ្ចូ
គាំងអស់ ៤ ម៉ឺន ២ ពាន់ ធម្មក្ខន្ធ, ៤១៤ ភាណវារៈ, ១ សែន ៣ ពាន់
៥០០ គណ្ឌៈ, ៣ លាន ៨ សែន ១ ម៉ឺន ២ ពាន់អក្ខរៈ, ៨០ ថ្ងៃទើបចប់,
ទេវតាបានសម្រេច ៨០ កោដិនត់ ។

ឯព្រះសម្ងាសម្ពុទ្ធព្រះអង្គទ្រង់សំដែងចរមគ្គព្រះអភិធម្មនោះ ហើយ
ទ្រង់កំណត់ធម្មក្ខន្ធ ភាណវារៈ គណ្ឌៈ អក្ខរៈដូច្នេះ ដើម្បីរក្សាធម្មវិស
និងអត្ថវិសេឲ្យថិតថេរចំរើរកាលយូរអង្វែងតទៅតាមសភាពពិត ការពារ
មិនឲ្យមានលម្ងៃ ធម្មវិស អត្ថវិសដទៃ ដែលពុំពិតកើតដោយតំនិតរបស់
ខ្លួនបួលមកថ្វមបន្ថែមផងបានដោយពិត ។

១៦- ធម្មភិទ្ធិ ខ្លួលថា សាធុ អត្ថវិ ប្រស្នានេះប្រៀតណាស់
ហើយ តែយើងនៅមានសេចក្តីសង្ស័យតទៅទៀត ត្រង់សេចក្តីដែល

អត្ថកថាអធិប្បាយថា ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងវិបរមេតព្រះអភិធម្មនោះ
កំណត់ ៨០ ថ្ងៃទើបចប់ ទេវតាបានសម្រេចមគ្គផល ៨០ កោដិ ចុះព្រះ
សម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សំដែងព្រះអភិធម្មតថស្ថឯសងគុណ
ប្រារព្ធចំពោះព្រះពុទ្ធមាតាបវេសព្រះឥន្ទ្រទេ លុះចប់ព្រះអភិធម្មកថាហើយ
ទេវតាបានសម្រេចមគ្គផលជាប់ ៨០ កោដិ ត្រង់ព្រះពុទ្ធមាតាមិនឮសំដែង
ប្រាប់ថាបានសម្រេចមគ្គផលអ្វីសោះ ឬបានសម្រេចដែរ តែកប់បញ្ចូល
ក្នុងពួកទេវតាចាំង ៨០ កោដិនោះ ឬព្រះពុទ្ធមាតាមានព្រះហ្ឫទ័យពុំបាន
ឃាតចុះកាន់ធម្មទេសនា ដោយមានព្រះហ្ឫទ័យផ្សាយទៅកាន់អារម្មណ៍
ផ្សេង ។ អាក់មានសម្រេចមគ្គផលទៅ ឬដូចម្តេចខ្លះ ?

អត្ថវិនិច្ឆ័យ វិសជ្ជនាថា បពិត្រធម្មាភីសម្ពុទ្ធព្រះសិរីមហាមាយាទេវបុត្រ
ព្រះពុទ្ធមាតាបានសម្រេចមគ្គផលពិត តែពុំបានកប់បញ្ចូលក្នុងពួកទេវតា
ចាំង ៨០ កោដិនោះទេ គឺបានសម្រេចជាខាងក្រោយបន្ទាប់ទេវតាចាំង ៨០
កោដិនោះឯង ព្រោះព្រះសិរីមហាមាយាទេវបុត្រជាព្រះពុទ្ធមាតា កាលបុរេ
បុះមកតាំស្តាប់ព្រះអភិធម្មចំពោះព្រះភ័ក្ត្រព្រះដ៏មានព្រះភាគនោះ បាន
ឧគ្គហេយ្យព្រះពុទ្ធបុត្រព្រះឥន្ទ្រប្រកបដោយមហាបុរិសលក្ខណៈ ៣២ និង
អនុព្យញ្ជន ៨០ ជាមហាបុរិសយ៉ាងឯកល្អក្រៃ ប្រសើរជាងមនុស្សទេវតា

ពាំងអស់កំកើតសេចក្តីស្នេហាស្រឡាញ់ពេញព្រះហ្ឫទ័យនឹងព្រះពុទ្ធបុត្រ
នោះពន់ពេកណាស់ មានសេចក្តីសោមនស្សត្រេកអរកើតឃើញរៀបរាប់ខ្លួន
ឯងថា អញជាមនុស្សកើតមកជាស្ត្រីប្រុសមើលសេសជាងស្ត្រីពាំងអស់ក្នុងលោក
អញមានវាសនាបានទ្រទ្រង់ខ្ចប់ព្រះត្រជាប់សុទ្ធបានប្រសូតមកហើយកំបានត្រាស់
ជឹងជាអគ្គព្រះអរហំសម្មាសម្ពុទ្ធប្រាកដក្នុងលោក ដោយសេចក្តីស្នេហា
នេះហើយ បានជាព្រះពុទ្ធមាតាពុំបានសម្រេចមគ្គផលជាមួយនឹងខ្មៅតា
ពាំង ៩០ គោដ លុះរំលងដល់ចប់ព្រះអភិធម្មនោះ ទើបអគ្គសម្ពុទ្ធព្រះ
មុនិន្ទ្រជិនស្រីជាម្ចាស់ ទ្រង់បានជ្រាបហេតុនេះហើយ កំទ្រង់សាសំដែង
ក្នុងគម្ពីរវិភង្គ ចំណែកចែកខ្ចប់ព្រះចតុកាយសច្ចពាំងប្លន់ដោយសេចក្តី
ពិស្តារមួយរំលងទៀត ដល់ចប់ព្រះចតុកាយសច្ចពាំង ៤ ស្រេចហើយ
ទើបសម្ពុទ្ធព្រះពុទ្ធមាតាបានសម្រេចសោតាបត្តិផល ជាវិសេសថ្លៃកាត់
ខ្មៅតាពាំងឡាយនោះ ព្រោះខ្មៅតាពួកខ្លះបានសម្រេចជាសត្តក្ខត្តុំសោតា
កំណាត់៧ជាតិទៀត ទើបបានសម្រេចដល់ព្រះនិព្វាន, ខ្មៅតាពួកខ្លះបាន
សម្រេចជា កោលំកោលសោតា កំណាត់៦ជាតិទៀត ទើបបានសម្រេច
ដល់ព្រះនិព្វាន, ខ្មៅតាពួកខ្លះបានសម្រេចជា ឯកពីជិសោតាកំណាត់១ជាតិ
ទៀតទើបបានសម្រេចដល់ព្រះនិព្វាន, ឯព្រះសិរីមហាមាយាខ្ចប់ព្រះ

ជាព្រះពុទ្ធមាតាបានសម្រេចសោតាប្លែកឈ្មោះថា លោកនាមិសប្បុរសោតា ជាសោតាវិសេសពុំបានត្រឡប់មកកាន់កាមលោកនេះវិញទេ តែឫតអំពីឋានតុសិតទៅ ខ្ជិនឡើងទៅកើតក្នុងឋានខាងលើៗ ហើយបានសម្រេចព្រះអរហត្តផលចូលកាន់ព្រះនិព្វានទៅតែម្តង ឯព្រះសម្មាសម្ពុទ្ធព្រះអង្គមានព្រះហឫទ័យប្រកបដោយមេត្តាករុណាវេនេយ្យធម៌ ទ្រង់លើកយកបរមត្ថព្រះអភិធម្មចំនួនម៉ឺនពីរពាន់ព្រះធម្មក្ខន្ធ មកសំដែងតបស្នងសងគុណសម្តេចព្រះអនន្តគុណជាព្រះពុទ្ធមាតា ដែលបានយាងយកព្រះពុទ្ធមាតាបានទៅសោយអត្ថរសនៃបរមត្ថព្រះអភិធម្មស្ថិតនៅក្នុងសោតាបត្តិផល បានឈ្មោះថាព្រះអង្គបានសងគុណសម្តេចព្រះអនន្តគុណ ជាព្រះពុទ្ធមាតាបង្កើតព្រះអង្គរួចជាជ្រះស្រឡះដោយពិត ហើយព្រះអង្គទ្រង់យាងចុះមកកាន់ឋានមនុស្សលោកវិញ ក្នុងថ្ងៃមហាបវារណានោះឯង ។

๑๗ - ធម្មវិទូ បានស្តាប់ប្រស្នានេះហើយក៏មានសេចក្តីពេញចិត្តក្រៃលែងទើប សួរប្រស្នាជាច្រើនទៀតថា ព្រះជាម្ចាស់ព្រះភាគជាម្ចាស់ទ្រង់ត្រាស់សំដែងបរមត្ថព្រះអភិធម្ម ក្នុងសប្តាហ៍ទី៧ នៅស្ថានសួគ៌តាវត្តឹង្សពិភពក្នុងខែប្រជុំនៃខែតាំងឆ្នាំនោះ, តើមានមនុស្សតាំងឆ្នាំក្នុងឆ្នាំដូចម្តេច ? បានឡើងទៅប្រជុំស្តាប់នៅទីនោះដែរឬដូចម្តេច ?

๑๗ - อัฏฐกถาวินัยวินิจฉัยกถา กล่าวว่า ก็ในคราวที่พระเจ้าอชาตศัตรูเสด็จไปสู่สำนักพระผู้มีพระภาคเจ้าเพื่อทรงสดับพระธรรมเทศนานั้น ได้ทรงสดับพระสามัญญผลสูตรแล้ว ทรงเลื่อมใสในพระรัตนตรัย ได้ทรงถวายบังคมพระผู้มีพระภาคเจ้าแล้วเสด็จกลับ ในวันรุ่งขึ้นได้ทรงนิมนต์พระผู้มีพระภาคเจ้าเสวยภัตตาหารในราชนิเวศน์ ครั้นเสวยภัตตาหารเสร็จแล้ว ได้ทรงถวายผ้าสาฎกคู่หนึ่งแด่พระผู้มีพระภาคเจ้า ทรงถวายผ้าสาฎกคู่หนึ่งแด่พระอัครมเหสี ทรงถวายผ้าสาฎกคู่หนึ่งแด่พระนางวาสุลทัตตาเทวี ทรงถวายผ้าสาฎกคู่หนึ่งแด่พระนางสามาวดี ทรงถวายผ้าสาฎกคู่หนึ่งแด่พระนางอุทุมพริกาเทวี ทรงถวายผ้าสาฎกคู่หนึ่งแด่พระนางวิเทหิกาเทวี ทรงถวายผ้าสาฎกคู่หนึ่งแด่พระนางกุลาวกเทวี ทรงถวายผ้าสาฎกคู่หนึ่งแด่พระนางปทุมวดี ทรงถวายผ้าสาฎกคู่หนึ่งแด่พระนางสุปปวาสาเทวี ทรงถวายผ้าสาฎกคู่หนึ่งแด่พระนางสุปปิยาเทวี ทรงถวายผ้าสาฎกคู่หนึ่งแด่พระนางอัมพปาลีเทวี ทรงถวายผ้าสาฎกคู่หนึ่งแด่พระนางมัลลิก

ឯហានមុនុស្សក្នុងកាលជាខាងក្រោយទៀតក៏ទេ ឬថាព្រះអង្គទ្រង់សំដែងព្រះអភិធម្មក្នុងហានមនុស្សពីកាលមុនបូមកហើយក៏ទេ តែជាព្រះសម្មាសម្ពុទ្ធទ្រង់សំដែងព្រះអភិធម្ម ក្នុងវិស្សានវដ្តជាមួយគ្នាមិនមុនមិនក្រោយ តែទ្រង់សំដែងព្រះអភិធម្មក្នុងហានសួគ៌ផង ក្នុងហានមនុស្សផង ក្នុងវដ្តវែតមួយ កាលតែមួយស្មើគ្នា ក្នុងសម័យដែលព្រះអង្គបានត្រាស់ដឹងព្រះអនុត្តរសម្មាជិញ្ញាណប្រាកដខ្លឹនក្នុងលោកហើយ តែក្នុងវិស្សាជាគំរប់ ៧នោះឯង ឯមនុស្សដ៏ខ្ពង់ខ្ពស់ដែលបានស្តាប់ព្រះអភិធម្មក្នុងចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគចប់ហើយ នាំមកបង្ហាត់បង្ហាញសិស្សានុសិស្សបានរឿនបេះចាំស្ទាត់ហ៊ើយ បង្ហាត់បង្ហាញគ្នាតៗមក ដល់កាលសព្វថ្ងៃនេះដោយពិត ។

១៩ - ធម្មវិទី សួរថា អើ អត្ថវាទី បើព្រះសម្មាសម្ពុទ្ធទ្រង់សំដែងព្រះអភិធម្ម ក្នុងវិស្សានវដ្តជាមួយគ្នាមិនមុនមិនក្រោយ ឯហានសួគ៌ផង ហានមនុស្សផង ក្នុងសម័យដែលព្រះអង្គបានត្រាស់ដឹងព្រះអនុត្តរសម្មាជិញ្ញាណប្រាកដខ្លឹនក្នុងលោកតាវិស្សាជាគំរប់ ៧នោះ តើព្រះអង្គទ្រង់រំលែកចែកពេលសំដែងព្រះអភិធម្មនោះដូចម្តេច? ប្រារព្ធចំពោះបុគ្គលណា? ទ្រង់ស្នើឲ្យលះហេតុដូចម្តេចខ្លះ?

អត្ថវិទី វិសជ្ជនាថា ក្នុងសម័យដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែង
ចរមគ្គព្រះអភិធម្មប្បការព្ធចំពោះព្រះសិរីមហាមាយាទេវបុត្រ ជាព្រះពុទ្ធ-
មាតានោះ ព្រះអង្គទ្រង់ពិចារណាវេលាមើលវេលា ឃើញបានជ្រាបច្បាស់ថា
អរុណជិតរះហើយ ក៏ព្រះអង្គទ្រង់និម្មិតជាពុទ្ធនិម្មិត ឲ្យសំដែងព្រះអភិធម្ម
ជំនួសព្រះអង្គ ហើយទ្រង់យាងចុះមកកាន់ជម្ពូទ្វីប យកអរុណ សោយ
ឈើស្នូន លុបព្រះភ័ក្ត្រ ខៀបមាត់ស្រែអនោតត្ត រួចស្រេចហើយទើប
ព្រះអង្គទ្រង់យាងទៅដល់ច្រកក្នុងកន្លែងក្បែរទ្វីប លុះបានចង្ហាន់ល្មមហើយ
ក៏ទ្រង់ត្រឡប់មកគង់លើបុប្ផាសនៈ នាប្រទេសហិមពាន្ត រំលោះនោះព្រះ
សារីបុត្តត្មេរជាមាន់អាយុ បានចូលទៅផ្ទៀងត្បាដបត្តិបំរើព្រះអង្គដោយគោ-
រពក្នុងវេលាសោយចង្ហាន់ ឯព្រះសម្មាសម្ពុទ្ធលុះទ្រង់ធ្វើកត្តកិច្ចសោយ
ចង្ហាន់ស្រេច ហើយ ក៏ព្រះអង្គទ្រង់សំដែងចរមគ្គព្រះអភិធម្មប្បការព្ធចំពោះ
ព្រះសារីបុត្តត្មេរថា ម្នាលសារីបុត្រ រំលោះថ្ងៃនេះយប់ម្សិលមិញ ព្រះ
តថាគតបានសំដែងចរមគ្គព្រះអភិធម្មចំនួនប៉ុណ្ណោះ ពុទ្ធនិម្មិតសំដែងជំនួស
តថាគតចំនួនប៉ុណ្ណោះ ត្រូវអ្នករៀនយកចុះ បើអ្នកបានរៀនយកហើយ
ដល់ត្រឡប់មកវិញ ចូរអ្នកបង្ហាត់បង្ហាញកុំកុំតាំង ៥០០ រូប ដែល
ជាសទ្ធិវិហារិករបស់អ្នកជានិរន្តរកាលទៅ ។ ព្រះសម្មាសម្ពុទ្ធទ្រង់

សំដែងធម្មទេសនា ព្រះអភិធម្មច្រាប់ព្រះសារីបុត្តត្ថេរសព្វគ្រប់ហើយ ក៏ព្រះអង្គទ្រង់យាងទៅគង់ឋានៈតាវត្តឹង្សាតិភពវិញ ហើយព្រះអង្គទ្រង់សំដែងព្រះអភិធម្មតអំពីពុទ្ធនិមិត្តទៅទៀត, ចំណែកខាងព្រះមហាសារីបុត្តត្ថេរ ក៏ត្រឡប់ទៅគាន់វិហារឯនរសង្កស្សវិញ ហើយសំដែងព្រះអភិធម្មបង្រៀនកិកូតាំង ៥០០ រូប ឲ្យរៀនព្រះអភិធម្មតែកល់ ៦ ថ្ងៃទៅ លុះដល់ព្រះអរហំសម្មាសម្ពុទ្ធទ្រង់សំដែងចប់ធម្មទេសនាព្រះអភិធម្មឯឋានៈតាវត្តឹង្សាតិភពចប់ហើយ កិកូតាំ ៥០០ រូប ក៏បានរៀនព្រះអភិធម្មចប់តែរហើយបានទ្រទ្រង់នូវព្រះអភិធម្មតាំងប្រាំពីរគម្ពីរ ព្រមទាំងបាលីនិងអដ្ឋកថាមុនជាងកិកូតាំងឡាយ ហើយបានបង្ហាត់បង្ហាញដល់សិស្សានុសិស្សជាបត ៦ គ្នាមកដល់កាលសព្វថ្ងៃនេះ ។ ឯព្រះសម្មាសម្ពុទ្ធទ្រង់ឈ្វេងយល់ច្បាស់នូវកិកូតាំង ៥០០ រូបនេះហើយ បានជាព្រះអង្គទ្រង់ទ្រលំទ្វាយសំដែងព្រះអភិធម្មច្រាប់ដល់ព្រះសារីបុត្តត្ថេរ ឲ្យរៀនយកទៅបង្ហាត់បង្ហាញដល់កិកូតាំង ៥០០ រូប នោះឯង ។

๒๐ - ធម្មវិធី ពោលថា សាធុ ។ អត្ថាវណ្ណនាប្រស្នានេះប្រៀបណាស់ហើយ តែយើងនៅមានសង្ស័យតទៅទៀត គ្រាន់តែក្យាងបុដ្ឋដែលលោចវិសជ្ជនាថា ព្រះសម្មាសម្ពុទ្ធទ្រង់ឈ្វេងយល់ច្បាស់នូវកិកូតាំង

៥០០ រូបនោះ ចានជាព្រះអង្គទ្រង់ទូលទ្វាយសំដែងព្រះអភិធម្មប្រាប់ព្រះសារីបុត្តត្ថេរ ឲ្យរៀនយកនាំទៅបង្ហាត់បង្ហាញកុំកុមារ ៥០០ រូបនោះ ប៉ុន្តែលុបព្វជាតិមុន កុំកុមារទាំងនោះចានបំពេញទសបារមីយ៉ាងណាមក? កើតជាជាតិអ្វី ចានធ្វើបុណ្យអ្វី ដែលជាបុណ្យអស្ចារ្យហេតុមានកំឡាំង គួរឲ្យចានទ្រង់ទូលបរមត្ថព្រះអភិធម្មចប់មុនជាងបុគ្គលទាំងអស់ក្នុងព្រះពុទ្ធសាសនានេះ?

អត្ថវិទី វិសជ្ជនាថា ក្នុងកាលសាសនាព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកស្សបព្រះអង្គចានត្រាស់ប្រាកដឡើងក្នុងលោកនេះ ឯកុំកុមារទាំង៥០០រូបនោះចានកើតជាសត្វប្រចៀវតូច ។ ហើយចានទៅអាស្រ័យក្នុងញ្រកកំណែមួយមានព្រះថេរៈពីរព្រះអង្គលោកចានទៅចង្រ្កមស្វាធ្យាយ ព្រះអភិធម្មចៀបញ្រកកំណែនោះ ឯសត្វប្រចៀវទាំងនោះក៏ចានផ្គងស្តាប់តាមយកនិមិត្តក្នុងសំឡេងមកជាអារម្មណ៍សម្រាប់ស្តាប់ព្រះអភិធម្មដោយគោរព តែថាសត្វប្រចៀវទាំងអស់នោះ ឥតចានដឹងអត្ថរសថាធម៌ប៉ុណ្ណោះ ឈ្មោះ ទន្ត តាយតន: ជាតុ ជាដើមក៏ទេដែរ គ្រាន់តែតាន់យកខ្លួនិមិត្តសំឡេងដែលលោកស្វាធ្យាយចំរើនព្រះអភិធម្មមកជាអារម្មណ៍ជាទីត្រេកអរប៉ុណ្ណោះ សត្វប្រចៀវទាំងនោះ កំតន់ចានធម្មសវនានិសង្សយ៉ាងធំៗតួមខ្លួនធំៗស់ លុះ

ឬតអំពីជាតិជាសត្វប្រចៀវនោះទៅ កំបានផ្ទាស់កំណើតពីសត្វតិរច្ឆាន
បានទៅកើតជាកំណើតទេវតាក្នុងឋានតាវត្តឹង្សទេវលោក បានសោយ
នូវសម្បត្តិទិព្វទាំង ១០ ប្រការជាសុទក្សេមសុខ្ខ ឥស់កាលជាអង្វែងមួយ
ពុទ្ធន្តរ តិបន្ទាះព្រះពុទ្ធមួយព្រះអង្គដោយពិត លុះដល់ឬតចុះមកអំពី
ឋានតាវត្តឹង្សពិភពនោះកំបានមកកើតក្នុងត្រកូលទាំង ៥០០ ជាស្តុកសម្ព
ខៀបក្រុងសាវត្ថីមានសេចក្តីជ្រះថ្លាកើតឡើងក្នុងឃមកឬឬជាហាយ៍ ចេស
ព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើងទាំងឡាយនេះ ហើយកំបានលះបង់ទ្រព្យ
សម្បត្តិកូនប្រពន្ធបួលមកសូមផ្នួសបួសក្នុងសំណាក់ព្រះសារីបុត្តត្ថេរជា ព្រះ
ឧបជ្ឈាយ៍លុះអង្គសម្តេចព្រះបរមគ្រូជាម្ចាស់ ទ្រង់ត្រាស់សំដែងព្រះអភិ-
ធម្មនៅឋានតាវត្តឹង្សពិភព ចប់ស្រេចហើយ ភិក្ខុទាំង ៥០០ ប្រុនោះកំបាន
រៀនយកនូវព្រះអភិធម្មទាំងប្រាំពីរគម្ពីរ អំពីសំណាក់ព្រះសារីបុត្តត្ថេរ
ជាព្រះឧបជ្ឈាយ៍ចប់ដែរ ហើយបានទ្រទ្រង់នូវបរមត្តព្រះអភិធម្មទាំងប្រាំ
ពីរគម្ពីរចប់មុនជាងបុគ្គលទាំងអស់ ក្នុងព្រះពុទ្ធសាសនានេះ ដោយផល-
និសង្សដែលបានតាមពស្តាប់ព្រះអភិធម្មកាន់យកនូវនិមិត្តសំឡេង នៃព្រះ
ថេរៈទាំងពីរអង្គដែលសោកកំពុងស្ងាធ្យាយនោះ យកមកជាអារម្មណ៍ជាទី
ត្រេកអរប៉ុណ្ណោះឯង ។

សប្បុរសទាំងឡាយ បើបានជ្រាបច្បាស់នូវផលានិសង្សស្តាប់ធម៌ព្រះអភិធម្មជាអស្ចារ្យយ៉ាងនេះហើយ គួរតែខំព្យាយាមស្តាប់ចម្រើនព្រះអភិធម្មឲ្យញឹកញាយរឿយ ។ ហើយខំរំពឹងគិតពិចារណាមើល ជ្រើសរើសយកសេចក្តីតាមសភាពពិត មិនត្រូវប្រកាន់មាំយកលិទ្ធិត្រូវផ្សេង ។ ដែលមិនសមគួរតាមបាលីនិងអដ្ឋកថា ដីកា និស្ស័យ យោជនា ព្រះអភិធម្មនោះទៀយ ដែលជាហេតុនាំឲ្យខាតប្រយោជន៍ គួរបានផលានិសង្សដ៏ខ្ពង់ខ្ពស់ ត្រឡប់ទៅជាបានផលានិសង្សខ្មៅតិចថោកទាបទៅវិញ ព្រោះតែពុំបានគិតពិចារណាដោយសេចក្តីម៉ដ្ឋចត់ប៉ុណ្ណោះឯង ។

ចប់អភិធម្មត្ថាធិប្បាយនិទានកថាដោយសង្ខេប ។

អភិធម្មត្ថាធិប្បាយបរមត្ថកថា

២១ - ធម្មវិទូ បានស្តាប់ហើយពោលថា ម្នាលអត្តវាទី យើងបានបុច្ឆាវិសជ្ជនាគ្នាអំពីអភិធម្មត្ថាធិប្បាយមកនេះ ក៏យើញថាល្មមសមគួរហើយ យើងនឹងចប់សេចក្តីដោយសង្ខេបតែប៉ុណ្ណោះចុះ ។ តអំពីនេះទៅយើងនឹងបុច្ឆា វិសជ្ជនាគ្នាអំពីអភិធម្មត្ថាធិប្បាយបរមត្ថកថាតទៅទៀត តើអត្តវាទី សម្តេចព្រះមុនីនាថជាម្ចាស់ទ្រង់ត្រាស់សំដែងរួបរួមកងធម៌ជាសុទ្ធមកាតជាំល្អិតជ្រាលជ្រៅហួតចង់ កំណត់ឲ្យឈ្មោះថាតម្ពីដេម្មសង្គណី

នោះតើព្រះអង្គទ្រង់កំណត់អក្សរប៉ុន្មានហៅថាមួយបាទ? ប៉ុន្មានបាទហៅ
ថាមួយតណ្ហៈ? ប៉ុន្មានតណ្ហៈហៅថាមួយការណាវៈ? ម្យ៉ាងទៀត ព្រះអង្គ
ទ្រង់សំដែងគម្ពីរធម្មសង្គណីកំណត់ចរិច្ចទ បទមាតិកា, បទការជនីយ,
ធម្មកន្ធនោះតើត្រូវកំណត់ពាក្យឲ្យបានជាំងច្បាស់លាស់ដូចម្តេចខ្លះ? សូម
លោកវិសជ្ជនាឲ្យសព្វគ្រប់ ដើម្បីនឹងបានស្តាប់ចូលចិត្តផងមើល?

អត្ថវិទី ពោលថា បពិត្រធម្មាចរិយ កាលអង្គព្រះកតវន្តមុនីជាម្ចាស់
ទ្រង់ត្រាស់សំដែងគម្ពីរធម្មសង្គណី រួបរួមធម៌ ដ៏ល្អិតម៉ដ្ត្រាលជ្រៅនោះ
ទ្រង់កំណត់ ៨អក្សរៈ ហៅថាមួយបាទ ៤ បាទ ហៅថាមួយតណ្ហៈ ២៥០
តណ្ហៈ ហៅថាមួយការណាវៈ (៨ ពាន់អក្សរៈ) ហើយព្រះអង្គទ្រង់សំដែង
កំណត់ជាចរិច្ចទ ១៥ មានកុសលចរិច្ចទជាដើម មានវិជ្ជាភាគចរិច្ចទ
ជាទីបំផុតខាងចុង ជាមាតិកាមាន ៣ គឺ ១ តិកមាតិកា ២ មានកុសល-
ត្តិកមាតិកាជាដើម មានឥទ្ធិសម្បទត្តិកមាតិកាជាទីបំផុតខាងចុង ។ ២-
ទុកមាតិកា ១០០ មានហេតុទុកមាតិកាជាដើម មានបដិច្ចទុកមាតិកាជាទី-
បំផុតខាងចុង ។ ៣ - សុត្តន្តិកមាតិកា ៤២ មានវិជ្ជាភាគទុកមាតិកា
ជាដើម មានទេសញ្ញាណទុកមាតិកាជាទីបំផុតខាងចុង ។ ឯតិកមាតិកា
ទាំង ២ នោះត្រូវឲ្យកំណត់ពាក្យធម្មកន្ធតាមរបៀបបទមាតិកា ដូចយ៉ាង

អកុសលត្តិកមាតិកាខាងដើមមានបីបទមាតិកា គឺ កុសលា ធម្មា ធម៌ទាំង-
ឡាយជាកុសល ឆ្នាះថាបទមាតិកា ១ ក៏ថាធម្មក្ខន្ធ ១ អកុសលា
ធម្មា ធម៌ទាំងឡាយជាអកុសល ឆ្នាះថាបទមាតិកា ១ ក៏ថា
ធម្មក្ខន្ធ ១ អព្យាកតា ធម្មា ធម៌ទាំងឡាយជាអព្យាក្រឹត ឆ្នាះថា
បទមាតិកា ១ ក៏ថាធម្មក្ខន្ធ ១ ។ គំរូឯតិកមាតិកាមួយៗមានបទ បទ
មាតិកាបី ។ មានធម្មក្ខន្ធបី ។ ដែរ ៤៤ តិកមាតិកាត្រូវជា ៦៦ ធម្មក្ខន្ធតត់
ហើយត្រូវរៀបតាមវារៈនៃចិត្តនិងចេតសិកធម៌ តាមបទ បទកាជន័យ
ដែលសំដែងញែកចែកចេញអំពីបទ បទមាតិកា ដូចឆ្នាំងបទថា កុសលា
ធម្មា ចិត្តនិងចេតសិកទាំងឡាយជាកុសលជាដើម ត្រូវរៀបតាមវារៈនៃចិត្ត
និងចេតសិកមួយ ។ ថាជាធម្មក្ខន្ធមួយ ។ ជាលំដាប់ទៅ វារៈនៃចិត្តនិង
ចេតសិកមានចំនួនប៉ុន្មាន ធម្មក្ខន្ធក៏មានចំនួនប៉ុណ្ណោះដែរ ឯទុកមាតិកា
ទាំង ១១០ នោះក្តី សុត្តន្តិកទុកមាតិកាទាំង ៤២ នោះក្តី ត្រូវរៀបតាមទុក-
មាតិកា គំរូឯបទទុកមាតិកាមួយ ។ មានធម្មក្ខន្ធពីរ ។ ដូចបទថា ហេតូ
ធម្មា ធម៌ទាំងឡាយជាហេតុ ន ហេតូ ធម្មា ធម៌ទាំងឡាយមិនមែនជា
ហេតុជាដើម សឹងមានធម្មក្ខន្ធពីរ ។ ដូចគ្នាទាំងអស់ ។

កុលបុត្រអ្នកសិក្សាបរមត្ថព្រះអភិធម្មកថិកម្ចាស់ធម្មសង្គណី ត្រូវកំណត់

អក្ខរៈ គណ្ហ : កាលាវរៈ មាតិកា ជាដើម ដូចបានអធិប្បាយដោយសង្ខេបមកនេះ ទើបគាចនឹងកាន់យកអត្ថរសចំពោះបរមត្ថត្រៃអភិធម្មតាមសភាពពិតទៅបានដោយងាយ ។

๒๒- ធម្មវិទី បានស្តាប់ហើយពោលថា សាធុ ។ ម្នាលអត្ថវិទី ប្រស្នាដែលលោកវិសជ្ជនាមកនេះត្រឹមត្រូវពិតហើយ តែយើងនឹងសួរប្រស្នាជាច្រើនទៀត ម្នាលអត្ថវិទី ក៏ក្នុងកុសលត្តិកមាតិកា ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា ជាបទមាតិកា សេចក្តីថា កុសលធម៌ទាំងឡាយ អកុសលធម៌ទាំងឡាយ អព្យាកតធម៌ទាំងឡាយ លុះដល់ព្រះអង្គទ្រង់សំដែងជាបទបទភាជនីយ ចំណែកចែកបរមត្ថធម៌ដោយសេចក្តីពិស្តារ ពន្យល់ដល់វេនេយ្យសត្វទាំងឡាយ ព្រះអង្គទ្រង់ត្រឡប់យកអកុសលធម៌ទាំងឡាយមកសំដែងជាមុន ឬទុសអំពីបទមាតិកានោះទៅ មិនយកកុសលធម៌ទាំងឡាយមកសំដែងជាមុនវិញឬត្រូវត្រង់តាមបទមាតិកានោះ តើព្រះអង្គទ្រង់ល្មើងយល់ហេតុផលដូចម្តេចខ្លះ ? ។

អត្ថវិទី វិសជ្ជនាថា បពិត្រធម្មវិទី ព្រះអរហំសម្មាសម្ពុទ្ធព្រះអង្គជាបុគ្គលឆ្លៀវឆ្លាសវាងវៃក្នុងពីរសំដែងធម៌ទេសនា ឧបមាដូចបុគ្គលណា

មួយជាតិមកប្រៀបផ្ទឹមនឹងព្រះអង្គពុំបានឡើយ ព្រោះព្រះអង្គជាអង្គ
សព្វញ្ញូទ្រង់ត្រាស់ដឹងសព្វឥតមានបន្ទោះ កាលដែលព្រះអង្គទ្រង់សំដែង
ធម៌ទេសនានោះ ទ្រង់ពិចារណាមើលឧបនិស្ស័យសត្វលោកទាំងឡាយ
ដោយសព្វគ្រប់ជាមុន បើព្រះអង្គបានពិចារណាឃើញសត្វទាំងឡាយ
ពួកខ្លះដែលមានឧបនិស្ស័យត្រាស់ដឹងមួន មានឥន្ទ្រិយចាស់ពុំពេញ
បរិបូណ៌ ស្គាល់ខុសត្រូវ គុណាទោស ល្អអាក្រក់ បុណ្យបាប មានមុខ
ឈមទៅកាន់ផ្លូវត្រូវនឹងតព្រះអង្គដូចគ្នាដែលប្រកបដោយអង្គទាំង ៨ មាន
សម្មាទិដ្ឋិ ឃើញឃើញត្រូវជាដើមហើយ ក៏ព្រះអង្គលើកយកកុសលធម៌
ទាំងឡាយមកសំដែងប្រាប់ពន្យល់ដល់សត្វទាំងឡាយពួកនោះ ឯ
ព្រះអង្គបានសម្រេចមគ្គផលត្រូវតាមបទមាតិកានោះទៅក៏មានខ្លះដែរ តែថាសត្វ
ទាំងឡាយដែលមានឧបនិស្ស័យត្រាស់ដឹងមួន មានឥន្ទ្រិយចាស់ពុំពេញ
បរិបូណ៌នោះតិចពន់ពេនណាស់ ឯសត្វទាំងឡាយដែលត្រាស់ទៅដោយ
កងកិលេសទាំងឡាយមានពត: ទោស: ជាដើម ដេកផ្ដាច់នៅក្នុងសង្សារ-
ចក្រ លុះទៅតាមអំណាចនៃតណ្ហាជឹកនាំត្រមុជចុះក្នុងសង្សារវដ្ដ ច្រាស
ចាកសទ្ធា សតិ ឋញ្ញា មិនដឿកម្មផល មិនមានសតិក្លាត់ព្រឹកនឹករក
កុសលផលបុណ្យសោះ អាចវឥតបញ្ញាវង្វិលកាន់ច្រឡំ សំគាស់ខុស

ជាត្រូវ គុណជាទោស បុណ្យជាអាប ល្អជាអាក្រក់ជាដើម ហើយ
ប្រព្រឹត្តធ្វើនូវអំពើបាបទាំងនោះគោមទំនើងចិត្តខ្លួន ឥតមានកោតញ្ញាញ្ញឹត
ឡើយ រីសត្វទាំងឡាយដែលប្រព្រឹត្តបែបនេះ មានច្រើនជាអនេកត្រា
ភប់ពុំអស់ឡើយ ។ ហេតុហ្នឹងហើយបានជាព្រះសម្មាសម្ពុទ្ធទ្រង់ធ្វើវ
ធ្វាសភាវៈក្នុងវិធីសំដែងធម៌ទេសនា ព្រះអង្គទ្រង់លើកយកអកុសល-
ធម៌ទាំងឡាយមកសំដែងប្រាប់ពន្យល់ដល់វេនេយ្យសត្វទាំងឡាយ ដែល
ប្រព្រឹត្តធ្វើនូវអំពើបាបដ៏លាមកនោះ ដោយគំនិតគិតខុសប្រាសចាក
សទ្ធា សតិ បញ្ញា ជាមិច្ចាទិដ្ឋិ ឃើញខុសកាន់ផ្លូវឆ្ងៃប្រកបដោយ
សេចក្តីអន្ធពាយផ្សេង ។ មានសោយខុក្ខកន្ធនរកជាដើម រកទីបំផុតជាតិ
គ្មាន ឲ្យវេនេយ្យសត្វទាំងនោះបានក្បាក់ជីនខ្លួន តក់ស្លុតគិតភ័យខ្លាចនឹងអំពើ
ដែលខ្លួនធ្វើខុសនោះ ឲ្យដឹកចែរមុខឈមមកកាន់សម្មាទិដ្ឋិ ឃើញ
ឃើញត្រូវជាផ្លូវត្រង់វិញ ដោយមេត្តាករុណាគុណរបស់ព្រះអង្គពិត ។
មានសេចក្តីឧបមាដូចបណ្ឌិតជាតបុរស ប្រកបដោយប្រាជ្ញាធ្វើវិធ្វាសភាវ
វៈក្នុងវិធីបង្ហាញផ្លូវ ដែលប្រកបដោយសេចក្តីមេត្តាករុណាដល់មនុស្ស
អ្នកដំណើរដើរវង្វេងផ្លូវ មិនដឹងទិស ប្រាកដត្រង់ណាសោះ បណ្ឌិតបុរស
នោះក៏អធិប្បាយ ពន្យល់បង្ហើល ប្រាប់ផ្លូវដែលរៀបរាប់ធ្វាយប្រកបដោយ

សេចក្តីអន្តរាយផ្សេង ។ ដែលជាហេតុនាំដំណើរឲ្យយឺតយូរលំបាកកំ
ណត់មិនបាន ឲ្យឆាកបែរមុខឈមមកកាន់ផ្លូវត្រង់ ដែលជាហេតុនាំ
ដំណើរឲ្យបានដើរដល់ទាប់ហើស មានឧបមាយ៉ាងណាមិញព្រះបរម
គ្រូជាម្ចាស់ ទ្រង់លើកយកអកុសលធម៌ទាំងឡាយដែលជាផ្លូវរឿបរាំង
ធ្វើយ មកសំដែងអធិប្បាយប្រាប់ឥឡូវនេះឲ្យសត្វទាំងឡាយ
ឲ្យបានដឹងច្បាស់ភ្ញាក់ខ្លួន តក់ស្លុតតក់ស័យនឹងផ្លូវរឿបរាំងធ្វើយប្រកប
ដោយសេចក្តីអន្តរាយផ្សេង ។ នោះ ឲ្យឆាកបែរមុខឈមមកកាន់ផ្លូវដែល
ប្រកបដោយអង្គទាំង ៨ មានសម្មាទិដ្ឋិជាដើម ប្រតិបត្តិ
ត្រូវតាមគន្លងផ្លូវត្រង់ជារបស់ព្រះអរិយបុគ្គលវិញ មានឧបមេយ្យដូច
បណ្តាតបុរសមានប្រាជ្ញាឈ្លាសវាងវៃ អ្នកបង្ហាញផ្លូវដូច្នេះឯង ។

២ញ - ធម្មវិទូ បានស្តាប់ហើយពោលថា ម្នាលអត្តវាទី ប្រស្នា
នេះ ពិរោះពិតណាស់ហើយ តែថាយើងនឹងសួរលោកតទៅទៀត
បុះពាក្យថាធម៌ ។ នោះមានប៉ុន្មាន? ធម្មស័ព្ទនោះតើសេចក្តីអធិប្បាយ
ដូចម្តេច?

អត្ថវាទី ស្រែជ្ញនាថា បពិត្រធម្មវាទី ឯពាក្យថាធម៌ ។ នោះតាមន័យ
ព្រះអភិធម្មសំដែងថាមាន ១០ គឺ សោតាបត្តិមគ្គ ១ សោតាបត្តិផល ១

សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១ ព្រះនិព្វាន ១ ថែមព្រះបរិយត្តិ ១ ទៀត ជាតំរប់ ១០ បានឈ្មោះថាធម៌ដោយពិត ម្យ៉ាងទៀត ធម្មស័ព្ទនេះ តាមន័យតដ្ឋកថាព្រមទាំងដីកាព្រះអភិធម្មវិភាវិនី ទ្រទ្រង់ ថាស្តុយខ្លីដែរ ។ អធិប្បាយថា សភាវៈចាំកឯណា ទ្រទ្រង់ទុកនូវសត្វទាំងឡាយឯណា ដែលទ្រទ្រង់ខ្លួនទុក សត្វទាំងឡាយនោះ មិនឲ្យធ្លាក់លិចចុះទៅក្នុងអបាយទាំងឡាយ ៤ ផង ក្នុងវដ្តទុក្ខទាំងឡាយផង សភាវៈចាំកនោះបានឈ្មោះដោយធម៌ពិត គឺថាបុគ្គលឯណាបានទ្រទ្រង់ធម៌ល្អ រក្សាធម៌ឲ្យល្អហើយ ទាំកធម៌ដែលល្អនោះឯងវិមានទ្រទ្រង់រក្សាបុគ្គលនោះឲ្យល្អវិញ មិនឲ្យធ្លាក់ចុះទៅក្នុងអបាយភូមិទាំង ៤ នោះទេឬយ បុគ្គលឯណាបានទ្រទ្រង់នូវធម៌ដ៏ខ្ពង់ខ្ពស់វិសេសបំផុតក្នុងសន្តានខ្លួនល្អហើយ ធម៌ដែលខ្ពង់ខ្ពស់នោះនឹង ទ្រទ្រង់រក្សាបុគ្គលនោះឲ្យស្ថិតនៅក្នុងហាន ដ៏ខ្ពង់ខ្ពស់វិសេសបំផុត គឺព្រះនិព្វានជាសុខក្សេមក្សាន្តវិញ ពុំបានឲ្យធ្លាក់ចុះទៅកាន់វដ្តទុក្ខទាំងឡាយនោះទៀតឡើយ ។ ឯសប្បុរសអ្នកសិក្សាព្រះអភិធម្ម ត្រូវរំពឹងមើលតាមសេចក្តីអធិប្បាយជាយ៉ាងសង្ខេបនេះចុះ តង់ទីធ្លាបានជ្រាបច្បាស់នូវអត្ថរសព្រះអភិធម្មដោយពិត ។

២៤- ធម្មវាទី ចានស្តាប់ហើយពោលថា អើអត្តវាទី លោកវិសជ្ជនា ពាក្យតីរមាត់ តែកប់ចំនួនធម៌ ១០ នឹងសេចក្តីអធិប្បាយធម្មស័ព្ទមកនេះ យើងស្តាប់ចានចូលចិត្តខ្លះហើយ តែយើងមានសេចក្តីសង្ស័យខ្លះ តទៅទៀត ត្រង់ពាក្យថាកុសលធម៌ អំពើដែលសត្វចាំងឡាយធ្វើល្អប្រពៃ កើតបុណ្យជាកុសលវិបាកនោះ ចានឈ្មោះថាធម៌ទ្រទ្រង់នូវសត្វចាំងឡាយ មិនឲ្យធ្លាក់ចុះកងអបាយភូមិផង ក្នុងវដ្តទុក្ខផង នោះយើងឥតមានសេចក្តីសង្ស័យសោះឡើយ យើងសង្ស័យតែត្រង់ពាក្យថា អកុសលធម៌ គឺអំពើដែលសត្វចាំងឡាយប្រព្រឹត្តធ្វើតាក្រក់លាមកនោះ ចានឈ្មោះថាធម៌ ទ្រទ្រង់នូវសត្វ ចាំងឡាយមិនឲ្យធ្លាក់ចុះកងអបាយភូមិនឹងកងវដ្តទុក្ខដែរ ពាក្យនេះយើងគិតពុំយល់ ស្តាប់ពុំចាន ស្មានពុំត្រូវ ព្រោះពាក្យនេះជំលួសត្រាលជ្រៅពេក ចូរលោកវិសជ្ជនាដោះស្រាយអធិប្បាយឲ្យមានសេចក្តីពក់ងាយឡើង យើងនឹងស្តាប់ឲ្យចូលចិត្តចានដោយងាយផងមើល ?

អ្នកវាទី វិសជ្ជនាថា បពិត្រធម្មវាទី ត្រង់ពាក្យថាកុសលធម៌និងអកុសលធម៌នោះគួរសង្ស័យពិតមែន ព្រោះព្រះសម្មាសម្ពុទ្ធព្រះអង្គសំដែងថា កុសលា ធម្មា អកុសលា ធម្មា ឃើញសេចក្តីថា កុសលកម្ម

ចាំដណ្ដាយកំចាត់ឈ្មោះថាធម៌ដែរ អកុសលកម្មចាំដណ្ដាយកំចាត់ឈ្មោះ
ថាធម៌ដែរ តែអត្ថរសរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់មិនមែនដូច្នោះទេ
តាមសេចក្ដីពិតថា សម្ដេចព្រះលោកនាថជាម្ចាស់ ព្រះអង្គជាមគ្គនាយក
ទ្រង់ដឹកនាំបង្ហាញផ្លូវសត្វលោក ជាមគ្គវិទូ ព្រះអង្គទ្រង់ជ្រាបច្បាស់នូវផ្លូវ
ល្អនិងផ្លូវគាក្រក់ពិតប្រាកដណាស់ ហើយព្រះអង្គទ្រង់សំដែងធម៌ប្រទាន
ប្រៀនប្រដៅដល់សត្វលោកចាំដណ្ដាយ ឲ្យបានដឹងច្បាស់នូវអំពើគាក្រក់
ចាំដណ្ដាយមានប្រព្រឹត្តធ្វើនូវកាយទុច្ចរិតជាដើម ដែលជាផ្លូវគាក្រក់រឿច
វាងឆ្ងាយ ប្រកបដោយសេចក្ដីអន្ដរាយផ្សេងៗ មានសោយទុក្ខវេទនាក្នុង
នរកជាដើម ដើម្បីឲ្យសត្វលោកចាំដណ្ដាយលះបង់ចោលពីសន្ដានខ្លួនឲ្យ
ស្រឡះចេញ បើបានលះបង់ហើយទើបបានឈ្មោះថាសត្វលោកចាំដ-
ណ្ដាយនោះជាបុគ្គលមានធម៌ពិត ជាគ្រឿងទ្រទ្រង់ខ្លួនមិនឲ្យលង់លិចបុះ
ទៅក្នុងអបាយភូមិចាំដណ្ដាយនោះឡើយ បើសត្វលោកចាំដណ្ដាយឯណា
មិនបានដឹងក្ដី បានដឹងហើយក្ដី ហើយពុំបានលះបង់ នៅតែប្រព្រឹត្ត
នូវអំពើគាក្រក់លាមកនោះជាដែល សត្វលោកចាំដណ្ដាយនោះបានឈ្មោះ
ថាជាបុគ្គលឥតធម៌គ្មានវត្ថុជាគ្រឿងទ្រទ្រង់ខ្លួនទុក មុខជានឹងលង់លិច
បុះទៅក្នុងអបាយភូមិចាំដណ្ដាយ ៤ នោះពុំខាន ឯព្រះសម្មាសម្ពុទ្ធព្រះអង្គ

ជាសាស្តាចារ្យ តែងហ៊ឺកហ៊ឺនប្រឹនប្រែជាពួកវេនេយ្យសត្វដែលព្រះអង្គ
គួរនឹងហ៊ឺកហ៊ឺនប្រឹនប្រែជាបាន ឲ្យទំរាំនឹងប្រែងសិក្សារៀនសូត្រឲ្យបាន
ចេះដឹងស្គាល់ច្បាស់នូវអំពើអកុសល ដែលជាអំពើឲ្យផលប្រកបដោយ
សេចក្តីអន្តរាយផ្សេងៗ មានអបាយទុក្ខជាដើម ជាបហានលក្ខណៈ មាន
កិរិយាឲ្យវេនេយ្យសត្វលះបង់ចេញជាលក្ខណៈ បើសត្វលោកបានលះ
បង់តាមពាក្យប្រដៅរបស់ព្រះអង្គហើយ ទើបបានឈ្មោះថាធម៌ដោយ
ពិត បើសត្វលោកពុំបានលះបង់ទេ ធំនឹងត្រឡប់បានឈ្មោះថាអធម៌តឹមនឹង
មែនជាធម៌ទៅវិញដោយពិត ទោះបីអំពើជាកុសលដែលជាអំពើឲ្យផល
ល្អមានឲ្យបានខ្លួនមនុស្សសម្បត្តិជាដើម បើបុគ្គលចាំនឹងប្បាយបានស្តាប់
ពុំខ្ចះខ្ចាយហើយសិក្សារៀនសូត្របានចេះដឹងច្បាស់លាស់ហើយ ទំរាំនឹង
ព្យាយាមធ្វើបុណ្យឲ្យកើតមានចំរើនច្រើនឡើងក្នុងសន្តានខ្លួន ទើបបាន
ឈ្មោះថាជាធម៌ពិតមែន បើពុំទំព្យាយាមធ្វើបុណ្យឲ្យកើតមានចំរើនច្រើន
ឡើងក្នុងសន្តានខ្លួនសោះទេ ក៏បានឈ្មោះថាអធម៌តឹងជាបុគ្គលវិតធម៌វិញ
ដដែលដោយពិត ព្រោះអត្ថសេក្ខកុសលត្តិកមាតិកានេះ ត្រង់ចរថា
កុសលា ធម្មា កុសលធម៌ទាំងឡាយ តឺព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់ចំពោះ
យកការនាលក្ខណៈ ឬការវេតព្ភូលក្ខណៈ កិរិយាដែលចំរើន ឬត្រូវចំរើន

បុណ្យឲ្យកើតមានប្រែនឡើងក្នុងសន្តានខ្លួនជាលក្ខណៈ ទើបព្រះសម្ពុ-
សម្ពុទ្ធព្រះអង្គឲ្យឈ្មោះថា ធម៌ជាគ្រឿងទ្រទ្រង់សត្វដោយពិតប៉ែមិនចំរើន
ឬថា មិនត្រូវចំរើនបុណ្យឲ្យកើតមានប្រែនឡើងក្នុងសន្តានខ្លួនជាលក្ខណៈ
សោះទេ ក៏ពុំបានឈ្មោះថាធម៌ជាគ្រឿងទ្រទ្រង់សត្វឡើយ ត្រង់បទថា
អកុសលា ធម្មា អកុសលធម៌ទាំងឡាយ គឺព្រះអង្គចំពោះយកបហាន-
លក្ខណៈ ឬបហាតព្វលក្ខណៈ តើរំយោដែលលះបង់ឬថាត្រូវតែលះបង់ខ្លួ
អំពើបាបមិនឲ្យកើតមានឡើងក្នុងសន្តានខ្លួនជាលក្ខណៈ ទើបព្រះអង្គ
ឲ្យឈ្មោះថា ធម៌ជាគ្រឿងទ្រទ្រង់សត្វដូចគ្នា ប៉ែមិនបានលះបង់ឬថាមិន
ត្រូវលះបង់ខ្លួអំពើបាបនោះជាលក្ខណៈសោះទេ ក៏ពុំបានឈ្មោះថាធម៌
ឡើយ ត្រឡប់បានឈ្មោះថា អធម៌គឺមិនមែនជាធម៌ឬជាបុគ្គលឥតធម៌ទៅ
វិញដោយពិត ត្រង់បទថា អព្យាកតា ធម្មា អព្យាកតធម៌ទាំងឡាយគឺព្រះ
អង្គចំពោះយកធម្មជាតដែលស្ងាត់ស្ងៀរជាកណ្តាល មិនមែនជាកុសល
មិនមែនជាអកុសល បណ្តាយទៅតែតាមកំឡាំងកុសលនឹងអកុសល
ឬកុសលមានកំឡាំងខ្លាំងជាង ក៏ប្រព្រឹត្តតាមកុសលទៅ ប៉ែអកុសល
មានកំឡាំងខ្លាំងជាង ក៏ប្រព្រឹត្តទៅតាមអកុសលទៅ ទើបព្រះសម្ពាសម្ពុទ្ធ
ព្រះអង្គឲ្យឈ្មោះថា អព្យាកតធម៌ដោយពិត បពិត្រធម្មាចរី ខ្ញុំអត្តាចរី

ចានវិសជ្ជនាតាមសភាពពិតមកដោយសង្ខេបតែប៉ុណ្ណេះឯង ។

២៥ - ធម្មរាជ៍ ចានស្តាប់ហើយពោលថា សាធុ ។ ម្នាលអត្តវាទី ប្រស្នាដែលលោកវិសជ្ជនាមកនេះពីកេះណាស់ហើយ យើញថាត្រឹមត្រូវតាមធម្មសន្ធានអត្ថរសនៃបរមត្ថព្រះអភិធម្មពិតមែនហើយ តែយើនឹងសួរប្រស្នាដទៃតទៅទៀត ម្នាលអត្តវាទី បុគ្គលជាតវ្ថីប្តវត្តុអ្វីដែលជាដើមហេតុជាមេបណ្តាលឲ្យកើតខ្សែនៃបុរាំកុសលកម្ម អកុសលកម្ម នឹងអព្យាកតកម្ម ក្នុងសន្តានសត្វលោកទាំងឡាយនេះ ឬរលោកវិសជ្ជនាមកយើនឹងបានស្តាប់ឬលចិត្តផងមើល ?

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី កុសលកម្មក្តី អកុសលកម្មក្តី អព្យាកតកម្មក្តី ដែលនឹងកើតខ្សែនៃក្នុងសន្តានសត្តនិកាយទាំងឡាយក្នុងលោកសន្និវាសនេះ មិនមែនកើតខ្សែនៃមកអំពីធម្មជាតវ្ថីប្តវត្តុអ្វីដទៃឡើយ គឺកើតមកតែអំពីចិត្តឬព្យ គឺធម្មសម្ភូតរូបសង្ខារធម្មប្រជុំត្រួតគ្នាកើតខ្សែនៃជាមួយនឹងចិត្តជាប្រធាន ដែលប្រកបដោយលក្ខណៈ ៤ យ៉ាងគឺ សភាវៈប្រជុំត្រួតគ្នានឹងចិត្តកើតខ្សែនៃជាមួយគ្នា រលត់ទៅជាមួយគ្នា ទទួលតារម្មណ៍ជាមួយគ្នា តាស្រ័យវត្ថុបជាមួយគ្នា រៀវលែងចាកគ្នា កើតខ្សែនៃពុំបានឡើយ ចិត្តឬព្យរបស់សត្វទាំងឡាយហ្នឹងហើយ ដែលជាសភាវៈបណ្តាលឲ្យកើត

ខ្សែនខ្លួនកុសលកម្មផង អកុសលកម្មផង អព្យាកតកម្មផង ក្នុងសន្តានរបស់
សត្តនិកាយទាំងឡាយក្នុងលោកសន្ធាវសនេះដោយចំណែកមួយមែនពិត។

២៦-ធម្មរាជី ពោលថា ម្នាលអត្តវាទី ប្រសិនដែលលោកវិសជ្ជនា
មកនេះត្រឹមត្រូវពិតហើយ តែយើងនៅមានសង្ស័យតទៅទៀត ត្រង់
ពាក្យដែលលោកពោលថា ចិត្តុប្បាទគឺធម្មសមូហៈសង្ខារធម៌ប្រជុំព្រមគ្នា
កើតឡើងជាមួយនឹងចិត្តជាប្រធាន ប្រកបដោយលក្ខណៈ ៤ យ៉ាងនោះ
តើលក្ខណៈអ្វីខ្លះ? លក្ខណៈមួយៗមានសេចក្តីអធិប្បាយដូចម្តេច? ប្តូរ
លោកវិសជ្ជនាមកឲ្យសព្វគ្រប់យើងនឹងបានស្តាប់ចូលចិត្តផងមើល?

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ចិត្តុប្បាទដែលប្រកបដោយ
លក្ខណៈ៤ យ៉ាងនោះគឺ ឧប្បាទលក្ខណៈ១ ឋិតិរក្ខនលក្ខណៈ១ ភង្គលក្ខណ-
លក្ខណៈ ១ វត្ថុលក្ខណៈ ១ ។ ឯឧប្បាទលក្ខណៈនោះ គឺសង្ខារធម៌
ប្រជុំព្រមជាមួយនឹងចិត្តដែលជាប្រធាន កើតឡើង ព្រមគ្នាជាលក្ខណៈ ១
រលត់ទៅព្រមគ្នាជាលក្ខណៈ ១ ខន្ធលក្ខារម្មណ៍ព្រមគ្នាជាលក្ខណៈ ១
អាស្រ័យខ្លួវត្ថុរូបជាលក្ខណៈ១, សេចក្តីអធិប្បាយក្នុងបរមត្ថព្រះអភិធម្មថា
សង្ខារធម៌នោះ គឺចេតសិកចាំង ៥២ ប្រជុំព្រមនឹងចិត្តជាអធិបតី ខន្ធលខ្លួ
ការម្មណ៍ ដែលចូលមកតាមវត្ថុរូប ប៉ះទង្គិចនឹងឋសាទរូបហើយ កាន់យកជា

ចំណីអាហារកើតឡើងព្រមគ្នា ដែលនឹងរលត់ទៅវិញក៏រលត់ទៅព្រមគ្នា
មិនមុនមិនក្រោយស្មើៗគ្នា តាមលំដាប់វិថីចិត្តនិងកូមរបស់ខ្លួនផ្សេង ។ ។

ម្យ៉ាងទៀត ក្នុងយោជនានិងជាព្រះអភិធម្មលោកសំដែងពន្យល់ថា
សង្ខារធម៌ អារម្មណ៍ផង វត្ថុផង ប្រជុំផ្សំចូលគ្នា ទើបបាននឹងហៅថាចេត-
សិក ជាគ្រឿងប្រកបក្នុងចិត្ត ឬថាជាពន្លឺរស្មីរបស់ចិត្ត បាននឹងហៅតាម
តិចិត្ត ១ ចេតសិក ១ តែថាចេតសិកនឹងកើតឡើងតាមទំនើងខ្លួនឯងពុំបាន
ល្អះតែចិត្តកើតឡើងមុន ចេតសិកក៏កើតឡើងព្រមជាមួយនឹងចិត្តទើបបាន
មានសេចក្តីឧបមាដូចព្រះរាជា និងពួកសេវាមាត្យទាំងឡាយ ឯពួក
សេវាមាត្យទាំងឡាយ នឹងប្រជុំគ្នាចាត់ចែងការពារការទាំងពួងចេញទៅ
ត្រួតត្រាស្រុកប្រទេសផ្សេងៗតាមទំនើងខ្លួនឯងពុំបានឡើយ ល្អះតែមាន
ព្រះរាជបញ្ជាត្រួតស៊ប់ដាំបម្រាមមកជាមុន ទើបសេវាមាត្យទាំងឡាយចាត់
ចែងការពារការត្រប់ដំពូក រៀបចំដំណើរតាមហែរហមអមស្តេចចេញអំពី
ព្រះបរមរាជវាំងទៅ ត្រួតត្រាស្រុកប្រទេសផ្សេងៗ តាមកំណត់ស្រុក
ប្រទេសជាអារម្មណ៍ ដឹកនាំដំណើរព្រះរាជាចេញទៅ ល្អះដល់ព្រះរាជា
ស្តេចទ្រង់ត្រួតត្រាស្រុកប្រទេសសំរេចតំបន់ត្រប់សព្វហើយ ទើបស្តេច
ទ្រង់យាងត្រឡប់មកព្រមទាំងពួកសេវាមាត្យទាំងឡាយ តាមបាម

ភេមដង្ហែត្រឡប់មកគាន់ព្រះនគរគង់លើបល្ល័ង្ក ក្នុងព្រះបរមរាជវាំងវិញ
មានសេចក្តីឧបមាយ៉ាងណា ឯការដ្ឋចិត្តកើតឡើង ទេតសិកធម៌ទាំងឡាយ
កំកើតឡើងត្រមជាមួយនឹងចិត្តដែរ ទេញ្ញទៅតាមវិញ្ញត្តិដែលជាផ្លូវ
ទៅរបស់ចិត្ត ទុំលួសត្រួតត្រាតិចារណានៅអារម្មណ៍ជាខាងក្រៅ ដែលបួល
មកតាមទ្វារទាំងឡាយមានចក្ខុទ្វារជាដើម ដើម្បីសំរេចកិច្ចផ្សេង ។ មាន
បជាសន្ធិកិច្ចជាដើម ស្រេចហើយទុំលួសយកចំណែកផលបានត្រប់ត្រាន់
តាមចំណែកធំនិងតូច សមគួរតាមការអារម្មណ៍ធំនិងតូចជាលំដាប់
រលត់ហើយទំលាក់ចោលនូវអារម្មណ៍ ការដ្ឋចិត្តត្រមទាំងទេតសិកទាំង
ឡាយ ក៏ត្រឡប់បួលមកគាន់គាយនគរ ស្ថិតនៅលើហទយៈបេះដូង
ដូចជាបល្ល័ង្កក្នុងប្រដុំនៃបរិសាទទាំងឡាយមានចក្ខុបរិសាទជាដើម មាន
សេចក្តីឧបមេយ្យដូចព្រះរាជាធំងសេវិកាមាត្យទាំងឡាយដូច្នោះឯង ។

២៧- ធម្មវិទូ ទុំលួសថាសាធុៗពាក្យណាស់ហើយអត្ថន័យនៃប្រស្នានេះ
តែយើងនឹងសួរលោកតទៅទៀត ចុះចិត្តស័ព្ទនេះ ប្រែបានដូចម្តេចខ្លះ ?
សេចក្តីអធិប្បាយថាដូចម្តេច ? ម្យ៉ាងទៀត ចិត្តនឹងទេតសិកតែមួយ
ហើយមាននាមពីរ សេចក្តីផ្សេងគ្នាយ៉ាងណា ? ឧបមាដូចតែអ្វី ?

អត្ថវិទូ សៃដ្ឋនាតបថា បពិត្រធម្មវិទូ ចិត្តស័ព្ទនេះប្រែថា ធម្មជាត

សម្រាប់តែត សំពាច់ដ៏នូវតារម្មណ៍កំបាន ជាធម្មជាតសម្រាប់ធ្វើជ្រើស
រើសនូវតារម្មណ៍ដ៏វិចិត្រវេចារផ្សេង ។ ដោយខ្លួនឯងកំបាន សេចក្តី
អធិប្បាយថា ចិត្តនេះ ជាធម្មជាតមិនបេះរើសតារម្មណ៍ កំកុងតារម្មណ៍
ទាំង ៦ នោះតាមតែតារម្មណ៍ណាក៏ជាយ ចិត្តតែងត្រូវតារតែត្រូវតារដឹង
ទាំងអស់ បើរូបារម្មណ៍មកតាន់ក្នុងដំក្អែកហើយ ចិត្តក៏តើតឡើងភ្លាមខ្លួល
តែត ខ្លួលដឹងថា នេះរូប បើសព្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍
ផោដ្ឋារម្មណ៍ ធម្មារម្មណ៍ ចូលមកតាន់ក្នុងដំត្រចៀក ច្រមុះ អណ្តាត
កាយ ចិត្ត វិញចិត្តក៏តើតារឡើងភ្លាម ខ្លួលតែត ខ្លួលដឹងថា នេះសំឡេង
នេះក្លិន នេះរស នេះសម្ផស្ស នេះធម៌ ដោយពិត វតមានតាក់ទានឡើយ
ត្រង់ចិត្តស័ព្ទថ្លែថា ធម្មជាតសម្រាប់ធ្វើតិច្ចជ្រើសរើសតារម្មណ៍ដ៏វិចិត្រវេ-
នារផ្សេង ។ ដោយខ្លួនឯងនោះ មានសេចក្តីឧបមាដូចនាយជាដំតូនូវដែល
ធ្វើវិធ្វាសារឯវែតាចធ្វើតិច្ចជ្រើសរើសនូវតារម្មណ៍ផ្សំគ្រឿងប្រដាប់ផ្សេង ។
មានក្រដាស សំពត់ ទៀវដៃ ថ្នាំតំនូវជាដើម ហើយតាំងតូរក្សារក្សាចំរេនា
ដ៏វិចិត្រផ្សេង ។ ជារូបតូច រូបធំ រូបល្អ រូបតាក្រក់ តាមត្រូវតារខ្លួនឯងដោយ
ពិត វតមានទើសខាលឡើយ មានសេចក្តីឧបមាយ៉ាងណា ចំណែកចិត្ត
ដែលមានកងិសន្តានសព្ទសត្វទាំងអស់ ជាធម្មជាតតាចធ្វើតិច្ចជ្រើសរើស

ខ្លួកអារម្មណ៍តាំងឡាយ មានរូបារម្មណ៍ជាដើម ហើយធ្វើចិត្តរបស់
ផ្សេង។ ខ្លួកអារម្មណ៍តាំងនោះ ឲ្យទៅជាអនិដ្ឋារម្មណ៍ជាអារម្មណ៍មិន
គប្បី តែអ្នកប្រាថ្នាតាំងឡាយមិនត្រូវការប្រាថ្នាត្រេកអរឡើយ ហើយ
ខ្លួនត្រូវការប្រាថ្នាត្រេកអរនឹងអនិដ្ឋារម្មណ៍នោះ ឲ្យកើតជាអកុសលផល
ច្រើនគួរធំ តបត្រឹមទៅកំពាន ឲ្យទៅជាឥដ្ឋារម្មណ៍ជាអារម្មណ៍គួរគប្បី
តែអ្នកប្រាថ្នាតាំងឡាយតែងប្រាថ្នា ត្រូវការ ត្រេកអរប្រព្រឹត្តធ្វើឲ្យកើតជា
កុសលផលបុណ្យគួរធំ តបត្រឹមទៅកំពាន មានឧបមេយ្យដូចនាយជាង
តំខ្លួរនោះឯង ។ ត្រង់ដួងចិត្តនឹងចេតសិកតែមួយហើយមាននាមឈ្មោះតាំរនោះ
មានសេចក្តីឧបមាដូចគួរក្តីងគោម បើប្រឆេះតួចឆេះឡើង អណ្តាតភ្លើង
ក៏តូចដែរ ពន្លឺរស្មីរបស់ភ្លើងផ្សាយចេញទៅកាន់ទិសក៏តូចប្លែកដែរ បើ
ប្រឆេះធំឆេះឡើង អណ្តាតភ្លើងក៏ធំ ពន្លឺរស្មីរបស់ភ្លើងផ្សាយចេញ
ទៅកាន់ទិសក៏ធំផ្សាយដែរ មានសេចក្តីឧបមាយ៉ាងណា ឯដួងចិត្តនឹង
ចេតសិកតែងទទួលយកនូវអារម្មណ៍ជាមួយគ្នារបស់អារម្មណ៍តូចតិចចូលមក
ដួងចិត្តកើតឡើង ចេតសិកជាពន្លឺរស្មីរបស់ដួងចិត្ត ក៏ផ្សាយចេញទៅ
កាន់អារម្មណ៍តូចតិចដែរ បើអារម្មណ៍ធំច្រើនចូលមក ដួងចិត្តកើតឡើង
ចេតសិកជាពន្លឺរស្មីរបស់ដួងចិត្ត ក៏ផ្សាយចេញទៅកាន់អារម្មណ៍ធំធ្លាយ

ច្រើនដែរ មានឧបមេយ្យដូចតួអណ្តាតក្តៅនិងពន្លឺរស្មីរបស់ក្តៅ គឺថា អារម្មណ៍ដូចប្រុងនេះប្រុងគោម ដួងចិត្តដូចតួអណ្តាតក្តៅ ចេតសិក ទាំងឡាយដូចពន្លឺរស្មីរបស់ក្តៅយ៉ាងនោះឯង ។

២៨ - ធម្មវាទី ពោលថា សាធុ ម្នាលអត្តវាទី ប្រស្នានេះប្រពៃ ហើយ តែយើងនឹងសួរប្រស្នាដទៃតទៅទៀត ម្នាលអត្តវាទី ចុះចិត្តនោះ ចេះនឹងហ្វឹកហ្វឺនប្រឿនប្រដៅឲ្យចម្រើនទៅតាមថ្នាក់ តាមជាន់ទាបខ្ពស់ជា លំដាប់ៗទៅបានប៉ុន្មានជាន់ ? ដូចម្តេចខ្លះ ? ប្រព្រឹត្តទៅក្នុងកូដប៉ុន្មាន ? ឈ្មោះអ្វីខ្លះ ? ចិត្តមានឈ្មោះផ្សេងៗគ្នា មានប៉ុន្មាន ? គឺចិត្តឈ្មោះអ្វីខ្លះ ?

អត្តវាទី វិសជ្ជនាតថា បពិត្រធម្មវាទី ប្រស្នានេះខ្ញុំនឹងអធិប្បាយ ជាសរុបតាក្យស្មូរទាំង ៣ ប្រស្នាតែម្តង តាមន័យបរមត្ថព្រះតថាគតជាម្ចាស់ ព្រះអរហំ សម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងពន្យល់ដល់វេនេយ្យសត្វ ទាំងឡាយថា ចិត្តដែលកើតមានក្នុងសន្តានសព្វសត្វទាំងអស់ក្នុងលោក សន្និវាសនេះ ដែលហ្វឹកហ្វឺនប្រឿនប្រដៅឲ្យចំរើនទៅតាមលំដាប់ថ្នាក់ លំដាប់ជាន់ទាបខ្ពស់នោះមានថ្នាក់ ៤ មានកូដ ៤ មានឈ្មោះ ៤ ដូចគ្នា ; សេចក្តីអធិប្បាយពន្យល់ថា ចិត្តទី ១ របស់សត្វទាំងឡាយឯណាដែល ប្រព្រឹត្តទៅលុះក្នុងអំណាចនៃតាមតណ្ហា ជឹកនាំឲ្យត្រេកត្រអាលនឹង

កាមគុណចំនួន ៥ ព្រោះមានរូប សំឡេង ក្លិន រស សម្ផស្សជាអារម្មណ៍ ចិត្តរបស់សត្វទាំងឡាយនោះមានឈ្មោះថាហ៊ានចិត្ត ជាចិត្តយ៉ាងថោកថយ ប្រព្រឹត្តទៅក្នុងកាមភូមិ តែងកើតនៅក្នុងកាមភព មានឈ្មោះថាកាមាវចរចិត្ត ។ ចិត្តទី២របស់សត្វទាំងឡាយឯណា ដែលប្រព្រឹត្តទៅលុះក្នុងអំណាចនៃរូបតណ្ហា ដែលបានលះបង់កាមគុណទាំង ៥ ហើយត្រេកត្រអាលតែនឹងរូបរបស់ខ្លួន ព្រោះមានរូបតណ្ហាជាអារម្មណ៍ ចិត្តរបស់សត្វទាំងឡាយនោះ មានឈ្មោះថា រូបរាគចិត្ត ជាចិត្តជាន់ខ្ពស់ ល្មមប្រព្រឹត្តទៅក្នុងរូបភូមិ តែងកើតនៅក្នុងរូបភព ជានឈ្មោះថារូបាវចរចិត្ត ។ ចិត្តទី ៣ របស់សត្វទាំងឡាយឯណា ដែលប្រព្រឹត្តទៅលុះក្នុងអំណាច នៃអរូបតណ្ហា ត្រេកត្រអាលតែនឹងនាមធម៌ ព្រោះមានអរូបធម៌ជាអារម្មណ៍ ចិត្តរបស់សត្វទាំងឡាយនោះបានឈ្មោះថា រូបរាគចិត្ត ជាចិត្តយ៉ាងជាន់ខ្ពស់បំផុត ប្រព្រឹត្តទៅក្នុងអរូបភូមិ តែងកើតនៅក្នុងអរូបភព ជានឈ្មោះថា អរូបាវចរចិត្ត ។ ចិត្តទី ៤ របស់សត្វទាំងឡាយឯណា ដែលប្រព្រឹត្តទៅក្នុងទីដ៏ខ្ពង់ខ្ពស់ផុតចាកលោកជាស្រេច ព្រោះមានព្រះនិព្វានជាអារម្មណ៍ ចិត្តរបស់សត្វទាំងឡាយនោះបានឈ្មោះថា លោកុត្តរចិត្ត ជាចិត្តយ៉ាងប្រសើរ

វិសេសខ្ពង់ខ្ពស់បំផុត ប្រព្រឹត្តទៅក្នុងលោកុត្តរភូមិ តទៅខ្ងែងសោយ
សុខដ៏ឧត្តមក្សេមក្សាន្ត ក្នុងទីបំផុតលោកចាំង ៣ គឺ កាមលោក ១ រូប-
លោក ១ អរូបលោក ១ ជាកិច្ចរបស់ពួកតណ្ហា ឋានឈ្មោះថា លោកុត្តរ-
ចិត្ត រូបមេចិត្តចាំងអស់ត្រូវជាថ្នាក់ ๔ ភូមិ ๔ ចិត្ត ๔ ដោយពិត ។

๒๙- ធម្មវាទី ឋានស្តាប់ហើយពោលថា ម្នាលអត្តវាទី ប្រស្នា
នេះយើងស្តាប់ចូលចិត្តហើយ តែយើងនឹងសួរលោកតទៅទៀត បុគ្គល់
ពាក្យដែលលោកវិសជ្ជនាមកថាភូមិមាន ๔ គឺកាមភូមិ ១ រូបភូមិ ១ អរូប-
ភូមិ ១ លោកុត្តរភូមិ ១ ជាបទមាតិកានោះយើងស្តាប់ឋានហើយ តែបទ
ភាជនីយៈយើងស្តាប់ពុំទាន់ឋានទៅទេ ដូច្នេះសូមឲ្យលោកសំដែង
ជាបទភាជនីយតទៅទៀត តើកាមភូមិមានប៉ុន្មាន ? រូបភូមិមានប៉ុន្មាន ?
អរូបភូមិមានប៉ុន្មាន ? លោកុត្តរភូមិមានប៉ុន្មាន ? ចូរលោកវិសជ្ជនាមក
ឲ្យសព្វគ្រប់យើងទើឋានស្តាប់ចូលចិត្តផងមើល ?

អត្តវាទី វិសជ្ជនាថា បពិត្រធម្មវាទី តាមបទភាជនីយៈលោក
សំដែងចំណែកចែកភូមិដោយពិស្តារថា ទី ១ កាមាវចរភូមិមាន ๑๑ ជាន់
គឺអបាយភូមិ ๔ ជាន់ នរក ๑ ប្រេត ๑ អសុរកាយ ๑ តិរច្ឆាន ๑
កាមសុគតិ ๗ ជាន់ ហ៊ានមនុស្ស ๑ ហ៊ានសួគ៌ ๖ ជាន់ គឺចាតុមហារាជ-

ก ๑ ត្រាវត្តីសា ๑ ឃោមា ๑ តុសិតា ๑ ឆម្ពានតៈ ๑ បរនិម្មិតវសវត្តី ๑
ត្រូវជាកាមភូមិ ๑๑ ជាន់ បើនឹងហៅថាកាមភព ๑๑ ជាន់ ទៅវិញក៏បាន;
ចំ៦រូបភូមិមាន ๑๖ ជាន់ មានព្រហ្មបារិសជ្ជាជាដើម មានអកនិដ្ឋ-
ព្រហ្មជាទីបំផុត ត្រូវជារូបភូមិ ๑๖ ជាន់ បើនឹងហៅថារូបភព ๑๖ ជាន់.
ទៅវិញក៏បាន; ចំ៣អរូបភូមិមាន ๔ ជាន់ គឺអាកាសានញ្ចាយតន ๑
វិញ្ញាណញ្ចាយតន ๑ អាកិញ្ចញ្ញាយតន ๑ នេវសញ្ញានាសញ្ញាយតន ๑
ត្រូវជាអរូបភូមិ ๔ ជាន់ បើនឹងហៅថាអរូបភព ๔ ជាន់ទៅវិញក៏បាន; ចំ៤
លោកុត្តរភូមិនោះ សេចក្តីអធិប្បាយថា ព្រះអរិយបុគ្គលទាំង ๔ ពួក
គឺសោតាបត្តិមគ្គពួក ๑ សោតាបត្តិផលពួក ๑ សកទាគាមិមគ្គពួក ๑
សកទាគាមិផលពួក ๑ គឺព្រះអរិយទាំង ๔ ពួកនេះ អាចត្រាច់ទៅ
កន្លងភូមិទាំង ๒๑ ជាន់ គឺកាមសុគតិភូមិ ๗ ជាន់ រូបភូមិ ๑๐ ជាន់ អរូបភូមិ
๔ ជាន់ ត្រូវជា ๒๑ ជាន់ រឿរលែងតែភូមិទាំង ๑๐ ជាន់ចេញ គឺសុទ្ធាវាស-
ភូមិ ๕ ជាន់អបាយភូមិ ๔ ជាន់ អសញ្ញីភូមិ ๑ ជាន់ លោកពុំបាននៅឥត
ឡើយ; ចំណែកខាងព្រះអនាគាមីបុគ្គលទាំង ๔ ពួក លោកអាចត្រាច់
ទៅកើតកន្លងសុទ្ធាវាសភូមិ ๕ ជាន់ គឺអវិហា ๑ អតប្បា ๑ សុទស្សា ๑
សុទស្សី ๑ អកនិដ្ឋ ๑ តែប៉ុណ្ណោះ ព្រោះលោកមានកាមរាគបានលះបង់

ជាស្រេចរហើយ មួយទៀត ព្រះអង្គទាំងឡាយដែលជាសេចក្តីល
សោតអាចកើតបានក្នុងភូមិទាំង ២៦ ជាន់ លើសលែងតែអបាយភូមិ ៤ និង
អសញ្ញីភូមិ ១ ចេញ បើសោកបានចំរើនសំរេចព្រះអរហត្តផលហើយ
ដល់កំណត់អស់អាយុសង្ខារ សោតនឹងរំលត់ទៅ បួសកាន់សាសនា
ជាស្ពានដ៏ទៀងសោយបរមសុខក្សេមក្សាន្តគឺអមតមហានិព្វានទៀងដោយ
ពិត ខ្ញុំអត្តាពី រៀបរួមមកអំពីភូមិទាំង ៤ ដោយសង្ខេបតែប៉ុណ្ណេះឯង ។

๓๐ - ធម្មវិទូ បានស្តាប់ហើយពោលថា សាធុ ៗ ប្រស្នានេះប្រ-
ពៃណាស់ហើយ តែយើងខ្ញុំសួរសោតតទៅទៀត ម្នាលអត្តាពី ចុះចិត្ត
ទាំង ៤ យ៉ាងនោះ តើចិត្តទី ១ កាមាវចរចិត្ត ជាចិត្តលុះទៅក្នុងអំណាចនៃ
កាមតណ្ហាដឹកនាំឲ្យត្រាច់ទៅដោយច្រើន សោយសុខទុក្ខក្នុងកាម
ភពនោះ តើមានចិត្តចំនួនប៉ុន្មាន ? ចិត្តទី ២ រូបាវចរចិត្ត ជាចិត្តលុះទៅក្នុង
អំណាចនៃរូបតណ្ហាដឹកនាំឲ្យត្រាច់ទៅដោយច្រើន សោយសុខក្នុងរូប-
ភពនោះ តើមានចិត្តចំនួនប៉ុន្មាន ? ចិត្តទី ៣ អរូបាវចរចិត្ត ជាចិត្តលុះទៅ
ក្នុងអំណាចនៃអរូបតណ្ហាដឹកនាំឲ្យត្រាច់ទៅដោយច្រើន សោយសុខក្នុង
អរូបភពនោះ តើមានចិត្តចំនួនប៉ុន្មាន ? ចិត្តទី ៤ លោកុត្តរចិត្ត ជាចិត្ត
ខ្ពង់ខ្ពស់ចាកលោកទាំង ៣ នោះ តើមានចិត្តចំនួនប៉ុន្មាន ? ឬក៏រួមចិត្តទាំង ៤

ដោយសង្ខេប តើមានចិត្តចំនួនប៉ុន្មាន? បើដោយពិស្តារតើមានចិត្តចំនួនប៉ុន្មាន? ចូរលោកវិសជ្ជនារៀបរាប់ចំនួនចិត្តឲ្យសព្វគ្រប់មកយើងនឹងបានស្តាប់ចូលចិត្តផងមើល?

អត្ថវិទី វិសជ្ជនាតបថា បពិត្រធម្មាចរិយ កាមាវចរចិត្តមាន ១ នោះមានចិត្តចំនួន ៥៤ ដួង, រូបាវចរចិត្តមាន ២ នោះ មានចិត្តចំនួន ១៥ ដួង, អរូបាវចរចិត្តមាន ៣ នោះ មានចិត្តចំនួន ១២ ដួង, លោកុត្តរចិត្តមាន ៤ នោះ មានចិត្តចំនួន ៨ ដួង ដោយសង្ខេប; បើដោយពិស្តារមានចិត្តចំនួន ៤០ ដួងសព្វបូករួមចិត្តទាំង ៤ យ៉ាងនោះ ដោយសង្ខេបមានចិត្តចំនួន ៨៩ ដួង, បើសំដែងដោយពិស្តារមានចិត្តចំនួន ១២១ ដួងគត់ ខ្ញុំអត្តាចារ្យ បានវិសជ្ជនារៀបរាប់ចំនួនទាំង ៤ យ៉ាងមកតែត្រឹមប៉ុណ្ណេះឯង ។

៣១ - ធម្មវិទី សួរទៀតថា ប្រសិនដែលលោកវិសជ្ជនារៀបរាប់ចំនួនចិត្តមកនេះត្រឹមត្រូវពិតហើយ ចុះកាមាវចរចិត្ត ៥៤ ដួង, ទាំងដើមនោះតែងជាអកុសលចិត្តប៉ុន្មាន? ជាអហេតុកចិត្តប៉ុន្មាន? ជាសហេតុកកាមាវចរចិត្តប៉ុន្មាន? ចូរលោកវិសជ្ជនារៀបរាប់មកមើល?

អត្ថវិទី វិសជ្ជនាតបថា បពិត្រធម្មាចរិយ កាមាវចរចិត្តមាន ១ ទាំងដើមនោះតែងជាអកុសលចិត្ត ១២ ជាអហេតុកចិត្ត ១៨ ជាសហេតុកចិត្ត ២៤

ត្រូវជាកាមាវចរចិត្ត ៥៤ យ៉ាងពិត ។

๓๒- ធម្មវិទិ បានស្តាប់ហើយសួរបញ្ជាក់ទៀតថា ម្នាលអត្ថ-
វាទី ពុះពាក្យថា អកុសលចិត្ត ១ នោះ តើសេចក្តីអធិប្បាយដូចម្តេច ?
ពាក្យថា អហេតុកចិត្ត ១ នោះ សេចក្តីអធិប្បាយដូចម្តេច ? ពាក្យថា
សហេតុកកាមាវចរចិត្ត ១ នោះ សេចក្តីអធិប្បាយដូចម្តេច ?

អត្ថវិទិ វិសជ្ជនាតបថា បពិត្រធម្មវាទី ឯអកុសលចិត្តនោះ
សេចក្តីអធិប្បាយក្នុងបរមត្ថព្រះអភិធម្ម លោកសំដែងពន្យល់ថាចិត្តរបស់
បុគ្គលទាំងឡាយឯណា តើតណ្ហាឯតទគ្គៈស្មើសោតាបំឥតបញ្ញាមិន
ឆ្ងៀវឆ្ងាសវាងវៃពិចារណាគាន់ប្រឡំក្នុងតារម្មណ៍ទាំងឡាយ ដែលជា
គុណមានផលប្រយោជន៍ក្នុងលោកនេះនឹងលោកខាងមុខ ពិចារណា ឃើញ
ឃើញទុសថា ឥតគុណ ឥតផលប្រយោជន៍ទៅវិញ មិនទំព្យាយាមប្រឹង
ប្រែងធ្វើឲ្យកើតផលឡើងក្នុងសន្តានខ្លួន តារម្មណ៍ទាំងឡាយដែលជា
ទោសឥតផលប្រយោជន៍សោះក្នុងលោកនេះនឹងលោកខាងមុខ ពិចារណា
ឃើញទុសថា មានគុណមានផលប្រយោជន៍ទៅវិញ ហើយទំព្យា-
យាមប្រឹងប្រែងប្រព្រឹត្តធ្វើអំពើទុសនោះពុំដាច់មានកម្មារម្មណ៍តារម្មណ៍ គឺ
អំពើបៀតបៀនសម្លាប់សត្វលួចប្រព្យាអែ ប្រព្រឹត្តក្បត់ក្នុងប្រពន្ធគូនៅវៃអែ

ជាដើម ដែលជាអំពើឥតប្រយោជន៍ប្រកបដោយទោសផ្សេងៗ ក្នុងលោកនេះនឹងលោកខាងមុខ ដោយចំណែកមួយ ព្រោះគ្មានសទ្ធា សតិ បញ្ញា ជាគ្រឿងជាស់តឿនខ្លួន ជាបុគ្គលវង្វែងកាន់ច្រឡំក្នុងអារម្មណ៍ ទំព្យាយាមធ្វើទៅតាមអំណាចនៃតាមតណ្ហាដឹកនាំដំរុលទៅក្នុងកាមគុណទាំង ៥ ឥតមានស្រាកស្រាន្តសោះ ចិត្តរបស់បុគ្គលទាំងឡាយនោះឯងបានឈ្មោះថាអកុសលចិត្តដោយពិត ។ ឯពាក្យថាអហេតុកចិត្តនោះ សេចក្តីអធិប្បាយក្នុងគម្ពីរអដ្ឋសាលិនីអដ្ឋកថាអកិរិយមហាសង្គណី លោកពន្យល់ថាចិត្តឯណាឥតហេតុ មិនអាចនឹងញ៉ាំងគុណវិសេសមានឈានសមាបត្តិជាដើមឲ្យកើតឡើងបានឡើយ ត្រាន់តែទឹកស្រាវជ្រាវរកអារម្មណ៍ ឃើញអារម្មណ៍ ខ្លួចាប់យកអារម្មណ៍ ពិចារណាកំណត់អារម្មណ៍បានត្រឹមវិថីចិត្តទី ៤ ហើយរលត់ធ្លាក់ទៅវិញ ធ្លាក់ចុះមកកាន់ភវង្គចិត្តវិញជាដដែល តុំបន្សាស់លាស់ថាជាកុសលឬជាអកុសលពេញទីនោះឡើយ ព្រោះកុសលនឹងអកុសលដែលនឹងកើតឡើងបន្សាស់លាស់តែក្នុងវេលាជួនវិថីចិត្តទី ៥ ប៉ុណ្ណោះ ចិត្តនោះឯងបានឈ្មោះថាអហេតុកចិត្តដោយពិត ។ ឯសហេតុកកាមាវចរចិត្តនោះ លោកសំដៅយកចិត្តដែលរុងរឿងធ្វើធ្លាសភាពវែ ស្គាល់ទុសត្រូវ គុណទោស បុណ្យបាប ប្រកបដោយ

ហេតុ មានអលោភចិត្ត គឺចិត្តមិនលោភហួសប្រមាណជាដើម អាចលះ
បង់សេចក្តីកំណាញ់ ការត់អាល័យថាវត្ថានព្រឹត្យឲ្យទានជាល់ប្តូរលុយជាដែ
ឋាន តើតជាកុសល ជាវិបាក ជាកិរិយា ឥឡូវនេះបានអន្តាស់ទៅមក
សោយសុខក្នុងកាមសុគតិភូមិទាំង ៧ ជាន់ដោយប្រើន ចិត្តនោះឯង
បានឈ្មោះថាសហេតុកកាមាវចរចិត្តដោយពិត ។ ខ្ញុំអត្ថាធិប្បាយ
ឈ្មោះចិត្តទាំង ៣ យ៉ាងមកដោយសង្ខេបតែប៉ុណ្ណេះឯង ។

๓๓ - ធម្មវិទូ បានស្តាប់ហើយ ពោលថា អើអត្ថាធិប្បាយ លោក
វិសជ្ជនាមកនេះ យើងស្តាប់បានហើយ តែយើងនឹងសួរតទៅទៀត
ចុះចិត្តដែលប្រកបដោយហេតុ ។ នោះមានចំនួនប៉ុន្មាន ? គឺហេតុអ្វីខ្លះ ?
ចូរលោកពន្យល់ចំនួនហេតុព្រមទាំងសេចក្តីអធិប្បាយ ឲ្យស្តាប់ត្រង់មកយើង
នឹងបានស្តាប់ចូលចិត្តផងមើល ?

អត្ថវិទូ វិសជ្ជនាតបថា បពិត្រធម្មវិទូ ចិត្តដែលប្រកបដោយ
ហេតុនោះ មាន ៦ គឺលោភៈ ១ ទោសៈ ១ មោហៈ ១ ទាំង ៣ នេះជា
អកុសលហេតុ ព្រោះចិត្តដែលសម្បយោគប្រកបព្រមដោយលោភៈបាន
បាន កំណាញ់ស្អិតស្អាញ ចំពាក់ជាប់នៅក្នុងវត្ថុទាំងពួងក្តី
ទោសៈ ក្រោធនឹង ការឈាហាវប្លែកប្លួសក្តៅនឹងសង្វាតទាំងពួងក្តី

មោហៈ វិនិឆ្ឆិតកាន់ប្រឡឹក្ខណាមម្មណ៍ សំគាល់ទុក្ខសច្ចារម្មណ៍ថាជាអនិច្ចា-
រម្មណ៍ក្តី ជាហេតុបណ្តាលឲ្យកើតឡើងជាអកុសលផលចាបជាយថាតុ ។
អលោភៈ ๑ អទោសៈ ๑ អមោហៈ ๑ ទាំង ๓ នេះ ជាកុសលហេតុ
ព្រោះចិត្តដែលសម្បយោគច្រកចព្រមដោយអលោភៈ មិនកំណាញ់ស្ទឹត
ស្ទាញ ចំពាក់ជាប់នៅក្នុងទ្រព្យសម្បត្តិទាំងពួងក្តី អទោសៈ មិនក្រោធ
ទឹង កាចសាហាវ មិនច្រខូចស្តុកស្តឹងសង្វាគទាំងពួងក្តី អមោហៈ មិន
វិនិឆ្ឆិតកាន់ប្រឡឹក្ខណាមម្មណ៍ សំគាល់ត្រូវ ឥដ្ឋារម្មណ៍ ថាជាឥដ្ឋារម្មណ៍
អនិដ្ឋារម្មណ៍ ថាជាអនិដ្ឋារម្មណ៍តាមសភាពពិតក្តី ជាហេតុបណ្តាលឲ្យ
កើតឡើងជាកុសលផលបុណ្យរាយតុ ។ ខ្ញុំអត្តាវ ចានវិសជ្ជនា
ហេតុ ๖ យ៉ាងត្រមាំងសេចក្តីអធិប្បាយមកដោយសង្ខេបតែប៉ុណ្ណេះឯង ។

๓๔-ធម្មវិទិ ពោលថា ម្នាលអត្តាវ ប្រស្នាដែលលោក
វិសជ្ជនាមកនេះ មានសេចក្តីចំពាក់ពាក់ពាមគ្នានឹងស្រួលយ៉ាងទៀត
ដូចត្រង់កុសលចិត្តទាំង ๒๑ សម្បយោគច្រកចព្រមដោយហេតុឲ្យឈ្មោះ
ថា សហេតុកកាមាវចរចិត្ត ត្រង់អកុសលចិត្តទាំង ๑๒ សម្បយោគ
ច្រកចព្រមដោយហេតុដែរ ដូចម្តេចក៏ពុំឲ្យឈ្មោះថា សហេតុកកាមាវច-
ចិត្តផង ? បើពុំឲ្យឈ្មោះថាសហេតុកកាមាវចចិត្តទេ តើព្រះសម្មាសម្ពុទ្ធ

ជាម្ចាស់ទ្រង់កំណត់ឲ្យឈ្មោះផ្សេងគ្នាដូចម្តេចខ្លះ ? សេចក្តីអធិប្បាយ
យ៉ាងណា ? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មក យើងនឹងបានស្តាប់
ចូលចិត្តឿងមើល ?

អត្ថវិទី វិសជ្ជនាតបថា បពិត្រធម្មាភិ ឯកុសលចិត្តចំនួន ២១ នោះ
សម្បយោគប្រកបព្រមដោយ អលោភៈ អទោសៈ អមោហៈ តើសេចក្តី
មិនលោភហួសប្រមាណផង មិនក្រោធទាំងប្រទូស្តសត្វនឹងសង្ខារផង
មិនវង្វេងគាន់ប្រឡំក្នុងអារម្មណ៍ផង មានបញ្ញាឆ្លៀវឆ្លាសវាងវៃស្គាល់
ខុសត្រូវ គុណាធោសជាដើម ដូចមានសេចក្តីអធិប្បាយដូចតទៅនេះ ។
ទី ១ កុសលចិត្តរបស់បុគ្គលដែលជាសម្ចាទិដ្ឋិ ពិចារណាយល់ឃើញត្រូវ
ដឹងច្បាស់ស្គាល់ច្បាស់នូវទោសនៃលោភៈ សេចក្តីលោភហួសប្រមាណ
ប្រព្រឹត្តកំណាញ់លាក់បាំងទ្រព្យរបស់ខ្លួនខុក តុំបានចែកទ្រព្យធ្វើ
បុណ្យឲ្យទាន ថាជាសភាវៈដឹកនាំសត្វចាំងឲ្យទៅកាន់អបាយភូមិ ៤
ដោយពិត ហើយទំព្យាយាមលះបង់សេចក្តីលោភ មន្ទិយកំឡាំងសេចក្តី
លោភឲ្យថយចុះតិចទៅ ទំព្យាយាមចំរើនអលោភៈ សេចក្តីមិនលោភ
មិនប្រព្រឹត្តកំណាញ់ បែកចែកទ្រព្យរបស់ខ្លួនធ្វើបុណ្យឲ្យទាន ញុំាង
បុណ្យឲ្យកើតមានច្រើនឡើងក្នុងសន្តានខ្លួន ។ ទី ២ ដឹងច្បាស់ស្គាល់

ច្បាស់នូវទោសនៃទោស: សេចក្តីក្រោធទាំង ប្រទូស្តសត្វទាំងសង្ខារគាំង-
ឡាយថាជាសភាវៈដឹកនាំសត្វគាំងឡាយទៅកាន់អបាយភូមិ ៤ ដោយពិត
ហើយទំព្យាយាមលះបង់ទោស: ជន្ធយកំឡាំងទោស: ទ្បែថយចុះតិចទៅ
ទំព្យាយាមចំរើនអទោស: សេចក្តីមិនក្រោធទាំងប្រទូស្តសត្វទាំងសង្ខារ
គាំងចិត្តសុចរិតប្រព្រឹត្តនូវសីល ៥ សីល ១ ចោសថដែលប្រកបព្រម
ដោយអង្គគាំង ៨ ញុំាងឫញ្ញាសីទ្បែកើតមានប្រើនឡើងក្នុងសន្តានខ្លួន ។
ទី ៣ ជាធ ច្បាស់ស្គាល់ច្បាស់នូវទោសនៃមោហ: សេចក្តីវង្វេងគាន់ប្រឡំ
អង្គារម្មណ៍ ដែលជាអារម្មណ៍ គួរតប្បីច្រឡំថាត្រេកអរពិត ថាជាអនិដ្ឋ-
រម្មណ៍ តីជាអារម្មណ៍មិនគួរតប្បីច្រឡំថាត្រេកអរទៅវិញ តីថាគាន់ឃក
អារម្មណ៍ដែលគួរតប្បីត្រេកអរប្រព្រឹត្តអ្វើ ថាជាអារម្មណ៍មិនគួរតប្បីត្រេក-
អរប្រព្រឹត្តអ្វើទៅវិញ ជាធច្បាស់ថាការដែលគាន់ប្រឡំអារម្មណ៍យ៉ាងនេះ
ជាសភាវៈដឹកនាំសត្វទាំងឡាយទៅកាន់អបាយភូមិ ៤ ដោយពិត ហើយ
ទំព្យាយាមលះបង់មោហ: ជន្ធយកំឡាំងមោហ: ទ្បែថយចុះតិចទៅ ទំព្យា-
យាមប្រឹងប្រែងរៀនសូត្រចំរើនអមោហ: សេចក្តីមិនវង្វេងគាន់ប្រឡំអា-
រម្មណ៍ ទ្បែបានបេះដូងពិតតាំងចិត្តចំរើនភាវនាកុសលផលបុណ្យទ្បែកើត
មានប្រើនឡើងក្នុងសន្តានខ្លួន ។ កំចិត្តដែលសម្បយោគប្រកបព្រមដោយ

កុសលហេតុ៣ យ៉ាងដូចបានអធិប្បាយមកនេះ ជាចិត្តមានកំឡាំងឲ្យ
ផលប្រកបដោយ៦ហេតុ ទើបព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ឲ្យឈ្មោះថា
សហេតុកកាមាវចរចិត្តដោយពិត ។ ឯអកុសលចិត្ត៧ នោះសម្ប-
យោគប្រកបព្រមដោយ លោភៈ ទោសៈ មោហៈ តើសេចក្តីលោភហួស
ប្រមាណផង ក្រោធទឹងប្រទូសច្រើនផង រឹងត្អឹងកាន់ច្រឡំការមិណ៍ផង
មិនមានបញ្ញាឆ្លៀវឆ្លាសវាងវៃ មិនស្គាល់ទុសត្រូវ គុណទោសជាដើម
ជាមិច្ឆាទិដ្ឋិ ពិចារណាយល់ឃើញខុសថា អលោភៈ សេចក្តីដែលមិន
លោភចង់បានលាក់ទ្រព្យទុក មិនកំណាញ់ ហើយបរិច្ចាគទ្រព្យធ្វើបុណ្យ
ឲ្យទាននេះជាការឥតប្រយោជន៍ យល់ឃើញខុសថា អទោសៈ សេចក្តី
ដែលមិនក្រោធទឹងមិនប្រទូសក្តុនធឹងសង្ឃារ ហើយទំនាំងចិត្តរក្សាសីល
នេះជាការឥតប្រយោជន៍ យល់ឃើញខុសថា អមោហៈ សេចក្តីដែល
មិនរឹងត្អឹងកាន់ច្រឡំប្រកាន់មាំថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បុញ្ញ
សីល ការនោជាដើម ដែលថាជាឥដ្ឋារម្មណ៍ ជាការមិណ៍ តិបុគ្គលតប្បី
ច្រាំថ្មាត្រកអរស្រឡាញ់តាមចិត្តប្រព្រឹត្តធ្វើ ហើយថាបានបុណ្យបានប្រ-
យោជន៍នោះពុំពិតទេ ជាពាក្យតេបញ្ឆោតដល់មនុស្សល្ងង់ខ្លៅតាំនឡាយ
ឲ្យឃ្លាតប្រយោជន៍ទៅឆ្ងាយតែប៉ុណ្ណោះទេ ចិត្តតំនិតរបស់បុគ្គលដែលយល់

ឃើញខុស តំនិតច្រឡំដូចអធិប្បាយដោយសង្ខេបមកខាងលើនេះបាន
ឈ្មោះថា ចិត្តប្រកបព្រមដោយលោភៈ ទោសៈ មោហៈ ត្រូវសង្កត់ចំពាក់
តំនិតល្អ ហើយក្បាំងតំនិតសាក្រក់លាមកឲ្យកើតឡើង ប្រព្រឹត្តធ្វើខូវអំពើ
ខុសវិតមានសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តកាយទុច្ចរិតជាដើម
ពេញទីឥតកោតញញើតឡើយ ។ តំណកុសលចិត្តទាំង ១៦ នេះ អកុ-
សលចិត្ត ១០ គឺលោភចិត្ត ៨ ទោសចិត្ត ២ ជាខុហេតុកៈ ប្រកបដោយ
ហេតុពីរ គឺលោភៈ ១ ទោសៈ ១, មោហចិត្ត ២ ជាឯកហេតុកៈ ប្រកបដោយ
ហេតុ ១ គឺមោហៈ ពោះបីប្រកបដោយហេតុយ៉ាងនេះក៏ដោយ តាំព្រះ
សម្មាសម្ពុទ្ធព្រះអង្គពុំបានឲ្យឈ្មោះថា សហេតុកកាមាវចរចិត្តឡើយព្រះ
អង្គទ្រង់ឲ្យឈ្មោះថា អសង្ខារិកចិត្ត ជាចិត្តមិនរុងរឿងល្អសោះឡើយ
ព្រោះអកុសលចិត្តទាំងនេះមានកំឡាំងខ្សោយ ឲ្យផលមិនប្រកបដោយ
ហេតុជាអហេតុកវិបាកចិត្តពិតៗ ឯកុសលចិត្តទាំងខ្សោយដែលប្រកបដោយ
ទ្វេហេតុក្តី ខុហេតុក្តី ព្រះអង្គឲ្យឈ្មោះថាសហេតុកកាមាវចរចិត្តផង
ឲ្យឈ្មោះថាសោភណចិត្ត ជាចិត្តដ៏រុងរឿងល្អផង ព្រោះកុសលចិត្ត
ទាំងខ្សោយមានកម្លាំងខ្លាំង អាចឲ្យផលប្រកបដោយហេតុជាសហេតុក-
វិបាកចិត្តដោយពិត ។ បពិត្រធម្មាភិ ខ្ញុំព្រះករុណាបានអធិប្បាយអំពី

កាមាវចរចិត្ត ដែលបានចំណែកចែកជាកុសលចិត្តផង អកុសលចិត្តផង ប្រកបដោយហេតុទាំងមិនប្រកបដោយហេតុផង ដែលមានឈ្មោះនាំឲ្យសេចក្តីអធិប្បាយផ្សេង។ គ្នាដោយសង្ខេបមកតែប៉ុណ្ណេះសូមជ្រាប ។

៣៥-ធម្មវិទី ពោលថា សាធុ។ ម្នាលអត្ថវិទី ប្រស្នាដែលលោកវិសជ្ជនាមកនេះប្រពៃហើយ តែយើងនឹងសួរលោកតទៅទៀត ។ ចុះអង្គសម្តេចព្រះសយម្ភូញ្ញាណជាម្ចាស់ទ្រង់ត្រាស់សំដែងអំពី ចិត្តដែលជាធម្មជាត ដ៏ល្អិត ឥតរូបអាចត្រាច់ទៅឆាប់ហ៊ោសកាន់អារម្មណ៍ផ្សេង។ មិនមានទីសាក់ ហើយព្រះអង្គទ្រង់ជ្រាបច្បាស់នូវភាវៈចិត្តរបស់សត្វទាំងឡាយ តើព្រះអង្គទ្រង់កំណត់ភាវៈចិត្ត ឲ្យឈ្មោះថា អសោកណាចិត្តមានចំនួនប៉ុន្មាន? កំណត់ភាវៈចិត្តឲ្យឈ្មោះថាសោកណាចិត្តដោយសង្ខេបមានចំនួនប៉ុន្មាន? ដោយពិស្តារមានចំនួនប៉ុន្មាន? គឺពួកចិត្តអ្វីខ្លះ ?

អត្ថវិទី វិសជ្ជនាតបថា បពិត្រធម្មវិទីព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ពិចារណាជ្រាបច្បាស់នូវភាវចិត្តនៃសត្វទាំងឡាយ ហើយព្រះអង្គទ្រង់កំណត់ភាវចិត្តទាំង ៣០ គត់ ដែលជាចិត្តអាច់ឥតតន្តីរស្មី ឥតមានសេចក្តីរុងរឿង បញ្ញាចេតសិកប្រកបកើតរលត់ព្រមជាមួយផងពុំបាន គឺអកុសលចិត្ត ១២ អហេតុកចិត្ត ១៨ ជាចិត្តមិនប្រកបដោយហេតុ ព្រះ

អង្គ្យស្សាយថា អសោកណចិត្តមានចំនួន ៣០ គត់ ជាចិត្តឥតពន្ធុស្មើមិន
មានសេចក្តីរុងរឿងល្អឡើយ ហើយព្រះអង្គទ្រង់កំណត់រាប់ចិត្តដែលរុង-
រឿងល្អយ៉ាងសង្ខេបមានចំនួន ៥៩ គឺការាប់ថាអសោកណចិត្ត ២៤ មហគ្គត-
ចិត្ត ២៧ គឺរូបាវចរចិត្ត ១៥ អរូបាវចរចិត្ត ១២ និងលោកុត្តរចិត្ត ៨ ត្រូវជា
៥៩ គត់ ។ បើដោយតាស្តារព្រះអង្គទ្រង់យកលោកុត្តរចិត្តទាំង ៨ បែកជា
ប្រាំ ។ តាមប្រភេទនៃឈានទាំង ៥ គឺមគ្គចិត្ត ២០ ផលចិត្ត ២០ ត្រូវជា
៤០ គត់ ផ្សំគ្នាទាំងអស់បានចំនួន ៩០ ហើយព្រះអង្គឲ្យស្សាយថា អសោក-
ណចិត្ត មានចំនួន ៩១ គត់ ជាចិត្តប្រកបដោយហេតុ មានពន្ធុស្មើរុងរឿង
ល្អដោយពិត ។ បពិត្រធម្មារាជ ខ្ញុំព្រះករុណាបានវិសជ្ជនារៀបរាប់អំពី
អសោកណចិត្តនិងសោកណចិត្តដោយសេចក្តីសង្ខេបមកតែប៉ុណ្ណេះឯង ។

៣៦-ធម្មរាជ បានស្តាប់ហើយ សួរតទៅទៀតថា ចុះអសោ-
កណចិត្តទាំង ៣១ នោះ បើវៀរលែងអសោកណចិត្ត ១២ ដែលប្រកប
ដោយហេតុនោះចេញ ចាយយកតែអសោកណចិត្ត ១៩ ដែលមនប្រ-
តបដោយហេតុនោះ មកចែកជាអកុសលវិបាកអហេតុកចិត្តមានប៉ុន្មាន?
ជាកុសលវិបាកអហេតុកចិត្តមានប៉ុន្មាន? ជាអហេតុកកិរិយាចិត្តមានប៉ុន្មាន?

អង្គរាជ វិសជ្ជនាតបថា បពិត្រធម្មារាជ ឯអសោកណចិត្តទាំង

๑๘ ដែលមិនប្រកបដោយហេតុនោះ ចែកជាអកុសលវិបាកអហេតុ-
កចិត្ត ๗ ជាកុសលវិបាកអហេតុកចិត្ត ๘ ជាអហេតុកកិរិយាចិត្ត ๓
រួមទាំងអស់ត្រូវជាអសោកណាចិត្ត ๑๘ គត់ ។ បពិត្រព្រះធម្មាធិ ម្ចុំព្រះ
តវុណា ចានវិសជ្ជនាពាប់ចំនួនអសោកណាចិត្ត ដែលចែកទៅតាមពួកតាម
ក្រុមផ្សេង ។ គ្នាដោយសង្ខេបតែប៉ុណ្ណេះឯង ។

๓๓ - ធម្មាធិទី ចានស្តាប់ហើយសួរសេចក្តីអធិប្បាយតទៅ
ទៀតថា ម្នាលអគ្គាធិទី ចុះអកុសលវិបាកអហេតុកចិត្តទាំង ๗ នោះគឺចិត្ត
អ្វីខ្លះ? អធិប្បាយដូចម្តេច? សូមលោកសំដែងសេចក្តីអធិប្បាយឲ្យ
ពិស្តារសេចក្រៃម៉ត់មក យើងនឹងស្តាប់ចូលចិត្តចានដោយងាយផងមើល?

អគ្គាធិទី វិសជ្ជនាតបថា បពិត្រធម្មាធិទី ព្រះអរហំសម្មាសម្ពុទ្ធ
ព្រះអង្គទ្រង់សំដែងអំពីអកុសលវិបាកអហេតុកចិត្តទាំង ๗ នោះជាសុទ្ធ-
តាត ដ៏ល្អិតជ្រាលជ្រៅពន់ពេកណាស់ ដូចមានសេចក្តីអធិប្បាយតទៅ
នេះ; គឺ ๑ - ๑បេក្ខាសហគតចក្ខុវិញ្ញាណ សេចក្តីអធិប្បាយថា អនិដ្ឋ-
រម្មណ៍ជាគោរម្មណ៍មិនជាទីប្រាថ្នាគឺរូបដែលអ្នកប្រាជ្ញទាំងឡាយ លោកមិន
ប្រាថ្នាមិនស្រឡាញ់គាប់ចិត្ត លោកតែងលះបង់វៀរលែង គេចវៀរចេញ
ជាធម្មតា ពោះ๑ចានចំនួនរូប គឺរូបដែលមានវិញ្ញាណ មានរូបមនុស្សប្រុស

ស្ត្រីនឹងរូបសត្វតូចធំជាដើមក្តីនឹងអនុបាទិន្នករូបដែលមិនមានវិញ្ញាណមាន
សំពត់អាវមាសគ្រាក់គ្រឿងប្រើប្រាស់ទាំងពួងជាដើមក្តី រូបារម្មណ៍ទាំង
នោះឈ្មោះថាពាហិរង្គនិទ្ទេសក្នុងបុព្វាបរៈខន្ធិចនិទ្ទេសក្នុងឯកជ្ឈាសាទ ចក្ខុវិញ្ញាណ
ដែលអាស្រ័យនៅក្នុងភ្នែក កើតឡើងអំពីចំមាយៃនអាហារុតុកម្មវិញ្ញាណ-
ធាតុជាសំភារៈ កើតឡើងមួយខណៈចិត្តធំ ជា ៣ ខណៈចិត្តតូចតី ។បេ។
រីថាចិត្តកើតឡើងតាមភាវនាក្នុងវិញ្ញាណក្ខន្ធ ប៉ិតប៉ោលនូវរូបា-
រម្មណ៍ដែលស្ថិតនឹងនៅក្នុងរង្វង់ចក្ខុទ្វារយ៉ាងរហ័ស, ភង្គៈកើតឡើងហើយ
ផែកវិលត់ចេញអំពីរូបារម្មណ៍នោះធ្លាក់ចុះមកកាន់ទ្វារភវង្គវិញ ៣ ខណៈ
ចិត្តតូចនេះហៅថា ១ ខណៈចិត្តធំ ទើបបានឈ្មោះថា ។បេ។ចក្ខុសម្ផស្ស-
ចក្ខុវិញ្ញាណ រីថាចិត្តអាចញ៉ាំងខន្ធសន្តានកុំឲ្យ តឹកតូងដែលឃើញជាដឹងថា រូបា-
រម្មណ៍ឲ្យសម្រេចបាន កើតរលត់ព្រមជាមួយ។បេ។វេទនា សញ្ញា ចេតនា
រួមនៃរូបារម្មណ៍ នឹងនៅក្នុងអនិដ្ឋារម្មណ៍ ជាកណ្តាលមិនកក្រើក តាល
ដែលចក្ខុវិញ្ញាណកើតឡើងហើយ រលត់ទៅវិញយ៉ាងនេះហើយ សម្ប-
ដិច្ឆនចិត្តក៏កើតឡើងបន្ទាប់អំពីចក្ខុវិញ្ញាណនោះ អំពីចំហាយៃនអាហារុ-
តវិញ្ញាតមនោធាតុជាសំភារៈ ហើយទទួលចាប់យកនូវរូបារម្មណ៍នោះ-
ជាមួយខណៈចិត្តធំ ៣ ខណៈចិត្តតូចដូចគ្នា ទើបបានឈ្មោះថា

อุเบกฺขาสหคตสมฺปยุตฺตจิตฺต วิถีจิตฺต ภวงฺคสมฺปยุตฺตกิจฺจ ตีรณ
กิจฺจเวสนฺตรจุติจิตฺตปฏิสนฺธิจิตฺตสมฺปยุตฺตกิจฺจ ตีรณกิจฺจเวสนฺตรจุติจิตฺต
ปฏิสนฺธิจิตฺตสมฺปยุตฺตกิจฺจ ตีรณกิจฺจเวสนฺตรจุติจิตฺตปฏิสนฺธิจิตฺตสมฺปยุตฺต
กิจฺจ ตีรณกิจฺจเวสนฺตรจุติจิตฺตปฏิสนฺธิจิตฺตสมฺปยุตฺตกิจฺจ ตีรณกิจฺจ
เ

ជាអកុសលផលបាបតេញ្ចី បើវិថីចិត្តនេះកំណត់អារម្មណ៍ខុសកងចិត្ត
ជាឥដ្ឋារម្មណ៍ត្រូវតាមទ្វារយនៃត្រចៀកជ្រុកជន កំតើតខ្លួនជាកុសល
ផលបុណ្យតេញ្ចី កំវិថីចិត្តដែលកំណត់ខ្លួនអារម្មណ៍យ៉ាងនេះ ទើប
បានឈ្មោះថា ភវង្គចិត្ត វិថីចិត្ត អាចញ៉ាំងភវង្គកិច្ច តឹកិច្ចដែល
ត្រូវធ្វើកំណត់អារម្មណ៍ ខុសកងចិត្តឲ្យសំរេចបាន បើកំណត់ខុសមិនត្រូវ
តាមទ្វារយនៃឋញ្ញាជាអនិដ្ឋារម្មណ៍ ហើយរលត់ចុះមក់គាន់មនោទ្វារវិញ
បណ្តាអកុសលចិត្តទាំង ១២ នោះ អកុសលចិត្តណាមួយតើតខ្លួនជា
អកុសលជវនៈខុសលេាយខ្លួរសនៃអនិដ្ឋារម្មណ៍ ដែលភវង្គចិត្ត
កំណត់ខុសហើយនោះ រឺអកុសលជវនេះ ដែលនឹងសោយខ្លួរសនៃអា-
រម្មណ៍នោះសោត កំសោយតែតាមកំឡាំងនៃអារម្មណ៍ជាលំដាប់ បើអា-
រម្មណ៍មានកំឡាំងខ្លាំងពេក អកុសលជវនៈសោយរសនៃអារម្មណ៍អស់
ភាវៈ ៧ជវនយ៉ាងច្រើន ជាបកំជ្ងន់ខ្លាំង បើអារម្មណ៍មានកំឡាំងល្មមខេ
អកុសលជវនៈសោយរសនៃអារម្មណ៍អស់ភាវៈ ៥ ឬ ៦ ជវន ជាបកំជ្ងន់ល្មម
ដែរ បើអារម្មណ៍មានកំឡាំងខ្សោយតិចចុះមកជាលំដាប់ អកុសល-
ជវនៈសោយរសនៃអារម្មណ៍អស់ភាវៈ ៤ ៣ ២ ១ ជវន ជាបកំតិចចុះមកជា
លំដាប់ៗដែរ ទើបបានឈ្មោះថា ភាមាវចរអកុសលជវនចិត្ត វិថីចិត្ត

រកញ្ចាំងជវនកិច្ច គឺកិច្ចដែលសោយនូវសៃនៃបុថុជ្ជនមិនបាន ហើយរលត់ត្រមជាមួយនឹងបុគ្គលវេទនា សោយរសនៃបុថុជ្ជនមិនឆ្ងាយទៅកើតអនិដ្ឋារម្មណ៍ ជាកណ្តាលមិនកន្ត្រើត ។ កាលបើអកុសលជវនកើតទៀតហើយរលត់ទៅវិញ យ៉ាងនេះហើយ អហេតុកសន្តតិរណចិត្តកើតទៀតពីចារណាកំណត់យកនូវរសនៃបុថុជ្ជនមិនអកុសលជវនសោយនោះ មកជាអារម្មណ៍ជាប់នៅក្នុងសន្តានខ្លួន បានឈ្មោះថា តទារម្មណអហេតុកអកុសលវិបាកចិត្ត តែម្យ៉ាងពិត ព្រោះសម្តែងព្រះសក្យមុនីជាម្ចាស់ ទ្រង់ត្រាស់សំដែងថា អកុសលធម៌ចំនួនប្លាយគឺអកុសលចិត្ត ១២ ក្តី អកុសលចេតសិកចំនួន ១៤ ក្តី ជាសភាវៈមានកំឡាំងខ្សោយ មានអាទុកាតតិចតន់តេចណាស់ ពុំអាចធ្វើនូវលោកុត្តរធម៌ឲ្យជាអារម្មណ៍បានឡើយ ទោះបីប្រកបដោយខុរហេតុឯករហេតុក៏ដោយ គង់ពុំអាចឲ្យផលជាសហេតុកតាមវិបាកចិត្តបានឡើយ នឹងឲ្យផលជាអហេតុកអកុសលវិបាកចិត្ត គឺ ១បញ្ចសហគតសន្តីរណចិត្ត ជាតទារម្មណអកុសលវិបាក ជាពួជបដិសន្ធិប្រព្រឹត្តទៅកន្លងអបាយភូមិ ៤ តែប៉ុណ្ណោះ ។

អធិប្បាយអំពីអហេតុកអកុសលវិបាកចិត្ត: ដែ ១ គឺបញ្ចវិញ្ញាណកើតឡើង

រកញ្ចាំងជវនកិច្ច គឺកិច្ចដែលសោយនូវសៃនៃវេទនាមួយ ឲ្យសម្រេចបាន ហើយរលត់ព្រមជាមួយនឹងបច្ចុប្បន្នវេទនា សោយសៃនៃវេទនាមួយនោះ ឈ្មោះថាអនន្តរកម្មណ៍ ជាកណ្តាលមិនកន្ត្រែង ។ កាលបើអកុសលជវនៈកន្លងទៅហើយរលត់ទៅវិញ យ៉ាងនេះហើយ អហេតុកសន្តតិណាមួយកន្លងទៅតាមលំដាប់ អហេតុកសន្តតិណាមួយនោះ ឈ្មោះថាអនន្តរបច្ចយ ដែលជាអារម្មណ៍ជាប់នៅក្នុងសន្តានខ្លួន ។ ចិត្តដែលកើតក្នុងអារម្មណ៍ជាប់នៅក្នុងសន្តានខ្លួន ឈ្មោះថា អនន្តរបច្ចយ ដែលជាអហេតុកអកុសលវិបាកចិត្ត តែមួយដងតែប៉ុណ្ណោះ ព្រោះសម្តែងដោយព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សំដែងថា អកុសលធម៌ទាំង ១២ ក្តី អកុសលចេតសិកទាំង ១៤ ក្តី ជាសភាវៈមានកំឡាំងខ្សោយ មានអាទុកាតតិចតួចពេកណាស់ ពុំអាចធ្វើនូវលោកុត្តរធម៌ឲ្យជាអារម្មណ៍បានឡើយ ទោះបីប្រកបដោយនូវហេតុឯកហេតុក៏ដោយ គង់ពុំអាចឲ្យផលជាសហេតុកអាវជ្ជនវិបាកចិត្តបានឡើយ នឹងឲ្យផលជាអហេតុកអកុសលវិបាកចិត្ត គឺឧបេក្ខាសហគតសន្តីរណចិត្ត ជាតួតទារម្មណអកុសលវិបាក ជាពួជបដិសន្ធិប្រព្រឹត្តទៅកន្លងអបាយភូមិ ៤ តែប៉ុណ្ណោះ ។

អធិប្បាយអំពីអហេតុកអកុសលវិបាកចិត្ត: ដែ ១ គឺបុព្វាណាកើតឡើង

ញាននេះប្រកបដោយទុក្ខវេទនាជួចគ្នា ។ ទុក្ខសហគតកាយវិញ្ញាណចិត្ត
វិញ្ញាណដែលកាន់ស្រ័យនៅក្នុងកាយទ្វារសំរាប់ដឹងនូវសម្ផស្សផ្សេងដែល
ជាអនិដ្ឋារម្មណ៍ គឺសម្ផស្សរបស់សត្វតិរច្ឆាន មានឆៃសន្ទើចទុំយ
កែបជាដើម ទើសម្ផស្សរបស់មនុស្សតិរច្ឆាន មានមនុស្សកាច
ត្រហីនជាដើម ចូលមកទាំងចិត្តដឹងកាយវិញ្ញាណកាន់ភាក់ងឹកាយទ្វារជាដើម
កាយវិញ្ញាណកាន់ខ្សឹងដឹងច្បាស់នូវសម្ផស្សតិរច្ឆាននោះហើយកើតព្រមជា
មួយទុក្ខវេទនា សោយនូវសេចក្តីជាដុំទារម្មណ៍ ជាទុក្ខសំបាកប្រព្រឹត្តទៅ
ក្នុងកាយទ្វារ ហើយរលត់ទៅវិញ ។ បេក្ខាសហគតសម្បដិច្ឆនចិត្ត វិបាកចិត្ត
កើតឡើងទទួលចាប់យកនូវជាដុំទារម្មណ៍នោះកើតព្រមជាមួយ ។ បេក្ខា
វេទនា ហើយរលត់ទៅវិញ ។ សម្បុរសតិរច្ឆានអកុសលវិបាកមេត្តា
ព្រះអង្គធម្មគប្បីកំណត់ដឹងតាមសេចក្តីអធិប្បាយក្នុងចក្ខុវិញ្ញាណ ទាំងដើម
នេះចុះ គង់ដឹងច្បាស់នូវសេចក្តីអធិប្បាយដោយពិត ខ្ញុំព្រះករុណាបាន
អធិប្បាយអំពីអកុសលវិបាកអហេតុកចិត្តទាំង ៧ ដោយសង្ខេបតែប៉ុណ្ណេះ ។

๓๘ - ធម្មវិទី ទទួលថា សាធុ ។ ម្នាលអត្តវាទី ប្រស្នានេះប្រពៃ
ហើយ ចុះកុសលវិបាកអហេតុកចិត្តទាំង ៨ នោះ សេចក្តីអធិប្បាយយ៉ាង
ដូចម្តេចខ្លះ ? ចូរលោកវិសជ្ជនាទ្បាស្តូតម្រង់មក យើងនឹងបានស្តាប់

ញាននេះប្រកបដោយទុក្ខវេទនាជួចគ្នា ។ ទុក្ខសហគតកាយវិញ្ញាណចិត្ត
វិញ្ញាណដែលកាន់ស្រ័យនៅក្នុងកាយទ្វារសំរាប់ដឹងនូវសម្ផស្សផ្សេងដែល
ជាអនិដ្ឋារម្មណ៍ គឺសម្ផស្សរបស់សត្វតិរច្ឆាន មានឆៃសន្ទើចទុំយ
កែបជាដើម ទើសម្ផស្សរបស់មនុស្សតិរច្ឆាន មានមនុស្សកាច
ត្រហីនជាដើម ចូលមកទាំងចិត្តដឹងកាយវិញ្ញាណកាន់ភាក់ងឹកាយទ្វារជាដើម
កាយវិញ្ញាណកាន់ខ្សឹងដឹងច្បាស់នូវសម្ផស្សតិរច្ឆាននោះហើយកើតព្រមជា
មួយទុក្ខវេទនា សោយនូវសេចក្តីជាដុំទារម្មណ៍ ជាទុក្ខសំបាកប្រព្រឹត្តទៅ
ក្នុងកាយទ្វារ ហើយរលត់ទៅវិញ ។ បេក្ខាសហគតសម្បដិច្ឆនចិត្ត វិបាកចិត្ត
កើតឡើងទទួលចាប់យកនូវជាដុំទារម្មណ៍នោះកើតព្រមជាមួយ ។ បេក្ខា
វេទនា ហើយរលត់ទៅវិញ ។ សម្បុរសតិរច្ឆានអកុសលវិបាកមេត្តា
ព្រះអង្គធម្មគប្បីកំណត់ដឹងតាមសេចក្តីអធិប្បាយក្នុងចក្ខុវិញ្ញាណ ទាំងដើម
នេះចុះ គង់ដឹងច្បាស់នូវសេចក្តីអធិប្បាយដោយពិត ខ្ញុំព្រះករុណាបាន
អធិប្បាយអំពីអកុសលវិបាកអហេតុកចិត្តទាំង ៧ ដោយសង្ខេបតែប៉ុណ្ណេះ ។

๓๘ - ធម្មវិទី ទទួលថា សាធុ ។ ម្នាលអត្តវាទី ប្រស្នានេះប្រពៃ
ហើយ ចុះកុសលវិបាកអហេតុកចិត្តទាំង ៨ នោះ សេចក្តីអធិប្បាយយ៉ាង
ដូចម្តេចខ្លះ ? ចូរលោកវិសជ្ជនាទ្បាស្តូតម្រង់មក យើងនឹងបានស្តាប់

ប្ញាវម្ភណ៍នោះឲ្យសំរេច ហើយកើតសេត់ព្រមជាមួយនឹងបេក្ខាវេទនា សោយនូវសេនៃប្ញាវម្ភណ៍ធំធំនៅក្នុងឥដ្ឋមជ្ឈត្តារម្ភណ៍ ជាកណ្តាលមិនកក្រើក ។ ឯកុសលវិបាកអហេតុកចិត្តទី ២.៣.៤ ក៏មានសេចក្តីអធិប្បាយជាលំដាប់គ្នាដូច្នេះដែរ ។ ត្រង់កុសលវិបាកអហេតុកចិត្តទី ៥ នោះមានសេចក្តីអធិប្បាយថា ចេរដោយឥដ្ឋារម្ភណ៍តាំងពីឆាយដែលជាឥដ្ឋារម្ភណ៍មានសម្ផស្សរបស់មនុស្សជាដើម ធំធំគ្រឿងប្រើប្រាស់ផ្សេងៗ មានសំពត់ អាវ ពួក ភនេ្ធល ខ្លែយជាដើម ចូលមកប៉ះទង្គិចនឹងកាយប្បសាទសុទ្ធសហគតកាយវិញ្ញាណ ក៏កើតខ្សែងភ្លាំងផុសន្ធកិច្ច គឺកិច្ចដែលប៉ះទង្គិចនូវដោដ្ឋារម្ភណ៍ ឲ្យសំរេចហើយកើតសេត់ព្រមជាមួយសុទ្ធវេទនា សោយនូវសេនៃដោដ្ឋារម្ភណ៍ ជាសុទ្ធសប្បាយប្រព្រឹត្តទៅក្នុងកាយទ្វារបេក្ខាសហគតសម្បដិច្ឆន្នចិត្តក៏កើតខ្សែងភ្លាំងសម្បដិច្ឆន្នកិច្ច គឺកិច្ចដែលទទួលចាប់ព្រមនូវដោដ្ឋារម្ភណ៍ឲ្យសំរេច ហើយកើតសេត់ព្រមជាមួយបេក្ខាវេទនា សោយនូវសេនៃដោដ្ឋារម្ភណ៍ធំធំនៅក្នុងឥដ្ឋមជ្ឈត្តារម្ភណ៍ជាកណ្តាលមិនកក្រើក សោមនស្សសហគតសន្តីរណចិត្តក៏កើតខ្សែងភ្លាំងសន្តីរណកិច្ច គឺកិច្ចដែលរិះគិតកំណត់នូវដោដ្ឋារម្ភណ៍ឲ្យសំរេចហើយកើតសេត់ព្រមជាមួយសោមនស្សវេទនា សោយនូវសេនៃ

ដោយផ្លូវមនោទ្វារ ។ កុសលវិបាកអហេតុកចិត្តទាំង ៨ ដួចនេះ ព្រោះតែអារម្មណ៍ខ្លាំងតិចតួចណាស់ រីឯចិត្តកើតឡើងតាមគោលនៃអារម្មណ៍ពុំជាប់ មានទណៈចិត្តតិចតួចជាអាយុនៃរូបធម៌ទាំងឡាយគឺជាអារម្មណ៍ មានទណៈចិត្តកើតឡើង ៩ ទណៈ ១០ ទណៈ ១១ ទណៈប្រព្រឹត្តកន្លងទៅ ហើយមានតែទណៈចិត្ត ៨-៧-៦ ជាអាយុនៃរូបធម៌ទាំងឡាយ សូម្បីវិថីចិត្ត ៣ គឺ តទាលម្ពណៈ ១ ជវនៈ ១ ភវង្គៈ ១ ហើយពុំបានកើតតទៅទៀត ត្រូវតែធ្លាក់ចុះមកតាមទ្វារតែមួយវិញ កុសលចិត្តប្រែបនេះ ពោះបីប្រកបដោយហេតុក៏ដោយ រមែងតែផ្សែផលជាកុសលវិបាកអហេតុកចិត្តតាមធម្មតាដោយពិត ខ្ញុំព្រះករុណាវិសជ្ជនាមកអំពីកុសលវិបាកអហេតុកចិត្តទាំង ៨ ដោយសង្ខេបតែប៉ុណ្ណេះឯង ។

๓๙- ធម្មវិទូ បានស្តាប់ហើយ សួរតទៅទៀតថា ម្នាលអត្តវិចុះអហេតុកវិបាកចិត្តទាំង ៣ នោះ មានសេចក្តីអធិប្បាយដូចម្តេចខ្លះ ? មានសេចក្តីផ្សឹងផ្ទាយយ៉ាងណាខ្លះ ? ចូរលោកវិសជ្ជនាឲ្យពិស្តារសព្វគ្រប់មក យើងនឹងបានស្តាប់ចូលចិត្តអស់សេចក្តីសង្ស័យផងមើល ?

អ្នកឫកិច្ច សៀវភៅអាចារ្យ បណ្ឌិតក្រុមប្រឹក្សា ឯអរហត្តកត្តាវិនិច្ឆ័យ ចំនួន ៣ នោះ សេចក្តីអធិប្បាយថា អរហត្តមគ្គជាតុ ផ្សាយចំហាយ តែសង្កាត់ទ្បើចំរើនទ្បើង ញ៉ាំងវិថីចិត្តទ្បើកតទ្បើងតាមការណ៍ ជ្រាវជ្រាវកន្លងបង្ហូរនូវមនោទ្វារ ឬថាធ្វើអោយការប្រកបមានញ៉ាញ៉ឹមស្រស់ស្រាយជាដើម ឈ្មោះថា អរហត្តកត្តាវិនិច្ឆ័យ ដូចមានសេចក្តីអធិប្បាយដូចតទៅនេះ ៖

ន័យ ១ - បញ្ចទ្វារវិថីចិត្ត ចែកចេញទៅជា ៥ គឺ: ១- ទុបេក្ខាសហគតបញ្ចទ្វារវិថីចិត្ត វិថីចិត្តដែលកើតទ្បើងអំពីកិរិយាមនោធាតុជាស់តឿនតវង្គ អាចញ៉ាំងអាវជ្ជនកិច្ច គឺកិច្ចដែលជ្រាវជ្រាវកន្លងបង្ហូរនូវមុខារម្មណ៍ ដែលចូលមកកាន់ទ្វង់ទ្វារបញ្ចទ្វារ ប៉ះពាល់នឹងបញ្ចប្បសាទទ្បើសំរេចបាន ហើយកើតរលត់ព្រមជាមួយទុបេក្ខាវេទនា សោយន្តរៈនៃមុខារម្មណ៍នឹងនៅជាកណ្តាលមិនកន្ត្រាក ។ ២- ទុបេក្ខាសហគតសោតទ្វារវិថីចិត្ត វិថីចិត្តដែលកើតទ្បើងអំពីកិរិយាមនោធាតុ ជាស់តឿនតវង្គ អាចញ៉ាំងអាវជ្ជនកិច្ច គឺកិច្ចដែលតាមការណ៍ជ្រាវជ្រាវកន្លងបង្ហូរសុតារម្មណ៍ ដែលចូលមកកាន់ទ្វង់ទ្វារប៉ះពាល់នឹងសោតបញ្ចប្បសាទទ្បើសំរេចបាន ហើយកើតរលត់ព្រមជាមួយទុបេក្ខាវេទនា សោយន្តរៈនៃសុតារម្មណ៍នឹងនៅជាកណ្តាល

មិនកក្រែក ។ ៣ - ។បេក្ខាសហគតយោនក្នុកវិជ្ជនចិត្ត រីថិចិត្តដែលកើតឡើងអំពីកិរិយាមនោធាតុជាស់តឿនកវង្គៈ អាចញុំងអោវិជ្ជនកិច្ច គឺកិច្ចដែលពិចារណាជ្រាវរកនូវនន្ធារម្មណ៍ ដែលចូលមកកាន់វង្វង់យោន-ក្នុវចំៈខ្ចប់ធំងយោនឬសាទឲ្យសំរេចបាន ហើយកើតរលត់ព្រមជាមួយ។បេក្ខាវេទនាសោយនូវរសនៃនន្ធារម្មណ៍ធំងនៅជាកណ្តាលមិនកក្រែក។ ៤ - ។បេក្ខាសហគតជវក្នុកវិជ្ជនចិត្ត រីថិចិត្តដែលកើតឡើងអំពីកិរិយាមនោធាតុ ជាស់តឿនកំវង្គអាចញុំងអោវិជ្ជនកិច្ច គឺកិច្ចដែលពិចារណាជ្រាវរកនូវរសារម្មណ៍ ដែលចូលមកកាន់វង្វង់ជវក្នុកវចំៈខ្ចប់ធំងជវក្នុប-សាទឲ្យសំរេចបាន ហើយកើតរលត់ព្រមជាមួយ។បេក្ខាវេទនា សោយនូវរសនៃរសារម្មណ៍ធំងនៅជាកណ្តាលមិនកក្រែក ។ ៥- ។បេក្ខាសហ-គតកាយក្នុកវិជ្ជនចិត្ត រីថិចិត្តដែលកើតឡើងអំពីកិរិយាមនោធាតុជាស់តឿនកវង្គអាចញុំងអោវិជ្ជនកិច្ច គឺកិច្ចដែលពិចារណាជ្រាវរកនូវផាដ្ឋ-ព្វារម្មណ៍ដែលចូលមកកាន់វង្វង់កាយក្នុកវចំៈធំងកាយឬសាទ ឲ្យសំរេចបាន ហើយកើតរលត់ព្រមជាមួយ។បេក្ខាវេទនា សោយនូវរសនៃផាដ្ឋ-ព្វារម្មណ៍ជាកណ្តាលមិនកក្រែក កំមញ្ចក្នុកវិជ្ជនចិត្តទាំង ៥ នេះ ត្រាន់តែពិចារណាជ្រាវរកនូវអារម្មណ៍តែប៉ុណ្ណោះឯង ។

ខ្ញុំ ២ - មនោទ្វារវិញ្ញាណធាតុ ១ បញ្ចទ្វារ ១ បេក្ខាសហគតមនោទ្វារវិញ្ញាណធាតុ ១ ជាមនោទ្វារវិញ្ញាណធាតុ ដែលមានសភាពដឹងច្បាស់តែនូវអារម្មណ៍ដែលមកប៉ះពាល់ដល់ទ្វារ

បញ្ញាទូរនឹងមនោទូរវែកប៉ុណ្ណោះឯង ។

ទី ៣- សោមនស្សសហគតហសិតុប្បាទចិត្តនោះ សេចក្តីអធិប្បាយក្នុងជាតហនចូលថា ហសិតុសទ្ទេ បេតុ សិតវចកោ តំហសិតសទ្ទំ ក្នុងទីនេះប្រែថា ត្រេកអរវែកឆ្ងៃ ញញឹម ស្រស់ប្រឹមប្រើយ បានដល់ព្រះទ័ណាស្រពាំងឡាយវែកម្យ៉ាងប៉ុណ្ណោះ ពុំបានដល់បុថុជ្ជនទីងសេនបុគ្គលពាំងឡាយឡើយ ព្រោះព្រះទ័ណាស្រពាំងឡាយលោកុមានអារម្មណ៍ពុំបានត្រេកត្រេកប្រកបដោយនេក្ខមគុណ លោកមានគុណវិសេសបេញ្ចាកកាមគុណពាំង ៥ ជាជ្រះស្រឡះហើយ ។ លោកបានឃើញនូវចំណែកនៃផែនដីដែលកបបាបល្អជាទីត្រេកអរដ៏សមគួរល្មមតម្កល់នូវព្យាយាមចំរើនព្រះកម្មដ្ឋានជាដើមហើយ លោកគិតថា "អហ្ន៎! ប្រទេសនេះស្អាតល្អគួរដល់ព្រះកម្មដ្ឋានពិត" សោមនស្សសហគតហសិតុប្បាទចិត្តវិថីចិត្តដែលត្រេកអរវែកឆ្ងៃញញឹមស្រស់ប្រឹមប្រើយ កើតឡើងប្រកបដោយសោមនស្សវេទនាសោយនូវរសនៃអារម្មណ៍ជាសុខប្រព្រឹត្តទៅក្នុងសន្តានៃព្រះទ័ណាស្រពាំងដោយពិត ម្យ៉ាងទៀតព្រះទ័ណាស្រពាំងឡាយដែលលោកនឹងត្រេកអរវែកឆ្ងៃដោយកិរិយាចិត្តពាំង ៥ គឺសហេតុកកាមាវចរកិរិយាចិត្ត ដែលប្រកបដោយ

សោមនស្សវេទនា ៤ អហេតុកកិរិយាចិត្តនេះ ១ ត្រូវជាកិរិយាចិត្ត ៥ កើតមាន
ដល់ព្រះខីណាស្រពវាំងឲ្យឃើញមួយចំណែកយ៉ាងប្រសើរដោយពិត ។
ឯហេតុដែលសម្តែងនូវបុគ្គលទី ៥ នេះ ប្រែថា អស់សំណើច សើចភ្លាកឲ្យ
បានដល់បុថុជ្ជនបុគ្គលទីដែលសេ ២ បុគ្គល ចាំងឲ្យឃើញនោះមាន ៦ យ៉ាងគឺ សិតំ
ក្រែកអាញញឹមស្រស់ស្រាយ ១ ហសិតំ អស់សំណើចទើចបបូរមាត់
សំដែងឲ្យមានធ្មេញចេញក្រៅ ១ វិហសិតំ អស់សំណើចសើចលាន់
រំលែកឲ្យមានសំឡេងពីពោះ ១ ឧបហសិតំ អស់សំណើចសើចអង្រួន
ញ័រចាំងក្បាល ១ អបហសិតំ អស់សំណើចសើចហូរចាំងទឹកភ្នែក ១
អបវិហសិតំ អស់សំណើចសើចញ័រគេស្ទាំងខ្លួន ១ អស់សំណើចចាំង ៦
យ៉ាងនេះបានដល់បុថុជ្ជនបុគ្គលទីដែលសេ ២ បុគ្គល ចាំងឲ្យ ដោយពិត
តែថាបុថុជ្ជនចាំងឲ្យអស់សំណើចដោយចិត្តចាំងឲ្យ ៨ គឺអកុសល ។
ចិត្តដែលប្រកបដោយសោមនស្សវេទនា ៤ កុសលចិត្តដែលប្រកបដោយ
សោមនស្សវេទនា ៤ ត្រូវជា ៨ តត់ ។ ដំនុំចិត្តចាំងឲ្យ ៨ នេះ
ចិត្តណាមួយកើតឡើងដល់បុថុជ្ជនចាំងឲ្យ ។ ស៊ីងត្រូវសើចកេះកេយ
ដោយចិត្តនោះជា ហីនៈ យ៉ាងថោកទាប ព្រោះបុគ្គលបុថុជ្ជនចាំងឲ្យ
ហនតាមតណ្ហាជាអារម្មណ៍ ។ ចំណែកខាងសេ ២ បុគ្គល ចាំងឲ្យ

វិញ្ញាណោកវែងត្រែកអរសើចពេរពេយប្រកបដោយចិត្តចាំងឡាយ ๖ គឺ
អកុសលចិត្តជាទិដ្ឋគតវិប្បយុត្ត ច្រាសចេញផុតពីមិច្ឆាទិដ្ឋិ ប្រកបដោយ
សោមនស្សវេទនា ๒ មហាកុសលចិត្តប្រកបដោយសោមនស្សវេទនា ๔
ត្រូវជា ๖ ។ ចំនុំចិត្តចាំង ๖ នេះ ចិត្តណាមួយកើតឡើងដល់សេខបុគ្គល
ចាំងឡាយ ។ សឹងត្រែកអរសើចពេរពេយដោយចិត្តនោះ ជាមជ្ឈិមយ៉ាង
កណ្តាលមិនចាន់ចាំងពេក ព្រោះសេខបុគ្គលចាំងឡាយលោភមានព្រះ
និព្វានជាអារម្មណ៍ដោយពិត ។ ឯព្រះសម្មាសម្ពុទ្ធចាំងឡាយ ព្រះអង្គ
ត្រែកអរសើចពេរពេយស្រស់ស្រាយច្រឹមច្រើយ ប្រកបដោយសហេតុកកាម-
វចរកិរិយាចិត្ត ๘ ដែលប្រកបដោយសោមនស្សវេទនា ។ ជំនុំមហា-
កិរិយាចិត្តចាំង ๘ នេះ . មហាកិរិយាចិត្តណាមួយ កើតឡើងដល់ព្រះ
សម្មាសម្ពុទ្ធចាំងឡាយ ។ សឹងត្រែកអរស្រស់ស្រាយច្រឹមច្រើយដោយមហា
កិរិយាចិត្តនោះយ៉ាងប្រសើរវិសេសខ្ពង់ខ្ពស់ចំផុត ព្រោះព្រះសព្វញ្ញុសម្ពុទ្ធ
ចាំងឡាយ ព្រះអង្គមានគុណសម្បត្តិគឺសព្វញ្ញុតញ្ញាណ ជាអារម្មណ៍
ដោយចំណែកមួយពិត ។ វិសជ្ជនាមកអំពីអហេតុកកិរិយាចិត្តចាំង ๓ ជា
សេចក្តីសង្ខេបតែប៉ុណ្ណេះ ។

๔๐ - ធម្មវាទី ក្រាបទូលហើយពោលថា សាធុ ។ ម្នាលអត្តវាទី

ប្រស្នានេះប្រៀពណា ស់ហើយ តែយើងនៅមានសេចក្តីសង្ស័យតទៅទៀត ព្រោះលោកវិសជ្ជនាគំពីអារម្មណ៍ទាំង៦ឡាយនោះ ត្រង់អារម្មណ៍ទាំង ៥ គឺ រូប សំឡេង ក្លិន រស សម្ផស្សនោះ យើងស្តាប់បានហើយឥតមានសង្ស័យទេ យើងសង្ស័យតែអារម្មណ៍ដែលមានឈ្មោះផ្សេងគ្នាទាំង ៤ គឺឥដ្ឋារម្មណ៍ ១ អនិដ្ឋារម្មណ៍ ១ ឥដ្ឋមជ្ឈត្តារម្មណ៍ ១ អនិដ្ឋមជ្ឈត្តារម្មណ៍ ១ ក៏អារម្មណ៍ទាំង ៤ នេះលោកបានអធិប្បាយមកខ្លះហើយតែពុំទាន់បានសព្វគ្រប់ យើងនឹងជ្រើសរើសសួនឲ្យច្បាស់លាស់ផងពុំទាន់បាន ដូច្នេះបួរលោកវិសជ្ជនាខ្លួនែអារម្មណ៍ទាំង៤យ៉ាងនេះឲ្យបានសេចក្តីពិស្តារសព្វគ្រប់មកម្តងទៀត យើងនឹងស្តាប់ឲ្យបានជ្រើសរើសសួនអស់សេចក្តីសង្ស័យផងមើល ?

អ្នកវិទ្ទិ វិសជ្ជនាតបថា បពិត្រធម្មាចារ្យ ឯអារម្មណ៍ទាំង ៤ នោះ ខ្ញុំព្រះករុណាបានពិនិត្យសង្កេតយកសេចក្តីកងដីកាទីឆអនុដីកា ព្រមទាំងយោជនាព្រះអភិធម្មនោះឃើញ សេចក្តីដូចតទៅនេះ ការម្មណ៍ទី ១ មានចាំល្អីថា តត្ថ កុសលវិបាកកិរិយា រូបាទយោ ឥដ្ឋា សេចក្តីថា បណ្តាអារម្មណ៍ទាំងឡាយនោះ អារម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើម ដែលកើតមកជាកុសលវិបាកដោយពិត បានឈ្មោះថា ឥដ្ឋារម្មណ៍ ជាអារម្មណ៍គួរប្រាថ្នាទាំងឡាយ · មានសព្ទគ្មាតោធិសត្វ ទឹង បរេត-

ខោនដ៏សត្វជារដើម លោកតែងត្រេកអរប្រាថ្នាស្រឡាញ់គាប់ចិត្ត ចំពោះ
តែត្រង់តាំងចិត្តជាម្ចាស់ ឬថាជានាយចៅហ្វាយត្រួតត្រាលើកាមតណ្ហា
ពុំបាននុះរៀងក្នុងអំណាចនៃកាមតណ្ហាដឹកនាំទៀយ ព្រោះអ្នកប្រាជ្ញ
តាំងឡាយនោះលោកជាសម្ចាធិដ្ឋប្រកបដោយវិចារណប្បញ្ញា តែងពិចា-
រណាជ្រើសរើសកំណាត់ដ៏ឆ្ងាស់ប្រាកដជាខ្លួនាមណ៍តាំង៩តួរបៃ សំឡេង
ក្លិន រស សម្ផស្សនោះថា ជាគ្រឿងល្បួងលួងលោមបញ្ឆោតរបស់
មារតាំង៥ មានតំលៃសមារជាដើមទេ តែបុគ្គលណាមួយត្រេកអរប្រាថ្នា
ស្រឡាញ់គាប់ចិត្តនឹកាមារម្មណ៍តាំង៩នេះ ខ្វាំងហួសប្រមាណពេក
មិនប្រព្រឹត្តធម៌សន្តោសត្រេកអរស្មើៗ ដ៏សមគួរតាមលាភហើយ មុខជា
កាខារម្មណ៍តាំង៩នេះ ទីដ៏សម្ងាប់បុគ្គលនោះវិញ បើទុកជាពុំបាន
ដល់ស្លាប់ខ្លួនទេ ក៏គង់ជានសេចក្តីទុក្ខលំបាកអាក្រក់ក្នុងបច្ចុប្បន្ននេះ
មានពាក្យគន្ធហានិន្ទាជាដើម ក្នុងលោកខាងមុខទីដ៏ធ្លាក់ទៅសោយទុក្ខ-
វេទនាក្នុងនរកយកកូមិតាំង៤ជាពុំខាន អ្នកប្រាជ្ញតាំងឡាយ លោកបាន
តិចារណាដ៏ឆ្ងាស់ប្រាកដយ៉ាងនេះហើយ លោកតាំងចិត្តមិនប្រាថ្នា
ត្រេកអរស្រឡាញ់គាប់ចិត្ត ទីដ៏រូប សំឡេង ក្លិន រស សម្ផស្ស តាំង
៥នេះ ខ្វាំងហួសប្រមាណឡើយ លោកតែងប្រតិបត្តិតាមពុទ្ធឧវាទ

ប្រព្រឹត្តធម៌សន្តោស ត្រេកអរស្រឡាញ់គាប់ចិត្តនឹងកាមារម្មណ៍ទាំង ៥ មានរូបារម្មណ៍ជាដើមនេះស្មើ។ សមគួរតាមលាភតិត ប្រកបដោយសោមនស្សវេទនា សោយនូវសេចក្តីសុខក្នុងចិត្ត តែងប្រព្រឹត្តធ្វើការជាកុសលមានលះបង់សេចក្តីលោភមិនកំណាញ់ បរិច្ចាគទ្រព្យធ្វើបុណ្យឲ្យទានជាដើម ហើយអ្នកប្រាថ្នាទាំងឡាយនោះ តែងទ្រាប់អន្ទោលទៅមកសោយសុខក្នុងកន្លែងសុគតិភពទាំង ៧ ជាន់ ដោយច្រើន ឈ្មោះថាឥដ្ឋារម្មណ៍ ជាអារម្មណ៍ទាំងឡាយកើតជាកុសលវិបាកចិត្តដោយពិត ។ អារម្មណ៍ទី ២ មានឆ្លើយថា អកុសលវិបាកកូនាវូចាខយោ អនិដ្ឋា សេចក្តីថា អារម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើមដែលកើតមកជាអកុសលវិបាកចិត្តពិត។ ឈ្មោះថា អនិដ្ឋារម្មណ៍ ជាអារម្មណ៍ គឺអ្នកប្រាថ្នាទាំងឡាយ មានសត្វញ្ញាសោធិសត្តនិងឥឋបច្ចេកសោធិសត្តជាដើម លោកមិនប្រាថ្នាត្រេកអរស្រឡាញ់គាប់ចិត្ត លោកតែងរៀវលែងចេញជាស្រឡះ មិនឲ្យជំពាក់ជាប់នៅក្នុងសន្តានចិត្តរបស់លោកឡើយ ចំណែកឯបុគ្គលពាលទាំងឡាយ ជាមិច្ចាទិដ្ឋិ យល់ឃើញខុស តែងមានចិត្តកើតឡើងយកអនិដ្ឋារម្មណ៍នោះ មកជាឥដ្ឋារម្មណ៍ជាទីប្រាថ្នាត្រេកអរ ស្រឡាញ់ គាប់ចិត្ត និងរូប សំឡេង ក្លិន រស

សម្ផសស្សនោះទៀតវិញ លុះទៅក្នុងអំណាចនៃតាមតណ្ហាដឹកនាំ ជាខ្ញុំបំរើតណ្ហា គឺថា បានរូបមួយហើយប្រាថ្នាចង់បានរូបពីរបីបួន តទៅទៀតជាដើម មិនប្រតិបត្តិតាមពុទ្ធឧវាទ គឺថាមិនប្រព្រឹត្តធម៌សន្តោសត្រេកអរស្មើៗ ឲ្យសមគួរតាមលោកឡើយ ជាបុគ្គលមានចិត្តវិបល្លាសប្រប្រួលគំនិតតិតខ្ពុសរវើរវាងតាន់ប្រឡំតារម្មណ៍ , សំគាល់ថាបុគ្គលអ្នកធ្វើបុណ្យឲ្យទានរក្សាសីលភាវនាជាដើមនេះជាការឥតប្រយោជន៍ ជាបុគ្គលប្រកបដោយ លោភៈ ទោសៈ មោហៈ ពេញទី ប្រព្រឹត្តកំណាញ់មិនបរិច្ចាគប្រព្យឲ្យទាន ឥឹងប្រទូស្តសត្វឥឹងសង្ឃារមិនរក្សាសីល វង្វេងតាន់ប្រឡំតារម្មណ៍មិនចំរើនមេត្តាភាវនាឡើយ ហើយប្រកបដោយស្មោមនស្សវេទនា សោយទុវែសនៃតាមារម្មណ៍ជាសុខសប្បាយក្នុងចិត្ត មានគំនិតស្មុគស្មាញតាមបង្គាប់តណ្ហាដឹកនាំឲ្យប្រាថ្នា ត្រេកត្រអាល់ស្រឡាញ់តាប់ចិត្តតែទង្វើ រូប សំឡេង ក្លិន រស សម្ផសស្ស ដែលជាគ្រឿងទាស់ឥឹងពុទ្ធឧវាទដោយពិតៗ បុគ្គលពាលពាំងឡាយនោះរមែងត្រាច់អន្ទាលទៅមកសោយទុក្ខវេទនាក្នុងអបាយភូមិទាំង ៤ ដោយច្រើន បានឈ្មោះថាអនិដ្ឋារម្មណ៍ជាអារម្មណ៍នាំឲ្យតើតជាអកុសលវិបាកចិត្តដោយពិត ៗ ទី ៣ ឥដ្ឋមជ្ឈត្តារម្មណ៍ មានសេចក្តីអធិប្បាយដូចគ្នានឹងឥដ្ឋារម្មណ៍នោះដែរ ប្លែក

ត្តាតែវេទនា តើជាឥដ្ឋារម្មណ៍ជាសោមនស្សវេទនា ឯឥដ្ឋមជ្ឈត្តារម្មណ៍នេះ
ជាឧបេក្ខាវេទនា ។ សោយទ្វារសនៃអារម្មណ៍ប្រព្រឹត្តទៅជាកណ្តាលនឹង
នៅកន្លែងឥដ្ឋារម្មណ៍មិនកក្រើក គឺជាមិនប្រែប្រួលត្រឡប់ទៅជា សុខ-ទុក្ខ
សោមនស្ស-ទោមនស្សឡើយ ។ ចាត់ឈ្មោះថា ឥដ្ឋមជ្ឈត្តារម្មណ៍
ជាអារម្មណ៍ ទាំងឡាយកើតជាកុសលវិបាកចិត្តដោយពិត ។ ទី ៤- អនិដ្ឋមជ្ឈ-
ត្តារម្មណ៍ សេចក្តីអធិប្បាយ ដូចគ្នានឹងអនិដ្ឋារម្មណ៍នោះដែរ ប្លែកតែផ្នែក
ត្តាតែវេទនា គឺថា អនិដ្ឋារម្មណ៍ជាសោមនស្សវេទនា ឯអនិដ្ឋមជ្ឈត្តារម្មណ៍
ជាឧបេក្ខាវេទនា ។ សោយទ្វារសនៃអារម្មណ៍ ប្រព្រឹត្តទៅជាកណ្តាលនឹង
នៅកន្លែងអនិដ្ឋារម្មណ៍មិនកក្រើក គឺជាមិនប្រែប្រួលត្រឡប់ទៅជា សុខ-ទុក្ខ-
សោមនស្ស-ទោមនស្សឡើយ ចាត់ឈ្មោះថាអនិដ្ឋមជ្ឈត្តារម្មណ៍ ជា
អារម្មណ៍ ទាំងឡាយកើតជាអកុសលវិបាកចិត្តដោយពិត ។ ខ្ញុំអត្ថាធិ
ចាត់អធិប្បាយអំពីអារម្មណ៍មានឈ្មោះផ្សេងគ្នាចាំងំ ៤ ដោយសង្ខេបមក
តែប៉ុណ្ណោះ ។

៤១- ធម្មវាទី ចាត់ស្តាប់ហើយសោសថា ម្នាលអត្ថាធិ អារម្មណ៍
ដែលមានឈ្មោះផ្សេងគ្នាចាំង ៤ ដែលលោកសែដ្ឋនាមកនេះ យើង
ស្តាប់ចាត់ហើយ តែយើងនៅមានសង្ស័យនឹងអារម្មណ៍ចាំង ៦ កន្លែងមាន-

វចវចិត្តតទៅទៀត គឺរូបាវម្មណ៍ ១ សទ្ទារម្មណ៍ ១ គន្ធារម្មណ៍ រសារម្មណ៍ ១ ផោដ្ឋព្វារម្មណ៍ ១ ធម្មារម្មណ៍ ១ ត្រូវជា ៦ គឺរូប សំឡេង ក្លិន រស សម្ផស្ស ធម៌ ដូចម្តេច ក៏ឈ្មោះថាអារម្មណ៍ ។ សព្វនេះ តើអធិប្បាយថាដូចម្តេច? ម្យ៉ាងទៀត ធម្មសព្វ ក្នុងកុសលត្តិកមាតិកាយើងបានសួរឈ្មោះលោកសៃជ្ជនាមករួចហើយ ចុះធម្មសព្វ ក្នុងធម្មារម្មណ៍ កាមាវចរចិត្តនេះ មានសេចក្តីអធិប្បាយដូចធម្មសព្វ ក្នុងកុសលត្តិកមាតិកានោះដែរ ឬផ្សេងគ្នាដូចម្តេចខ្លះ? ចូរលោកសៃជ្ជនាឲ្យពិស្តារសេចក្តីគ្រប់មក យើងនឹងបានស្តាប់ចូលចិត្តផងមើល ?

អត្ថវិទី សៃជ្ជនាតបថា បពិត្រធម្មវាទី ក្នុងចូលីអដ្ឋកថា ដីកាអនុដីកា ព្រមទាំងយោជនាព្រះអភិធម្ម លោកសំដែងសេចក្តីពន្យល់ថា រូប សំឡេង ក្លិន រស សម្ផស្ស ធម៌នេះ លោកកំណត់ឲ្យឈ្មោះជាពីរគឺ អារម្មណៈ ១ អារម្មណៈ ១ ។ ឥ ឲ ១ អារម្មណៈ នោះមានចូលីបទវិគ្រោះថា ចិត្តចេតសិកេហិ អារម្មីយតី,តំ> អារម្មណំ សេចក្តីថា វត្ថុទាំង ៦ មានរូបវត្ថុជាដើមឯណា ដែលចិត្តនិងចេតសិកទាំងឡាយ ចាប់តោងជាប់ជាកំឡាំង ហេតុនោះវត្ថុទាំង ៦ នោះបានឈ្មោះថា អារម្មណៈ ជាធម្មជាតសម្រាប់ចិត្តនិងចេតសិក ចាប់តោងជាប់ជាកំឡាំង

ទើបកើតខ្សឹងជាន មានសេចក្តីឧបមាដូចបុរសទ្វិន មានកំឡាំងថយពន់
ភាគជាអ្នកឯបុរសទ្វិនមានកំឡាំងថយយ៉ាងនេះហើយដែលនឹងក្រោកឈរ
ខ្សឹងបាត់នៅនឹងជានោះ លុះតែជានអាស្រ័យនឹងខ្សែផ្តាប្តូរខ្សែគ្រឹត្រ
ដែលបុគ្គលជានចងសំយុងចុះមកឲ្យទើបយកដៃចាប់តាងនូវខ្សែផ្តាប្តូរខ្សែ
គ្រឹត្រនោះ ហើយទំប្រឹងព្យាយាមចាប់ស្រាវតាមខ្សែនោះក្រោកឈរខ្សឹង
ទើបបាត់នៅនឹងជាន ដើខ្សែនោះមានកំឡាំងជាប់មាំមួន បុរសដែលចាប់
តាងនូវខ្សែក៏ឈរបាត់នៅនឹងជានយូរដែរ ដើខ្សែនោះមិនជាប់មាំមួន ត្រូវ
ផុយជាប់ទៅហើយ បុរសដែលចាប់តាងនូវខ្សែឈរនោះ ក៏នឹងដួល
ធ្លាក់ចុះមកអង្គុយកន្ទក់ន្ទែងរបស់ខ្លួនវិញជាដែល មានសេចក្តីឧបមា
យ៉ាងណា ឯតាម្មណ៍ទាំង ៦ ដូចខ្សែដែលបុគ្គលចងសំយុងចុះទ្រុងប៉ន្មាន
បសាទទាំង ៦ មានចក្ខុប្បសាទជាដើម ចិត្តនឹងចេតសិកដូចបុរសទ្វិនមាន
កំឡាំងថយទំប្រឹងចាប់តាងនូវខ្សែតីតាម្មណ៍ទាំង ៦ តាម្មណ៍ណាមួយ
ចាប់ស្រាវតាមខ្សែតីតាម្មណ៍នោះ ទំក្រោកឈរខ្សឹងបាត់នៅនឹងជានតាម
កម្លាំងនៃតាម្មណ៍ជាលំដាប់ដោយពិត ដើតាម្មណ៍ធំមានកម្លាំងខ្លាំងចិត្ត
នឹងចេតសិកក៏ចាប់តាងយកជាតាម្មណ៍បាត់នៅនឹងជានយូរ ដើតាម្មណ៍
តូចមានកម្លាំងខ្សោយ ចិត្តនឹងចេតសិកចាប់តាងយកជាតាម្មណ៍បាត

នៅនឹងយូរពុំបាន នឹងដាច់ចេញពីអារម្មណ៍ភ្លាត់ចុះមកកាន់ភូវតវត្ថុវិញ
ដដែល មានសេចក្តីឧបមេយ្យដូចបុរសខ្វិននោះឯង ទើបគប្បីមានវាក្យ
ពាំង ៦ ថានឈ្មោះថាធម្មជាតសំពាប់ចិត្តនឹងចេតសិកឲ្យចាប់តោងកើតឡើង ។
ខ ២ អារម្មណ:នោះ មានបាលីបង្ហាញវិគ្រោះថា ចិត្តចេតសិកានិ អាគន្ត្វា
ឯត្ថ រម្មន្តីតិ > អារម្មណំ សេចក្តីថា ចិត្តនឹងចេតសិកទាំងឡាយ មកហើយ
ក្រែកអរក្នុងរូបវត្ថុជារមណីយនេះ ហេតុនោះ រូបវត្ថុជារមណីយនោះបាន ឈ្មោះ
ថាអារម្មណ៍ ជាគ្រឿងមកក្រែកអរនៃចិត្តនឹងចេតសិក គឺថា រូបប្បសាទ
កាន់ភ្នែកក្តី បាន់ភ្នែកក្តី ចក្ខុវិញ្ញាណក្តី ចក្ខុផស្សៈក្តី ចក្ខុវេទនាក្តី
កាន់ភ្នែកក្តី ចក្ខុសម្បយុត្តធម៌ទាំងឡាយក្តី ចូលទៅកាន់ភ្នែកក្តី ។ សោតប្បសាទ
កាន់ត្រចៀក ឃានប្បសាទ ជិវ្ហាប្បសាទ កាយប្បសាទ មនោប្បសាទ ចំរុះនឹង
បសាទនោះៗ ព្រមទាំងវិញ្ញាណ ផស្សៈ វេទនា សម្បយុត្តធម៌ទាំងឡាយ
ក៏កើតឡើងមកតាមភូវតវត្ថុនោះៗ ខន្ធទាំងក្រែកអរនឹងរូប សំឡេង ក្លិន រស
ផោដ្ឋព្វៈ ធម្មារម្មណ៍នោះៗឯង ទើបបានឈ្មោះថាអារម្មណ៍ រូបវត្ថុជារមណីយ
ជាគ្រឿងមកក្រែកអរនៃចិត្តនឹងចេតសិកជាយថាតថៈ ។ ឯធម្មសព្ភាវក្នុង
ធម្មារម្មណ៍ជាកាមាវចរចិត្តនេះ សេចក្តីអធិប្បាយមិនបានដូចធម្មសព

ក្នុងកុសលត្តិកមាតិកានោះទេ ព្រោះធម្មសព្វកុងកុសលត្តិកមាតិកានោះ
លោកចំពោះយកសភាវៈបាត ជាធម្មជ្រុជ្រុងសព្វគាំងឡាយមិនឲ្យក្លាក់ប្លុះ
ទៅក្នុងអង្គ ៤ និងកុងវដ្តទុក្ខដោយពិត តំធម្មសព្វកុងធម្មារម្មណ៍នេះ
លោកចំពោះយកព្រះបរិយត្តិធម៌ ដែលប្តូរលបានជ្រុជ្រុងចាំទុកក្នុងសន្តាន
ខ្លួនដោយសមគួរតាមសភាពពិត ដូចមានបទវិគ្រោះថា ធម្មតិ យថា
សភាវៈតោ តំ > ធម្មោ សេចក្តីថា (សភាវៈណា) ដែលអ្នកប្រាជ្ញបាន
ជ្រុជ្រុងចំណាំចាំទុកដោយសមគួរតាមសភាពពិត (សភាវៈនោះឯង)
បានឈ្មោះថាធម្មោ គឺសភាវៈដែលអ្នកប្រាជ្ញបានជ្រុជ្រុងចំណាំចាំទុក
កុងចិត្តដោយសមគួរតាមសភាពពិត ធម្មោ ឯវ អារម្មណំ > ធម្មារម្មណំ
ធម៌មែនពិត ជាទីបកប្រែកវៃចិត្តនិងចេតសិកថាឈ្មោះថាធម្មារម្មណ៍
សេចក្តីអធិប្បាយថា សម្បុរសចាំងឡាយដែលមានសេចក្តីប្រាថ្នាចង់ឲ្យ
សូម្បីរម្ងាប់ជាបធម៌ ហើយទំប្រឹងព្យាយាមស្តាប់ធម្មសវនៈទន្ទេញធម្ម-
សព្វជ្រុជ្រុងចំណាំចាំទុកធម្មសកុងចិត្ត ហើយទំរៀនប្រែត្រង់រៃគិតជញ្ជឹង
ពិចារណាយកសេចក្តីអត្ថសំពោរតាមធម្មសដែលខ្លួនបានជ្រុជ្រុងទុក
ជាហើយ ប៉ែបានចាំធម្មសគឺសេចក្តី បានកំណាត់ដំងឡាស់អត្ថស
ព័ន្ធសេចក្តីពិតប្រាកដហើយទំព្យាយាមប្រតិបត្តិតាមឲ្យសមគួរដល់ធម្ម-

វេទនាឯអត្តសោនោះឯង ឋានឈ្មោះថាធម្មារម្មណ៍ តាមវចនកុសលចិត្ត
ចាប់យកធម៌ជាតារម្មណ៍ ត្រូវខ្ញុំនឹងជាឥដ្ឋារម្មណ៍តាមនុយនៃព្រះជ្ឈា
នឹងកើតជាតាមវចនកុសលវិបាកដោយពិត បើមិនបានប្រតិបត្តិតាមឲ្យសម
គួរដល់ធម្មវេទនាឯអត្តសោនោះទេ គង់ឋានឈ្មោះថាធម្មារម្មណ៍ដែរ តែថា
ឋានខាងតាមវចនអកុសលចិត្តចាប់យកធម៌ជាអនិដ្ឋារម្មណ៍ មិនបានត្រូវ
តាមនុយនៃព្រះជ្ឈា នឹងកើតហើយអកុសលវិបាកអហេតុកចិត្តពិត ។ មួយទៀត
វិញទៀត ក្នុងគម្ពីរអដ្ឋសាលិនី អដ្ឋកថាអតិធម្មសង្គណី លោកសំដែង
ចំពោះយកឋានទាំង ៣ យ៉ាង គឺជីវិតឋាន ១ ឋានឋាន ១ វេទនា ១
ដែលសម្តេចព្រះអនន្តញ្ញាណជាម្ចាស់ ព្រះអង្គទ្រង់អនុញ្ញាតឲ្យកុំកុសង្ឃ
ខ្លួលត្រកអនាថ៌បានផង ព្រះអង្គទ្រង់អនុគ្រោះដល់ឋាយតាយតាំង
ទាំងឡាយ ដែលមានសទ្ធាបានបរិច្ចាគទ្រព្យធ្វើបុណ្យឲ្យទានបានផល-
និសង្សច្រើនដ៏ឥតដ៏ឥស់ផង ដូចមានសេចក្តីអធិប្បាយតទៅនេះ ។

ទី ១- គឺឲ្យទានកត្តទាំង ១៨ ដែលជាគ្រឿងចិញ្ចឹមជីវិតដល់កុក្ខ-សាម-
ណេរទាំងឡាយ ដែលបានបួសក្នុងព្រះពុទ្ធសាសនានេះថានឈ្មោះថា
ជីវិតទាន ឯកត្តទាំង ១៨ នោះគឺ: ១- សង្ឃកត្ត កត្តាហារដែលឋាយត
តាយតាំងឡាយ ថានថាត់ថែងចង្ហាន់ដំណែងតបំពោះព្រះកុក្ខសង្ឃ

ដែលនិមន្តមកអំពីទិសទាំង ៤ ខ្លួលចង្ហាន់បិណ្ឌបាតឥតកំណត់ ។
๒- ទុតិយភត្ត ភត្តាហារដែលគេយកមកយើងាំង្វាយ បាននាត់
ចែងចង្ហាន់បិណ្ឌបាតបំពេញកិច្ច ឬតិយទីដែលគណៈសង្ឃទាំងពីរពួកបាន
ចាត់ឲ្យមកខ្លួលចង្ហាន់បិណ្ឌបាតសមគួរតាមពាក្យគេយកនិមន្ត ។
៣- និមន្តភត្ត ភត្តាហារដែលគេយកមកយើងាំង្វាយ បានចូលមក
កាន់ភេនិធានក្នុងអាគម ហើយកាន់យកចុត្រលោកឥតបំពេញរួប យក
ទៅចាត់ជាក់ចង្ហាន់បិណ្ឌបាតប្រគេនសង្ឃ ចំណែកខាងភិក្ខុសង្ឃបាន
ដឹងហើយក៏ចេញ ៧ខ្លួលចង្ហាន់បិណ្ឌបាត សំគាល់តាមចាត្រមេស
ខ្លួន ។ ៤- សលាកភត្ត ភត្តាហារដែលគេយកមកយើងាំង្វាយ
បានផ្ទីស្លាកជាក់ឈ្មោះខ្លួន ព្រមទាំងទីលំនៅ ហើយបូលមកកាន់វត្ត
រួចគាំងប្រដុំលោកចាប់ស្លាក(១) លុះត្រឹកឡើងលោកក៏និមន្តទៅខ្លួល
ចង្ហាន់បិណ្ឌបាតតាមស្លាកមេសខ្លួន ។ ៥- បក្ខិកភត្ត ភត្តាហារដែល
គេយកមកយើងាំង្វាយ បាននាត់ចែងចង្ហាន់បិណ្ឌបាតបំពេញព្រះ

๑- ក្នុងព្រះវិនយធរសិក្ខាបទគេយកមកយើង យកស្លាកទៅឲ្យលោកចាប់ពេលព្រឹក
បានហើយនាំលោកទៅខ្លួលភត្តឯផ្ទះក៏បាន ។ បើមានភត្តបម្រុងមកស្រេចឲ្យលោកចាប់ស្លាក
ហើយប្រគេនភត្តក្នុងវត្តក៏បាន បានឈ្មោះថាសង្ឃឆាន់ក្នុងណាគាន់ដូចគ្នា ។

សង្ឃកម្ម សុក្កបក្ខឬកាឡបក្ខ តែកន្លះទៃទាំងខ្នើតឬទាំងរនោចមួយបក្ខ។ (១)
តាមសទ្ធា ។ ៦- ឧបោសថកម្ម កត្តាហារដែលតាយកតាយិកាតាំងឡាយ បានសមាទានឧបោសថរួចហើយចាត់ចែងឆ្ងាន់បិណ្ឌបាត បំពោះកិច្ចសង្ឃតែក្នុងថ្ងៃឧបោសថក្នុងមួយទៃ ។ អស់ពេល ២ ដង ៤ ដង ៨ ដង តាមថ្ងៃឧបោសថដ៏សមគួរតាមសទ្ធា ។ ៧- ចាដិបទិកកម្ម កត្តាហារដែលតាយកតាយិកាតាំងឡាយ បានចាត់ចែងឆ្ងាន់បិណ្ឌបាត បំពោះព្រះកិច្ចសង្ឃក្នុងថ្ងៃ ១ កើតឬថ្ងៃ ១ រោច ជាកម្មដែលព្រះពុទ្ធទ្រង់សរសើរថាជាកម្មដ៏ធ្ងន់មានផលានិសង្សច្រើន ។ ៨- តិលានកម្ម កត្តាហារដែលតាយកតាយិកាតាំងឡាយ បានចាត់ចែងឆ្ងាន់បិណ្ឌបាត បំពោះព្រះកិច្ចសង្ឃដែលមានជម្ងឺអាពាធតែម្យ៉ាង ។ ៩- គិលានុបដ្ឋាកកម្ម កត្តាហារដែលតាយកតាយិកាតាំងឡាយ បានចាត់ចែងឆ្ងាន់បិណ្ឌបាតបំពោះកិច្ចឧបដ្ឋាកសាមណេរ ដែលបំរើជម្ងឺកិច្ចអកអាពាធតែម្យ៉ាង ។ ១០- គមិកកម្ម កត្តាហារដែលតាយកតាយិកាតាំងឡាយ បានចាត់ចែងឆ្ងាន់បិណ្ឌបាត បំពោះព្រះកិច្ចសង្ឃដែលមានកិច្ចរៀបចំដំណើរទីដ៏ចេញទៅកាន់ទីឆ្ងាយ ។ ១១- អាគន្តុកកម្ម កត្តាហារដែល

១- ពីថ្ងៃបាដិបទ អដ្ឋមី ចាតុទ្ទសី បណ្ណរសីឧបោសថ ខ្នើត ៤ ថ្ងៃ រនោច ៤ ថ្ងៃ ។

ខាយកតាយិកាទាំងឡាយ បានចាត់ចែងចង្ហាន់បិណ្ឌបាតចំពោះព្រះ
ភិក្ខុសង្ឃដោតាគន្តុកៈ ដែលទើបទទឹងនិមន្តមកដល់ថ្មីៗ ។ ១២- ជុវកត្ត
កត្តាហារដែលតាយកតាយិកាទាំងឡាយ បានចាត់ចែងចង្ហាន់បិណ្ឌ-
បាត មួយសំពាប់ប្តីរសំពាប់ ចំពោះព្រះភិក្ខុសង្ឃក្នុងវត្តមួយៗ ពាល់ៗថ្ងៃ
តុំបានដាច់ ។ ១៣- តុដិកត្ត កត្តាហារដែលតាយកតាយិកាទាំង-
ឡាយ បានបវារណាហើយចាត់ចែងចង្ហាន់បិណ្ឌបាតចំពោះភិក្ខុសង្ឃ
ឬសាមណេរ ដែលបានមកនៅកឋិនតុដិ ដែលខ្លួនបានកសាងទុកក្នុង
ព្រះពុទ្ធសាសនា ។ ១៤- ឯរកត្ត កត្តាហារដែលតាយកតាយិកា
ទាំងឡាយ បានចាត់ចែងដាក់វេនផ្ទាស់ប្តូរគ្នា ម្ពងត្រង់ផ្ទះអកឯណោះ ម្ពង
ត្រង់ផ្ទះអកឯណោះ ចំពោះភិក្ខុសង្ឃ-សាមណេរដែលនៅកឋិនវត្តមួយៗ ។
១៥- វិហារកត្ត កត្តាហារដែលតាយកតាយិកាទាំងឡាយ បាន
ចាត់ចែងចង្ហាន់បិណ្ឌបាតចំពោះភិក្ខុសង្ឃសាមណេរដែលនៅកឋិនវត្តមួយៗ
បានឆាន់គ្រប់គ្រាន់បរិបូណ៌ទាំងអស់ ។ ១៦- បត្តកត្ត កត្តាហារ
ដែលតាយកតាយិកាទាំងឡាយ បានចាត់ចែងចង្ហាន់បិណ្ឌបាតចំពោះ
ភិក្ខុសង្ឃបួនៗអង្គ ដែលខ្លួនបានសូមមកអំពីគណសង្ឃៗបានចាត់មកឲ្យ
ខ្លួនចង្ហាន់បិណ្ឌបាតនៅផ្ទះខ្លួនពាល់ៗ ថ្ងៃតុំបានដាច់ ។ ១៧- អដ្ឋ-

ភត្តក្ខ ភត្តហារវេលាយាគុភត្តយាគុខាទនីយ ជាទិតាវកាលបញ្ចាន់ បិណ្ឌបាតចំពោះភិក្ខុសង្ឃទ្រាំបីរូបវេលាខ្លួនបានសួរមកអំពីគណៈសង្ឃ បានចាត់មកឲ្យខ្លួលបញ្ចាន់បិណ្ឌបាតនៅផ្ទះខ្លួនពាល់ ๆ ថ្ងៃ តុំបានជាប់ ។

๑๘- គុឡភត្ត (๑) ភត្តហារវេលាយាគុភត្តយាគុខាទនីយ បានចាត់បែងភត្តលាយដោយស្ករគំរៅមានជាយដំណើប បបរស្ករនំលតជាដើម ចំពោះភិក្ខុសង្ឃ សាមណេរវេលានៅភត្តវត្តមួយ ๆ តាមសទ្ធា ។ ឯាយាគុភត្តយាគុខាទនីយ បានទឹកត្រកដល់ព្រះធម៌តីព្រះសុគតោវាទ ធីដ្ឋាតុញ្ញាតនេះជាអារម្មណ៍. តាមវិបរក្ខុសលចិត្តកំតើតឡើង ជំនុំភត្តទាំង ๑๘ នោះ ក្នុងភត្តណាមួយ ហើយមានសេចក្តីជ្រះថ្លាបានបរិភោគទ្រព្យធ្វើបុណ្យឲ្យទានភត្តនោះ ។ ចំពោះព្រះភិក្ខុសង្ឃថានឈ្មោះថាជីវិតទានដោយឯក ។

ទី ๒ - បាឋទាន ឲ្យទានទឹកបានទាំង ๘ មានទឹកស្វាយពុំជាដើម ចំពោះភិក្ខុសង្ឃ សាមណេរ ថានឈ្មោះថាបានទាន ។

ទី ๓ - វិសទាន ឲ្យសេទឹកគេសជ្ជៈទាំង ๕ យ៉ាងមានទឹកសម្បៅ

๑- គុឡភត្ត ក្នុងវិនយធរសិក្ខាបទថា គុឡសត្តនេះ ប្រែថាអង្គញ់ថានផលភត្តដែលទាយកទាយិកាថានថវៃងរូចហើយចូលទៅក្នុងវត្ត ធ្វើស្អាតមិនទាន់ហើយយកអង្គញ់មកចែកឲ្យភិក្ខុសង្ឃទាំងអស់ហើយប្រគេនភត្តតាមអង្គញ់នោះ ថានឈ្មោះថាសុទ្ធតែទាក់ណាទានខ្លួនឯង ។

ឱឯនវនីតជាវដ្ដ ចំពោះកិក្ខុសង្ឃ - សាមណេរ បាននាំយកទៅថ្វាយ - ទាន ។ ក៏បានទានធំរសទានទាំងពីរយ៉ាងនេះលោកពប់បញ្ចូលក្នុងកន្លែងសង្ឃទានដោយចេតិត ។ បុគ្គលដែលបានធ្វើកវត្ថុដល់ពុទ្ធទាំង ៣ ឡាយនេះជាអារម្មណ៍ ហើយមានសេចក្តីគេញចិត្តធំឯទានណាគាមវិចរកុសលចិត្តកំរើតរឡើង បរិច្ចាគទ្រព្យធ្វើទាននោះឯង បានឈ្មោះថាធម្មារម្មណទាន ឲ្យទានបរមត្ថមានធម៌ជាអារម្មណ៍ដោយចេតិត ។ ខ្ញុំអត្តភាពី បានវិសជ្ជនាមកអំពីអារម្មណ៍ទាំង ៦ ដោយសង្ខេបតែប៉ុណ្ណោះ ។

๔๒ - ធម្មវិទូ បានស្តាប់ហើយពោលថា ម្នាលអត្តភាពី យើងបានបុច្ឆាវិសជ្ជនាគ្នាអំពីអារម្មណចិត្តទាំង ៣០ គឺអកុសលចិត្ត ១២ ដោយសង្ខេប អហេតុកចិត្ត ១៨ ដោយពិស្តារ ព្រមទាំងអារម្មណ៍ ៥-៤-៦ ជាសេចក្តីពិស្តារខ្លះ សង្ខេបខ្លះ ល្មមស្តាប់បានហើយ ឥឡូវនេះយើងនឹងសួរលោកអំពីសោភណចិត្ត ៥៩ ដែលជាចិត្តប្រកបដោយហេតុមានពន្ធឹសើរឯរឿងល្អតទៅទៀត ។ ចុះសោភណចិត្តទាំង ៥៩ នោះមើលចែកជាកុសលតាមភូមិមានចំនួនប៉ុន្មាន ? ចែកជាវិបាកចិត្តតាមភូមិមានចំនួនប៉ុន្មាន ? ចែកជាកិរិយាចិត្តតាមភូមិមានចំនួនប៉ុន្មាន ? ចូរលោកវិសជ្ជនា

បែកចំនួនចិត្តនេះតាមពួកឲ្យសព្វគ្រប់មកមើល ?

អ្នកវិទ្ធិ វិសជ្ជនាកបថា ម៎តាត្រូវធម្មវាទី ឯសោភណចិត្តទាំង ៤៨ នោះព្រះបរមគ្រូជាម្ចាស់ព្រះអង្គទ្រង់ត្រាស់សម្តែងបែកជា កុសលចិត្ត ៦១ គឺកាមាវចរកុសលចិត្ត ៨ រូបាវចរកុសលចិត្ត ៥ អរូបាវចរកុសលចិត្ត ៤ លោកុត្តរកុសលចិត្ត ៤ ត្រូវជា ៦១ បែកជាវិបាកចិត្ត ៦១ គឺកាមាវចរ-វិបាកចិត្ត ៨ រូបាវចរវិបាកចិត្ត ៥ អរូបាវចរវិបាកចិត្ត ៤ លោកុត្តរវិបាកចិត្ត ៤ ត្រូវជា ៦១ បែកជាកិរិយាចិត្ត ១៧ គឺកាមាវចរកិរិយាចិត្ត ៨ រូបាវចរកិរិយាចិត្ត ៥ អរូបាវចរកិរិយាចិត្ត ៤ ត្រូវជា ១៧ ព្រោះលោកុត្តរកិរិយាចិត្តពុំមានទេ។ បពិត្រមេចិត្តទាំងអស់ត្រូវជាសោភណ-ចិត្ត ៤៨ តត់ ។ ខ្ញុំអត្ថាទី បានវិសជ្ជនាមកអំពីសោភណចិត្តបែកទៅតាមពួកចិត្ត ជាកុសលចិត្ត ជាវិបាកចិត្ត ជាកិរិយាចិត្ត ដោយសង្ខេបតែប៉ុណ្ណេះឯង ។

៤៣- ធម្មវិទ្ធិ ពុទ្ធស្តាប់ហើយពោលថា អើ ! អត្ថាទី លោកបានវិសជ្ជនាចំណែកសោភណចិត្តទាំង ៤៨ តាមពួកចិត្ត កំត្រឹមត្រូវពិតមែនហើយ តែយើងនឹងសួរលោកតទៅទៀត ។ ត្រង់ចិត្ត-សព្ទនេះ យើងបានសួរឲ្យលោកវិសជ្ជនាមកប្លែកហើយ យើងឥតមាន

សង្ស័យទេ ឃើងសង្ស័យតែត្រង់ចិត្តតែមួយហើយឲ្យឈ្មោះផ្សេងគ្នាថា បីយ៉ាង ថាកុសល ថាវិបាក ថាកិរិយានេះ តើមានសេចក្តីផ្សេងគ្នាយ៉ាងណាខ្លះ? អធិប្បាយថាដូចម្តេចខ្លះ? មានសេចក្តីឧបមាដូចពួកអ្វីខ្លះ? គួរលោកវិសជ្ជនាឲ្យពិស្តារសព្វគ្រប់មកយើងទាំងបានស្តាប់ចូលចិត្តជាមិនមើល?

អត្ថវិទី វិសជ្ជនាតបថា បពិត្រធម្មវាទី ត្រង់ចិត្តតែមួយឲ្យឈ្មោះផ្សេងគ្នាជាញយ៉ាងនោះដូចេ្នះត្រង់ឈ្មោះថាកុសលនោះ សេចក្តីអធិប្បាយពិស្តារថាចិត្តព្រមទាំងសោភណារចេតសិកប្រជុំគ្នា តើតរឡែងព្រមជាមួយគ្នា មានអារម្មណ៍តែ ១ មានវត្ថុតែ ១ ដ៏ភ្លឺស្វាងរុងរឿងល្អ មានបញ្ញាធ្វើវាសវាងវៃអាចប្រតិកាត់នូវអំពើបាបធម៌ ដឹកត្រង់ណាមកដែលបណ្ឌិតអប្បីត្តិមតិអំពើបាបធម៌ដែលបុគ្គលធ្វើប្រកបដោយលោភៈ សេចក្តីលោភចង់បានហួសប្រមាណ ទោសៈ សេចក្តីក្រោធខឹងប្រទូស្តសត្វទាំងសង្សារ មោហៈ សេចក្តីវង្វេងភាន់ច្រឡំអារម្មណ៍ លះបង់ខាលចេញជាស្រឡះ ហើយទំាក្សាយាមចំរើន អលោភៈ អទោសៈ អមោហៈ ឲ្យតែតមានប្រឹនឡើងក្នុងសន្តានខ្លួន អាចបង្កើតព្រឹត្តិធ្វើបុណ្យឲ្យទាន សមាទានក្សាសីល ៥ សីល ឧបោសថ ប្រកបព្រមដោយ

អដ្ឋ ៨ នីឯចំរើនសមថកម្មដ្ឋានជាដើមបានឈ្មោះថាកុសលចិត្ត ។ ត្រង់ថា
វិបាកនោះ សេចក្តីថា វិថីចិត្តដែលចាប់គោចយកនូវផលនៃអំពើជាឥដ្ឋា-
រម្មណ៍ដែលកុសលជវនៈបានសោយសំរេចហើយជាប់មកក្នុងសន្តានខ្លួន
បាននឹងឈ្មោះថាវិបាកចិត្ត ប្តូថាតទាលម្ពណៈក៏បាន ។ ត្រង់ថាកិរិយានោះ
សេចក្តីថា វិថីចិត្តដែលធ្វើផលគឺកិត្តិគុណសព្វឲ្យល្បីផ្សាយទៅ
កាន់ទិសផ្សេង ។ បាននឹងឈ្មោះថាកិរិយាចិត្ត ដូចមានសេចក្តីឧបមាក្នុង
អដ្ឋកថា លោពសំដែងពន្យល់ថា ធម្មតាផ្កាឈើទាំងឡាយដែលកើត
មានឡើងក្នុងលោកនេះមិនដូចគ្នាទេ ព្រោះផ្កាឈើដែលគ្រាន់តែមាន
ពណ៌និងសណ្ឋានល្អផ្សេង ។ ឥតក្លិនក្រអូបច្រើនជាអនេក ឈើដែល
មានផ្កាមានពណ៌និងសណ្ឋានល្អផ្សេង ។ ហើយមានក្លិនក្រអូបផងតិចពន់
ពេកណាស់ មានសេចក្តីឧបមាយ៉ាងណា ឯកុសលចិត្តដូចប្រឌ្ឋា វិបាក-
ចិត្តដូចពណ៌និងសណ្ឋានល្អផ្សេង ។ បេស់ផ្កា កិរិយាចិត្តដូចខ្យល់សំពាប់
ធ្វើក្លិនក្រអូបបេស់ផ្កាឲ្យផ្សាយចេញទៅកាន់ទិសទាំងពួង គឺថាបុគ្គល
ទាំងឡាយឯណាដែលមានកុសលចិត្តតិច វិបាកចិត្តដែលជាផលកើត
មកអំពីកុសលក៏តិចដែរ ដូចផ្កាឈើទាំងឡាយដែលឥតក្លិនមានតែពណ៌
និងសណ្ឋានល្អផ្សេង ។ តុំមានក្លិនក្រអូបផ្សាយទៅកាន់ទិសទាំងពួង

ទៀត ប៉ុគ្គលខ្លាំងខ្លាយនោះមានច្រើនជាអនេក តើតទៀតក្នុងលោកនេះមានតែរូបមានតែពណ៌ទឹងសណ្ឋានល្អផ្សេង ។ ឥតកិរិយាចិត្តពុំមានវែចិត្ត ដែលទឹងធ្វើក្តីតិគុណសព្វឲ្យល្បីផ្សាយទៅកាន់ទិសផ្សេង ។ ទៀត ចំណែកខាងប៉ុគ្គលឯណាដែលមានកុសលចិត្តតើតទៀងច្រើនវិបាកចិត្តដែលជាផលតើតមកអំពីកុសលកំច្រើនដែរ ដូចជាឈើដែលមានពណ៌ទឹងសណ្ឋានល្អផ្សេង ។ មានក្តីងក្រអូប មានផ្កាចម្បាំ និងផ្លែម៉ូរតូជាដើម ប៉ុគ្គលនោះមានតិចពន់ពេកណាស់ តើតទៀងក្នុងលោកនេះ មានរូបទឹងពណ៌សណ្ឋានល្អផ្សេង ។ មានកំងកិរិយាចិត្ត អាចធ្វើក្តីងក្រអូបតិតិគុណសព្វ ឲ្យល្បីផ្សាយទៅកាន់ទិសផ្សេង ។ ជំប្រសើរ តែថាមិនមានច្រើនទេ ព្រោះមហាកិរិយាចិត្តនេះមិនមានដល់ប៉ុថ្នូនទឹងសេចប៉ុគ្គលខ្លាំងខ្លាយទៀត មានតែដល់ព្រះទីណាស្រេចខ្លាំងខ្លាយតែប៉ុណ្ណោះ ឯកុសលចិត្តដូចប្រុបផ្កា វិបាកចិត្តដូចក្តីងក្រអូបទៅកទឹងផ្កា កិរិយាចិត្តដូចក្តីងក្រអូបផ្សាយចេញអំពីតួផ្កា មានសេចក្តីឧបមេយ្យដូចផ្កាឈើខ្លាំងខ្លាយនោះឯង ។

ម្យ៉ាងទៀត លោកសម្តែងពន្យល់តទឹងអង្គថា ម្នាលប៉ុគ្គលអ្នកឆ្លៀវឆ្លាស ខ្លាំងខ្លាយដោយប្រៀងប្រៀបគេនាក្រមិនត្រឹមតែនោះប៉ុណ្ណឹងទុក ដល់ទានទឹក

ក្រៀងក្រាក់ចុះមកក្នុងផ្លូវដើមធ្នាំ ហើយក្តុរកស់សាបគ្រោះជកស្ទង់ចាត់
ថែទាំក្សាស្រែជកបដល់ស្រូវខុំ ហើយច្រូតកាត់បែនបាកទើបធារ
ស្រូវជាក់ជង្រែរហើយ ខុកជាក់គ្រឿងប្រដាប់មានទន្លីលនោស់ជាដើមជា
ស្រេច ក៏ស្រូវដែលនៅក្នុងជង្រែរនោះ លុះដល់ពេលម្ចាស់ស្រូវ
គេត្រូវការ ហើយបានុចាត់ចែងធ្វើស្រូវទាំងនោះទៅតាមប្រាថ្នា មាន
ចំណែនធ្វើអាហារបរិភោគជាដើមមានសេចក្តីចបាយាំងណា បុគ្គលដែល
មានកុសលចិត្តកើតឡើងក្នុងសន្តានខ្លួន មានសេចក្តីជ្រះថ្លាហើយចាត់
ចែងធ្វើការជាកុសលផ្សេង ។ ប្រកបដោយកុសលចេតនាមួយរយើក ។
នោះដកបដល់ហើយស្រេច បាននាំថាកុសលចិត្ត បុណ្យដែលជា
ផលកើតមកអំពីកុសលចិត្តនោះ ។ ជាម៉ឺងទៅក្នុងជង្រែកគឺជួងហ្មុំយ
បាននាំថាវិបាកចិត្តឬថាតទាលម្ពណៈកំបាន កិរិយាធ្វើគុណសម្បត្តិ
ទាំងពួងមានបញ្ញាសម្បត្តិជាដើម ទ្បើផ្សាយចេញអំពីវិបាកចិត្តនោះ ។
ល្អរៀបគាន់ចំសាផ្សេង ។ ចម្ការស់លាស់ដោយរហ័ស បាននាំថា
កិរិយាចិត្ត មានសេចក្តីឧបមេយ្យដូចបុគ្គលអ្នកចាត់ចែងធ្វើស្រូវនោះឯង ។
ខ្ញុំអត្ថាធិ បានវិសជ្ជនាអំពីកុសលចិត្ត វិបាកចិត្ត កិរិយាចិត្ត ដោយ
សង្ខេបមកតែប៉ុណ្ណេះឯង ។

๔๔- ធម្មរាជ៏ ទ្រង់ស្តាប់ហើយទ្រង់សួរថា អើអតីតព្រះសង្ឃដែលលោកវិសជ្ជនាបកនេះត្រឹមត្រូវហើយ តែយើងនឹងសួរគេទៀត ។ ប៉ុន្តែកាមាវចរកុសលចិត្តចំនួន ៨ នោះ ផ្សឹងគ្នាដោយវេទនាមានប៉ុន្មាន ? គឺវេទនាអ្វីខ្លះ ? ដោយញាណមានប៉ុន្មាន ? គឺញាណអ្វីខ្លះ ? ដោយសង្ខារកេមានប៉ុន្មាន ? គឺសង្ខារកេអ្វីខ្លះ ? ចូរលោកវិសជ្ជនាឲ្យស្តេចត្រង់មកមើល ?

អ្នកវិទ្យាវិសជ្ជនាតបថា បពិត្រធម្មរាជ៏ ឯកាមាវចរកុសលចិត្តចំនួន ៨ នោះ ផ្សឹងគ្នាដោយវេទនាមានតែសោមនស្សវេទនា ១ ឧបេក្ខាវេទនា ១ ផ្សឹងគ្នាដោយញាណមាន ៤ គឺសោមនស្ស-ញាណសម្បយុត្ត-អសង្ខារិក ១ សោមនស្ស-ញាណសម្បយុត្ត-សសង្ខារិក ១ ឧបេក្ខា-ញាណសម្បយុត្ត-អសង្ខារិក ១ ឧបេក្ខាញាណសម្បយុត្ត-សសង្ខារិក ១ ផ្សឹងគ្នាដោយសង្ខារកេមាន ៨ គឺ កុសលចិត្តទី ១ ឧដ្ឋិតទី ៣ ដែលប្រកបដោយសោមនស្សវេទនា ចំណែកខាងញាណសម្បយុត្ត ១ ខាងញាណវិប្បយុត្ត ១ កុសលចិត្តទី ៥ ឧដ្ឋិតទី ៧ ដែលប្រកបដោយឧបេក្ខាវេទនា ចំណែកខាងញាណសម្បយុត្ត ១ ខាងញាណវិប្បយុត្ត ១ ត្រូវជាអសង្ខារិក ៤, កុសលចិត្តទី ២ ឧដ្ឋិតទី ៤ ដែលប្រកបដោយសោមនស្សវេទនា

ចំណែកខាងញាណសម្បយុត្ត ១ ខាងញាណវិប្បយុត្ត ១ កុសលចិត្តទី ៦ ឧបេក្ខាវេទនា ចំណែកខាងញាណសម្បយុត្ត ១ ខាងញាណវិប្បយុត្ត ១ ត្រូវជាសសង្ខារិក ៤ រួមទាំងអស់ត្រូវជាសង្ខារិក ៨ ដោយពិត ។

៤៥ - ធម្មវិទី ក៏ទទួលស្តាប់ហើយពោលថា ម្នាលអត្តវាទីប្រស្នាដែលលោកវិសជ្ជនាមកនេះយើងស្តាប់បានហើយ តែយើងនឹងសួរប្រស្នាដទៃតទៅទៀត ។ ចុះកាមាវចរកុសលចិត្តទាំង ៨ នោះ ដែលផ្សងគ្នាដោយសោមនស្សវេទនាឧបេក្ខាវេទនា តើមានសេចក្តីអធិប្បាយផ្សងគ្នាយ៉ាងណាខ្លះ ? ដោយញាណសម្បយុត្តនឹងញាណវិប្បយុត្ត តើមានសេចក្តីអធិប្បាយផ្សងគ្នាយ៉ាងណាខ្លះ ? ដោយអសង្ខារិកនឹងសសង្ខារិក តើមានសេចក្តីអធិប្បាយផ្សងគ្នាយ៉ាងណាខ្លះ ? ចូរលោកវិសជ្ជនាឲ្យពិស្តារសេចក្តីត្រង់មកយើងនឹងស្តាប់ចូលចិត្តបានដោយងាយផងមើល ?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី បណ្តាកាមាវចរកុសលចិត្តទាំង ៨ នោះ បឋមកុសលចិត្តទី ១ មានសេចក្តីអធិប្បាយថា: បុគ្គលឯណាបានអាស្រ័យនូវវេទយ្យធម្មសម្បត្តិ គឺបរិបូណ៌ដោយវេទយ្យវត្ថុ មានសំពត់សំពាប់ធ្វើចីវរជាដើមក្តី កត្តាហារទាំងពួងដ៏ឧត្តមក្តី សេនាសនៈ

តែសំភប់ដែកអង្គុយមានតម្លៃខ្ពើយជាដើមក្តី គ្រឿងកែសជ្ជៈទាំងពួង ជំនួញក្តី បដិគ្គាហកសម្បត្តិ គឺថាប្តូរដោយបុគ្គលអ្នកឧបួលដែលប្រកបដោយវត្តប្បដិបត្តិដ៏សមរម្យល្អ គួរដល់សមណសារុប្បក្តី បដិគ្គាហក-បុគ្គលដែលធ្លាប់ស្រឡាញ់កប់ភាន់ជាញាតិប្តូជាមិត្រសំឡាញ់ក្តី ប្តូរបាសម្បត្តិដទៃដែលជារហស្ស ឲ្យតើតសេចក្តីសោមនស្សមានចិត្តត្រេកអរតែពុយប្រកបដោយសោមនស្សវេទនា សោយទ្រព្យនៃឥដ្ឋារម្មណ៍ជាសុខសប្បាយប្រព្រឹត្តទៅក្នុងចិត្ត ។ បានបំពេញទ្រព្យសម្ភារដ៏តិចជាងឆ្លាស់ឃើញត្រូវឲ្យពេញបរិបូណ៌ភាមរង្គត្រូវអ្នកជំនិតមគ្គជាបឋម ប្រព្រឹត្តទៅដោយទន្យមានទន្យថាទានដែលអញបានឲ្យហើយនេះ ជាទានមានផលានិសង្សច្រើន អាចនាំមកទ្រព្យប្រយោជន៍ធំសេចក្តីសុខសេចក្តីចំរើនជាអនេកប្បការជាដើម; ជាញាណសម្បយុត្តប្រកបត្រមដោយញាណគឺបញ្ញាជាធំឆ្លាស់ទ្រព្យហេតុទាំង ៤ យ៉ាង តាមសភាពពិត គឺ: ๑- កម្មដ្ឋានឆ្លាស់ថា បុគ្គលធ្វើអំពើអាក្រក់លាមកធំបានសេចក្តីអាក្រក់លាមកវិញ បុគ្គលធ្វើអំពើល្អដ៏ប្រសើរធំបានសេចក្តីល្អដ៏ប្រសើរវិញ ។ ๒- ឧបបត្តិ ដំឆ្លាស់ថាបុគ្គលដែលចូលទៅជិតកើតក្នុងព្រហ្ម-លោកដោយមិនមានសេចក្តីព្យាបាទមានមេត្តាព្រហ្មវិហារជាដើម ។

៣ - ឥន្ទ្រិយបរិបុណ្ណ មានបញ្ញាជាធំចាស់ដោយជុំវិញ ព្រោះមានចិត្ត
មិនរបើនរើរួសប្រកាន់ចំដ្ឋមានះឡើយ ទំព្យាយាមដើរសាកសួរនូវអត្ថ-
វសធម៌ធម្មវស ចំពោះអ្នកប្រាជ្ញដែលមានបញ្ញាចាស់មានចិត្តជ្ជន់កងព្រះ
ពុទ្ធសាសនា ញ៉ាំងបញ្ហាវបស់ខ្លួនឲ្យសំរេច រេចរៀះចៀសចេញ
មិនសេពនប់នូវបុគ្គលពាលអប់ឥតបញ្ញាឡើយ ហើយសែ្វងរកសេព-
នប់នូវបុគ្គលជាបណ្ឌិតមានបញ្ញាដ៏ល្អិតជ្រាលជ្រៅ ទំពិចារណាសាកសួរ
ប្រព្រឹត្តសន្សំនូវញាណ តិបញ្ហាវបស់ខ្លួនឲ្យបានជ្រាលជ្រៅទៅក្នុង
អត្ថវសធម្មវសដោយពិត ។ ៤. កិលេសទូរីភាវៈ ជឹងបង្ហាស់
ថាភាវៈដែលធ្វើឲ្យចាកកិលេសនោះ ត្រូវតែសង្កត់សង្កិនកុំចាត់បង់នូវ
កងកិលេសទាំងពួងដោយឈានសមាបត្តិជាដើមទើបបាន ។ បុគ្គល
ដែលដឹងបង្ហាស់នូវហេតុទាំង ៤ យ៉ាងនេះ . ទើបបានឈ្មោះថាញាណ-
សម្បយុត្តប្រកបព្រមដោយញាណ ។ លុះបានដឹងចាស់យ៉ាងនេះហើយ
មានចិត្តពុំបានលះបង់កងសេចក្តីទុក្ខប្រកបសម្រេនបុរេឡើយ មិនមាន
បុគ្គលទាំងឡាយដទៃ មកជួយជ្រោមជ្រែងរំឭកជាស់តឿនឲ្យមាន
ស្មារតីក្បៀវក្បាឡើយ តែថាមានពុទ្ធសប្បាយជ្រះថ្លាចំពោះបុគ្គលអ្នក
ខ្ជួលក្តី អាហារបិណ្ឌបាតក្តី ទីសេនាសនៈក្តី ភេសជ្ជក្តី ដែលជាទីគេញ

ចិត្ត កំកើតទុស្សហ៍ព្យាយាមក្រៀវក្លាខ្លឹងរដោយខ្លួនឯង ហើយបាន
ធ្វើបំពេញនូវបុញ្ញកិរិយាវត្ថុចាំង ១០ យ៉ាង មានបរិច្ចាគទ្រព្យឲ្យទានជា
ដើម បានឈ្មោះថាអស្ចារ្យកែ កុសលចិត្តប្រកបដោយសេចក្តីសប្បាយ
កើតទុស្សហ៍ព្យាយាមយ៉ាងក្រៀវក្លាធ្វើការជាកុសលផ្សេង ៗ ដោយខ្លួន
ឯង ក្នុងកាលឯណា បឋមកុសលចិត្តប្រកបដោយសោមនស្សវេទនា
ញាណសម្បយុត្តអស្ចារ្យកែកំកើតខ្លឹងច្រើនដងដល់បុគ្គលនោះ ក្នុងកាល
នោះឯង ។

ទុតិយកុសលចិត្តទី ២ មានសេចក្តីអធិប្បាយដូចបឋមកុសលចិត្តនោះ
ដែរ ប្លែកគ្នាតែត្រង់សស្ចារ្យកែ ព្រោះទុតិយកុសលចិត្តនេះជាសស្ចារ្យកែ
សេចក្តីអធិប្បាយថា បុគ្គលឯណាមានកុសលចិត្តប្រកបដោយសោម-
នស្សវេទនាញាណសម្បយុត្តដែរ តែថាជាបុគ្គលមានចិត្តធ្ងន់ក្រាន់
លិចចុះកន្លងសេចក្តីឆ្លៀវឆ្លាសទម្រន់ចុះ មិនធ្វើបំពេញនូវបុញ្ញកិរិយា-
វត្ថុចាំង ១០ យ៉ាង មានបរិច្ចាគទ្រព្យឲ្យទានជាដើម ព្រោះមិន
សប្បាយពេញចិត្តចំពោះដូវកាលក្តីបុគ្គលអ្នកខ្វះខួលក្តី អាហារបិណ្ឌបាតក្តី
ទីសេនាសនៈក្តី គាំឲ្យមានចិត្តធ្ងន់ក្រាន់ធ្វើបុណ្យឲ្យទានមិនកើតខ្លឹងឡើយ
លុះមានបុគ្គលចាំងឲ្យដងខែនោះបីជាញាតិសាច់សាលោហិតក្តី ជាមិត្ត

សំភ្លក់ញ៉ាំនឹងគ្នាក្តី ចូលមកជួយនិយាយព្យាករជាស់គ្នៀន ទើបមាន ។ស្ទាហ៍សេចក្តីព្យាយាមក្នុងការគោរពតែតទៀងឯង ចាន់ចាត់ចែងធ្វើបំពេញនូវបុញ្ញកិរិយាវត្តចាំង ១០ យ៉ាង មានបរិច្ចាគទ្រព្យធ្វើបុណ្យទ្បានជាដើម ចានណ្ហោះថាសប្បុរិសក្នុងលោក ក្នុសលចិត្តប្រកបដោយសេចក្តីជ្រាញ្ញាន់ ឆ្លៀវប្រអួសមិនសប្បាយពេញចិត្តនឹងធ្វើបុណ្យទ្បានទៀយ លុះមានបុគ្គលដទៃមកជួយនិយាយព្យាករជាស់គ្នៀន ទើបមាន ។ស្ទាហ៍សេចក្តីព្យាយាមក្នុងការគោរពតែតសប្បាយពេញចិត្តចានចាត់ចែងឯង ធ្វើការក្នុសលផ្សេង ៗ តាមកម្លាំងសទ្ធាក្នុងកាលឯណា ខុតយកុសលចិត្តដែលប្រកបដោយសោមនស្សវេទនា-ញាណសម្បយុត្ត-សសង្ខារិក ក៏តែងខ្លឹងក្នុងការដែលប្រាកដដល់បុគ្គលនោះក្នុងកាលនោះឯង ។

តតិយកុសលចិត្តទី ៣ មានសេចក្តីអធិប្បាយថា: ពាលទារកក្នុងពាំងព្យាយដែលតុំពាន់រឿនសូត្រចេះដឹងចំណេះវិជ្ជាមាំមួន ទៅក្នុងសេចក្តីខ្វះខំនិតមានកិរិយាប្រព្រឹត្តសន្សំនូវកុប្រតិបត្តិតែតទៀង ដោយសារបានឃើញនូវសេចក្តីគោរពប្រតិបត្តិនៃជនពាំងព្យាយជាញាតិ មានមាតាបិតាជាដើម ដែលទំព្យាយាមធ្វើចំពេញនូវបុញ្ញកិរិយាវត្តពាំង ១០ ក្នុងព្រះពុទ្ធសាសនា, ពាលទារកពាំងព្យាយនោះ លុះបាន

ឃើញកិលេ្ល សាមណេរទាំង ៣ ឡាយហើយ មានសេចក្តីសោមនស្សត្រេក-
អរកែកយកកើតឡើង តែថាជាញាណវិប្បយុត្តច្រាសចេញផុតពីក
ញ្ញាណគឺមិនមានបញ្ញាពិចារណាដំឯងឡាស់នូវហេតុទាំង ៤ យ៉ាងនោះទេ
ហើយមានចិត្តពុំបានលិចចុះ ក្នុងសេចក្តីឆ្លៀវឆ្លាសជ្រួតជ្រាន់ឡើយ
មិនមានបុគ្គលទាំង ៣ ឡាយដទៃ មកជួយនិយាយរំឭកជាស់តឿនឲ្យមាន
ស្មារតីព្យាយាមក្សៀវក្សាឡើយ តែមានចិត្តសប្បាយជ្រះថ្លានឹងកិលេ្ល
សាមណេរដែលខ្លួនបានឃើញនោះ ក៏កើតមានស្មារតីព្យាយាមក្សៀវក្សា
ឡើងដោយខ្លួនឯង មានទេយ្យវត្ថុអ្វីបន្តិចបន្តួចក៏ដែលខ្លួន ក៏លះបង់
នូវទេយ្យវត្ថុនោះប្រគេនដល់កិលេ្ល សាមណេរទាំង ៣ ឡាយនោះដោយរហ័ស
ឬថាធ្វើបំពេញនូវប៉ុណ្ណាកិរិយាវត្តឯណាមួយក្តី កន្លងកាលឯណា តតិយ-
ឈានសមចិត្តប្រកបដោយសោមនស្សវេទនាញាណវិប្បយុត្តអស់ឆ្ងាយកែ ក៏
កើតឡើងច្រួតជាប់ជាប់ពីសេចក្តីទាំង ៣ ឡាយនោះក្នុងកាលនោះឯង ។

ចតុត្ថជ្ឈានចិត្តទី ៤ មានសេចក្តីអធិប្បាយដូចតតិយជ្ឈានចិត្ត
ទី ៣ នោះដែរ ប្លែកតែត្រង់សង្ខារកែ គឺចតុត្ថជ្ឈានចិត្តជាសុខសង្ខារកែ
សេចក្តីអធិប្បាយថា ពាសេចក្តីទាំង ៣ ឡាយមានចិត្តលិចចុះក្នុងសេចក្តីឆ្លៀវ
ឆ្លាសជ្រួតជ្រាន់មិនសប្បាយ ពេញចិត្តនឹងធ្វើបុណ្យសោះ ល្អុះមាន

បុគ្គលចាំងឡាយដទៃមានមាតាបិតាជាដើម ចានជួយនិយាយល្បួងលួង
លោមរឿងជាស់គ្នីនថា កូន! អ្នកត្រូវគាន់យកវត្ថុនេះទៅប្រគេនលោក
អ្នកត្រូវថ្វាយបង្គំលោកជាដើម ទើបពាក់ចាំងឡាយនោះមានទុស្សាហ៍
សេចក្តីព្យាយាមក្រៀវក្លាកើតឡើង ចានប្រគេនទេយ្យវត្ថុដល់លោក
ចានថ្វាយបង្គំលោក ចានចាត់ចែងធ្វើការកុសលផ្សេង ។ តាមកម្លាំង
សទ្ធាក្នុងកាលឯណា. បតុគ្គកុសលចិត្តដែលប្រកបដោយសោមនស្ស-
វេទនាញាណវិប្បយុត្តសសង្ខារិក កំកើតឡើងច្រាកដដល់ពាលពាក
ចាំងឡាយនោះក្នុងកាលនោះឯង ។ កំណត់មហាដីកា លោកសំដែងពាក
សេចក្តីថា កុសលចិត្តទី ៣-៤ នោះលោកយកពាលពាកចាំងឡាយ
មកជាទីតាំង ហាក់ដូចជាកុសលចិត្តទី ៣-៤ នោះកើតឡើងចាន
តែត្រឹមពាលពាកក្មេងតូច ។ ប៉ុណ្ណោះ តែមិនមែនតែដូច្នោះទេ ទោះបី
ប្តីប្រពន្ធស្តីក្មេងចាស់ក្តី កំតង់មានកុសលចិត្តទី ៣-៤ នោះកើតឡើង
ដូចគ្នាដែរ មានសេចក្តីអធិប្បាយដូចពាលពាកចាំងឡាយនោះឯង ។

ឯកុសលចិត្តទី ៥-៦-៧-៨ មានសេចក្តីអធិប្បាយដូចកុសលចិត្តទី-
១-២-៣-៤ នោះដែរ ផ្សេងគ្នាតែវេទនា ព្រោះកុសលចិត្តទី ៥-
៦-៧-៨ នេះ ប្រកបដោយទុបេក្ខាវេទនាសោយនូវសេចក្តីសុខក្នុងឥដ្ឋារម្មណ៍

ច្រាកដត្រង់រង្វង់ក្នែកឬត្រង់ហាខយវត្ថុ ๑ ๆ ๔-សុខំ ប្រព្រឹត្តទៅដោយ
ស្រួលក្នុងសម្បយុត្តធម៌មានសោយនូវសេនៃអារម្មណ៍ ជាទីត្រេកអរ
ពេញចិត្តជាលក្ខណៈ ដូចជាត្រីរកាមានត្រះភជ្ជាទ័យជ្រះថ្លាសោយ
នូវកាជនមានឧជារសដ៏ឆ្ងាញ់ ๆ ๕-ឯកគ្គតា ភាវៈនៃចិត្តដ៏ប្រ-
សើរ មានអារម្មណ៍តែមួយដំកល់មាំមិនចាន់រើរាយ ដោយអារម្មណ៍
ផ្សេង ๆ ចានឈ្មោះថា បឋមជ្ឈានកុសលចិត្ត ๆ

ទី ๒-ទុតិយជ្ឈានកុសលចិត្ត មានសេចក្តីអធិប្បាយដូចបឋមជ្ឈាន
កុសលចិត្តទី ๑ នោះដែរ ប្លែកផ្សេងគ្នាតែអង្គ ត្រង់ទុតិយជ្ឈានកុសល
ចិត្តនេះប្រកបដោយអង្គ ๓ គឺ: ๑ វិចារៈ ๒-បីតិ ๓-សុខៈ ๔-ឯកគ្គតា
ត្រូវជាអង្គ ๔ ចានឈ្មោះថា ទុតិយជ្ឈានកុសលចិត្ត ๆ

ទី ๓-តតិយជ្ឈានកុសលចិត្ត ប្រកបដោយអង្គ ๓ គឺ: ๑-បីតិ
๒-សុខៈ ๓-ឯកគ្គតា ត្រូវជាអង្គ ๓ ចានឈ្មោះថា តតិយជ្ឈានកុសល-
ចិត្ត ๆ

ទី ๔-ចតុត្ថជ្ឈានកុសលចិត្ត ប្រកបដោយអង្គ ๒ គឺ: ๑-សុខ
๒-ឯកគ្គតា ជាអង្គ ๒ ចានឈ្មោះថា ចតុត្ថជ្ឈានកុសលចិត្ត ๆ

ទី ๕-បញ្ចមជ្ឈានកុសលចិត្ត ប្រកបដោយអង្គ ๒ គឺ: ๑-ឧបេក្ខា

ធម្មជាតសំឡឹងមើលមាំ គឺជាធម្មជាតប្រព្រឹត្តទម្លាប់នូវនីវរណធម៌ទាំង ៥ ប្រាំ
បាន យ៉ាងចុះជាខាងក្នុង ។ សេចក្តីស្រួលកាយស្រួលចិត្តគឺបណ្តាត
ពោលថាសេចក្តីសុខ យ៉ាងសំខាន់ដោយពិត, ២. ឯកគ្គតាការនៃចិត្តដ៏ប្រ-
សើរមានអារម្មណ៍តែមួយដំកល់មាំមិនបានរើរាយដោយអារម្មណ៍ផ្សេង ។
ជាអង្គ ៤ បានឈ្មោះថាបញ្ចមជ្ឈានកុសលចិត្ត ។

ម្យ៉ាងទៀតទៀត ព្រះយោគីកុលបុត្ត ដែលនឹងធ្វើឈានទាំងនេះឲ្យ
កើតឡើងជានក្ខត្តសន្តានរបស់ខ្លួននោះ ត្រូវលះបង់នីវរណធម៌ទាំង ៥ ឲ្យ
ស្រឡះហើយទំព្យាយាមឲ្យមាំមួនប្រកបដោយធម៌ ៤ យ៉ាងជាដើម គឺ
ការនោ ទំចំរើនទូវព្រះកម្មដ្ឋានសមគួរតាមចរិតរបស់ខ្លួន ១, សមាធិ
ដំកល់ចិត្តឲ្យមាំ នឹងនៅក្នុងអារម្មណ៍ នៃព្រះកម្មដ្ឋានដែលខ្លួនបានរៀនមក
ហើយមិនឲ្យនីវរណធម៌ទាំង ៥ ចូលមកបៀតបៀនបាន ១ ទើបអាច
ញុំាងឈានទាំងនេះឲ្យកើតឡើងក្នុងសន្តានរបស់ខ្លួនបាន ដោយពិត ។
វិសជ្ជនាមកអំពីប្រាថ្នាចង់កុសលចិត្តទាំង ៥ ដោយសង្ខេមតែប៉ុណ្ណេះឯង ។

៥១-ធម្មវាទី បានស្តាប់ហើយពោលថា ម្នាលអត្តពីប្រស្នា
ដែលលោកវិសជ្ជនាមកនេះត្រឹមត្រូវហើយ តែយើងនឹងសួរប្រស្នាដទៃ
តទៅទៀត ។ ប៉ុពោក្សថា សមថកម្មដ្ឋាននិងវិបស្សនាកម្មដ្ឋាននោះមាន

សេចក្តីអធិប្បាយដូចម្តេច ? សមថកម្មដ្ឋានទាំង ៤០ នោះគឺកម្មដ្ឋានអ្វីខ្លះ ? ចូរលោកវិសជ្ជនាអំពីពាក្យថា សមថកម្មដ្ឋាន វិបស្សនាកម្មដ្ឋានធំឯកប់ ចំនួនកម្មដ្ឋានទាំង ៤០ ព្រមទាំងពាក្យប្រែអធិប្បាយឲ្យសព្វគ្រប់មកយើងធឹងបានស្តាប់ចូលចិត្តផងមើល ?

អត្ថវិជ្ជី វិសជ្ជនាតបថា បពិត្រធម្មាចរិ សេចក្តីអធិប្បាយថា ចិត្តកាន់យកនូវអារម្មណ៍ទាំង ឡាយមានបឋវីកសិណារម្មណ៍ជាដើម មកជាទីតាំងបរិកម្មចំរើនធ្វើកំណត់ខុកកងចិត្ត តាវនាឲ្យរឿយ ។ រម្ងាប់នូវនីវរណធម៌បានហើយ ញុំាងឧបចារសមាធិនឹងអប្បនាសមាធិឲ្យកើតឡើងច្រាកដ បានឈ្មោះថា សមថកម្មដ្ឋាន ។ ព្រះយោគាវចរកុលបុត្របានចំរើនតាវនាដោយបញ្ញាពិចារណាឃើញដោយសាមាន្យលក្ខណៈ ទុក្ខលក្ខណៈ អនត្តលក្ខណៈ ជារដើមជាអារម្មណ៍ បានឈ្មោះថា វិបស្សនាកម្មដ្ឋាន ដោយពិត ។ ឯចំនួនសមថកម្មដ្ឋានទាំង ៤០ នោះ គឺកសិណ ១០ អសុភ ១០ អនុស្សតិ ១០ ព្រហ្មវិហារ ៤ សញ្ញា ១ វវដ្ឋាន ១ សរូប ៤ ត្រូវជា ៤០ គត់ ។ សេចក្តីអធិប្បាយថា កសិណទាំង ១០ នោះ ចែកជាភូតកសិណ ៤ គឺ ១- បរិកម្មចំរើនធ្វើកំណត់ខុកកងចិត្តកាវនាថា បឋវី ។ សំឡឹងយកខុគ្គហនិមិត្តដែលកើតមកពីតំ

មណ្ឌលនៃដីជាគារម្មណ៍ កន្លងមនោទ្វារដោយចក្ខុបញ្ញាជាទីត្រេកអរនៃចិត្ត ឆ្ពោះថា បឋវីកសិណ ។ ๒- បរិកម្មចំរើនធ្វើកំណត់ខុសក្នុងចិត្តការនាថា អាបោ ។ សំឡឹងយកនិគ្គហនិមិត្តដែលកើតមកអំពីមណ្ឌលនៃទឹកជាគារម្មណ៍កន្លងមនោទ្វារដោយចក្ខុបញ្ញាជាទីត្រេកអរនៃចិត្ត ឆ្ពោះថា អាបោកសិណ ។ ๓- បរិកម្មចំរើនធ្វើកំណត់ខុសក្នុងចិត្តការនាថា តេជោ ។ សំឡឹងយកនិគ្គហនិមិត្តដែលកើតមកអំពីមណ្ឌលនៃភ្លើងជាគារម្មណ៍កន្លងមនោទ្វារដោយចក្ខុបញ្ញាជាទីត្រេកអរនៃចិត្ត ឆ្ពោះថា តេជោកសិណ ។ ๔- បរិកម្មចំរើនធ្វើកំណត់ខុសក្នុងចិត្តការនាថា វាយោ ។ សំឡឹងយកនិគ្គហនិមិត្តដែលកើតអំពីមណ្ឌលនៃខ្យល់ជាគារម្មណ៍កន្លងមនោទ្វារដោយចក្ខុបញ្ញាជាទីត្រេកអរនៃចិត្ត ឆ្ពោះថា វាយោកសិណ ។ បែកទៅជាវណ្ណកសិណ ๔ គឺ: ๕- បរិកម្មចំរើនធ្វើកំណត់ខុសក្នុងចិត្តការនាថា នីលំ ។ សំឡឹងយកនិគ្គហនិមិត្តដែលកើតមកអំពីមណ្ឌលនៃផ្កាឬសំពត់ មានពណ៌ខៀវជាគារម្មណ៍កន្លងមនោទ្វារដោយចក្ខុបញ្ញាជាទីត្រេកអរនៃចិត្ត ឆ្ពោះថា នីលកសិណ ។ ๖- បរិកម្មចំរើនធ្វើកំណត់ខុសក្នុងចិត្តការនាថា បីតំ ។ សំឡឹងយកនិគ្គហនិមិត្តដែលកើតមកអំពីមណ្ឌលនៃផ្កាឬសំពត់ មានពណ៌លឿងជាគារម្មណ៍កន្លង

មនោទ្វារ ដោយចក្ខុបញ្ចាដាទីក្រែកអរនៃចិត្ត ជានឈ្មោះថា ចក្ខុ-
សំណា ។ ๗- បរិកម្មចំរើនធ្វើកំណត់ខុសកង្វល់ចិត្តភាវនាថា រលាហិតំ។
សំឡឹងយកខ្ពស់ហនិមិត្តដែលកើតមកអំពីមណ្ឌលនៃផ្កាឬសំពត់ មានព័ណ៌
ក្រហមជាអារម្មណ៍កង្វល់មនោទ្វារដោយចក្ខុបញ្ចាដាទីក្រែកអរនៃចិត្ត ជាន
ឈ្មោះថា រលាហិតកសំណា ។ ๘- បរិកម្មចំរើនធ្វើកំណត់ខុសកង្វល់ចិត្ត
ភាវនាថា ឧទាតំ។ សំឡឹងយកខ្ពស់ហនិមិត្តដែលកើតមកអំពីមណ្ឌលនៃ
ផ្កាឬសំពត់មានព័ណ៌សជាអារម្មណ៍កង្វល់មនោទ្វារដោយចក្ខុបញ្ចាដាទីក្រែក
អរនៃចិត្ត ជានឈ្មោះថា ឧទាតកសំណា ។ ๙- បរិកម្មចំរើនធ្វើកំណត់
អាកាសទីវាលខេខុសកង្វល់ចិត្តភាវនាថា អាកាសោ។ សំឡឹងយក
ខ្ពស់ហនិមិត្តដែលកើតមកអំពីមណ្ឌល នៃអាកាសជាអារម្មណ៍កង្វល់មនោទ្វារ
ដោយចក្ខុបញ្ចាដាទីក្រែកអរនៃចិត្ត ជានឈ្មោះថា អាកាសកសំណា ។
๑๐ - បរិកម្មចំរើនធ្វើកំណត់ខុសកង្វល់ចិត្តដោយអំណាចនៃពន្លឺមានពន្លឺព្រះ
ចន្ទ្រជាដើមភាវនាថា អាលោកោ។ សំឡឹងយកខ្ពស់ហនិមិត្តដែលកើត
មកអំពីមណ្ឌលនៃពន្លឺជាអារម្មណ៍កង្វល់មនោទ្វារដោយចក្ខុបញ្ចាដាទីក្រែក-
អរនៃចិត្ត ជានឈ្មោះថា អាលោកកសំណា ។ ឧសំណាទាំង ๑๐
នេះ សម្រេចដល់ខ្ពស់ហជាឈានសមាធិនឹងអប្បនាសមាធិ ជានហូតបញ្ចូ-

មជ្ឈានដោយឥតក ។

អស្សុភ ១០ នោះគឺ: ១-បរិកម្មចំរើនធ្វើកំណត់ខុកក្នុងចិត្តភាវនាថា ខុមាតកំ។ រំពឹងកាន់យកខុគ្គហនិមិត្តដែលកើតមកអំពីសាកសព(*) មានសរីរៈស្រស់គួរខ្ពើមហើមពោងឯខ្ទើងជាអារម្មណ៍ជាទីសង្វេគ ឋាននាមថា ខុខុមាតកៈ ។ ២-បរិកម្មចំរើនធ្វើកំណត់ខុកក្នុងចិត្តភាវនាថា វិនីលកំ។ រំពឹងកាន់យកខុគ្គហនិមិត្តដែលកើតមកអំពីសាកសព មានសរីរៈស្រស់ហើមភ្លាំង មានឥណ្ហិខៀវផ្សឹង។ ដោយប្រើនជាអារម្មណ៍ជាទីសង្វេគ ឋាននាមថា វិនីលកៈ ។ ៣-បរិកម្មចំរើនធ្វើកំណត់ខុកក្នុងចិត្តភាវនាថា វិបុព្វកំ។ រំពឹងកាន់យកខុគ្គហនិមិត្តដែលកើតមកអំពីសាកសពមានខ្ទុះហូរចេញផ្សឹង។ ជាអារម្មណ៍ជាទីសង្វេគ ឋាននាមថា វិបុព្វកៈ ។ ៤-បរិកម្មចំរើនធ្វើកំណត់ខុកក្នុងចិត្តភាវនាថា វិច្ឆិទ្ទកំ។ រំពឹងកាន់យកខុគ្គហនិមិត្តដែលកើតមកអំពីសាកសព មានសរីរៈដែលឋិតកាត់ជាច់ពាក់កណ្តាលជាតិរំណាត់ជាអារម្មណ៍ជាទីសង្វេគ ឋាននាមថា វិច្ឆិទ្ទកៈ ។ ៥-បរិកម្មចំរើនធ្វើកំណត់ខុកក្នុងចិត្តភាវនាថា វិក្ខាយិតកំ។ រំពឹងកាន់យកខុគ្គហនិមិត្តដែលកើតមកអំពីសាកសព មានសរីរៈ

---

*- ដែលហៅថា "សាកអសុភ" តែក្នុងវិនយាគុប្រើមថា "សាកសព" ផ្តុំដូរវិញ ។

ស្រស់ដែលសត្វក្អែក-ឆ្កែ-ចចកជារដើម ទំពាស៊ីហើយជាគម្មណ៍ជាទី
សង្វែត ឋានឈ្មោះថា វិក្ខាយិតកៈ ។ ៦- បរិកម្មចំរើនធ្វើកំណាត់
ខ្មុកក្នុងចិត្តភាវនាថា វិក្ខិត្តកំ ។ រំពឹងកាន់យកនូវគ្គហនិមិត្តដែលកើតមក
អំពីសាកសពមានសរីរៈស្រស់ជាអម្ពារដែលសត្វឆ្កែ ចចកជារដើម ទំពាស៊ី
ចោលហើយឋិតឋេរជាគម្មណ៍ជាទីសង្វែត ឋានឈ្មោះថា វិក្ខិត្តកៈ ។
៧ : បរិកម្មចំរើនធ្វើកំណាត់ខ្មុកក្នុងចិត្តភាវនាថា ហតវិក្ខិត្តកំ ។ រំពឹងកាន់
យកនូវគ្គហនិមិត្តដែលកើតមកអំពីសាកសពមានសរីរៈស្រស់ ដែលបុគ្គល
កាត់ចំក្រាំជាច់ជាកំណាត់តូច-ធំដោយកាំបិត ហើយចោលផ្សឹង ។ ជា
គម្មណ៍ជាទីសង្វែត ឋានឈ្មោះថា ហតវិក្ខិត្តកៈ ។ ៨-បរិកម្មចំរើនធ្វើកំ-
ណាត់ខ្មុកក្នុងចិត្តភាវនាថា លោហិតកំ ។ រំពឹងកាន់យកនូវគ្គហនិមិត្តដែលកើត
មកអំពីសាកសពមានសរីរៈ ស្រស់ ប្រឡាក់ដោយឈាមក្រហមក្រាលដែលបុគ្គលកាត់ជាច់ហើយថ្មី ។ ជាគម្មណ៍ជាទីសង្វែត ឋានឈ្មោះថា
លោហិតកៈ ។ ៩- បរិកម្មចំរើនធ្វើកំណាត់ខ្មុកក្នុងចិត្តភាវនាថា បុឡុវកំ ។
រំពឹងកាន់យកនូវគ្គហនិមិត្តដែលកើតមកអំពីសាកសព មានសរីរៈស្រស់
លាយប្រឡំដោយក្រកូលនៃសត្វដង្កូវពាំងឡាយហូរចេញពុំជាច់ ជាគ-
ម្មណ៍ជាទីសង្វែត ឋានឈ្មោះថា បុឡុវកៈ ។ ១០-បរិកម្មចំរើនធ្វើ

កំណាត់ពុទ្ធគុណនិយាយថា អង្គុត ។ រំពឹងគាន់យកគ្គហនិមិត្តដែលកើត
មកអំពីសាកសពមានតែពន្លឺនិងទេដូចគាម្ភណ៍ជាទីសង្វែង បានឈ្មោះ
ថា អង្គុត: ។ អសុភកំណត់ ១០ នេះ សម្រេចដល់ឧបចារសមាធិនិង
អប្បនាសមាធិ បានត្រឹមតែបឋមជ្ឈានប៉ុណ្ណោះ ។

អនុស្សតិកំណត់ ១០ នោះ គឺ: ១- ធ្វើបរិកម្មចំរើនតាំងសតិនឹកពិចារណា
រឿយៗ ខ្លួនព្រះពុទ្ធគុណកំណត់ ១០ រំពឹងគាថានាថា សោ ភគវា អរហំ
អរហំ សោ ភគវា អរហំ, សោ ភគវា អរហំ សម្មាសម្ពុទ្ធោ
សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ។ល។ សោ ភគវា អរហំ ពុទ្ធោ
សោ ភគវា អរហំ ពុទ្ធោ, សោ ភគវា អរហំ ភគវា សោ ភគវា អរហំ
ភគវា ឬថារំពឹងគាថាទៀតបន្តុះមកថា អរហំ អរហំ សម្មាសម្ពុទ្ធោ
សម្មាសម្ពុទ្ធោ ។ល។ ពុទ្ធោ ពុទ្ធោ ភគវា ភគវា តាំងដំកល់
ចិត្តទៀងមាំដោយអំណាចនៃកិរិយាបង្អោន បង្វិលផ្ទេរចិត្តទៀតជ្រុងទៅ
សិង្គីក្នុងព្រះពុទ្ធគុណជាគាម្ភណ៍ គាចត្រេចសង្កត់ខ្លួនវិរៈណាធម៌តាំង៨ជាន
មានតខ្លួនស្មើកើតឡើងអំពីចិត្តដ៏ស្អាតជួរវេងវែង ។ ផ្សាយចេញទៅតាម
កាយក្លាសម្រេចបានត្រឹមឧបចារសមាធិ បានឈ្មោះថា ពុទ្ធានុស្សតិ ។
២-ធ្វើបរិកម្មចំរើនតាំងសតិនឹកពិចារណារឿយៗខ្លួនព្រះធម្មគុណ រំពឹងគាថានាថា

ស្វាក្ខាតោ ភគវតោ ជម្មោ ស្វាក្ខាតោ ភគវតោ ជម្មោ,សន្ទិដ្ឋិកោ សន្ទិដ្ឋិកោ, អកាលិកោ អកាលិកោ, ឯហិបស្សិកោ ឯហិបស្សិកោ, ឧបនយិកោ ឧបនយិកោ, បច្ចត្តំវេទិតព្វោ វិញ្ញូហិ បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ឬថាវំពីឆ៍ការនោឡ្វែតិចបុះមកថា ជម្មោ ជម្មោ តាំងតម្កល់ចិត្តឲ្យមាំ ដោយអំណាចនៃកិរិយាបង្អោនបង្វិរដម្រុលចិត្តឲ្យទៅជ្រុតនៅស៊ប់ក្នុងព្រះធម្មគុណជាអារម្មណ៍ អាចត្រូបសង្កត់នូវនីវរណធម៌ទាំង ៥ បាន មានពន្លឺរស្មីកើតឡើងអំពីចិត្តដ៏ស្អាតផូរផង់ផ្សែង ។ ផ្សាយចេញទៅតាមកាយទ្វារសម្រេចបានត្រឹម ឧបចារសមាធិ បានឈ្មោះថា ធម្មានុស្សតិ ។

៣ - ធ្វើបកម្មចំរើនតាំងសតិនឹកពួកព្រៃយ ។ នូវព្រះសង្ឃគុណពីឆ៍ការនោថា សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ។ល។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ឬថាវំពីឆ៍ការនោឡ្វែតិចបុះមកថា សង្ឃោ សង្ឃោ តាំងតម្កល់ចិត្តឲ្យមាំ ដោយអំណាចនៃកិរិយាបង្អោន បង្វិរ ដម្រុលចិត្តឲ្យទៅជ្រុតនៅស៊ប់ក្នុងព្រះសង្ឃគុណជាអារម្មណ៍ អាចត្រូបសង្កត់នូវនីវរណធម៌ទាំង ៥ បាន មានពន្លឺរស្មីកើតឡើងអំពីចិត្តដ៏ស្អាតផូរផង់ផ្សែង ។ ផ្សាយចេញទៅតាមកាយទ្វារ សម្រេចបានត្រឹម ឧបចារសមាធិ បានឈ្មោះថា

សង្ឃាទុសត្តៃ. ។ ៤- ធ្វើបវារណាកម្មចំពោះតាំងសតិនឹងព្រះរឿយ ។ នូវសីល-
គុណរបស់ខ្លួនដ៏បរិសុទ្ធល្អដោយការៈមានសីលមិនបានជាប់ជាដើម ពីតិ
ការនោះថា សីលំ ។ តាំងភាពលំចិត្តឲ្យមាំដោយអំណាចនៃកិរិយាបង្អោន
បង្ហូរជម្រុលចិត្តទៅឲ្យត្រេកអៀសិប់ក្នុងសីលគុណជាការម្មណ៍ អាចត្រូវ
សង្កត់នូវនីវរណធម៌ទាំង ៥ បាន មានពាក្យស្មើកើតឡើងអំពីចិត្តដ៏ស្អាត
ជូរផង់ផ្សង ។ ផ្សាយចេញទៅតាម-កាយទ្វារសម្រេចបានត្រឹមឧបចារ-
សមាធិ បាននាំឈ្មោះថា សីលានុសត្តៃ ។ ៥- ធ្វើបវារណាកម្មចំពោះតាំងសតិនឹង
ព្រះរឿយ ។ នូវចាគគុណ គុណដែលខ្លួនបានបរិច្ចាគបាយទឹកសំពត់ឃាន
ជំនិះ ផ្ការម្រង គ្រឿងក្រអូប គ្រឿងលាប ទីដំណេក ទីនៅអាស្រ័យ
គ្រឿងប្រទីបសម្រាប់អុជ ឲ្យជាទានមិនកើប ដោយការៈនៃខ្លួនមានចិត្ត
គំណោញជាមនុស្សប្រាសចេញជាស្រឡះហើយ ពីតិការនោះថា ចាគំ (๑) ។
តាំងភាពលំចិត្តឲ្យមាំ ដោយអំណាចនៃកិរិយាបង្អោនបង្ហូរជម្រុលចិត្តឲ្យ
ទៅត្រេកអៀសិប់ក្នុងចាគគុណជាការម្មណ៍ អាចត្រូវសង្កត់នូវនីវរណធម៌
ទាំង ៥ បាន មានពាក្យស្មើកើតឡើងអំពីចិត្តដ៏ស្អាតជូរផង់ផ្សង ។ ផ្សាយ
ចេញទៅតាមកាយទ្វារ សម្រេចត្រឹមឧបចារសមាធិ បាននាំឈ្មោះថា

• មានឆាលីខ្លះថា ចាគោ ។ តែក្នុងនីកាព្រះអភិធម្មថា ចាគំ ។ ដូច្នេះ ។

ចាតានុស្សតិ ។ ៦ - ធ្វើបរិកម្មចំរើនតាំងសតិនឹកឃើញរឿយ ។ នូវខេវាគុណឲ្យជាបន្ទាល់សាក្សីនៃខ្លួន ដ៏ឯប្បាស់ថា ខេវាតាំងឡាយប្រកបដោយគុណជមិតាំង ឡាយ ៩ មានសទ្ធាគុណជាដើម យ៉ាំងណាមិញ អញក៏ប្រកបដោយគុណជមិតាំង ៩ យ៉ាំងនោះដែរ ហើយរំពឹងការនាថា ខេវាតា ។ តាំងតម្កល់ចិត្តឲ្យមាំដោយអំណាចនៃកិរិយាបង្អោនបង្វែរជម្រុះចិត្តឲ្យទៅជ្រុះនៅសិប់ក្នុងខេវាតគុណជាតារម្មណ៍ អាចត្រូបសង្កត់នូវនីវរណជមិតាំង ៩ បាន មានពន្លឺស្មើតែឡើងអំពីចិត្តដ៏ស្អាតផូរផង់ផ្សែង ។ ផ្សាយទៅតាមតាយក្នុង សម្រេចត្រឹមឧបចារសមាធិ បានឈ្មោះថា ខេវាតានុស្សតិ ។ ៧ - ធ្វើបរិកម្មចំរើនតាំងសតិនឹកឃើញរឿយ ។ នូវឧបសមគុណនៃព្រះនិញ្វាន ដែលជាគុណជាតកើតឡើងអាចរម្ងាប់នូវកងទុក្ខតាំងអស់បាន រំពឹងការនាថា សន្តំ ។ លេតំទុក្ខ ។ អច្ចុតំ ។ មិនច្យុត ។ សិវំ ។ ខេមំ ។ តាំងតម្កល់ចិត្តឲ្យមាំដោយអំណាចនៃកិរិយាបង្អោនបង្វែរជម្រុះចិត្ត ឲ្យទៅជ្រុះនៅសិប់ក្នុងឧបសមគុណជាតារម្មណ៍ អាចត្រូបសង្កត់នូវនីវរណជមិតាំង ៩ បាន មានពន្លឺស្មើតែឡើងអំពីចិត្តដ៏ស្អាតផូរផង់ផ្សែង ។ ផ្សាយចេញទៅតាមតាយក្នុងសម្រេចត្រឹមឧបចារសមាធិ បានឈ្មោះថា ឧបសមានុស្សតិ ។ ៨ - ធ្វើបរិកម្មចំរើនតាំង

សតិនឹកវត្តុកវើយ ។ ខ្លួមរណៈសេចក្តីស្លាប់មិនទៀងជាប់ខ្លួន តែកើត
ឡើងហើយតាត់ផ្តាច់បង់នូវជីវិតន្ទ្រិយឲ្យសូន្យទៅ ឥតកំណត់កាលឡើយ
ពីឯការនាថា មរណំ ។ ស្លាប់ ។ តាំងឥម្ភល់ចិត្តឲ្យមាំជាយអំណាចនៃ
កិរយាបង្អោន បង្វិរ ជម្រុលចិត្តឲ្យទៅជ្រុកនៅសិប់ក្នុងមរណានុស្សរណៈ
កិរយានឹកវត្តុកវើយ ។ ខ្លួរសេចក្តីស្លាប់ជាអារម្មណ៍ អាចត្រូបសង្កត់
ខ្លួនីវរណធម៌ទាំង ៥ បាន . មានឥន្ទ្រីស្មើកើតឡើង . អំពីចិត្តដ៏ស្អាតផ្លូវ-
ជង់ផ្សែង ។ ផ្សាយទៅតាមកាយទ្វារ សម្រេចត្រឹម ឧបចារសមាធិ បាន
ឈ្មោះថា មរណានុស្សតិ ។ ៩- ឆ្លើបវិតម្ចំរើនតាំងសតិនឹកវត្តុក
វើយ ។ ខ្លួរកាយគោជ្ឈសន្ទិមិត្ត ចំណែកនៃពាងកាយម៉ាន់សក់ជាដើម
ពីឯការនាខ្លួរអាការ ៣២ មានចំរើនថា កេសា ។ លោមា ។ នខា ។ ទន្តា ។
តចោ ។ ជាអនុលោមបតិលោមជាដើម ថាជារបស់ឥតខ្លឹមសារសូន្យសោះ
គួរខ្ពើមដៀលពិត តាំងដំកល់ចិត្តឲ្យមាំជាយអំណាចនៃកិរយាបង្អោន
បង្វិរជម្រុលចិត្តឲ្យទៅជ្រុកនៅសិប់ ក្នុងកាយគោជ្ឈសន្ទិមិត្តជាអារម្មណ៍
អាចត្រូបសង្កត់ខ្លួនីវរណធម៌ទាំង ៥ បាន មានឥន្ទ្រីស្មើកើតឡើងអំពីចិត្តដ៏
ស្អាតផ្លូវជង់ផ្សែង ។ ផ្សាយទៅតាមកាយទ្វារ សម្រេចដល់ឧបចារសមាធិ
ឧដ្ឋានសមាធិ ត្រឹមឋបមជ្ឈានប៉ុណ្ណោះ បានឈ្មោះថា កាយគតា-

សតិ ๆ ๑๐ ធ្វើបរិកម្មចំរើនតាំងសតិនឹកឮកប្រយ៉ ។ ឮអានាបាន:ឮល់ដែលខ្ចូនដកដង្ហើមចេញនឹងដកដង្ហើមចូល ឮដឹងប្រាស់ថា អញដកដង្ហើមចេញវែង អញដកដង្ហើមចូលកំវែងជាដើម រំពឹងតាំនៅថា តានាបានំ ។ អស្សាសបស្សាសា ។ តាំងតម្កល់ចិត្តឲ្យមាំដោយអំណាចនៃកំរោបង្អួនបន្ទូរជម្រុលចិត្តឲ្យទៅជ្រុកនៅសិប់ក្នុងអស្សាសបស្សាសនិមិត្តជាតារម្មណ៍ តាបត្រូបសង្កត់ឮនូវនីវរណតមិនាំង ៥ បាន មានពន្លឺរស្មីកើតឡើងអំពីចិត្តដ៏ស្អាតផូរផង់ផ្សង ។ ផ្សាយចេញទៅតាមតាយទ្វារ សម្រេចដល់បថាវសមាធិនិងអប្បនាសមាធិរហូតបញ្ចាមជ្ឈានដោយពិត បានឈ្មោះថាតានាបានសត្តិ, ត្រូវជាអនុស្សតិ ๑๐ ។

ត្រហ្មវិហារ ๔ នោះគឺ: ๑ : បរិកម្មចំរើនឲ្យប្រៀប ។ ដើម្បីលះបង់នូវព្យាបាទ សេចក្តីក្រោធនឹងតំនុំគំគួនដល់សត្វទាំងឡាយ ដោយមេត្តាចិត្តផ្សាយទៅតាន់ទិសទាំងពួងមានសេចក្តីស្រឡាញ់ពាប់តានស្មើ ប្រមូលមកនូវប្រយោជន៍នឹងសេចក្តីសុខ ។ ចំរើនដល់សព្វសត្វទាំងឡាយជាលក្ខណៈ រំពឹងតាំនៅថា សព្វេ សត្តា អវេរា ហោន្តុ ។ សត្វទាំងឡាយទាំងពួង ចូរកុំឲ្យមានតៀរៅឡើយ ។ សព្វេ សត្តា សុខិតា ហោន្តុ ។ សត្វទាំងឡាយទាំងពួង ចូរឲ្យបានសេចក្តីសុខក្សេមក្សាន្ត ។ តាំងតម្កល់ចិត្តឲ្យ

មាំដោយអំណាចនៃកិរិយា បង្អើន បង្ហូរផ្សែចិត្តឲ្យទៅជ្រកនៅសិចក្នុង
មេត្តាគុណ មានសត្វប្រមាណពុំបានជាអារម្មណ៍ អាចគ្របសង្កត់នូវ
នីវរណធម៌ទាំង ៥ បាន មានពន្លឺស្មើកើតឡើងអំពីចិត្តដ៏ថ្លាស្អាតផូរផង់
ផ្សែង ។ ផ្សាយចេញទៅតាមកាយថ្ងាវ សម្រេចដល់ឧបចារសមាធិ
និងអប្បនាសមាធិត្រឹមចតុកជ្ឈាន បាននាំឈ្មោះថា មេត្តាព្រហ្មវិហារ ។
២- បឋមចំរើនឲ្យរឿយ ។ ដើម្បីលះបង់នូវវិហឹសកម្ម អំពើបៀតបៀន
សម្លាប់សត្វទាំងឡាយ ដោយករុណាសេចក្តីអាណិតអាសូរចំពោះសត្វ
ទាំងឡាយដែលមានសេចក្តីទុក្ខលំបាកផ្សែង ។ មានប្រាថ្នាឲ្យនាំសត្វ
ឲ្យរួចផុតចាកទុក្ខជាលក្ខណៈតែងតែនៅថា សព្វ សត្តា ទុក្ខា ប្បមុញ្ចន្តុ ។
សត្វទាំងឡាយចាំងតួនបួងឲ្យរួចផុតចាកទុក្ខ ។ តាំងតម្កល់ចិត្តឲ្យមាំដោយ
អំណាចនៃកិរិយា បង្អើន បង្ហូរផ្សែចិត្តឲ្យទៅជ្រកនៅសិចក្នុងករុណា-
គុណ មានសត្វប្រមាណពុំបានជាអារម្មណ៍ អាចគ្របសង្កត់នូវ
នីវរណធម៌ទាំង ៥ បាន មានពន្លឺស្មើកើតឡើងអំពីចិត្តដ៏ថ្លាស្អាតផូរផង់
ផ្សែង ។ ផ្សាយចេញទៅតាមកាយថ្ងាវ សម្រេចដល់ឧបចារសមាធិនិង
អប្បនាសមាធិត្រឹមចតុកជ្ឈាន បាននាំឈ្មោះថា ករុណាព្រហ្មវិហារ ។
៣- បឋមចំរើនឲ្យរឿយ ។ ដើម្បីលះបង់នូវសេចក្តីឈ្នានច្រណែនឈ្លោ-

ន័ស មិនត្រេកអរចំពោះសេចក្តីសុខ ចំរើនធំរកោនសម្បត្តិនៃបុគ្គលដទៃ
មានកិរិយាត្រេកអរពេកយចំពោះសុខសម្បត្តិ របស់អ្នកដទៃជាលក្ខណៈ
រំពឹងគាំនាថា សព្វ សត្តា លទ្ធសុខសម្បត្តិតោ មា វិគច្ឆន្តុ ។ សត្វទាំង
ឡាយ ចាំងពួនចូរកុំឲ្យច្រាសឃ្លាតចាកសុខសម្បត្តិដែលខ្លួនបានហើយ ។
តាំងគម្កល់ចិត្តឲ្យមាំជាយកំណាចនៃកិរិយា បង្អោន បង្វែរជម្រុលចិត្តឲ្យ
ទៅជ្រកនៅសិប់ក្នុងមុខតាគុណ មានសត្វប្រមាណពុំបានជាអារម្មណ៍
គាចត្រូបសង្កត់ខ្ទប់នីវរណធម៌ទាំង ៥ បាន មានពន្លឺស្មើតេឡើងគំពីចិត្ត
ដ៏ថ្លាស្អាតផូរផង់ផ្សេង ។ ផ្សាយចេញទៅតាមគាយក្នុង សម្រេចដល់ចតុ-
ចារសមាធិនិងអប្បនាសមាធិត្រឹមចតុកជ្ឈាន បានឈ្មោះថា មុខតា
ត្រហ្មវិហារ ។ កំត្រហ្មវិហារទាំង ៣ មានមេត្តាជាដើមនេះប្រកបដោយ
សោមនស្សវេទនា ជាចេតសិកធម៌មានកម្លាំងថយ ជាគូសត្រូវនឹងចោ-
មនស្សវេទនាឲ្យសម្រេចបានតែត្រឹមចតុកជ្ឈាន ពុំបានសម្រេចដល់បញ្ច-
មជ្ឈានឡើយ ព្រោះមេត្តា ករុណា មុខតាដែលប្រកបដោយសោមនស្ស
នេះ ជាធម៌សម្រាប់លះបង់នូវអកុសលទាំង ៣ គឺព្យាបាទ: ១ វិហឹសា
១ អនភិរតិ សេចក្តីមិនត្រេកអរចំពោះសុខសម្បត្តិអ្នកដទៃ ១ ឲ្យជ្រះស្រ-
ឡះបាន អាចសម្រេចបានតែត្រឹមចតុកជ្ឈានប៉ុណ្ណោះ ។ ៤- បរិកម្មចំរើនឲ្យ

រឿយ ។ ដើម្បីលះបង់នូវចិត្តដែលត្រេកអរក្នុងអកុសលកម្មមានសេចក្តីព្យាបាទជាដើមដោយ ។ បេក្ខាចិត្តជាកុសលប្រតិបដោយបញ្ញាដ៏ឯប្បាស់ជាកម្មជារបស់ខ្លួនពិត ។ មានកិរិយាប្រព្រឹត្តទៅជាតណ្ហាលក្ខណៈក្នុងឥដ្ឋារម្មណ៍ នឹងអនិដ្ឋារម្មណ៍ជាលក្ខណៈ ព្រឹទ្ធាចារ្យនិយាយថា សត្វ សត្តា ឃថា ភ តថា ភ កម្មស្សកា ឥហគ្គុ ។ សត្វទាំងឡាយទាំងពួង មានកម្មស្អាប់ត្រកំរបស់ខ្លួនជាយ៉ាងណា ។ នឹងកើតមានផ្លែផ្កាដូចជាយ៉ាងនោះ ។ តាំងកម្ពស់ចិត្តឲ្យមាំដោយអំណាចនៃកិរិយា បង្អោនចង្អុលចិត្តឲ្យទៅត្រេកនឿសិប់ក្នុងបេក្ខាគុណ មានសត្វនិងសង្ខារប្រមាណពុំបានជាអារម្មណ៍ អាចគ្របសង្កត់នូវគុណធម៌ទាំងឡាយមានឱឡារិកធម៌ជាដើមបាន សម្រេចដល់ឧបចារសមាធិនិងអប្បនាសមាធិ ចំពោះតែបញ្ចមជ្ឈានដែលជាឈានដ៏ឧត្តមខ្ពង់ខ្ពស់ ព្រោះបេក្ខាព្រហ្មវិហារដែលប្រកបដោយបេក្ខាវេទនានេះមានកម្លាំងខ្លាំង អាចញុំាងបញ្ចមជ្ឈានឲ្យតើតខ្លឹងបានដោយពិត ។

៣៩ - បដិកូលសញ្ញា សេចក្តីអធិប្បាយថា ព្រះយោគាវចរកុលបុត្រ បានបរិកម្មចំរើនធ្លាប់ណាត់ចំណាំចាំក្នុងទុកចិត្តប្រព្រឹត្តទៅដោយកិច្ចពិចារណានូវអាហារទាំងពួងថាជាវត្ថុ គឺបុគ្គលតប្បីខ្ចើមរអើមក្រៃពេក ព្រឹទ្ធាចារ្យនិយាយថា កវលិង្ការាហារេ បដិកូលោ ។ អាហារដែលបុគ្គលធ្លាប់

ឲ្យជាពំនួត គួរឧត្តមរអើមក្រៃពេក ។ ដោយអំណាចនៃកាលទាំង-
ឡាយ មានគមនកាល ។ ជាទីដើរចេញទៅ, ឋិតិកាល ។ ជាទី
សែ្វងរកអាហារ, និសជ្ជកាល ។ ជាទីបរិភោគជាដើម តាំងតម្កល់ចិត្ត
ឲ្យមាំដោយអំណាចនៃកិរិយា បង្អោនបង្វែរជម្រុលចិត្តឲ្យទៅជ្រុកនៅស៊ប់
ក្នុងទីបដិកូលជាអារម្មណ៍ អាចត្រូបសង្កត់នូវនីវរណធម៌ទាំង ៥ បាន
សម្រេចត្រឹមឧបចារសមាធិ បាននាមឈ្មោះថា បដិកូលសញ្ញា ។

៣៦ - ធាតុវវត្ថាន ព្រះយោគាវចរកុលបុត្រ បានបរិកម្មចំរើនធ្វើ
កំណត់ខុសកន្លងចិត្តនូវធាតុទាំង ៤ មានមហាធាតុជាដើម ថាជាសភាវៈ
ទ្រទ្រង់នៅ មិនមែនជាសត្វ មិនមែនមានជីវិត តែងសូន្យទៅជាធម្មតា
មានពាក្យពីរោះកាវនាថា កេសា ធាតូ ។ សក់ទាំងឡាយជាធាតុ ។ លោម
ធាតូ ។ កេមទាំងឡាយជាធាតុ ។ ជាដើម តាំងតម្កល់ចិត្តឲ្យមាំដោយ
អំណាចនៃកិរិយាបង្អោនបង្វែរជម្រុលចិត្ត ឲ្យទៅជ្រុកនៅស៊ប់ក្នុងកិរិយា
កំណត់ធាតុទាំង ៤ ជាអារម្មណ៍ ។ អាចត្រូបសង្កត់នូវនីវរណធម៌ទាំង ៥
បាន សម្រេចឧបចារសមាធិ បាននាមឈ្មោះថា ធាតុវវត្ថាន ។

អរូប ៤ នោះគឺ: ទី ១ - ព្រះយោគាវចរកុលបុត្រ ដែលបាននេះ
ស្មាត់ក្នុងរូបជ្ឈាន ទាំង ៥ ហើយបានពិចារណាឃើញនូវទោសនៃ

ភូតរូបចាំង ៤ ដែលធំគ្រាតគ្រាតមិនចង់ឲ្យមានទេ ឬ ចង់ឲ្យមានតែអាកាសធាតុទ្រទ្រង់នូវពិលទេដែលល្អិតផុតផង់ បណ្តាកសិណចាំង ១០ នោះដែលរើទេ ឯងហើយ តើថាលើកសែងចោលនូវកសិណបដិភាគនិមិត្តចាំង ៩ បេញ ដោយពុំបានធ្វើកំណត់ខុសក្នុងចិត្តទេ ហើយត្រាតែកាន់យកបដិភាគនិមិត្តមួយដែលកើតអំពីអាកាសកសិណមកបរិកម្មចំរើនវិញ ។ ភាវនាថា អនន្តំ អាកាសំ ។ អាកាសមានទីបំផុតមិនមាន ។ ឬថា អនន្តោ អាកាសោ ។ អាកាសមានទីបំផុតមិនមាន ។ សំឡឹងបដិភាគនិមិត្តដែលកើតមកអំពីមណ្ឌលនៃអាកាសដ៏ធំទូលាយ មានទីបំផុតមិនមាននោះជាអារម្មណ៍ ក្នុងមនោទ្វារ ដោយចក្ខុបញ្ញាជាទីតេញចិត្តចូលកាន់យកនូវមជ្ឈានតិអាកាសានញ្ចាយតនៈអរូបជ្ឈានទី ១ មានតែអាកាសមានទីបំផុតមិនមានជាអារម្មណ៍ក្នុងអាកាសារម្មណ៍នោះឯង ។ ទី ២- ព្រះយោគាវចរកុលបុត្រ ចាប់ពិចារណាឃើញនូវទោសនៃអាកាសថាធំទូលាយតន់តេកណាស់ នាំឲ្យលំបាកមិនចង់ឲ្យមានទេ ឬ ចង់ឲ្យមានតែវិញ្ញាណជាអារម្មណ៍វិញ ហើយតាំងព្យាយាមបរិកម្មចំរើនតាទៅថា អនន្តំ វិញ្ញាណំ អនន្តំ វិញ្ញាណំ វិញ្ញាណមានទីបំផុតមិនមាន ។ តាំងចំរើនយ៉ាងនេះឲ្យរឿយ ។ ញ៉ាំងអរូបវិញ្ញាណជាបឋមជ្ឈានដែលមានទីបំផុត

មិនមាន ឲ្យបានសម្រេចបួលកាន់បញ្ចមជ្ឈានគឺវិញ្ញាណញ្ចាយតន - អរូប-
ជ្ឈានទី ៤ មានតែអរូបវិញ្ញាណជាបឋម មានទីបំផុតមិនមានជាអាយតនៈ
កើតវិញ្ញាណារម្មណ៍នោះឯង ។ ទី ៣ ព្រះយោគាវចរកុលបុត្របានពិចារ-
ណាឃើញនូវទោសនៃអរូបវិញ្ញាណជាបឋម ផ្សាយទៅដ៏ធំធ្លាយទូលាយ
ពន់ពេកវកទីបំផុតគ្មាន មិនចង់ឲ្យមានអរូបវិញ្ញាណជាបឋមបន្តិចបន្តួចជា
អាយតនៈហើយតាំងក្បាយមបវិតម្មថា នត្ថិ កិញ្ចិ នត្ថិ កិញ្ចិ អរូបវិញ្ញាណ
បន្តិចបន្តួចមិនមានទៀយ ។ តាំងចំរើនយ៉ាងនេះឡើយ ។ ដរាបដល់បាន
សម្រេចលះអស់អរូបវិញ្ញាណជាបឋម ហើយចូលកាន់បញ្ចមជ្ឈាន គឺអា-
កិញ្ចញ្ញាយតន - អរូបជ្ឈានទី ៣ មិនមានអរូបវិញ្ញាណជាបឋមបន្តិចបន្តួច
ជាអាយតនៈកើតបឋមអរូបវិញ្ញាណាការម្មណ៍ គឺឈានមានការមិនមាននៃ
អរូបវិញ្ញាណជាបឋមជាអារម្មណ៍នោះឯង ។ ទី ៤-ព្រះយោគាវចរកុលបុត្រ
បានពិចារណាឃើញនូវទោសនៃអរូបជ្ឈានទី ៣ នេះថា នៅមិនទាន់ល្អិត
ដ៏ខ្ពស់ផុតផ្លែផង់ ព្រោះនៅមានសញ្ញាដ៏គ្រោតគ្រោតមិនចង់ឲ្យបានឡើយ
ហើយតាំងក្បាយមបវិតម្មការនាថា ឯតំ សន្តំ បណីតំ អរូបជ្ឈាន
ទី ៣ នេះដ៏ស្ងប់ទៀ អរូបជ្ឈានទី ៣ នេះ ដ៏ខ្ពស់ម៉ត់ទៀ តាំង
ចំរើនយ៉ាងនេះឡើយ ។ ដរាបបានសម្រេច បួលកាន់បញ្ចមជ្ឈាន គឺ

នេវសញ្ញានាសញ្ញាយតន - អរូបជ្ឈានទី ៤ មិនមានសញ្ញាដ៏គ្រោតគ្រោតសោះ តែថាមិនមែនជាមិនមានសញ្ញាសោះ គឺមានសញ្ញាដ៏ល្អិតផ្សេងជាអាយតនៈក្នុងតតិយារូបជ្ឈានារម្មណ៍ គឺឈានមានអរូបជ្ឈានទី ៣ ជាអារម្មណ៍នោះឯង ។ ឯអរូបជ្ឈានទាំង ៤ នេះប្រកបដោយអង្គតិរៗ ដូចគ្នាគឺ ឧបេក្ខា ១ ឯកគ្គតា ១ សេចក្តីអធិប្បាយដូចអរូបជ្ឈានទី ៥ ដែរ រួមព្រះកម្មដ្ឋានទាំងអស់ គឺកសិណ ១០ អសុភ ១០ អនុស្សតិ ១០ ព្រហ្មវិហារ ៤ បដិកូលសញ្ញា ១ ធាតុវវដ្ឋាន ១ អរូបជ្ឈាន ៤ ត្រូវជាសមថកម្មដ្ឋាន ៤០ គត់ ដោយសង្ខេបតែប៉ុណ្ណេះឯង ។

៥២-ធម្មវិទី ចាន់ស្តាប់ហើយសោលថា សាធុៗម្ចាស់អត្ថាធិប្រស្នាដែលលោកវិសជ្ជនាមកនេះប្រពៃណាស់ចៅយ តែយើងនឹងសួរលោកតទៅទៀត ។ ចុះព្រះយោគាវចរកុលបុត្រ ដែលមានព្យាយាមនឹងរៀនព្រះកម្មដ្ឋានត្រូវឲ្យរៀនសមគួរតាមចរិតរបស់ខ្លួន តើចរិតនោះមានប៉ុន្មាន ? គឺចរិតអ្វីខ្លះ ? កងចរិតមួយៗ មានសេចក្តីអធិប្បាយយ៉ាងណាខ្លះ ? ប្អូរលោកវិសជ្ជនាពន្យល់ចំនួនចរិត ព្រមទាំងសេចក្តីអធិប្បាយ ឲ្យសព្វគ្រប់មក យើងនឹងបានស្តាប់ចូលចិត្តផងមើល ?

អត្ថវិទី វិសជ្ជនាតបថា បពិត្រធម្មវិទី ព្រះយោគាវចរកុលបុត្រដែល

រឿនព្រះកម្មដ្ឋានសមគួរតាមចរិតរបស់ខ្លួននោះ ដោយសង្កេបចរិតមាន៦គឺ រាគចរិត ១ ទោសចរិត ១ មោហចរិត ១ សទ្ធាចរិត ១ ពុទ្ធិចរិត ១ វិតក្កចរិត ១ សេចក្តីអធិប្បាយក្នុងចរិតមួយៗ ដូចេះ ខ ๑- បុគ្គលដែលមានរាគៈជាចរិតនោះតែងមានមាយាបំពុងបាំងទោស ដែលមានក្នុងខ្លួនមិនឲ្យប្រាកដដល់អ្នកដទៃ សំដែងនូវគុណដែលពុំមានក្នុងខ្លួនថាមានក្នុងខ្លួន មានចិត្តប្រកបដោយអស្មិមានៈបើងរើងរូស មានប្រាថ្នាតែអំពើដ៏លាមក ជាអ្នកប្រាថ្នាច្រើនពេកហួសប្រមាណ មិនប្រព្រឹត្តធម៌សន្តោសក្រែកអរស្មើៗ សមគួរតាមលាភ ចូលចិត្តតែប្រដាប់តាក់តែងស្អិតស្អង់កង់កាយជាដើម ចានេះថា បុគ្គលជារាគចរិតៗ ខ ๒- បុគ្គលដែលមានទោសៈជាចរិតនោះ តែងមានចិត្តក្រោធទីឆ ច្រើនតំនុំតុំគួនដល់អ្នកដទៃ ចូលចៅដុតចង់តឿរខុកចំពោះបុគ្គលដទៃ គោលលុបគុណអ្នកដទៃ មានចិត្តថ្នូសា ឈ្លានៈ ប្រណែនខ្លួនសេចក្តីសុខ- ចំរើនឥស្សាតិអ្នកដទៃមិនឲ្យលើសខ្លួន ប្រព្រឹត្តកំណាញ់ព្រឮសាក់លៀមខុកមិនឲ្យដល់បុគ្គលដទៃជាដើម ចានេះថា បុគ្គលជាទោសចរិតៗ ខ ๓- បុគ្គលដែលមានមោហៈជាចរិតនោះ តែងមានសេចក្តីវិលប្រអូសច្រើនធំឯកង្គុយងោកងក់ស្មោកជេកលក់ច្រើន មានចិត្តកយមាយផ្សាយហុយ

ខ្លឹងដូចដែរ ត្រូវឲ្យលើ តែងមានចិត្តក្តៅក្រហាយស្តាយក្រោយជានិច្ច
មានចិត្តសង្ស័យច្រើនមិនចេះជាប់ស្រេច ប្រកាន់យកមាំតែអំពើដែល
មិនមែនជាបុណ្យនៃប្រាជ្ញា លះបង់នូវអំពើដែលធ្វើទុសហើយបានដោយ
កម្រៃក្រៃពេកជាដើម បានឈ្មោះថា បុគ្គលជាមោហចរិត ។ ទី ៤ បុគ្គល
ដែលមានសទ្ធាជាចរិត តែងបរិច្ចាគទានរួចហើយតែងមានចិត្តត្រេកអរ
មិនបានក្តៅក្រហាយស្តាយក្រោយ មានប្រាថ្នាត្រូវការចង់ឃើញនូវព្រះ
អរិយបុគ្គលជាំដរាយ តែងមានសេចក្តីបំណងចង់ស្តាប់នូវព្រះ
សទ្ធម្ម មានសេចក្តីត្រេកអរជ្រះថ្លាច្រើន មិនបានសម្តែងសេចក្តីអំនួត
អួតគុណដែលមិនមានក្នុងខ្លួនឡើយ ជាបុគ្គលមិនមានមាយាចិត្តបាំង
នូវទោសខ្លួនទុក មានសេចក្តីជ្រះថ្លាតែក្នុងទីដែលគួរជ្រះថ្លាជាដើម បាន
ឈ្មោះថាបុគ្គលជាសទ្ធាចរិត ។ ទី ៥ - បុគ្គលដែលមានសេចក្តីចេះដឹង (ឥញ្ញា)
ជាចរិត ជាបុគ្គលនិយាយប្រដៅបានដោយងាយ ចូលចិត្តសេពគប់នូវ
កល្យាណមិត្តដែលមានចិត្តល្អជាកុសល ជាបុគ្គលដឹងប្រមាណក្នុងកិច្ច
បរិភោគនូវភោជនមិនល្មោភឥតកំណត់ មានសតិក្បាក់ស្រឡឹកដឹងខ្លួនល្អ
មានព្យាយាមប្រកបការឿយ ។ ក្នុងកិរិយាក្បាក់ស្រឡឹកពុំភ្លេច មានសេចក្តី
សង្វេគក្នុងទីចាំដរាយដែលគួរសង្វេគ ខំព្យាយាមតម្កល់នូវសេចក្តី

បន្ទូត ដោយ ១ ជាយនៃប្រជាជាដើម ជានឈ្មោះថា បុគ្គលជាពុទ្ធ-
ចរិត ៣ ទី ៦ - បុគ្គលដែលមានវិតក្កៈជាចរិត តែងនិយាយពាក្យ
សំដីច្រើនប្រកបដោយពាក្យសំនួន ចូលចិត្តគ្រេកអរតែក្នុងពួកមនុស្ស
ប្រជុំគ្នាច្រើន មិនគ្រេកអរក្នុងកិរិយាប្រកបរឿយ ៗ ក្នុងធម៌ជាកុសល
មានកិច្ចពុំបានតម្កល់ខ្ជាប់ខ្ជាំឡើយ ច្រើនត្រិះរិះតែពីរឿងផ្សេងៗនូវកិច្ច
កន្លងវេលាយប់ ហើយក្តុះបំភ្លឺនូវកិច្ចនោះឡើងវិញកន្លងវេលាថ្ងៃ មានចិត្ត
គំនិតច្រើនរើសុះរៀបក្នុងអារម្មណ៍ទាំងណោះម្តង ទាំងណោះម្តង ជាដើម
ជានឈ្មោះថា បុគ្គលជាវិតក្កចរិត ៣ វិសជ្ជនាមកអំពីចរិតទាំង ៦ ព្រម
ទាំងសេចក្តីអធិប្បាយដោយសង្ខេបតែប៉ុណ្ណេះឯង ៗ

៥៣- ធម្មវិទូ ជានស្តាប់ឮយ៉ាងនោះថា អើតន្តភ្លេ លោក
វិសជ្ជនាមកនេះយើងស្តាប់ជានហើយ ចុះព្រះកម្មដ្ឋានទាំង ៤០ នោះ
បើចែកតាមនុលោមតាមបុគ្គលដែលប្រកបដោយចរិតទាំង ៦ នោះ តើព្រះ
កម្មដ្ឋានណាខ្លះដែលសមគ្នា ? មានចំនួនប៉ុន្មានដែលជាទីសប្បាយដល់
បុគ្គលទាំងឡាយដែលប្រកបដោយចរិតទាំង ៦ នោះ ? ប្លែរលោកវិសជ្ជនា
ប្បាសំលាស់មកយើងនឹងបានស្តាប់ចូលចិត្តផងមើល ?

អត្ថវិទូ វិសជ្ជនាតបថា បពិត្រធម្មវិទូ ព្រះកម្មដ្ឋាន ១ តែសុក

๑๐ កាយគតាសតិ ๑ ជាទីសប្បាយនៃបុគ្គលជាពតចរិតដោយតិត ។ ព្រះកម្មដ្ឋាន ៨ គឺព្រហ្មវិហារ ៤ វណ្ណកសិណ ៤ ជាទីសប្បាយនៃបុគ្គលជាពោសចរិត ។ ព្រះកម្មដ្ឋានតែ ១ គឺអានាបានសតិ ជាទីសប្បាយនៃបុគ្គលជាមោហចរិតផង វិតក្កចរិតផង ។ ព្រះកម្មដ្ឋាន ៦ គឺអនុស្សតិ ចំនួន ៦ មានពុទ្ធានុស្សតិជាដើម ជាទីសប្បាយនៃបុគ្គលជាសទ្ធាចរិត ។ ព្រះកម្មដ្ឋាន ៤ គឺមរណានុស្សតិ ១ ឧបសមានុស្សតិ ១ បដិកូលសញ្ញា ១ ចតុធាតុវវត្ថាន ១ ជាទីសប្បាយនៃបុគ្គលជាពុទ្ធិចរិត ។ ព្រះកម្មដ្ឋានដ៏សេសសល់ចំនួន ១០ គឺកូនកសិណ ៤ អាកាសកសិណ ១ អាលោកកសិណ ១ អរូបជ្ឈាន ៤ ត្រូវជា ១០ ជាទីសប្បាយនៃបុគ្គលប្រកបដោយចរិតចំនួន ៦ មានបុគ្គលជាពតចរិតជាដើម, បណ្តាចរិត ចំនួន ៦ នោះ កសិណដែលធំត្រាស់ខ្លួនឯងជាទីសប្បាយនៃបុគ្គលជាមោហចរិត, កសិណដែលតូចស្តើងជាទីសប្បាយនៃបុគ្គលជាវិតក្កចរិត ។ រីឯអនុស្សតិមកអំពីព្រះកម្មដ្ឋានចំនួន ៤០ ដែលអនុលោមសមគួរតាមចរិតចំនួន ៦ ដោយសង្ខេបតែប៉ុណ្ណេះឯង ។

៥៤- ធម្មវិទូ ! ចុះស្តាប់ហើយសួរតទៅទៀតថា ម្នាលអត្តវាទីក្នុងព្រះកម្មដ្ឋានចំនួន ៤០ នោះ, តើមានការនាប៉ុន្មាន ? មានន័យប៉ុន្មាន ?

មានសមាធិប៉ុន្មាន ? តើតមានផ្សែងគ្នាយ៉ាងណាខ្លះ ? ចូរលោកវិសជ្ជនា
ឲ្យសព្វគ្រប់មកយើងនឹងបានស្តាប់ចូលចិត្តផងមើល ?

អ្នកវិទ្យុ វិសជ្ជនាតបថា បពិត្រធម្មាចរ្យ កុដិព្រះកម្មដ្ឋានចាំង ៤០
នោះមានភាវនា ៣ គឺបឋមភាវនា ១ ឧបចារភាវនា ១ អប្បនាភាវនា
១ ។ មានឧបេក្ខា ៣ គឺបឋមឧបេក្ខា ១ ទុតិយឧបេក្ខា ១ តតិយឧបេក្ខា ១ ។
មានសមាធិ ៣ គឺបឋមសមាធិ ១ ឧបចារសមាធិ ១ អប្បនាសមាធិ ១
ដូចមានសេចក្តីអធិប្បាយតទៅនេះ គឺភាវនាចាំង ៣ នោះគឺ: ១-ភាវនា
ដែលមានកម្លាំងខ្សោយជាចំណែកខាងដើមដែលព្រះយោគាវចរកុលបុត្រ
ទំព្យាយាមចំរើនធ្វើកំណត់ជាអារម្មណ៍ នៃព្រះកម្មដ្ឋានមានបឋវីកសិណ
ជាដើម កុដិមនោទ្វារហើយតិចារណារឿយ ។ សំឡឹងមើលឧបេក្ខាតើត
អំពីមណ្ឌលនៃកសិណ បានឈ្មោះថា បឋមភាវនា ។ ២-ភាវនាដែល
មានកម្លាំងខ្លាំងបានទុតិយឧបេក្ខាតើតឡើង ហើយជាភាវចរកុសលដែល
បានសង្កត់សង្កិនខ្ទប់នីវរណធម៌បាន មានឧត្តេជកកុសលជវនជាទីបំផុត
គ្រាប់ទៅក្នុងទីជិតនៃអប្បនា ដូចជាឧបចារនៃស្រុក បានឈ្មោះថា
ឧបចារភាវនា ។ ៣-ភាវនាដែលព្រះយោគាវចរកុលបុត្រចំរើនលាបង់ខ្ទប់
នីវរណធម៌ចាំងច្រាំបាន ហើយចូលកាន់មុហុត្តគតគុណជំប្រុសើរតែ បឋម-

ជ្ឈាន. មានវិតក្កជាប្រធានជាវូចារៈបុរសល្បីបំផុត ឬនឈ្មោះថា អប្ប-
នាកាវនា ។ ឯបរិកម្មភាវនាសម្រេចបានក្នុងព្រះកម្មដ្ឋានចំនួន , ឧប-
ចារភាវនាសម្រេចបានតែក្នុងព្រះកម្មដ្ឋាន ១០ គឺ អនុស្សតិ ៨ មានពុទ្ធ-
នុស្សតិជាដើម បដិកូលសញ្ញា ១ ធាតុវវដ្ឋាន ១ ។ អប្បនាភាវនាសម្រេច
បានក្នុងព្រះកម្មដ្ឋានចំនួន ៣០ គឺកសិណ ១០ អនាបានសតិ ១ ប្រកបក្នុង
បញ្ចមជ្ឈាន អសុភ ១០ កាយគតាសតិ ១ ប្រកបក្នុងបឋមជ្ឈាន ព្រហ្ម-
វិហារឈានមេត្តាជាដើម ប្រកបក្នុងចតុត្ថជ្ឈាន ឧបេក្ខាព្រហ្មវិហារ ១
ប្រកបក្នុងបញ្ចមជ្ឈាន កំពុងដ្ឋានចំនួន ៤៦ នេះ ប្រកបក្នុងវូចារជ្ឈាន
អាណុម្ប ៤ ប្រកបក្នុងអវូចារជ្ឈានចំនួន ៤ ដោយពិត ។ និមិត្ត ៣ នោះគឺ:
១-ព្រះយោគាវចរកុលបុត្រចាប់យកនិមិត្តផ្សែងមានកសិណមណ្ឌលជាដើមជាអារម្មណ៍ទំព្យាយាមចំរើនបរិកម្មវិញ ។ ឈ្មោះថាបរិកម្ម-
និមិត្ត ។ ២-ព្រះយោគាវចរកុលបុត្រចាប់រៀនយកនិមិត្តដែលកើតមកអំពី
បរិកម្មភាវនាកើតឡើងច្បាស់ក្នុងចិត្តមនោទ្វារហើយ ដឹងច្បាស់ដោយបច្ចុ-
បញ្ញាជួបជាចាប់ឃើញច្បាស់ដោយភ្នែក ឈ្មោះថា ឧគ្គហនិមិត្ត ។
៣-អំពីឧគ្គហនិមិត្តនោះ ព្រះយោគាវចរកុលបុត្រទំប្រកបចំរើនវិញ ។
ដោយបរិកម្មសមាធិក្នុងឧគ្គហនិមិត្តនោះ , លុះដល់អារម្មណ៍ដែលសម្រេច

ដោយការនា ហៅថា បញ្ញត្តិរួចផុតស្រឡះចាកវត្ថុធម៌ដែលមានចំណែក
ដួច ។ គ្គហនិមិត្តនោះ ដ៏ឆ្អែតស្កប់ស្កាត់ថ្លាស្អាតកើតប្រាកដក្នុងចិត្ត ក្នុង
កាលណា ឈ្មោះថា បដិភាគនិមិត្ត កើតឡើងប្រាកដក្នុងកាល
នោះឯង ។ ឯនិមិត្តទាំងពីរនេះបរិកម្មនិមិត្ត ១ ។ គ្គហនិមិត្ត ១ នេះសម្រេច
បានក្នុងព្រះកម្មដ្ឋានទាំងអស់សមគួរតាមហេតុពិត, ឯបដិភាគនិមិត្តសម្រេច
បានតែក្នុងព្រះកម្មដ្ឋាន ៦២ គឺកសិណ ១០ អសុភ ១០ កាយគតាសតិ ១
អានាបានសតិ ១ ចុំណោះ ។ សមាធិ ៣ នោះគឺ ១ - ព្រះយោគាវចរ -
កុលបុត្រដែលមានចិត្តដំកល់ម៉ាំមិនរើរវេរាយក្នុងកិច្ចបរិកម្ម ឈ្មោះថា
បរិកម្មសមាធិ ។ ២ - ព្រះយោគាវចរកុលបុត្រដែលមានចិត្តដំកល់ម៉ាំមិនរើ -
រវេរាយក្នុងកិច្ច ។ បចារ ឈ្មោះថា ។ បចារសមាធិ ។ ៣ - ព្រះយោគា -
ចរកុលបុត្រដែលមានចិត្តដំកល់ម៉ាំមិនរើរវេរាយក្នុងកិច្ចអប្បនា ឈ្មោះ
ថា អប្បនាសមាធិ ។ ម្យ៉ាងទៀត ព្រះយោគាវចរកុលបុត្រទាំងឡាយ
ដែលបានព្យាយាមរៀនទូវបណ្តាព្រះកម្មដ្ឋានទាំង ៤០ នោះ ព្រះកម្មដ្ឋាន
ឯណាមួយ ហើយបានកើតគុណវិសេសត្រឹម ។ បចារ តាំនាប្ត ។ បចារ -
សមាធិបានឈ្មោះថា កាមាវចរកម្មដ្ឋាន បើបានកើតគុណវិសេសដល់
អប្បនាតាំនា ឬអប្បនាសមាធិ បានឈ្មោះថា រូបាវចរកម្មដ្ឋាន ឬ

អប្បោរវៀរកម្មដ្ឋានដោយសមគួរតាមលំដាប់ ។ រីសជ្ឈនាមកអំពីភាវនា ៣ និមិត្ត ៣ សមាធិ ៣ ដោយសេចក្តីសង្ខេបតែប៉ុណ្ណេះឯង ។

៥៥- ធម្មវិទូ បានស្តាប់ហើយគោលថា ម្នាលអត្តវាទី ប្រស្នានេះប្រសែរហើយ តែយើងនឹងសួរប្រស្នាដទៃតទៅទៀត បុព្រះយោគាវចរកុលបុត្រដែលមានប្រាថ្នាចំរើនព្រះកម្មដ្ឋានទាំងអស់នេះ ក្នុងគម្ពីរព្រះត្រៃបិដកគឺព្រះវិន័យព្រះសូត្រព្រះអភិធម្ម ក្នុងកាលមុនជាមាន ដើមដែលពុំទាន់ភាវនាព្រះកម្មដ្ឋានណាមួយ តើមានចាប្បីបង្ហាប់ឲ្យសូត្រភាពនាខ្លះដែរ ឬគ្មានទេ? ឬមានចាប្បីបង្ហាប់ឲ្យសូត្រដូចម្តេចខ្លះ? ចូរលោកវិសជ្ឈនាឲ្យប្រាកដមកយើងនឹងបានស្តាប់ចូលចិត្តផងមើល ?

អ្នកវិទូ វិសជ្ឈនាតបថា បពិត្រធម្មវាទី ខ្ញុំព្រះករុណាបានសង្កេតពិនិត្យមើលចាប្បីក្នុងគម្ពីរព្រះត្រៃបិដក ដោយសព្វគ្រប់ពុំឃើញមានចាប្បីក្នុងគម្ពីរណាបង្ហាប់ឲ្យសូត្រភាពនាព្រះកម្មដ្ឋាននោះទេ ឃើញមានតែចាប្បីក្នុងគម្ពីរព្រះវិសុទ្ធិមគ្គមានបង្ហាប់ថា ព្រះយោគាវចរកុលបុត្រដែលនឹងរៀនព្រះកម្មដ្ឋាននោះ ត្រូវសូត្រចាប្បីសួមសេចក្តីសង្គ្រោះ អំពីសំណាក់អាចារ្យនឹងសូត្រសួមសេចក្តីសង្គ្រោះ អំពីសំណាក់ព្រះសង្ឃសម្ពុជាមុនសិន ដើម្បីការពារនូវសេចក្តីអន្តរាយទាំងឡាយ មិនឲ្យកើតមានឡើង

ដល់ខ្ញុំកន្លងកាលដែលចំរើនព្រះកម្មដ្ឋាននោះ ឯចារ្យសម្រាប់សូត្រ
សូមសេចក្តីសង្គ្រោះអំពីសំណាក់អាចារ្យនោះគឺ ត្រូវបួលទៅជិតតាន់សំ-
ណាក់អាចារ្យគោរពថ្វាយបង្គំហើយសូត្រថាឡើយ (ខុកាស) ឥមាហំ
ភន្តេ អត្តភាវំ តុម្ហាកំ បរិច្ចជ្ជាមិ (សូមខុកាស) បពិត្រលោក
ដ៏ចំរើន ខ្ញុំព្រះករុណា សូមលះបង់នូវអត្តភាពនេះចំពោះលោកម្ចាស់,
ទុតិយម្បិ ឥមាហំ ភន្តេ អត្តភាវំ តុម្ហាកំ បរិច្ចជ្ជាមិ បពិត្រ
លោកដ៏ចំរើន ខ្ញុំព្រះករុណា សូមលះបង់នូវអត្តភាពនេះចំពោះលោកម្ចាស់
អស់ពីរៈជាគំរប់ពីរដងផង, តតិយម្បិ ឥមាហំ ភន្តេ អត្តភាវំ
តុម្ហាកំ បរិច្ចជ្ជាមិ បពិត្រលោកដ៏ចំរើន ខ្ញុំព្រះករុណា សូមលះបង់នូវ
អត្តភាពនេះចំពោះលោកម្ចាស់អស់ពីរៈជាគំរប់បីដងផង ។ បើសូត្រ
សូមសេចក្តីសង្គ្រោះអំពីសំណាក់ព្រះសម្មាសម្ពុទ្ធនោះ ត្រូវតាំងនមស្សការ
នឹករលឹកព្រះពុទ្ធគុណ ធម្មគុណ - សង្ឃគុណស្រេចហើយសូត្រថាឡើងវិញ
សន្តហរថា (ខុកាស) ឥមាហំ ភគវតិ អត្តភាវំ តុម្ហាកំ បរិច្ច-
ជ្ជាមិ (សូមធ្លាក់ខ្លួនក្នុងទីនេះ) បពិត្រព្រះដ៏មានព្រះភាគខ្ញុំព្រះអង្គ
សូមលះបង់នូវអត្តភាពនេះថ្វាយចំពោះព្រះអង្គ, ទុតិយម្បិ ឥមាហំ

ភគវា អត្តភារំ តម្ហាកំ បរិប្ជុជ្ជាមិ បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះករុណា សូមលះបង់នូវអត្តភាពនេះ ថ្វាយចំពោះព្រះអង្គអស់កាល:ជានិរន្តរ, តតិយម្បិ ខ្ញុំ ភគវា អត្តភារំ តម្ហាកំ បរិប្ជុជ្ជាមិ បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គសូមលះបង់នូវអត្តភាពនេះថ្វាយចំពោះព្រះអង្គ អស់កាល:ជានិរន្តរ ។ ស្រេចហើយទើបទ្បៀបរៀនព្រះកម្មដ្ឋានជាខាងក្រោយ ឥដ្ឋបានសម្រេចដូចសេចក្តីប្រាថ្នាដោយពិត ឯសាធុជនជាយោគាវចរកុលបុត្រដែលនឹងចំរើនព្រះកម្មដ្ឋាននោះ បើពុំបានសូត្រចូលសន្ធហ:នេះទេ បានឈ្មោះថា ពុំទាន់បានទូន្មែនឹងមាំក្នុងព្រះពុទ្ធសាសនាឡើយ បើបានសូត្រចូលសន្ធហ:នេះហើយទើបបានឈ្មោះថា បានទូន្មែនឹងមាំក្នុងព្រះពុទ្ធសាសនាដោយពិត អាចបានសម្រេចទូន្មែនប្រាជ្ញាដ៏ចំរើនពេញបរិបូណ៌ ព្រះធម៌ឥតកើតឡើងប្រាកដក្នុងមនោទ្វារ-កាយទ្វារតាមសភាពពិត ។ មួយវិញទៀត អាចកំចាត់បង់នូវសេចក្តីអន្តរាយទាំងពួង មានកេរៀវមិច្ឆាគឺអាម្មណ៍គួរខ្ជាប់ស្អប់ស្មៃឯជាដើម មិនបានកើតចូលមកកាន់ចក្ខុទ្វារ-មនោទ្វារ បើកុំឲ្យកើតមកហើយក៏គង់វិនាសសាបសូន្យបាត់បង់ទៅវិញមួយរំពេច ។ ម្យ៉ាងទៀតមកកំពុងលើសម្រាប់សូត្រសូមសេចក្តីសង្គ្រោះ ប្តូរយកខ្លួន ក្នុងកាលមុន

ពេលដែលបំពេញកម្មការនា ដោយសេចក្តីសង្ខេបតែប៉ុណ្ណេះឯង ។

៥៦- ធម្មវិទី បានស្តាប់ហើយពោលថា ម្នាលអត្តវិ ប៉ុន្តែ:- យោគាវចរកុលបុត្រដែលបានចំរើនព្រះកម្មដ្ឋានញ៉ាំងឈាន ឲ្យកើតឡើងហើយថា ត្រូវចំរើនឲ្យស្ទាត់ក្នុងឈានដោយវសីពាន់ប្រាំនោះ តើតីវសីក្នុង?? សេចក្តីអធិប្បាយថាដូចម្តេច ?

អត្តវិទី វិសជ្ជនាតបថា បពិត្រធម្មវិ ឯព្រះយោគាវចរកុលបុត្រដែលបានចំរើនធ្វើឈានឲ្យកើតឡើងហើយ ត្រូវធ្វើឈានឲ្យស្ទាត់ជំនាញដោយវសីពាន់ប្រាំនោះគឺ: ១ - អាវជ្ជនវសី ចំរើនឲ្យស្ទាត់ជំនាញមិនបាច់ចាំកាន់យកនូវកង្វល់តទៅតមកអំពីកង្វល់កើតឡើងតស់ពាក់:មួយដង តាំងពីកន្លងទាន់នាទេអំពីជវនៈទី ៤ ទី ៥ នោះទៅយ ហើយអាចពិចារណាដ៏ច្បាស់នូវអង្គនៃឈានក្នុងលំដាប់នៃជវនៈដែលកើតឡើងក្នុងអារម្មណ៍មួយៗដោយពិត ។ ២- សមាបជ្ជនវសី ចំរើនឲ្យស្ទាត់ជំនាញមិនបាច់ផ្សងចិត្តស្ទុះទៅកាន់កង្វល់ពីរបីក្នុងលំដាប់នៃចិត្តដែលមានគ្រាជ្ញាដើម្បីចូលកាន់ឈាន ហើយអាចនឹងចូលកាន់ឈានក្នុងលំដាប់នៃជវនៈដែលកើតឡើងហើយដោយហ៊ាស ។ ៣- អធិដ្ឋានវសី ចំរើនឲ្យស្ទាត់ជំនាញដឹងពេលដើម្បីកាត់ផ្តាច់នូវវេលានៃកង្វល់ហើយដំកល់នូវឈាន ឲ្យឋិតនៅសម

គួរតាមកាលវៃលខ្លួនកំណត់ខុសហើយ ប្រកបក្នុងកិរិយាវក្សាខ្លួវជាវេនមិន
ឲ្យភ្លាត់ចុះមកតាន់អង្គវិញ អាចជំកល់តាំងនៅក្នុងឈានមិនឲ្យជ្រុលហួសអំពីកាលវៃលខ្លួនបានកំណត់ខុសនោះឡើយ ។ ៤-វុដ្ឋានវសី ចំរើនឲ្យស្ទាត់ជំនាញ មិនបានឲ្យប្រព្រឹត្តកន្លងខ្លួវកាលវៃលខ្លួនបានកំណត់ខុសដោយសមគួរ ហើយអាចនឹងចេញចាកឈានវៃលខ្លួនបានបួលសមគួរតាមកំណត់ តែថាមិនបានចេញចាកឈានខាងក្នុងចន្លោះនៃកាលវៃលខ្លួនកំណត់ អាចចេញអំពីឈានដោយអំណាចនៃកាលដ៏សមគួរតាមកំណត់ពិត ។ ៥-បច្ចវេក្ខណាវសី ចំរើនឲ្យស្ទាត់ជំនាញក្នុងខណៈតិចារណាដោយប្រាថ្នាដឹងច្បាស់ខ្លួឈានដោយកិច្ចតាំងខ្លួយ មានតិចារណាខ្លួវអង្គនៃឈានតាំងខ្លួយ ដោយសមគួរតាមប្រាថ្នាជាដើមនឹងលះបង់ខ្លួវអង្គនៃឈានដ៏គ្រោតគ្រោត ហើយបួលតាន់ឈានជាលំដាប់ មានខុតិយជ្ឈានតតិយជ្ឈានជាដើម ដែលមានអង្គដ៏ល្អិតផ្លូវផង់ជាសុខសប្បាយយ៉ាងសំខាន់ ។ ព្រះយោគាវចរកុលបុត្រដែលបានឈានហើយត្រូវហាត់ចិត្តឲ្យស្ទាត់ជំនាញដោយវសីតាំងប្រាំនេះ ទើបបានឈ្មោះថាបានឈានពិតប្រាកដមែន ។ រៃសួនាមកអំពីវសីតាំងប្រាំដោយសង្ខេបតែប៉ុណ្ណេះឯង ។

កុសលចិត្តដែលធ្វើវិនាសកាន់តែចាស់ណា ឃើញជាកំណាស់នូវព្រះ
អរិយសច្ចទាំង ៤ មានទុក្ខសច្ចជាដើម ហើយលះបង់ប្រព្រឹត្តនូវគ្រ
ឿងកាន់ព្រះអរិយគោត្រក្នុងមុនចាកលោកទាំង ៣ មានកាមលោកជា
ដើម ហៅថា លោកុត្តរកុសលចិត្តមាន ៤ គឺព្រះអរហំសម្មាសម្ពុទ្ធទ្រង់
សំដែងនៅចែកជា ៤ ចំណែកតាមប្រភេទនៃមគ្គ ៤ ឲ្យ ឈ្មោះថា សោតាបត្តិ-
មគ្គចិត្ត ១ សកទាគាមិមគ្គចិត្ត ១ អនាគាមិមគ្គចិត្ត ១ អរហត្តមគ្គចិត្ត ១
ឯវិបាកវបស់លោកុត្តរកុសលចិត្តនោះ ព្រះអង្គទ្រង់សំដែងនៅចែកជា ៤
ចំណែក តាមប្រភេទនៃផល ៤ ឲ្យ ឈ្មោះថា សោតាបត្តិផលចិត្ត ១
សកទាគាមិផលចិត្ត ១ អនាគាមិផលចិត្ត ១ អរហត្តផលចិត្ត ១ ព្រោះ
ការ:នៃលោកុត្តរវិបាកចិត្តនោះជាផលរបស់លោកុត្តរកុសលចិត្តនោះឯង ។
សេចក្តីអធិប្បាយពាក្យថា ទី ១ - សោតសត្ត ប្រែថា ស្តាប់ ព្រោះ
អាស្រ័យនូវព្រះនិព្វានធ្វើឲ្យជាអារម្មណ៍ហើយស្តាប់ប្រតិបត្តិតាម, សោត-
សត្ត ប្រែថា ទៀ ព្រោះព្រះធម៌ដ៏ប្រសើរប្រែកបដោយអង្គទាំង ៨ លោក
ពោលឲ្យ ឈ្មោះថា សោត: ច្រកតែងស្ទើរដោយទៀទ័ក, អាសត្ត ប្រែថា
ខាងដើម ឬទីមួយ, បត្តិសត្ត ប្រែថា កំរោងផល ស្តាប់គ្នាជាអាបត្តិ
ប្រែថា កំរោងផលជាខាងដើមឬទីមួយ; ប្រជុំបទ ៣ គស្តាប់គ្នាជា

សោតាបត្តិ ជានសេចក្តីថា កិរិយាដល់ជាទាន់ដោយឫទ្ធិមួយនៃព្រះធម៌ដ៏ប្រសើរដែលប្រកបដោយអង្គ ៨ ជានឈ្មោះថា . សោតៈ ប្រែថា ស្តាប់ ព្រោះអាស្រ័យនូវព្រះនិព្វាន ធ្វើឲ្យជាអារម្មណ៍ហើយស្តាប់ប្រតិបត្តិតាមគឺបង្អោនចង្អុរជម្រុលចិត្តឲ្យចូលទៅជិតកាន់ព្រះនិព្វាន ជានឈ្មោះថា សោតៈ ប្រែថា ខ្សែ ព្រោះព្រះធម៌ដ៏ប្រសើរដែលប្រកបដោយអង្គទាំង ៨ នោះដ៏ច្រើនដូចស្មើដោយខ្សែទឹកបង្អោនចង្អុរជម្រុលចិត្តឲ្យចូលទៅជ្រកនៅស៊ប់សួនក្នុងមហាសមុទ្រ គឺព្រះនិព្វាន, មគ្គសព្ទ ប្រែថា ស្មូដ៏រកនូវព្រះនិព្វាន សេចក្តីអធិប្បាយថា ព្រះធម៌ដ៏ប្រសើរឯណា សម្រាប់ស្មូដ៏រកព្រះនិព្វាន ឬថា ដែលបុគ្គលទាំងឡាយអ្នកមានប្រយោជន៍ដោយព្រះនិព្វាន ត្រូវស្មូដ៏រកព្រះធម៌ដ៏ប្រសើរនោះ ជានឈ្មោះថា មគ្គ ម្យ៉ាងទៀត ព្រះធម៌ដ៏ប្រសើរណា រមែងសម្លាប់ផ្តាច់បង់នូវកិលេសទាំងឡាយ ដោយសមុច្ឆេទប្បហារហើយប្រព្រឹត្តទៅ ព្រះធម៌ដ៏ប្រសើរនោះ ជានឈ្មោះថា មគ្គ គឺព្រះអរិយមគ្គប្រកបដោយអង្គ ៨ ពិត, កុសលចិត្តដែលកើតឡើងធំធំរលត់ទៅវិញជាមួយនឹងមគ្គ ជានឈ្មោះថា មគ្គចិត្ត, ប្រជុំបទទាំង ៣ តភ្ជាប់គ្នា ជានឈ្មោះថា សោតាបត្តិមគ្គចិត្ត ជានសេចក្តីថា កុសលចិត្តកើតឡើងធំធំរលត់ទៅវិញ ជាមួយនឹងមគ្គ

ដែលជាផ្លូវសម្រាប់ស្វែងរកនូវព្រះនិព្វាន ឬថាផ្លូវដែលបុគ្គលចាំងឲ្យ
អ្នកមានប្រយោជន៍ដោយព្រះនិព្វានត្រូវស្វែងរក ឬថាជាធម៌ដ៏ប្រសើរ
តែងសម្លាប់ផ្តាច់បង់នូវកិលេសចាំងឲ្យ ដោយសមុច្ឆេទប្បហានរបស់
ព្រះអរិយបុគ្គលទី ១ ដែលចានជាន់ជាទាំងដើមនៃទ្វីមួយនៃព្រះអរិយ-
មគ្គពិត ។ ទី ២-សកឹសព្ទ ប្រែថា អស់ពាះមួយដង, អាគមិសព្ទ ប្រែថា
ត្រឡប់មក តក្លាប់គ្នាចាំងពីរបែបជា សកិទាគាមិ បានសេចក្តីថាព្រះ
អរិយបុគ្គលត្រឡប់មកកាន់មនុស្សលោកនេះ ដោយអំណាចនៃបដិសន្ធិ-
ចិត្តអស់ពាះមួយដងទៀត មគ្គសព្ទ ទី ២ នេះ អធិប្បាយដូចមគ្គសព្ទទី ១
ដែរ កំពុសលចិត្តដែលកើតឡើងនឹងរលត់ទៅវិញជាមួយនឹងមគ្គ បាន
ឈ្មោះថា មគ្គចិត្ត តក្លាប់គ្នាចាំង ៤ បរ បានឈ្មោះថា សកិទាគាមិ-
មគ្គចិត្ត បានសេចក្តីថា កុសលចិត្តកើតឡើងនឹងរលត់ទៅវិញជាមួយ
នឹងមគ្គដែលជាផ្លូវដ៏ប្រសើរសម្រាប់ស្វែងរកនូវព្រះនិព្វាន ឬថាជាផ្លូវ
ដែលបុគ្គលចាំងឲ្យ អ្នកមានប្រយោជន៍ដោយព្រះនិព្វានត្រូវស្វែងរក
ឬថាជាធម៌ដ៏ប្រសើរតែងសម្លាប់ផ្តាច់បង់នូវកិលេសចាំងឲ្យដោយសមុ-
ច្ឆេទប្បហាន របស់ព្រះអរិយបុគ្គលទី ២ អ្នកត្រឡប់មកកាន់មនុស្សលោក
នេះ ដោយអំណាចនៃបដិសន្ធិចិត្តអស់ពាះមួយដងទៀត ដោយពិត ។

ខ្ញុំ ๓ - អនាគាមិសកឬ ប្រែថា ព្រះអរិយបុគ្គលលោកពុំបានត្រឡប់មក
កាន់កាមជាតុនេះជាយអំណាចនៃបដិសន្ធិចិត្តឡើយ មគ្គសកឬខ្ញុំ ๓ នេះ
អធិប្បាយដូចមគ្គសកឬខ្ញុំ ๑ ដែរ កំពុសលចិត្តកើតឡើងនឹងរលត់ទៅវិញ
ជាមួយនឹងមគ្គ ចានឈ្មោះថា មគ្គចិត្ត ឥស្សាចំគាំងឆ្ងាយ ចានឈ្មោះ
ថា អនាគាមិមគ្គចិត្ត ចានសេចក្តីថា កុសលចិត្តកើតឡើងនឹងរលត់ទៅ
វិញជាមួយនឹងមគ្គជាផ្លូវដ៏ប្រសើរ សម្រាប់សែ្វងរកនូវព្រះនិព្វាន ឬថាជា
ផ្លូវដែលបុគ្គលចាំងឡាយអ្នកមានប្រយោជន៍ ដោយព្រះនិព្វានត្រូវសែ្វងរក
ឬថាជាធម៌ដ៏ប្រសើរ តែងសម្លាប់ផ្តាច់បង់នូវកិលេសចាំងឡាយ ដោយ
សមុច្ឆេទប្បហាន របស់ព្រះអរិយបុគ្គលខ្ញុំ ๓ លោកពុំបានត្រឡប់មក
កាន់កាមជាតុនេះជាយអំណាចនៃបដិសន្ធិចិត្តទៀតឡើយ ។ ខ្ញុំ ๔ - អរហត្ត
មគ្គចិត្ត សេចក្តីអធិប្បាយថា កុសលចិត្តកើតឡើងនឹងរលត់ទៅវិញជា
មួយនឹងមគ្គជាធម៌ដ៏ប្រសើរ តាចសម្លាប់ផ្តាច់បង់នូវកិលេសចាំងឡាយ
ចានជាយសមុច្ឆេទប្បហាន របស់ព្រះអរិយបុគ្គលខ្ញុំ ๔ ដែលលោកចាន
សម្លាប់ផ្តាច់បង់នូវសែ្រតីកិលេសចាន លោកពុំបានធ្វើនូវអំពើចាបសា-
មកកន្លងសែ្វងកំចាំងឡើយ លោកចានផ្តាច់បង់នូវតាំសង្សារបត្រចាន ជា
បុគ្គលគួរទទួលនូវបូជាដ៏វិសេស ដែលមនុស្សព្រមចាំងទេវតាចាំងឡាយ

នាំមកបូជាចំពោះលោក ដោយភាវៈនៃលោកជាខេត្តណេយ្យបុគ្គលដ៏ប្រសើរឥតខ្ចីខ្ចះ ។ ឯផលចិត្តទាំង ៤ មានសេចក្តីអធិប្បាយដូចគ្នានឹងមគ្គចិត្តដែរ ម្យ៉ាងទៀតត្រង់ពាក្យថា លោកុត្តរវិបាកចិត្ត លោកឲ្យឈ្មោះថា ផលចិត្តវិញ ព្រោះថាចិត្តជាផលដែលព្រះអរិយបុគ្គលលោកបានហើយ កើតមកអំពីលោកុត្តរកុសលចិត្តនោះឯង ។ រួមគ្នាទាំងអស់ត្រូវជាលោកុត្តរចិត្តទាំង ៨ ព្រោះពុំមានកិរិយាចិត្តឡើយ ។ វិសជ្ជនាមកអំពីលោកុត្តរសោភណចិត្តទាំង ៨ ដោយសេចក្តីពិស្តារខ្លះ សង្ខេបខ្លះតែប៉ុណ្ណោះឯង ។

៥៨-ធម្មវិទី បានស្តាប់ហើយ សួរតទៅទៀតថា ម្នាលអត្ថកថី ចុះបើសំដែងជាបុគ្គលាធិដ្ឋានយកបុគ្គលជាធីតាំងវិញ តើបុគ្គលប្សរតេទទាំងអស់មានប៉ុន្មានពួក? ចែកផ្សងគ្នាដូចម្តេចខ្លះ? អធិប្បាយយ៉ាងណាខ្លះ? ចូរវិសជ្ជនារៀបរាប់ឲ្យសព្វគ្រប់មកយើងនឹងបានស្តាប់ចូលចិត្តផងមើល?

អត្ថវិទី វិសជ្ជនាតបថា បពិត្រធម្មកថី តើបុគ្គលប្សរតេទលោកសំដែងចែកជា ១៦ ពួក គឺព្រះអរិយបុគ្គល ៨ ពួក គឺបុគ្គលដែលបានសម្រេចសោតាបត្តិមគ្គពួក ១ ។ ល ។ បុគ្គលដែលបានសម្រេចព្រះ

អរហត្តផលពួក ๑ ត្រូវជាព្រះអរិយបុគ្គលចាំង ๘ ពួក; ចើសំដែង
ប្រៀបមានព្រះអរិយបុគ្គលចាំង ๘ ពួកនោះឡើតចបុរមកុមាន ๔ ពួកគឺ:
សោតាបន្នបុគ្គល ๑ សកទាគាមីបុគ្គល ๑ អនាគាមីបុគ្គល ๑ អរហន្ត-
បុគ្គល ๑ ត្រូវជា ๔ ពួក; បុថុជ្ជនបុគ្គលមាន ๔ ពួកគឺ: តិហេតុកបុគ្គល ๑
ទុហេតុកបុគ្គល ๑ អហេតុកបុគ្គល ๑ ពាធាយិកាហេតុកសត្ត ๑ ត្រូវជា ๔
ពួក ជាន់សេចក្តីថាចើចែកដោយពិស្តារមាន ๑๒ ពួកដោយសង្ខេបមាន ๘
ពួកត្រូវថាមគ្គចិត្តកើតឡើងហើយ ផលចិត្តក៏កើតឡើងជាលំដាប់នៃមគ្គ-
ចិត្តនោះដែរ តែថាដែលលោកចែកព្រះអរិយបុគ្គលទៅជា ๘ ពួកនោះ
គឺលោកចែកទៅតាមលោកុត្តរកុសលវិបាកចិត្តនោះឯង ។

๕๘- ធម្មវាទី ជាន់ស្តាប់ហើយ សួរតទៅទៀតថា ម្នាល
អត្តវាទី ចុះព្រះសោតាបន្នបុគ្គលទី ๑ ក្តី ព្រះសកទាគាមីបុគ្គលទី ๒ ក្តី
ព្រះអនាគាមីបុគ្គលទី ๓ ក្តី ព្រះអរហន្តបុគ្គលទី ๔ ក្តី លោកជាន់
លះបង់នូវសំយោជនធម៌ប៉ុន្មាន? រៀវលែងចាកចើចិត្តប៉ុន្មាន? មានចើចិត្ត
ប៉ុន្មាន ដែលបំតនៅក្នុងសន្តានរបស់លោកដ៏សមគួរតាមជាន? សេចក្តី
អធិប្បាយផ្សេងគ្នាយ៉ាងណាខ្លះ? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់យើងនឹង
ស្តាប់ចូលចិត្តផងមើល?

អត្ថវិទី វិសជ្ជនាតថា បតិក្រុងម្ចាស់ ព្រះសាតាបន្ទប្បត្តសី ๑
នោះ លោកបានលះបង់នូវសំយោជនធម៌ជាំ ๓ បាន តំសក្កាយទិដ្ឋិ
សេចក្តីប្រកាន់ក្តីប្បជិបត្តិតាមតំនិតយល់ឃើញរបស់ខ្លួន ๑ វិចិកិច្ឆា
សេចក្តីសង្ស័យមិនបះជាប់ស្រេច ๑ សីលព្វតបរាមាសៈ សេចក្តី
បរិបូរណ៍ដែលប្រកាន់សីលវត្តរបស់ខ្លួនថាប្រសើរពិសេស ๑ តីដរឿ
លែងជាកវិថីចិត្ត ๓๘ តីអហេតុកហសនកិរិយាចិត្ត ๑ តាមាវចរមហា-
កិរិយាចិត្ត ๘ មហគ្គតកិរិយាចិត្ត ๙ (ជា ๑๘) អកុសលចិត្តប្រកប
ដោយសោមនស្សវេទនាជាទិដ្ឋគតសម្បយុត្ត ๒ អកុសលចិត្តប្រកបដោយ
ឧបេក្ខាវេទនាជាទិដ្ឋគតសម្បយុត្ត ๒ វិចិកិច្ឆាសម្បយុត្ត ๑ (ជា ๕)
មគ្គចិត្ត ๔ ផលចិត្ត ๓ មហគ្គតចិត្ត ๙ ត្រូវជា ๓๙ ពុំបានកើតអនេឡ័ង
ក្នុងសន្តានលោកនោះឡើយ មានតែវិថីចិត្ត ๘๑ តីអហេតុកអកុសល-
វិបាកចិត្ត ๗ អហេតុកកុសលវិបាកចិត្ត ๘ សហេតុកមហាវិបាកចិត្ត ๘
(ជា ๒๓) បញ្ចទ្វារាវជ្ជនចិត្ត ๑ មនោទ្វារាវជ្ជនចិត្ត ๑ (ជាអាវជ្ជនចិត្ត២)
សហេតុកកាមាវចរកុសលចិត្ត ๘ រូបាវចរកុសលចិត្ត ๕ អរូបាវច-
កុសលចិត្ត ๔ លោកុត្តរកុសលចិត្ត ๔ (ជា ๑๘) អកុសលចិត្ត ๗
សោភនចិត្តផលចិត្ត ๑ រួមជាំនិងអស់ត្រូវជា ๘๑ តើតរឡើងត្រាកដកន្លង

សន្ដានៃព្រះសោតាបន្នបុគ្គលនោះ សមគួរតាមបានដោយពិត ។

ទី ๒ - ព្រះសកទាគាមីបុគ្គលនោះលោកចន្ទលះបង់នូវសំយោជន-ធម៌ជាចំណែកនៃកាមធាតុទាំង ៥ បានគឺ សក្កាយទិដ្ឋិ ๑ វិចិកិច្ឆា ๑ សីលព្វតបរាមាសៈ ๑ កាមរាគៈ សេចក្ដីជម្រែកត្រេកត្រអាលក្នុងកាមគុណ ๑ បដិឃៈ សេចក្ដីថាំងថ្នាក់ស្អប់ក្រហាយចិត្តប្រកបដោយទោមនស្ស ๑ ត្រូវជា ៥ តែថាកាមរាគៈនិងបដិឃៈចិត្តទាំង ២ នេះ គ្រាន់តែតិចស្តើងប៉ុណ្ណោះ ឧដ្ឋរៀវលែងចាកវិចិកិច្ឆាចិត្ត ៣៨ គឺ កិរិយាចិត្ត ๑៨ អកុសលចិត្ត ៥ មគ្គចិត្ត ៣ ផលចិត្ត ៣ មហគ្គតកិរិយាចិត្ត ៩ ត្រូវជា ៣៨ ពុំបានកើតឡើងក្នុងសន្ដានលោកនោះឡើយ មានតែវិចិកិច្ឆាចិត្ត ៥๑ គឺ វិបាកចិត្ត ២៣ តាវជ្ជនចិត្ត ២ កុសលចិត្ត ๑៨ អកុសលចិត្ត ៧ សកទាគាមិផលចិត្ត ๑ រួមទាំងអស់ត្រូវជា ៥๑ កើតឡើងប្រាកដក្នុងសន្ដានៃព្រះសកទាគាមីបុគ្គលនោះ សមគួរតាមបានដោយពិត ។

ទី ៣ - ព្រះអនាគាមីបុគ្គលនោះលោកបានលះបង់នូវសំយោជន-ធម៌ជាចំណែកនៃកាមធាតុទាំង ៥ ជាស្រេចឡើយ ឧដ្ឋរៀវលែងចាកវិចិកិច្ឆាចិត្ត ៤๐ គឺ កិរិយាចិត្ត ๑៨ អកុសលចិត្ត ៧ មគ្គចិត្ត ៣ ផលចិត្ត ៣ មហគ្គតវិបាកចិត្ត ៩ ត្រូវជា ៤๐ ពុំបានកើតឡើងក្នុងសន្ដានលោកនោះឡើយ

មានតែវិថីចិត្ត ๔๙ គឺកាមាវចរវិបាកចិត្ត ๒๓ តាវជ្ជនចិត្ត ๒ កុសលចិត្ត ๑๘ អកុសលចិត្ត ๙ អនាគាមិផលចិត្ត ๑ រួមចំនឹងអស់ត្រូវជា ๔๙ កើតឡើងប្រាកដក្នុងសន្តានរបស់ព្រះអនាគាមីបុគ្គលនោះ សមគួរតាមបានដោយពិតៗ

ទី ๔ - ព្រះអរហន្តបុគ្គលនោះលោកបានលះបង់នូវសំយោជនធម៌ចាំង ๑๐ គឺ សំយោជនធម៌ ជាចំណែកនៃកាមធាតុ ๕ ឧទ្ធម្ភាគិយសំយោជនធម៌ជាចំណែកនៃរូបាវចរធាតុ ๕ គឺរូបរាគៈ សេចក្តីជម្រកត្រេកត្រអាលក្នុងរូបតណ្ហា ๑ អរូបរាគៈ សេចក្តីជម្រកត្រេកត្រអាលក្នុងអរូបតណ្ហា ๑ មានៈ សេចក្តីប្រកាន់ចិត្តរបស់ខ្លួនថាអញ ๑ ឧទ្ធច្ចៈ ចិត្តរាយមាយហុយឡើងជួបផែនត្រូវឲ្យល់ ๑ អវិជ្ជា សេចក្តីមិនដឹងប្រាកដក្នុងព្រះតិរយៈសច្ចៈចាំងបួន ๑ ទើបរៀបលែងចាកវិថីចិត្ត ๔๙ គឺអកុសលចិត្ត ๑๒ កាមាវចរកុសលចិត្ត ๘ រូបាវចរកុសលចិត្ត ๕ អរូបាវចរកុសលចិត្ត ๔ លោកុត្តរកុសលចិត្ត ๔ (ជា ๓๓) ផលចិត្ត ๓ មហគ្គតវិបាកចិត្ត ๕ ត្រូវជា ๔๕ ពុំបានកើតឡើងក្នុងសន្តានលោកនោះឡើយ មានតែវិថីចិត្ត ๔๔ គឺអកុសលសហេតុកវិបាកចិត្ត ๗ កុសលអហេតុកវិបាកចិត្ត ๘ សហេតុកមហាវិបាកចិត្ត ๗ (ជា ๒๓) អហេតុកកិរិយាចិត្ត ๓ មហាកិរិយាចិត្ត ๘ មហគ្គតកិរិយាចិត្ត ๕ (ជា ๒๐) អហេតុកផលចិត្ត ๑ រួមចំនឹងអស់ត្រូវជា

๘๔ កើតអឡីឯក្នុងជាតិឯសន្តានរបស់ព្រះអរហន្តបុគ្គលនោះ សមគួរតាមបានដោយពិត ។ វិសជ្ជនាមកអំពីព្រះអរិយបុគ្គលទាំង ๔ ពួក ដោយសេចក្តីសង្ខេបតែប៉ុណ្ណេះឯង ។

๖๐-ធម្មវាទី បានស្តាប់ហើយ សួរតទៅទៀតថា ម្នាលអត្តវាទីចុះបុថុជ្ជនបុគ្គលទាំង ๔ ពួកនោះ ក្នុងបុគ្គលមួយពួក ។ រៀរលែងចាកវិថីចិត្តប៉ុន្មាន ? មានវិថីចិត្តប៉ុន្មាន បានតទៅក្នុងសន្តានខ្លួន ? ផ្សងគ្នាយ៉ាងណាខ្លះ ? ប្អូរលោកវិសជ្ជនាមកយើងនឹងបានស្តាប់ប្អូលចិត្តផងមើល ?

អ្នកវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯបុថុជ្ជនបុគ្គលទាំង ๔ ពួកនោះគឺ ពួក ๑ - តាំងហេតុកបុថុជ្ជនបុគ្គលនោះតែងរៀរលែងចាកវិថីចិត្ត ๓๙ គឺ:អហេតុកកិរិយាហសិតុប្បាទចិត្ត ๑ សាហេតុកកាមាវចរកិរិយាចិត្ត ๘ មហគ្គតកិរិយាចិត្ត ๙ (ជា ๑๘) លោកុត្តរចិត្ត ๘ មហគ្គតវិបាកចិត្ត ๙ (ជា ๑๗) រួមទាំងអស់ត្រូវជា ๓๙ តុំបានកើតឡើងក្នុងសន្តានរបស់តាំងហេតុកបុថុជ្ជនបុគ្គលនោះឡើយ មានតែវិថីចិត្ត ๘๔ គឺអហេតុកអកុសលវិបាកចិត្ត ๗ អហេតុកកុសលវិបាកចិត្ត ๘ សាហេតុកកាមាវចរវិបាកចិត្ត ๘ (ជា ๒๓) អាវជ្ជនចិត្ត ๒ តាមាវចរកុសលចិត្ត ๘ មហគ្គតកុសលចិត្ត ๙ អកុសលចិត្ត ๑๒ (ជា ๓๑) រួមទាំងអស់ត្រូវជា ๘๔ កើតឡើងត្រាកដ

កងសន្ធានៃតិហេតុកបុថុជ្ជនបុគ្គលនោះ សមគួរតាមបានដោយតិត ៣
ខ្ញុំ ខ - ទ្វិហេតុកបុថុជ្ជនបុគ្គលនោះតែងរៀរលែងចាកវិថីចិត្ត ១៣ គឺសហេតុ-
កកាមាវចរវិបាកចិត្តជាញាណវិប្បយុត្ត ៤ មហគ្គតកុសលចិត្តជាអប្បនា-
ជវន ៥ ត្រូវជា ១៧ តុំបានកើតខ្សើងក្នុងសន្ធានៃទ្វិហេតុកបុថុជ្ជន
បុគ្គលនោះឡើយ មានតែវិថីចិត្ត ៤១ គឺអហេតុកអកុសលវិបាកចិត្ត ៧
អហេតុកកុសលវិបាកចិត្ត ៨ សហេតុកកាមាវចរវិបាកចិត្ត ជាញាណវិប្ប-
យុត្តដែលមានកម្លាំងខ្លាំងជា ៤ ក្រែង ៤ តាវជ្ជនចិត្ត ២ សហេតុកកាមាវច-
កុសលចិត្ត ៨ អកុសលចិត្ត ១២ រួមចំនួនសរុបត្រូវជា ៤១ កើតខ្សើងច្រាលដ
កងសន្ធានៃទ្វិហេតុកបុថុជ្ជនបុគ្គលនោះ សមគួរតាមបានដោយតិត ៣
ខ្ញុំ ៣ - អហេតុកបុថុជ្ជនបុគ្គលនោះតែងរៀរលែងចាកវិថីចិត្ត ១៣ គឺ
សហេតុកកាមាវចរវិបាកចិត្តជាញាណសម្បយុត្ត ៤ មហគ្គតកុសលចិត្ត
ជាអប្បនាជវន ៥ ត្រូវជា ១៣ តុំបានកើតខ្សើងក្នុងសន្ធានៃអហេតុក-
បុថុជ្ជនបុគ្គលនោះឡើយ មានតែវិថីចិត្ត ៤១ គឺអហេតុនអកុសលវិបាក-
ចិត្ត ៧ អហេតុកកុសលវិបាកនចិត្ត ៨ សហេតុកកាមាវចរវិបាកចិត្តជាញាណ
វិប្បយុត្តដែលមានកម្លាំងខ្លាយជាទុមកៈ ៤ តាវជ្ជនចិត្ត ២ សហេតុកកា-
មាវចរកុសលចិត្ត ៨ អកុសលចិត្ត ១២ រួមចំនួនសរុបត្រូវជា ៤១ កើតខ្សើង

ច្រោកជុកដ៏សន្ធានៃអហេតុកបុថុជ្ជនបុគ្គលនោះ សមគួរតាមបានដោយ
ពិត ។ ទី ៤ - អាចារ្យពិភាហេតុកបុថុជ្ជនសត្តនោះតែងរៀបរៀងចាតវិថីចិត្ត
១៧ គឺ សហេតុកកាមាវចរវិបាកចិត្ត ៨ មហគ្គតកុសលចិត្តជាអប្បនាជវៈ
៩ ត្រូវជា ១៧ ពុំបានកើតឡើងក្នុងសន្ធានៃអាចារ្យពិភាហេតុកបុថុជ្ជន-
សត្តនោះឡើយ មានតែវិថីចិត្ត ៣៧ គឺអហេតុកអកុសលវិបាកចិត្ត ៧
អហេតុកកុសលវិបាកចិត្ត ៨ អាវជ្ជនចិត្ត ២ សហេតុកកាមាវចរកុសល-
ចិត្ត ៨ អកុសលចិត្ត ១២ រួមទាំងអស់ត្រូវជា ៣៧ កើតឡើង
ច្រោកជុកដ៏សន្ធានៃអាចារ្យពិភាហេតុកបុថុជ្ជនសត្តនោះ សមគួរតាមបាន
ដោយពិត ។ សៀវភៅនាមកអំពីបុថុជ្ជនបុគ្គលទាំង ៤ ពួកដោយសេចក្តី
សង្ខេបតែប៉ុណ្ណេះឯង ។

៦១- ធម្មវិទូ បានស្តាប់ហើយពោលថា អើអត្ថន័យលោកសៀវភៅ
មកនេះយើងស្តាប់បានខ្លះនៅសង្ស័យខ្លះតែត្រង់ពាក្យដែលលោកពោល
ថា ទ្វិហេតុកបុគ្គលទី ២ ថារៀបរៀងចាតវិថីចិត្ត ១៣ ជាស្រឡះមានតែ
វិថីចិត្ត ៨១ កើតឡើងច្រោកជុកដ៏សន្ធានៃទ្វិហេតុកបុគ្គលនោះ ព្រោះ
ថាសហេតុកកាមាវចរវិបាកចិត្តជាញាណវិប្បយុត្ត មានតម្លាំងខ្សោយ
ច្រើន អហេតុកបុគ្គលទី ៣ ថារៀបរៀងចាតវិថីចិត្ត ១៣ ជាស្រឡះ

ដូចគ្នាដែរ មានវិថីចិត្ត ៤១ កើតរឿងក្នុងសន្តានរបស់អហេតុ-
កបុគ្គលនោះ ព្រោះថា សហេតុកកាមាវចរវិបាកចិត្តជាញាណវិប្បយុត្ត
មានកម្លាំងខ្សោយជាងមក: តើមានសេចក្តីអធិប្បាយផ្សេងគ្នាដូចម្តេចខ្លះ?
អាថាយិកាហេតុកសត្តវារ ៤ ជាវៀរលែងវិថីចិត្ត ១៧ ជាស្រឡះមាន
តែវិថីចិត្ត ឆក្ក៧ កើតរឿងក្នុងសន្តានរបស់អាថាយិកាហេតុកសត្ត
នោះ តើមានសេចក្តីអធិប្បាយផ្សេងគ្នា អំពីអហេតុកបុគ្គលនោះដូច
ម្តេចខ្លះ? ប៉ុន្តែលោកវិសុទ្ធាមកម្ពុងខឿតឲ្យច្បាស់លាស់. យើងនឹងមិន
ស្តាប់ចូលចិត្តផងមើល ?

អត្ថវិទី វិសុទ្ធាគមថា បពិត្រធម្មាភិ ទី ២ ទ្វិហេតុកបុគ្គល
ដែលវៀរលែងចាកវិថីចិត្ត ១៧ ពុំបានកើតរឿងក្នុងសន្តានខ្លួននោះ
ឡើយ មានតែវិថីចិត្ត ៤១ កើតរឿងក្នុងសន្តានខ្លួន ព្រោះថា
សហេតុកកាមាវចរវិបាកចិត្តជាញាណវិប្បយុត្ត មានកម្លាំងខ្លាំងជាងក្រៃ
នោះ មានសេចក្តីអធិប្បាយថា បុគ្គលដែលប្រកបដោយកុសលចិត្តទី ៣-
៤-៧-៨ ជាញាណវិប្បយុត្តអសង្ខារិកក្តី សសង្ខារិកក្តី កំពុងរណ:
ដែលបរិច្ចាគទ្រព្យធ្វើទានក្តី តាំងសមាទានរក្សាសីលក្តី តាំងចំរើន
ភាវនាព្រះកម្មដ្ឋានក្តី ជាបុគ្គលមានចិត្តដ៏ក្លៀវក្លាខ្លាំងនឹងប្រែនប្រែនចាត់

ចែងធ្វើការងារកុសលមិនបានខ្ជិលប្រកបសព្វញាត្រាន់ឡើយ ដកបដិ
សម្រេចបុណ្យមួយសែក ។ ហើយមានចិត្តមិនបានក្តៅក្រហាយជាទាន
ក្រោយ តែងមានចិត្តត្រេកអរនឹករលឹកបុណ្យដែលខ្លួនបានធ្វើកន្លងទៅ
ហើយជាប់ជានិច្ចពុំបានភ្លេចឡើយ កើតជាសហេតុកកាមាវចរវិបាកចិត្ត
ជាញាណវិប្បយុត្តអសង្ខារិកក្តី សសង្ខារិកក្តី ជាមានកម្លាំងខ្លាំងជាគួ
បជាសន្ធិកើតជាមនុស្សជាន់កណ្តាល មានសព្វាវជ្ជកម្ម-ផលតែងបរិច្ចាគ
ទ្រព្យធ្វើបុណ្យឲ្យទាន តែងសមាទានក្សាសីល ៥ សីល ៨ ឬសីល
តែថាជាបុគ្គលល្ងង់ខ្លៅពុំសូវមានប្រាជ្ញាន៏ឆ្លៀវឆ្លាសនោះឡើយ ក៏បាន
ឈ្មោះថា ទ្វិហេតុកបុថុជ្ជនបុគ្គលតែង ។ ទី ៣-អហេតុកបុថុជ្ជនបុគ្គល
ដែលវៀរលែងចាកវិចិត្តចិត្ត ១៣ ពុំបានកើតឡើងក្នុងសន្តានខ្លួន មានតែ
វិចិត្តចិត្ត ៤ ១ កើតឡើងប្រាកដក្នុងសន្តានខ្លួន ព្រោះថា សហេតុកកាមា-
វចរវិបាកចិត្តជាញាណវិប្បយុត្តមានកម្លាំងខ្សោយជាទុមកៈនោះ មាន
សេចក្តីអធិប្បាយថា បុគ្គលដែលប្រកបដោយកុសលចិត្តទី ៣ . ៤ . ៧ . ៨
ជាញាណវិប្បយុត្ត អសង្ខារិកក្តី សសង្ខារិកក្តី ក្នុងខណដែលបានបរិ-
ច្ចាគទ្រព្យធ្វើបុណ្យឲ្យទានក្តី តាំងសមាទានក្សាសីលក្តី តាំងចំរើនភាវនា
ព្រះកម្មដ្ឋានក្តី ជាបុគ្គលមានចិត្តឥតសទ្ធាមិនបានជ្រះកម្មផល មិនបាន

ត្រកអរជ្រះថ្លាក្នុងការជាកុសលនោះប៉ុន្មានឡើយ ធ្វើដោយការខ្មីស
ខាលខ្លីឯញាតិមិត្តសំឡាញ់ដែលនៅផ្ទះជិតខាង ដែលគេតែងធ្វើបុណ្យ
ផ្សាយនឿយ ។ ឬថា គេបានមកបបួលជំរុញផ្សាបួលធ្វើបុណ្យខ្លីឯគេក្តី
ដែលខ្លីឯធ្វើបុណ្យនោះទៀត មានសេចក្តីទុំលប្រអូសធុញច្រានំច្រែន
អង្គុយស្ងៀម មិនមានខ្សល់ទាំ ទំព្យាយាមជួយចាត់ចែងការជាកុសល
នោះឡើយ លុះបានធ្វើបុណ្យផ្សាយរួចស្រេចហើយ កំកើតវិប្បដិសា-
រីមានសេចក្តីក្តៅក្រហាយជាខាងក្រោយ កំបុណ្យទានដែលបុគ្គលបាន
ធ្វើប្រកបដោយកាមាវចរកុសលចិត្ត ជាញាណវិប្បយុត្តមានកម្លាំងខ្សោយ
យ៉ាងនេះ បានឈ្មោះថា សហេតុកកាមាវចរវិបាកចិត្តមានកម្លាំងខ្សោយ
ជាទុមកៈ ជំរុញតាម តុំបានផ្សាបដិសន្ធិឡើយ ខ្លីឯក្លាក់ចុះមកផ្សាប-
សន្ធិជាអហេតុកកំណើតវិញ គឺទុបេក្ខាសហគតសន្តីរណៈជាអហេតុក-
កុសលវិបាកចិត្ត ៨ ជាតួបដិសន្ធិ កើតជាមនុស្សជាន់ទាប មានភ្នែកខ្វាក់
ត្រចៀកថ្លង់ ខ្លីឯគំពីកំណើតជាដើម ជាមនុស្សអកិក្ខមិនគួរដល់បព្វជ្ជា
ខ្លីឯឧបសម្បទាកុងព្រះពុទ្ធសាសនាឡើយ បានឈ្មោះជា អហេតុក-
បុថុជ្ជនបុគ្គលដោយតែង ។ ៤- អាចារ្យពិការហេតុកបុថុជ្ជនសត្ត ដែល
ឮរៀបលែងចាកវិថីចិត្ត ១៧ តុំបានកើតឡើងក្នុងសន្តានខ្លួន មានតែវិថីចិត្ត

៣៧ តែតទៅទៀតទ្រង់ចងសន្ធានថា អាថ៌យិកាហេតុកសត្តនោះ ព្រោះថា
វៀរលែងចាកសហេតុកកាមាវចរចិត្ត ជាញាណវិប្បយុត្តជាស្រេច។
មានសេចក្តីអធិប្បាយថា បណ្តាអកុសលចិត្ត ១២ នោះ បុគ្គលដែល
ប្រកបដោយអកុសលចិត្តឯណាមួយ ហើយប្រព្រឹត្តធ្វើទុច្ចរិតតិចតួច
បាន ៣ មានកាយទុច្ចរិតជាដើម ដែលជាចិត្តមានកម្លាំងខ្សោយឲ្យផល
ជាអហេតុកកំណើត គឺ ឧបេក្ខាសហគតសន្តីរណៈជាអហេតុកអកុសល
វិបាកចិត្តខ្លះ ៧ ជាតួបដិសន្ធិកើតក្នុងអបាយភូមិចាំង ៤ គឺ នរក ១ ប្រេត ១
អសុរកាយ ១ តិរច្ឆាន ១ សោយទុក្ខវេទនាដោយប្រើន បាននាមថា
អបាយិកាហេតុកសត្តដោយពិត ។

វិសជ្ជនាបកអំពីបុគ្គលទី ២.៣.៤ ដែលមានសេចក្តីផ្សេងគ្នាដោយ
សង្ខេបតែប៉ុណ្ណេះឯង ។

๖๒ - ធម្មវិទូ បានស្តាប់ហើយសួរតទៅទៀតថា ម្នាលអត្តវាទី
យើងនៅមានសង្ស័យក្នុងព្រះអរិយបុគ្គលចាំង ៤ ពួកតទៅទៀត តែត្រង់
ព្រះអរិយបុគ្គលចាំង ៣ ពួក គឺព្រះសោតាបន្នបុគ្គលពួកទី ១ ផ្សេងគ្នា
ដោយឈ្មោះមាន ៣ យ៉ាង មានសត្តក្ខត្តុបរមៈសោតាបន្នបុគ្គលជាដើម,
ព្រះអនាគាមីបុគ្គលពួកទី ៣ ផ្សេងគ្នាដោយឈ្មោះមាន ៥ យ៉ាង មាន

អត្ថបទនិទ្ទេសអនាគាមីបុគ្គលជាដើម, ព្រះអរហន្តបុគ្គលពួកទី ៤ ផ្សេងគ្នាជាយ៉ាងណា មានព្រះអរហន្តបដិសម្ភិទាញាណជាដើម ក៏ព្រះអរិយបុគ្គលទាំង ៣ ពួកនេះយើងពុំបានសួរលោកឡើយ ព្រោះលោកអ្នកប្រាជ្ញទាំងឡាយលោកធ្លាប់សំដែងមកហើយ ។ ហើយ យើងនៅសង្ស័យតែត្រង់ព្រះសកិទាគាមីបុគ្គលពួកទី ២ ព្រោះពុំដែលឮលោកអ្នកប្រាជ្ញណាមួយសំដែងប្រាប់ថា មានឈ្មោះផ្សេងគ្នាយ៉ាងណាសោះឬមានឈ្មោះតែមួយទេ បើមានឈ្មោះផ្សេងគ្នាដែរ តើមានឈ្មោះប៉ុន្មាន? គឺអ្វីខ្លះ? សេចក្តីអធិប្បាយថាដូចម្តេចខ្លះ!

អត្ថវិទី វិសជ្ជនាតបថា ចតុត្រធម្មកថី ព្រះសកិទាគាមីបុគ្គលនោះមិនមែនមានឈ្មោះតែមួយទេ តាមន័យដីកាសង្គហៈលោចសំដែងពន្យល់ថា ព្រះសកិទាគាមីបុគ្គលផ្សេងគ្នាជាយឈ្មោះមាន ៧ គឺ ឯកពីជី ឯក បទិនិព្វាយី ព្រះសកិទាគាមីបុគ្គលលោកបានសម្រេចដល់សកិទាគាមិផលក្នុងជាតមនុស្សលោកនេះ ហើយបានចំរើនវិបស្សនាកម្មដ្ឋានបានសម្រេចដល់ព្រះអរហត្តផល កំចាត់បង់នូវកិលេសទាំងអស់ ហើយបានរំលាយខន្ធចូលកាន់ព្រះនិព្វាន ក្នុងជាតមនុស្សលោកនេះ ១, ឥក្ខ បទិ ឥក្ខ បទិនិព្វាយី ព្រះសកិទាគាមីបុគ្គលលោកបាន

សម្រេចដល់សកិទាគាមិផលក្នុងឋានទេវលោកនោះ ហើយបានចំរើន
វិបស្សនាកម្មដ្ឋានបានសម្រេចដល់ព្រះអរហត្តផល កំចាត់បង់នូវកិ-
លេសទាំងអស់ ហើយបានលះបង់នូវបួលកាន់ព្រះនិព្វានក្នុងឋាន
ទេវលោកនោះ ១, ឯ បត្វា តត្ថ បរិនិព្វាយី ព្រះសកិទាគាមី-
បុគ្គលលោកបានសម្រេច ដល់សកិទាគាមិផលក្នុងឋានមនុស្សលោកនេះ
ហើយបានច្យុតទៅកើតក្នុងឋានទេវលោកនាយ បានចំរើនវិបស្សនា-
កម្មដ្ឋានបានសម្រេចដល់ព្រះអរហត្តផល កំចាត់បង់នូវកិលេសទាំង
អស់ ហើយបានលះបង់នូវបួលកាន់ព្រះនិព្វានក្នុងឋានទេវលោកនោះ ១,
តត្ថ បត្វា ឯ បរិនិព្វាយី ព្រះសកិទាគាមីបុគ្គលលោកបានសម្រេចដល់
សកិទាគាមិផលក្នុងឋានទេវលោកនោះ លុះបានច្យុតបុះមកកើតក្នុងឋាន
មនុស្សលោកវិញ ហើយបានចំរើនវិបស្សនាកម្មដ្ឋានបានសម្រេចដល់
ព្រះអរហត្តផលកំចាត់បង់នូវកិលេសទាំងអស់ ហើយបានលះបង់នូវ
បួលកាន់ព្រះនិព្វានក្នុងឋានមនុស្សលោកនេះ ១, ឯ បត្វា តត្ថ និព្វុតត្តា
ឯ បរិនិព្វាយី ព្រះសកិទាគាមីបុគ្គលលោកបានសម្រេចដល់សកិទាគា-
មិផលក្នុងឋានមនុស្សលោកនេះ លុះបានច្យុតទៅកើតក្នុងឋានទេវលោក
នោះ ដល់អស់អាយុក៏ច្យុតបុះមកកើតក្នុងឋានមនុស្សលោកវិញ ហើយ

ចានចំរើនវិបស្សនាកម្មដ្ឋាន ចានសម្រេចដល់ព្រះអរហត្តផលកំចាត់បង់នូវ
កិលេសទាំងអស់ ហើយចានលោះទុក្ខបួលកាន់ព្រះនិព្វានក្នុង
ហានមនុស្សលោកនេះទ; ត្រង់ជាសកិទាគាមីបុគ្គលផ្សេងគ្នាដោយឈ្មោះ
មាន ៤ នៃថាលោកលើកយកនាមព្រះសកិទាគាមីបុគ្គលជាគំរប់ ៤
តែមួយយកមកឲ្យឈ្មោះថា សកិទាគាមីបុគ្គលដោយពិត ចានសេចក្តី
ថា ព្រះអរិយបុគ្គលលោកត្រឡប់មកកាន់ហានមនុស្សលោកនេះដោយ
អំណាចនៃបដិសន្ធិចិត្តអស់វារៈមួយជាតិទៀត ទើបសម្រេចដល់ព្រះនិព្វាន
ដោយពិត ។ វិសជ្ជនាមកអំពីព្រះសកិទាគាមីបុគ្គលផ្សេងគ្នាដោយឈ្មោះ
មាន ៤ ដោយសង្ខេបតែប៉ុណ្ណោះឯង ។

៦៣ - ធម្មវាទី ចានស្តាប់ហើយសួរប្រស្នាជាខែកទៀតថា
ម្នាលភន្តេ ចុះធម៌ទាំងឡាយ ៥៦ ចានឈ្មោះថា ខេតសិក តើត
នឹងសេត់ព្រមជាមួយនឹងចិត្តនោះ បើខែកទៀតាមពួកក្រុមវេស់ខេត-
សិកមានប៉ុន្មានពួក? ក្នុងពួកមួយៗ មានចំនួនប៉ុន្មាន? ចូរលោក
វិសជ្ជនារៀបរាប់តាមពួកក្រុមវេស់ខេតសិកមក យើងនឹងចានស្តាប់
ចូលចិត្តផងមើល?

អ្នកវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ធម៌ទាំងឡាយ ៥៦

ចានឈ្មោះថា ចេតសិកនោះ បើចែកទៅតាមពួកក្រុមបេស់ចេតសិក មាន ៣ ពួកគឺអញ្ញសមានាចេតសិកពួកទី ១ មានចំនួន ១៣ អកុសលចេតសិកពួកទី ២ មានចំនួន ១៤ សោភណចេតសិកពួកទី ៣ មានចំនួន ២៥ រួមចាំងអស់ត្រូវជា ៥២ ដោយពិត សូមជ្រាប ។

៦៤ - ធម្មវិទូ ចានស្តាប់ហើយពោលថា អើអត្ថវិទូ លោកចានវិសជ្ជនាមកនេះត្រឹមត្រូវហើយ ប៉ុន្តែអញ្ញសមានាចេតសិកពួកទី ១ មានចំនួន ១៣ នោះ បើចែកទៅជាសព្វចិត្តសាធារណៈចេតសិកមានចំនួនប៉ុន្មាន ? អធិបតេយ្យថាដូចម្តេចខ្លះ ? ចែកទៅជាបកិណ្ណកចេតសិកមានចំនួនប៉ុន្មាន ? សេចក្តីផ្សងគ្នាយ៉ាងណាខ្លះ ? ចុះលោកវិសជ្ជនាឲ្យសព្វគ្រប់មកយើងនឹងចានស្តាប់ចូលចិត្តផងមើល ?

អត្ថវិទូ វិសជ្ជនាតបថា បពិត្រធម្មវិទូ ឯអញ្ញសមានាចេតសិក ១៣ នោះ គឺលោកសម្តែងចែកជាសព្វចិត្តសាធារណៈចេតសិកគឺជាចេតសិកធម្មសាធារណៈខ្លះ កើតចានគ្រប់វិថីចិត្តចាំងអស់មាន ៧ គឺ: ๑- ផស្សៈ ចេតសិកធម្មប្រត្រឹត្តទៅក្នុងទ្វារចាំង ៥ មានការប៉ះពាល់នូវគារម្មណ៍ជាលក្ខណៈ មានការដុសខាត់នូវគារម្មណ៍ជាកិច្ច មានការប្រជុំចូលប្រទះគ្នាដោយចក្ខុនិន្ទ្រៀបជាដើមជាទីដាក់លៃនវជ្ជានិជ្ជារម្មណ៍ ។

๒- เวทนา ធម្មជាតិប្រព្រឹត្តទៅក្នុងទ្វារទាំង ๖ មានភាវៈសោយ
បរិភោគនូវារម្មណ៍ជាលក្ខណៈ ជាផល
ជាទីដល់នៃឥដ្ឋានិដ្ឋារម្មណ៍ ។ ๓- សញ្ញា ធម្មជាតិសម្រាប់ធ្វើសំ-
គាល់ចំណាំហើយដឹងច្បាស់នូវារម្មណ៍ព័ណ៌ខៀវ ក្រហម សឿងជាដើម
ជាលក្ខណៈ ជាផលជាទីដល់នៃឥដ្ឋានិដ្ឋារម្មណ៍ ។ ๔- ចេតនា
ធម្មជាតិជាធំអាចចាត់ចែងនិរៈតិតមាន។ សព្វហ៍ព្យាយាមដំកូវៃក្លាក្រៃលែង
ជាខ្លួនណាក្រនុណាក្នុងឥដ្ឋានិដ្ឋារម្មណ៍ឲ្យជាធម៌ កើតនឹងរលត់ត្រមដោយ
ខ្លួនឯង ។ ๕- ឯកគ្គតា ភាវៈនៃចិត្តបឋមនឹងនៅក្នុងអារម្មណ៍តែមួយ ពុំ
បានរវើរវាយទៅក្នុងអារម្មណ៍ផ្សេង ។ ល ។ ๖- ជីវិតិន្ទ្រិយំ ធម្ម-
ជាតិតែងប្រព្រឹត្តរស់នៅជង ញ៉ាំងខ្លួនឲ្យធ្វើជាធំក្នុងកិច្ចទាំង ๔ ប្រាយដែល
ប្រព្រឹត្តទៅក្នុងធម៌ជំប្រកបកើតនឹងរលត់ត្រមជាមួយគ្នាជង ។ ๗- មន-
សិការៈ ភាវៈធ្វើកំណត់នូវារម្មណ៍ផ្សេង ។ ពុកក្នុងចិត្ត គឺថាចេត-
សិកធម៌ដែលប្រកបកើតត្រមជាមួយនឹងវិថីចិត្តទី ๕ សម្រាប់ធ្វើកំណត់នូវ
អារម្មណ៍ពុកក្នុងចិត្ត បើធ្វើកំណត់នូវារម្មណ៍ ពុំសូវជាអនិដ្ឋារម្មណ៍មិនត្រូវ
តាម។ ប្រាយនៃប្រជ្ញាទេ នឹងកើតជាអកុសលផលប្រាបពិត បើធ្វើកំណត់នូវ
អារម្មណ៍ត្រូវជាឥដ្ឋារម្មណ៍ត្រូវត្រង់តាម។ ប្រាយនៃប្រជ្ញាហើយ នឹងកើត

ជាកុសលផលបុណ្យដោយពិត ។

លោកសំដែងពីចេតសិកដែលប្រកបដោយអកុសលហេតុ ដែលជាចេតសិកធម៌ដែលប្រព្រឹត្តទៅដោយអកុសលហេតុ ដែលជាមួយនឹងសោភណចិត្តទាំង ២ និងសោភណចិត្តទាំង ២ ក្នុងវិថីចិត្តផ្សេង ។ មាន ៦ គឺ: ๑- វិតក្កៈ ចេតសិកធម៌សម្រាប់ត្រិះរិះគិតនូវអារម្មណ៍ ឬថាញុំងចិត្តឲ្យទៅកាន់អារម្មណ៍ប្រព្រឹត្តទៅក្នុងសម្បយុត្តធម៌ មានកិរិយាលើកឡើងនូវវិថីចិត្តកាន់អារម្មណ៍ជាលក្ខណៈ ប្រកបកើតឡើងព្រមក្នុងវិថីចិត្ត ៥៥ គឺភាវនាចិត្ត ៤៤ ឋបនាជវនចិត្ត ๑๑ រឿវិលងងឹតវិញ្ញាណ ๑๐ និងអបុញ្ញាវជ្ជនចិត្ត ๑๒ អបុញ្ញាវជ្ជនចិត្ត ๒ លោកុត្តរចិត្ត ๓๒ ចេញពុំបានកើតឡើយ ។ ๒- វិចារៈ ចេតសិកធម៌សម្រាប់ពិចារណានូវអារម្មណ៍ មានកិរិយាជុំវិញអារម្មណ៍រឿយៗ ជាលក្ខណៈ ជាទីតាំង ប្រកបកើតឡើងព្រមក្នុងវិថីចិត្ត ๖๖ គឺភាវនាចិត្ត ๔๔ ឋបនាជវនចិត្ត ๑๑ ទុតិយជ្ឈានចិត្ត ๑๑ រឿវិលងងឹតវិថីចិត្ត ๘๘ គឺវិញ្ញាណ ๑๐ និងតតិយ-ចតុត្ថ-បញ្ចមជ្ឈានទាំង ๘๙ ចេញពុំបានកើតឡើយ ។ ๓- អធិមោក្ខៈ ចេតសិកធម៌ដែលប្រែផុតចេញចាកសេចក្តីមិនជ្រះថ្លាហើយជ្រះថ្លា មានកិរិយាចូលចិត្តព្រមក្នុងអារម្មណ៍មិនកក្រើកជាលក្ខណៈ ជាទីតាំង ប្រកបកើតឡើងព្រមក្នុងវិថីចិត្ត ๗๘ គឺភាវ-

វចរចិត្ត ๘๓ មហគ្គតចិត្ត ๒๗ លោកុត្តរចិត្ត ๘ រឿរលងរែក
វិញ្ញាណ ๑๐ នឹងវិចិកិច្ឆាសម្បយុត្ត ๑ បេញ ពុំបានកើតឡើយ ។
๔- រីយំ សេចក្តីឧបត្ថម្ភនុំកចំរើនដូរកុសលធម៌ជាំជួន មិនឲ្យសាច
សូន្យទៅមានកិរិយាផ្តន់ឡើងដូរព្យាយាមជាំ គ្រប់សង្កត់នូរសេចក្តីខ្ជិល
ជាលក្ខណៈ ជាមូលហេតុនៃសម្បត្តិជាំជួន ប្រកបកើតឡើងត្រម
ក្នុងរិចិចិត្តជាំ ๗๓ គឺសោភណចិត្ត ๔๔ អសោភណចិត្ត ๑๔
រឿរលងរែករិចិចិត្ត ๑๖ នឹងវិញ្ញាណ ๑๐ បញ្ចទ្វារវជ្ជនចិត្ត ๑ សម្បដិ-
ច្ឆនចិត្ត ๒ សន្តីរណចិត្ត ๓ បេញ ពុំបានកើតឡើយ ។ ๙- ប័ត
សេចក្តីអំណារពេញចិត្ត មានឆ្អែតកាយឆ្អែតចិត្ត ជាលក្ខណៈ មានពេញ
កាយ ពេញចិត្តជាកិច្ចប្រកបកើតឡើងត្រមក្នុងរិចិចិត្តជាំ ๔๑ គឺសោ-
មនស្សសហគតកាមាវចរចិត្ត ๑๘ បឋម-ទុតិយ-តតិយជ្ឈានចិត្ត ๓๓
រឿរលងចាករិចិចិត្ត ๗๐ គឺឧបេក្ខាសហគតចិត្ត ๔๔ បដិឃចិត្ត ๒
កាយវិញ្ញាណ ๒ បញ្ចមជ្ឈានចិត្ត ๑๑ បេញ ពុំបានកើតឡើយ ។
๑๐- ឆន្ទៈ បេតសិកធម៌ជាបុព្វការ មានការៈប្រាថ្នាជើម្បីធ្វើជា
លក្ខណៈ មានកិរិយាស្វែងរកនូរអារម្មណ៍ជាកិច្ច ប្រកបកើតឡើង
ត្រមក្នុងរិចិចិត្តជាំ ๑๔ គឺកាមាវចរចិត្ត ๓๔ មហគ្គតចិត្ត ๒๗

លោកុត្តរចិត្ត ៨ រៀរាលដាចតវីថិចិត្ត ៦០ គឺអរហត្តុកចិត្ត ១៨ មោមូហ-
ចិត្ត ២ ចេញ តុំបានកើតឡើយ ។ រួមសព្វចិត្តសាធារណចេតសិក ៧
បកិណ្ណកចេតសិក ៦ ត្រូវជា ១៣ ដោយសេចក្តីសង្ខេបតែប៉ុណ្ណេះឯង ។

៦៥- ធម្មវិធី បានស្តាប់ចោទសួរតទៅទៀត ថាម្នាលអត្ត-
វាទី ចុះអកុសលចេតសិកពួកទី ២ មានចំនួន ១៤ នោះ គឺចេតសិក
ក្នុងនុះ ? សេចក្តីអធិប្បាយដូចម្តេចខ្លះ ? ចូរលោកវិសជ្ជនាមកយើងនឹង
បានស្តាប់ចូលចិត្តផងមើល ?

អត្ថវិធី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯអកុសលចេតសិក
ពួកទី ២ ចាំង ១៤ នោះគឺ: ១- មោហ សេចក្តីវង្វេងកាន់ច្រឡំអា-
រម្មណ៍សំគាល់ខុសថា គុណព្រះរតនត្រ័យដែលជាឥដ្ឋារម្មណ៍ថាជាអនិ-
ដ្ឋារម្មណ៍ទៅវិញ កាន់ច្រឡំខុសថា ព្រះអរិយសច្ចចាំង ៤ មានទុក្ខសច្ច
ជាដើមនេះជាធម៌មិនពិតវេ ឬគួលអ្នកធ្លាប់បុណ្យឲ្យទានរក្សាសីលចំរើន
ភាវនា ថាបានបុណ្យច្រើនក៏មិនពិតដែរ សេចក្តីវង្វេងកាន់ច្រឡំអា-
រម្មណ៍យ៉ាងនេះជាដើម ហៅថា មោហ ដោយពិត ។ ២- អហិ-
រិកំ សេចក្តីមិនខ្មៅមថាប មិនខ្មាសបាប ធ្វើទុនមិនបានឲ្យបរិសុទ្ធ ឲ្យប-
ញ្ញាក់ទៅដោយបាបធម៌ចាំង ឲ្យមានអកុសលកម្មបថចាំង ១០ជាដើម ។

គ - អនោគ្គប្បំ សេចក្តីមិនបានតក់ស្លុតភ្ញាប់ភ្ញាប ធ្វើខ្លួនមិនបានឲ្យ
បរិសុទ្ធឲ្យក្តៅក្រហាយរោលកាលៅជាយបាបធម៌ទាំង ឡាយ មានអកុ-
សលកម្មបថទាំង ១០ ជាដើម ។ ង - ទុទ្ធុំ សេចក្តីកយមាយហុយ
ឡើងជូបផែនក្រៅឡល់ថ្នាំផ្សាយហុយឡើងជូបផ្សែងក្តៅ ។ បេតសិកធម៌
ទាំង ង នេះប្រកបកើតឡើងត្រមតែក្នុងអកុសលចិត្តទាំង ១ង ជាយតិត ។
ច - លោភោ សេចក្តីចង់បានហួសប្រមាណ មានចិត្តជំពាក់ជាប់នៅ
ក្នុងអារម្មណ៍ទាំងពួងជាលក្ខណៈ ប្រកបកើតឡើងត្រមក្នុងលោភសហគត
ចិត្តទាំង ច ជាយតិត ។ ឆ - ទិដ្ឋិ សេចក្តីយល់ឃើញខុស ប្រ-
កាន់យកមាំតែតាមគំនិតរបស់ខ្លួនដែលតិតយល់ឃើញជាប្រមាណ មាន
មិនជឿគុណព្រះរតនត្រ័យជាដើមជាលក្ខណៈ ។ ជ - មានោ សេចក្តី
រមើរមឹងរួសប្រកាន់អស្មិមាន:មិនស្តាប់តាក្យប្រជៀល្ង មានប្រកាន់ជាតិកំ-
ណើតខ្លួនជាប់អហង្ការថា មានតែអញប្រសើរជាងគេជាដើមជាលក្ខណៈ ។
បេតសិកធម៌ទាំងពីរនេះ ប្រកបកើតឡើងត្រមក្នុងអកុសលចិត្តជាទិដ្ឋិគត
សម្បយុត្តទាំង ៤ ជាយតិត ។ ជ-ឧទ្ធច្ចោ សេចក្តីក្រោធខឹងប្រទូសស្តូ
ឧឹងសង្កាជាដៃជើមម្យ៉ាងនៃទោសៅ មានការ:កាបសាហារជាលក្ខណៈ ។
ញ - ឥស្សា សេចក្តីច្រណែនឯស្សាទិដ្ឋិទ្រព្យរបស់ឃសម័ត្តិអ្នកដទៃ មិន

ចង់ឲ្យគេមានចិត្តប្រសើរលើសជាងខ្លួនជាដើម មានកំរោយឫស្សាខ្លួ
សម្បត្តិនៃបុគ្គលដទៃជាលក្ខណៈ ។ ๑๐- មច្ឆរិយំ សេចក្តីកំណាញ់
ចំអាក់សត្រកូលញាតិមិត្ត សំឡាញ់មិនឲ្យអ្នកដទៃចូលទៅជិតបានខ្លាច
ខាតលាភ កំណាញ់លាភមិនឲ្យអ្នកដទៃគេមានលាភបានខ្លួបបច្ច័យចាំង ๔
លើសខ្លួន កំណាញ់គុណវិសេសនិងធម៌មិនឲ្យអ្នកដទៃគេសរសើរអ្នក
ដទៃលើសខ្លួនឡើយ ។ ๑๑- កុក្កុច្ចំ សេចក្តីក្តៅក្រហាយជាខាង
ក្រោយ ដោយសំគាល់ថា អំពើជាកុសលគឺអញមិនបានធ្វើហើយ អំ-
ពើដ៏លាមកអាក្រក់ជាអកុសលគឺអញបានធ្វើហើយជាដើម ។ កំចេតសិក
ធម៌ចាំង ๔ នេះប្រកបកើតឡើងត្រមក្នុងបដិឃចិត្តចាំង ๒ ដោយពិត ។
๑๒- ថីនំ សេចក្តីរួលប្រអូសធុញទ្រាន់ធ្ងន់កាយធ្ងន់ចិត្ត មានមិនបង់
ក្រោកឡើងធ្វើការងារចាំងពួងជាលក្ខណៈ ។ ๑๓- មិទ្ធំ សេចក្តី
ងងុយអង្គុយងោកក្បាលធ្វើឲ្យធ្ងន់នាមកាយចាំង ๓ មានវេទនាខន្ធជាដើម
មាននាមកាយចាំង ๓ មិនគួរដល់ការងារចាំងពួងជាលក្ខណៈ ។
๑๔- វិចិកិច្ឆា សេចក្តីសង្ស័យមិនចេះដាច់ស្រេចក្នុងវត្ថុចាំង ๘ ឃាំង
គឺ:- សង្ស័យក្នុងគុណព្រះពុទ្ធ ๑, សង្ស័យក្នុងគុណព្រះនពលោ-
កុត្តរធម៌ ๑, សង្ស័យក្នុងគុណព្រះអរិយសង្ឃ ๑, សង្ស័យក្នុ

សិក្ខាបទ ៣ មានអធិស័យសិក្ខាជាដើម ១, សង្ឃ័យក្នុង ១ ខ្នងជាតុអាយតនៈជាអតីត ១, សង្ឃ័យក្នុង ១ ខ្នងជាតុអាយតនៈជាអនាគត ១, សង្ឃ័យក្នុងទី ៣ នេះ គឺ ១ ខ្នងជាតុអាយតនៈជាតីតនិងអនាគត ១, សង្ឃ័យក្នុងធម៌ទាំង ២ ប្រាយជាកុសលនិងជាអកុសល ដែលកើតឡើងព្រមក្នុងបច្ចុប្បន្ននេះ ១ ។ ក៏បេតសិកធម៌ ១ នេះប្រកបកើតឡើងព្រមក្នុងអកុសលចិត្តជាវិចិកិច្ឆាសហគតចិត្តតែ ១ ដោយឥតិ ។ សៃដ្ឋនាមកអំពីអកុសលបេតសិកពួកទី ២ ទាំង ១៤ ដោយសេចក្តីសង្ខេបតែប៉ុណ្ណេះឯង ។

៦៦- ធម្មវិទូ បានស្តាប់ហើយសួរតទៅទៀតថា ម្នាលអត្ថវិទូ ចុះសោភណបេតសិកពួកទី ៣ មានចំនួន ២៥ នោះ គឺបេតសិកអ្វីខ្លះ? សេចក្តីអធិប្បាយថាដូចម្តេចខ្លះ? ចូរលោកសៃដ្ឋនាមកយើងនឹងបានស្តាប់ចួលចិត្តផងមើល?

អត្ថវិទូ សៃដ្ឋនាតបថា បពិត្រធម្មវិទូ ឯសោភណបេតសិកពួកទី ៣ ទាំង ២៥ នោះគឺ: ១- សទ្ធា បេតនាដែលជ្រះថ្លាស្អាតជឿកម្ម ផលជាគំរប្បាស់ដោយខ្លួនឯង មានលក្ខណៈ ៣ យ៉ាង គឺសេចក្តីជឿជាក់ជ្រះថ្លាក្នុងគុណព្រះរតនត្រ័យ មានកិរិយាចរិយាតម្រង់ធ្វើបុណ្យឲ្យទានរក្សាសីល ៥ សីល ។ ឆ្លុះសម្ថនិងចំរើនព្រះកម្មដ្ឋានជាលក្ខណៈ ១, សេចក្តី

ដឿជាក៏ទៅជាមុន មានកិរិយាស្ទុះទៅ ដើរបបួលដឹកនាំអ្នកជាខ្មែ
ធ្វើបុណ្យឲ្យទានរក្សាសីល ៥ សីល១ដោសថនឹងចំរើនព្រះកម្មដ្ឋានជា
លក្ខណៈ ១, សេចក្តីដឿជាក់ក្នុងគុណត្រៃរតនត្រេយមិនកក្រើក មាន
កិរិយាញុំាងចិត្តដែលល្អក់មិនជ្រះថ្លាឲ្យនៃនាសទៅ ហើយញុំាងចិត្តដែល
ជ្រះថ្លាល្អឲ្យកើតខ្លឹងជាលក្ខណៈ ១ ៧ ឯសទ្ធាចេតសិកនេះ មាន
សេចក្តី១បមាដូចកែវមណីរោជតិ ដែលស្តេចព្រះបរមចក្រោធរៅក្នុងទឹក
ប្រកបដោយចរកវដ៏ល្អក់ហើយ អាចកំចាត់បង់នូវមន្ទិលសៅហ្មងដែលល្អក់
នោះឲ្យនៃនាសបាត់អស់ទៅ ញុំាងទឹកដែលវង្វាល្អដូចកញ្ចក់ឲ្យកើត
ខ្លឹងយ៉ាងណាមិញ កំសទ្ធាចេតសិកនេះកែកើតខ្លឹងក្នុងសន្តានចិត្តនៃ
បុគ្គលឯណាហើយ អាចញុំាងជួងចិត្តដែលសៅហ្មងល្អក់នៃបុគ្គលនោះ
ឲ្យជ្រះថ្លាល្អខ្លឹងជាកុសល ១បមាដូចកែវមណីរោជតិយ៉ាងនោះឯង ៧
២- សតិ ស្មារតីភ្ញាក់ធឹកវឹកនូវកុសលធម៌រឿយ ១ ពុំបានភ្លេច
១បមាដូចនាយឃ្មាំងរក្សាព្រះពជ្រត្បូរស្តេច តែងយកសេចក្តីក្រែបបង្គំ
ទូលអំពីចំនួនព្រះពជ្រត្បូរគាំងអស់សព្វ ១ ថ្ងៃ ឲ្យស្តេចទ្រង់ជ្រាបសព្វ
ត្រប់មិនឲ្យភ្លេចយ៉ាងណាមិញ ឯសតិចេតសិកនេះកែកើតខ្លឹងក្នុង
សន្តានចិត្តនៃបុគ្គលឯណាហើយ អាចញុំាងសន្តានចិត្តនៃបុគ្គលនោះឲ្យ

ភ្ញាក់ខ្លួនឬកឬឿយ ។ ខ្លួកុសលជម្ចាំងពួងមិនឲ្យកើតយ៉ាងនោះដែរ ។
๓- ហ៊ីរិ សេចក្តីខ្ពើមឆ្អប់ឆ្អាមក្នុងសោភជាធំ លះបង់នូវអកុសលកម្ម ហើយញ៉ាំងកុសលកម្មឲ្យកើតឡើងក្នុងសន្តានខ្លួនលះបង់នូវអំពើប្រកបដោយទោស ហើយញ៉ាំងអំពើដែលមិនប្រកបដោយទោសឲ្យកើតឡើងក្នុងសន្តានខ្លួន ឈ្មោះថាមានការពារខ្លួនឲ្យចៀសចេញអកុសលកម្មដ៏លាមកក្នុងសោភជាលក្ខណៈ ។ ๔- ឱត្តប្បំ សេចក្តីខ្លាចក្រហាយឆ្អាប់ស្អុកខ្លាចឆ្អប់ក្នុងសោភជាធំលះបង់នូវអកុសលកម្ម ហើយញ៉ាំងកុសលកម្មឲ្យកើតឡើងក្នុងសន្តានខ្លួនលះបង់នូវអំពើប្រកបដោយទោស ហើយញ៉ាំងអំពើដែលមិនប្រកបដោយទោសឲ្យកើតឡើងក្នុងសន្តានខ្លួន ឈ្មោះថាមានការពារខ្លួនឲ្យចៀសចេញអកុសលកម្ម ដ៏លាមកក្នុងសោភជាលក្ខណៈ ។
๕- អលោភោ សេចក្តីមិនសោកហួសប្រមាណដែលជាបដិបក្ខដល់មន្ទិលគឺសេចក្តីកំណាញ់ ជាហេតុនឹងឲ្យមានសទ្ធាជឿកម្មផល អាចបរិច្ចាគទ្រព្យធ្វើបុណ្យឲ្យទានបាន មានកិរិយាមិនជំពាក់ជាប់ចិត្តក្នុងអារម្មណ៍ទាំងពួងជាលក្ខណៈ ។ ๖- អទោសោ សេចក្តីមិនបានគ្រោធខឹងប្រទូសក្តីនឹងសង្សារដែលជាបដិបក្ខដល់មន្ទិល គឺការៈទ្រូស្តស័លជាហេតុនឹងឲ្យមានព្យាយាមរក្សាសីលបាន មានកិរិយាមិនបានការបសា-

ហាវនីដ្ឋប្បទស្តជាលក្ខណៈ ។ ៧- តត្រមជ្ឈត្តតា ការៈនៃចេតនា ដែលសំឡឹងមើលដំណើរបស្សនាវារម្មណ៍ មិនបានកាន់ច្រឡំ ហើយប្រព្រឹត្តទៅជាកណ្តាលនីដ៏នៅក្នុងអារម្មណ៍ទាំង ៦ នោះ ។ ៨- កាយប-ស្សទ្ធិ សេចក្តីរម្ងាប់ស្ងប់ស្ងាត់នៃនាមកាយគឺអរូបក្ខន្ធទាំង ៣ មានវេទនា-ខន្ធជាដើម មានកិរិយាចូលទៅជិតរម្ងាប់នូវសេចក្តីក្រវល់ក្រវាយនៃនាមកាយ ដែលកើតជាបដិបក្ខដល់កិលេសមានទុច្ចរិតជាដើមជាលក្ខណៈ ។ ៩ ចិត្តបស្សទ្ធិ សេចក្តីរម្ងាប់ស្ងប់ស្ងាត់នៃចិត្ត មានកិរិយាចូលទៅជិតរម្ងាប់នូវសេចក្តីក្រវល់ក្រវាយនៃចិត្ត ដែលកើតជាបដិបក្ខដល់កិលេសមានទុច្ចរិតជាដើមជាលក្ខណៈ ។ ១០- កាយលហុតា ការៈប្រព្រឹត្តទៅស្រាលរហ័សនៃនាមកាយ មានកិរិយាចូលទៅជិតរម្ងាប់នូវការៈធ្ងន់នៃនាមកាយ ដែលកើតជាបដិបក្ខដល់កិលេសគឺសេចក្តីខ្ជិលច្រអូស ដ៏ធ្ងុយងោកដ៏កដែលជាហេតុធ្វើឲ្យធ្ងន់នៃនាមកាយជាលក្ខណៈ ។ ១១- ចិត្តលហុតា ការៈប្រព្រឹត្តទៅស្រាលរហ័សនៃចិត្ត មានកិរិយាចូលទៅជិតរម្ងាប់នូវការៈធ្ងន់នៃចិត្ត ដែលកើតជាបដិបក្ខដល់កិលេស គឺសេចក្តីខ្ជិលច្រអូស ដ៏ធ្ងុយងោកដ៏កដែលជាហេតុធ្វើឲ្យធ្ងន់នៃចិត្តជាលក្ខណៈ ។ ១២- កាយមុទុតា ការៈរីកចម្រើនភ្លូនៃនាមកាយមានកិរិយាចូល

ទៅជាតម្លាប់នូវការៈបើធំរឹងរូសនៃនាមកាយ ដែលកើតជាបដិបក្ខដល់កិលេសតិចដ្ឋមានៈ ជាហេតុធ្វើឲ្យបើធំរឹងរូសនៃនាមកាយជាលក្ខណៈ ។ ๑๓ - ចិត្តមុទុតា ការៈកែកាយទន់ភ្លន់នៃចិត្ត មានកិរិយាចូលទៅជាតម្លាប់នូវការៈបើធំរឹងរូសនៃចិត្ត ដែលកើតជាបដិបក្ខដល់កិលេសតិចដ្ឋមានៈ ជាហេតុធ្វើឲ្យបើធំរឹងរូសនៃចិត្តជាលក្ខណៈ ។ ๑๔ - កាយកម្មញ្ញតា ការៈស្ពាតល្អកដ៏បរិសុទ្ធនៃនាមកាយ មានកិរិយាចូលទៅជាតម្លាប់នូវការៈមិនស្ពាតល្អកដ៏បរិសុទ្ធនៃនាមកាយ ដែលកើតជាបដិបក្ខដល់និវរណធម៌ ๕ មានកាមច្ឆន្ទៈជាដើមជាលក្ខណៈ ។ ๑๕ - ចិត្តកម្មញ្ញតា ការៈស្ពាតល្អកដ៏បរិសុទ្ធនៃចិត្ត មានកិរិយាចូលទៅជាតម្លាប់នូវការៈមិនស្ពាតល្អកដ៏បរិសុទ្ធនៃចិត្ត ដែលកើតជាបដិបក្ខដល់និវរណធម៌ ๕ មានកាមច្ឆន្ទៈជាដើមជាលក្ខណៈ ។ ๑๖ - កាយបាគុញ្ញតា ការៈស្ពាត់ជំនាញនៃនាមកាយ មានកិរិយាចូលទៅជាតម្លាប់នូវការៈលំបាកឈឺចាប់នៃនាមកាយ ដែលកើតជាបដិបក្ខដល់កិលេសតិអសទ្ធាមិនផ្សឹកម្ន-ផល ជាហេតុធ្វើឲ្យលំបាកឈឺចាប់នៃនាមកាយជាលក្ខណៈ ។ ๑๗ - ចិត្តបាគុញ្ញតា ការៈស្ពាត់ជំនាញនៃចិត្ត មានកិរិយាចូលទៅជាតម្លាប់នូវការៈលំបាកឈឺចាប់នៃចិត្ត ដែលកើតជាបដិបក្ខដល់កិលេស តិ អសទ្ធា មិនផ្សឹកម្ន - ផល

ជាហេតុធ្វើឲ្យលំបាកឈឺចាប់នៃចិត្តជាលក្ខណៈ ។ ๑๘- កាយុជុគ្គតា ភាវៈប្រព្រឹត្តទៅត្រង់នៃនាមកាយ មានកិរិយាពិចារណាឃើញជាគំរប្បាស់នូវភាវៈរឿបនៃនាមកាយ ដែលកើតជាបដិបក្ខដល់កិលេសតីភាវៈខ្ជិលជាហេតុធ្វើឲ្យរឿបនៃនាមកាយជាលក្ខណៈ ។ ๑๙- ចិត្តជុគ្គតា ភាវៈប្រព្រឹត្តទៅត្រង់នៃចិត្ត មានកិរិយាពិចារណាឃើញជាគំរប្បាស់នូវភាវៈរឿបនៃចិត្តដែលកើតជាបដិបក្ខដល់កិលេស តីភាវៈខ្ជិលជាហេតុធ្វើឲ្យរឿបនៃចិត្តជាលក្ខណៈ ។ កំចេតសិកធម៌ទាំង ๑๙ នេះបានឈ្មោះថា សោភណាចេតសិក ប្រកបកើតឡើងព្រមគ្នាក្នុងសោភណចិត្តទាំង ๗๙ ដោយពិត ។ ๒๐- សម្មាវាចា ប្រព្រឹត្តនូវពាក្យសំដីដ៏ល្អប្រពៃ មានវៀរលែងចាកវចីទុច្ចរិតទាំង ๔ មិនពោលនូវពាក្យមុសាវាទជាដើមជាលក្ខណៈ ។ ๒๑- សម្មាកម្មន្តា ប្រព្រឹត្តធ្វើនូវការងារដ៏ល្អប្រពៃ មានវៀរលែងចាកកាយទុច្ចរិតទាំង ๓ មិនប្រព្រឹត្តសម្លាប់សត្វលួចប្រព្រឹត្តនេជាដើមជាលក្ខណៈ ។ ๒๒- សម្មាអាជីវៈប្រព្រឹត្តិរកស៊ីចិញ្ចឹមជីវិតដ៏ល្អប្រពៃ គឺវៀរលែងចាកកាយទុច្ចរិត ๓ វចីទុច្ចរិត ๔ និងជំអួញទាំង ๕ ប្រការជាស្រឡះ (ចេតសិកធម៌ទាំង ๓ នេះបានឈ្មោះថា វិរតិចេតសិក សម្រាប់វៀរលែងចាកកុសលចិត្ត ដែលគួរគប្បីវៀរលែងប្រកបកើតឡើងព្រមក្នុងវីថីចិត្ត

ចាំង ១៦ គឺកាមាវចរកុសលចិត្ត ៨ លោកុត្តរចិត្ត ៨ ត្រូវជា ១៦ ដោយ
ពិត) ។ ๒๓ - ករុណា សេចក្តីអាណិតអាសូរដល់សត្វចាំងឡាយ
ដែលដល់នូវសេចក្តីទុក្ខលំបាកទាំង មានប្រាថ្នាដើម្បីនឹងនាំចេញនូវ
សត្វចាំងឡាយ ដែលដល់នូវសេចក្តីទុក្ខលំបាកនោះឲ្យរួចផុតចេញចាក
ទុក្ខវេទនាជាលក្ខណៈ ។ ๒๔ - មុទិតា សេចក្តីរីករាយចំពោះត្រជាក់ត្រក -
អរចំពោះព្រត្យរបស់យសស័ក្តិដែលបុគ្គលដទៃបានហើយ ពុំបានឋូសប្រ
ឈាមឈ្នានីសឡើយ មានកិរិយាអនុមោទនាត្រេកអរនឹករាយនូវសម្បត្តិ
នៃបុគ្គលដទៃជាលក្ខណៈ (កំរេតសិកធម៌ចាំង៧នេះបានឈ្មោះថា
អប្បមញ្ញាចេតសិក ព្រោះមានចេតនាផ្សាយទៅកាន់សត្វនឹងសង្ខារ
ចាំងឡាយប្រមាណពុំបានជាអារម្មណ៍ ប្រកបតែនឹងព្រមក្នុងវីថីចិត្ត
ចាំង ๔๘ គឺមហគ្គតចិត្ត ๑๒ កាមាវចរកុសលចិត្ត ๘ សរួមតុកកាមាវច
កិរិយាចិត្ត ๘ ត្រូវជា ๔๘) ។ ๒๕ បញ្ចិន្ទ្រិយំ ធម្មជាតដែលដឹងច្បាស់
ដោយអំណាចនៃលក្ខណៈចាំង ๓ មានសទ្ធិន្ទ្រិយ ជាដើម បាន
ឈ្មោះថាបញ្ចា តែថាបញ្ចានោះឯងព្រះអរហំសម្មាសម្ពុទ្ធទ្រង់ដាក់ឈ្មោះថា
ឥន្ទ្រិយ ព្រោះថាជាអធិបតី ជាធំក្នុងកិរិយាដឹងច្បាស់ដឹងសមគួរតាមសភាព
ពិត មានកិរិយាយល់ឃើញត្រូវជាលក្ខណៈ បញ្ចានោះឯង បានឈ្មោះថា

បញ្ចន្ទ្រិយដោយពិត តែងប្រតបកើតឡើងព្រមក្នុងវិថីចិត្តចាំង ៤៧ គឺ
គាមាវចរសោភណចិត្តជាញាណសម្បយុត្ត ១២ មហគ្គតចិត្ត ២៧ លោកុត្តរ-
ចិត្ត ៨ ត្រូវជា ៤៧ ដោយពិត ។ វិសជ្ជនាមកអំពីសោភណចេតសិក
ពួកទី ៣ ចាំង ៤៥ ដោយសង្ខេបតែប៉ុណ្ណោះ ។

ឬកម្មអញ្ញសមានាចេតសិកពួកទី ១ មានចំនួន ១៣ អកុសលចេត-
សិកពួកទី ២ មានចំនួន ១៤ សោភណចេតសិកពួកទី ៣ មានចំនួន ២៥
ត្រូវជាចេតសិកធម៌ ៥២ ដោយសង្ខេបតែត្រឹមប៉ុណ្ណេះឯង ។

៦៧- ធម្មវិទី ពានស្តាប់ហើយពោលថា សាធុ ។ ម្នាល
អត្តវិទី លោកបានវិសជ្ជនាមកនេះប្រពៃណាស់ហើយ តែថាយើង
លើកចិត្តនឹងចេតសិកទុកសិនចុះ យើងនឹងសួរលោកអំពីរូបវិញ
ចុះពាក្យថារូប ។ សព្វនេះ ប្រែថាដូចម្តេច ? សេចក្តីអធិប្បាយថា យ៉ាង
ណាខ្លះ ?

អត្តវិទី វិសជ្ជនាគបថា ចតុត្រូធម្មវិទី ឯរូបសព្វនោះ សេចក្តី
ប្រែថា ធម្មជាតសក្រាបនិងសរសាយសូន្យទៅដោយត្រជាក់នឹងក្តៅជា
ដើម បានឈ្មោះថា រូប សេចក្តីអធិប្បាយថា រូបសព្វទាំងឡាយតែ
កើតមានឡើងហើយ តែងនិងសាបសូន្យដោយវដ្តត្រជាក់រដូវមកបៀត

បៀនបូប ធ្វើឲ្យបូបគ្រាំគ្រាស៊ូតស្រោចនជ្រុញជ្រែរទៅ ជាបច្ច័យឲ្យ
កើតជាជកផង វិនាសទៅដោយកំដៅព្រះអាទិត្យដែលរះឡើងនីមួយកំដៅ
ភ្លើងក្តៅស្អុះស្អាប់ចូលមកបៀតបៀនរូប ធ្វើឲ្យរូបគ្រាំគ្រាសៅហ្មងជ្រុញ
ជ្រែរទៅផ្សេង ។ ពលំថ្ងៃជាបច្ច័យឲ្យកើតជាជក ។ ជាបច្ច័យឲ្យកើតឥន្ទ្រិយ
ជម្ងឺឈឺចាប់ មានឈឺក្បាលវិលមុខជាដើមផង វិនាសទៅដោយរមួល
តោះហ្មងចុយស្រែកទឹកនឹងប៉ះពាល់ដោយសម្ផស្ស នៃសត្វរោមមួស
សុបសង្កើចនឹងឲ្យលំត្មុះកំដៅថ្ងៃនឹងឥស៊ីតូចឥស៊ីធំជាដើម ចូលមកបៀត
បៀនរូបមានទាំងញាក់យកជាតឈាមជាដើម ជាបច្ច័យឲ្យកើតជាជក
គ្រាំគ្រាទៅជានិច្ចនិច្ចមន្តង ។ តែពលំ ។ ថ្ងៃទៅ តុំយូរប៉ុន្មានក៏កើតជាបច្ច័យ
ដល់ឥន្ទ្រិយជម្ងឺឈឺចាប់យ៉ាងតិច ។ ផកបដល់ជម្ងឺឈឺចាប់យ៉ាងធ្ងន់ខ្លាំងជា
បច្ច័យដល់មរណៈសេចក្តីស្លាប់សូន្យទាំងកម្ម ចិត្ត រូប គាហារ អស់ទៅ
សល់នៅតែអនុបាទិន្នករូបឥរិយាបថសព សូន្យរលោងទៅ ជាដី ទឹក ភ្លើង
ខ្យល់អស់ទៅវិញ ឋានឈ្មោះថា រូប ព្រោះរូបទាំង ៤ មានឧបចយរូបជា
ដើម ប្រកបដោយលក្ខណៈ ៣ យ៉ាង គឺអនិច្ចលក្ខណៈ ១ ទុក្ខលក្ខណៈ ១
អនត្តលក្ខណៈ ១ ជារូបមិនខៀងតែងប្រែប្រួលទៅផ្សេង ។ តែងនាំមក
នូវសេចក្តីទុក្ខលំបាកផ្សេង ។ ជារបស់ពុំបានប្រព្រឹត្តទៅតាមអំណាច

នៃខ្ញុំ គឺថាពុំបានស្តាប់បង្គាប់ខ្ញុំដោយត្រឹម ។ ខ្ញុំអត្តភាព ចានវិសជ្ជនា
មកអំពីរូបស័ព្ទ ព្រមទាំងសេចក្តីអធិប្បាយដោយសង្ខេបតែប៉ុណ្ណេះ
សូមជ្រាប ។

៦៨- ធម្មរាជ្ញី បានស្តាប់ហើយសួរគេថាទៀត ម្នាលអត្តភាព
បុរសតាវធម៌ទាំងពីរយ៉ាង គឺមហាភូត: ១ ។បាទាយ: ១ ដែលព្រះសព្វញ្ញូ
សម្ពុទ្ធព្រះអង្គទ្រង់លើកឡើងតាន់បញ្ញត្តិ ឲ្យឈ្មោះថា រូប, តែក្រនីរូប-
ស័ព្ទនោះ លោកបានវិសជ្ជនាមករួចហើយ យើងពុំបានសួរទេ យើង
នឹងសួរចំពោះតែក្រនីមហាភូតស័ព្ទនឹង ។បាទាយស័ព្ទទាំងពីរបទនេះ មាន
សេចក្តីអធិប្បាយថាដូចម្តេចខ្លះ? ចូរលោកវិសជ្ជនាមកយើងនឹងបាន ស្តាប់
ចូលចិត្តផងមើល?

អត្តរាជ្ញី វិសជ្ជនាតបថា បពិត្រធម្មរាជ្ញី ឯមហាភូតស័ព្ទនោះ
ប្រែថា សតាវធម៌មានសភាពធំកើតឡើងច្រាកដហើយ, សេចក្តីអធិ-
ប្បាយថា សតាវ: ទាំង៤យ៉ាង គឺកម្ម ១ ចិត្ត ១ ឧតុ ១ អាហារ ១
ជាបច្ច័យប្រជុំព្រមស្មើគ្នា ក្នុងផលគឺរូបទ្បើកើតឡើងច្រាកដ ដូចមាន
ចាលីកឯគម្ពីរដីកានឹងយោជនាព្រះអភិធម្មតន្ត្រីលំដាប់ថា ។បាទិន្នានុបា-
ទិន្នសន្ធានេសុ សសម្ភារធម្មេសុ មហន្តា ហុត្វា ភូតាតិ មហាភូតា

ជម្ម (ប្រែថា) សភាវធម៌ទាំង ៤ ឃ្លាយជាឯណា មានភាពជាប្រជុំកើត
ឡើងច្រើនកន្លែងហើយ ក្នុងសន្តានរបស់ពួកខ្ញុំនឹងអនុពួកខ្ញុំកើតជាមួយ
គំណាចដែលប្រព្រឹត្តទៅជាមួយនឹងសេចក្តីអធិប្បាយថា សភាវធម៌ទាំង
ឃ្លាយនោះ ពួកខ្ញុំហៅថា មហាភូត សេចក្តីអធិប្បាយថាជាតុទាំង
៤ គឺបឋវីជាតុ ។ ដែលមានសភាពរឹង ជាលក្ខណៈ ១, អាបោជាតុ ។
ដែលមានសភាពទន់ជ្រាយជាដើម ជាលក្ខណៈ ១, តេជោជាតុ ។ ដែលមាន
សភាពអប់រុំក្តៅ ។ ជាលក្ខណៈ ១, វាយោជាតុ ។ ដែលមានភាពបក់មក
រេហើយ ។ ជាលក្ខណៈ ១ ជាតុទាំង ៤ នេះប្រជុំព្រមស្មើគ្នាក្នុងភពសម្រាប់
កើតឯណា សភាវធម៌ទាំង ៤ មានកម្មជាដើម ចូលមកប្រជុំព្រម
ស្មើគ្នាក្នុងភពសម្រាប់កើតនោះហើយញ៉ាំងផល គឺកលលរបស់ឲ្យកើតឡើង
ច្រើនជា ៧ ថ្ងៃ ។ ជាលំដាប់គ្នា ។ ល ។ ជាពួកខ្ញុំ អនុពួកខ្ញុំ-
រូបខ្លះ ទើបបានឈ្មោះថា មហាភូត តក្លាប់គ្នានឹងរូប ហៅថា
មហាភូតរូប ដោយពិត ។ ពួកយើងខ្ញុំនោះ មានសេចក្តីអធិប្បាយថា:
ជម្ម៌ជាតឯណាដែលអាស្រ័យកាន់យកទាំងរូបមហាភូតរូបទាំង ៤ ហើយ
ញ៉ាំងផល គឺរូបជាឥន្ទ្រិយខ្លះ ឥន្ទ្រិយក្រៅខ្លះ ឲ្យកើតចំរើនច្រើនឡើង
សមគួរតាមលំដាប់ ធម្ម៌ជាតនោះបានឈ្មោះថា ពួកយើង តក្លាប់គ្នា

ធំដែរបូប ហៅថា ទុកាយរូប ដោយពិត ។ រីសជ្ឈនាមកអំពីមហាភូតសម្ភូ
ធិដែរទុកាយសម្ភូ តាំងពីរបទនេះដោយសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

๖๙- ជម្ពុរាទី ចានស្តាប់ហើយសួរគេទៀតថា ម្នាលអគ្គវ័
ចុះមហាភូតរូបនោះមានចំនួនប៉ុន្មាន? គឺរូបអ្វីខ្លះ? ចូរលោកវិសជ្ឈនាកប់ចំនួន
រូបព្រមទាំងសេចក្តីប្រែរធិប្បាយឲ្យសព្វគ្រប់មក យើងនឹងបានស្តាប់
ចូលចិត្តផងមើល?

អគ្គរាទី វិសជ្ឈនាកបថា បពិត្រធម្មាវ័ មហាភូតរូបនោះមាន ៤
គឺ: ๑- បឋវីធាតុ ។ ដែមានចំនួន ๒๐ គឺ កេសា សក់តាំងខ្លាយ ๑
លោមា រោមតាំងខ្លាយ ๑ នខា ក្រចកតាំងខ្លាយ ๑ ទន្តា ធ្មេញ
តាំងខ្លាយ ๑ តចោ សែ្បក ๑ មំសំ សាច់ ๑ នហារូ សរសៃតាំង-
ខ្លាយ ๑ អដ្ឋី ឆ្អឹងតាំងខ្លាយ ๑ អដ្ឋិមិញ្ជំ ខួរក្នុងឆ្អឹង ๑ វក្កំ ពោះ
ប្តកម្រងបស្សាវៈ ๑ ហទយំ បេះដូង ๑ យកនំ ថ្លើម ๑ កិលោមកំ
ពោះ ๑ បិហកំ ក្រពះ ឬលំពែងអាសៈ ๑ បប្ផាសំ សួត ๑ អន្តំ ពោះ
វៀនធំ ๑ អន្តគុណំ ពោះវៀនតូច ๑ ឧទរិយំ អាហារឬ ๑ ករីសំ
អាហារចាស់ ๑ មត្ថកមត្ថលុង្គំ ខួរក្បាលក្បាល ๑ ។ ๒- អាបោ-
ធាតុ ។ ទឹកមានចំនួន ๑๒ គឺ បិត្តំ ទឹកប្រមាត់ ๑ សេម្ហំ ទឹកស្លេស្ម ๑

ប៊ុញ្ជូ ទឹកខ្ទុះ ១ លោហិតំ ទឹកឈាម ១ សេពោ ទឹកញើស ១ មេទោ ទឹកខ្ទាញ់ទាប់ ១ អស្សុ ទឹកភ្នែក ១ វសា ទឹកខ្លាញ់ពពាំងឆ្អែ ១ ខេឡា ទឹកមាត់ ១ សិង្ឃានិកា ទឹកសម្បោរ ១ លសិកា ទឹកលំអិល ១ មុត្តំ ទឹកមូត្រ ១ ។ ៣- គេរជាតុ ។ ក្លែងមានចំនួន ៤ គឺសន្ធប្បគ្គិ ជាតុក្លែងអប់រុំក្តៅស្រួលផ្សាយទៅក្នុងកាយជាប្រក្រតី ១ បរិទយ្ហគ្គិ ជាតុក្លែងក្តៅពេលពាលផ្សាយទៅក្នុងកាយ ១ បរិណាមគ្គិ ជាតុក្លែងដុតកហារឆ្អែប្រុងប្រៀងក្រមផ្សាយ ១ ជារសឆ្អែជ្រួតជ្រាបទៅក្នុងសព្វាង្គកាយ ១ ជីរណគ្គិ ជាតុក្លែងដុតរាងកាយឆ្អែជ្រួញជ្រីវគ្រាំគ្រាចាស់ជាដើម ១ ។ ៤- ភាយោជាតុ ។ ឆ្អែលមានចំនួន ៦ គឺឧទ្ធង្គមា ភាគ ឆ្អែលំពាំងឆ្អែយបក់ពីខាងក្រមផ្សាយឡើងទៅខាងលើ ១ អាធោគមា ភាគ ឆ្អែលំពាំងឆ្អែយបក់ពីខាងលើផ្សាយចុះមកខាងក្រោម ១ កុច្ឆិសយា ភាគ ឆ្អែលំពាំងឆ្អែយបក់លែវលំផ្សាយនៅក្នុងពោះ ១ កោដ្ឋាសយា ភាគ ឆ្អែលំពាំងឆ្អែយបក់ផ្សាយនៅក្នុងគោះវៀនធំ-តូច ១ អង្គមង្គានុសារិនោ ភាគ ឆ្អែលំពាំងឆ្អែយបក់ផ្សាយសព្វទៅក្នុងអវយវៈធំ តូច ១ អស្សាសបស្សាសា ភាគ ឆ្អែលំពាំងឆ្អែយសម្រាប់ដកដង្ហើមចេញចូលដកដង្ហើមចូល ១ ។ ក៏ជាតុទាំង ៤ នេះ ជាន

ឈ្មោះថា មហាភូតរូបដោយពិត ។ សេដ្ឋនាមកអំពីមហាភូតរូបទាំង ៤ ដោយសេចក្តីសន្មតតែប៉ុណ្ណោះឯង ។

៣០ - ធម្មវាទី ពាន ស្តាប់ហើយសួរតទៅទៀតថា ម្នាលអត្តវាទី ចុះពាយរូបនោះមានចំនួនប៉ុន្មាន ? គឺរូបអ្វីខ្លះ ? ឬរលោកសេដ្ឋនាឲ្យសព្វគ្រប់មកយើងនឹងពាន ស្តាប់ចូលចិត្តផងមើល ?

អត្តវាទី សេដ្ឋនាតបថា បពិត្រធម្មវាទី ឯពាយរូបនោះមានចំនួន ៦៨ គឺ: ១- ចក្ខុ រូបគឺភ្នែក ២- សោត: រូបគឺត្រចៀក ៣ - ឃាន: រូបគឺច្រមុះ ៤ - ជិវ្ហា រូបគឺអណ្តាត ៥ - កាយ: រូបគឺពាងកាយ (ក៏រូបទាំង ៥ នេះឈ្មោះថាបសាទរូប ជារូបខាងក្នុងសម្រាប់ជ្រះថ្លាប៉ះពាល់ត្រូវនូវអារម្មណ៍) ៦ រូបារម្មណ: រូបគឺរូបជាអារម្មណ៍ ៧ - សទ្ទារម្មណ: រូបគឺសំឡេងជាអារម្មណ៍ ៨-គន្ធារម្មណ: រូបគឺក្លិនជាអារម្មណ៍ ៩-រសារម្មណ: រូបគឺរសជាអារម្មណ៍ (ក៏រូបទាំង ៤ នេះឈ្មោះថា សិយរូបជារូបខាងក្រៅជាសិយជាទីតាំង តែថាជាចំណីអាហារនៃបញ្ចវិញ្ញាណដោយពិត) ១០ - ឥត្ថីភាវ: រូបគឺភាពជាស្ត្រី ១១ - បុមភាវ: រូបគឺភាពជាប្រុស (រូប២នេះឈ្មោះថាភាវរូប) ១២ - ហទយ: រូបគឺហឫទ័យជាទីតាំងស្រ័យនៃមនោធាតុ ១៣ ជីវិត: រូបគឺជីវិតជាធំជាទីប្រព្រឹត្តទៅនៅ មានកិរិយា

ក្នុងអតិមហគ្គារម្មណ៍ គារម្មណ៍មានចិត្តប្រែនទាំងនោះ មាន ២ យ៉ាងគឺ ១ - គារម្មណ៍មានចិត្ត ១៨ គឺអតីតភវង្គៈ ១ ភវង្គចលនៈ ១ ភវង្គុបច្ឆេទៈ ១ បញ្ចទ្វារាវជ្ជនៈ ១ បញ្ចវិញ្ញាណៈ ១ សម្បដិច្ឆនៈ ១ សន្តីរណៈ ១ វោដ្ឋព្វនៈ ១ ជវនៈ ៥ គគារម្មណៈ ៤ ឫតិចិត្ត ១ បដិសន្ធិចិត្ត ១ ភវង្គចិត្ត ១ ត្រូវជា ១៨ តត់ កាវចិត្ត

កើតឡើងមានទំណាចិត្តកើតប្រែនទាំងយ៉ាងនេះ. បញ្ចារម្មណ៍មានរូប
ជាដើមជាវេបស់បដិសន្ធិចិត្ត ជាអារម្មណ៍គឺបណ្តិតកំណត់ថា កម្មនិមិត្ត
ជាបច្ចុប្បន្នពិត, អារម្មណ៍ជាវេបស់ភវង្គចិត្ត ជាអារម្មណ៍គឺបណ្តិតកំណត់
ថា កម្មនិមិត្តជាអតីតដោយពិត ។ ទី ២ - អារម្មណ៍មានទំណាចិត្ត ១៩
គឺអតីតភវង្គ: ១ ភវង្គចលន: ១ ភវង្គុប្បាច្ឆេទ: ១ បញ្ចទ្វារាវជ្ជន: ១
បញ្ចវិញ្ញាណ: ២ សម្បដិច្ឆន: ២ សន្តីរណ: ៣ វោដ្ឋព្វន: ១ ជវន: ៧
តទារម្មណ: ៥ ភវង្គ: ១ ចុតិចិត្ត ១ បដិសន្ធិចិត្ត ១ ភវង្គចិត្ត ១
ត្រូវជា ១៩ គត់ ក៏ថាចិត្តកើតឡើងមានទំណាចិត្តប្រែនទាំងដ៏ក្រៃលែង
យ៉ាងនេះ បញ្ចារម្មណ៍មានរូបជាដើម ជាវេបស់បដិសន្ធិចិត្ត ទីឆភវង្គ-
ចិត្តទាំងឡាយនោះ ជាអារម្មណ៍គឺបណ្តិតកំណត់ថា កម្មនិមិត្តជាអតីត
តែម្យ៉ាងពិត ។ សេចក្តីអធិប្បាយថា បណ្តាអារម្មណ៍ទាំង ៧ នោះ
អារម្មណ៍ឯណាគឺបណ្តិតកំណត់ថា កម្មនិមិត្តវេបស់បដិសន្ធិចិត្តទាំងដើម
អារម្មណ៍នោះឯង ឆានឈ្មោះថា ជាអារម្មណ៍វេបស់ចុតិចិត្តដោយពិត ។
ព្រោះហេតុនោះ អារម្មណ៍ទាំង ៦ មានរូបជាដើម ឆានឈ្មោះថា ជាអ-
រម្មណ៍វេបស់ចុតិចិត្តទាំងអស់ជាអតីតតែម្យ៉ាងពិត ។ តែថាគន្ថដីកាអភិ-
ធម្មត្ថសង្គហ: លោកភទន្តរៀបថា ឆម្ចារម្មណ៍ដែលមកណាសន្តជវន តឹ

ជវនជិតស្លាប់ កាន់យកប្រព្រឹត្តទៅក្នុងមនោទ្វារជាអារម្មណ៍របស់បុគ្គលចិត្ត-
បដិសន្ធិចិត្ត ភវង្គចិត្តចាំងឮជាដរាបជាតាមវេនវិថីក តែបណ្តិតតំណាល់ថា
កម្មារម្មណ៍ ជាកម្មនិមិត្តជាអតីតតែមួយនិងតែ ។ ឯចំណែកបួនារម្មណ៍
មួយដែលមរណាសន្នជវន កាន់យកប្រព្រឹត្តទៅក្នុងមនោទ្វារជាអារម្មណ៍
របស់បុគ្គលចិត្ត-បដិសន្ធិចិត្ត-ភវង្គចិត្តចាំងឮជាដរាបជាតាមវេនវិថីក តែបណ្តិត
តំណាល់ថា គតនិមិត្ត ជាបច្ចុប្បន្នដោយចំណែកមួយតែង ។ ឯវិថីចិត្ត
ប្រព្រឹត្តទៅក្នុងមនោទ្វារមាន ១ណាចិត្តតែប ប្រែនដូចមាននៅសេចក្តីអធិប្បាយ
តទៅនេះ ខ្ញុំ ១- អរិកូតារម្មណ៍ វិថីចិត្តតើតខ្លឹនក្នុងអារម្មណ៍ដែលមិនឃើនច្បាស់ មាន១ណាចិត្តយ៉ាងតិច ១២ គឺភវង្គ: ១ ភវង្គចលន: ១
ភវង្គុប្បាច្ឆេទ: មនោទ្វារាវជ្ជន: ១ ជវន: ៥ បុគ្គលចិត្ត ១ បដិសន្ធិចិត្ត ១
ភវង្គចិត្ត ១ ត្រូវជា ១២ គត់ មាន១ណាចិត្តយ៉ាងប្រែន ១៣ គឺភវង្គ: ១
ភវង្គចលន: ១ ភវង្គុប្បាច្ឆេទ: ២ មនោទ្វារាវជ្ជន: ១ ជវន: ៥ ភវង្គ: ១
បុគ្គលចិត្ត ១ បដិសន្ធិចិត្ត ១ ភវង្គចិត្ត ១ ត្រូវជា ១៣ គត់ ។ ខ្ញុំ ២
អរិកូតារម្មណ៍ វិថីចិត្តតើតខ្លឹន ក្នុងអារម្មណ៍ដែលតើតខ្លឹនច្បាស់ឃើន
មាន១ណាចិត្តយ៉ាងតិច ១៣ គឺភវង្គ: ១ ភវង្គចលន: ១ ភង្គុប្បាច្ឆេទ: ១
មនោទ្វារាវជ្ជន: ១ ជវន: ៥ តទាលម្ពណ: ១ បុគ្គលចិត្ត ១ បដិសន្ធិចិត្ត ១

ភវង្គចិត្ត ๑ ត្រូវ ๑๓ តត់ មានខណចិត្តយ៉ាងច្រើន ๑๔ គឺ ភវង្គចលនៈ ๑ ភវង្គុបច្ឆេទៈ ๑ មនោទ្វារាវជ្ជនៈ ๑ ជវនៈ ๗ តទារម្មណៈ ๒ ភវង្គៈ ๑ ចុតិចិត្ត ๑ បដិសន្ធិចិត្ត ๑ ភវង្គចិត្ត ๑ ត្រូវជា ๑๔ តត់ ។

សេចក្តីពន្យល់ថា អារម្មណ៍ពាំង ๖ ជាអារម្មណ៍របស់វិថីចិត្តពាំងខ្លាយដែលប្រព្រឹត្តទៅក្នុងមនោទ្វារ ជាអារម្មណ៍តែតឡើងត្រាកជក្នុងខណៈដែល ភវង្គចលនចិត្ត ជាចលមតែតឡើងដោយពិត អធិប្បាយថា: បុគ្គលឯណាមួយ ប្រព្រឹត្តធ្វើអំពើបាបលាមក ទន្ទឹងប្តូរទៅកើតក្នុងនរក ឯរូបារម្មណ៍ មានអណ្តាតភ្លើងនរកជាដើម ជាខ្មុតនិមិត្តដល់បុគ្គលនោះ តែតឡើងត្រាកជក្នុងមនោទ្វារជាបច្ចុប្បន្នដោយចំណែកមួយពិត ។ បុគ្គលឯណាមួយប្រព្រឹត្តធ្វើអំពើល្អជាកុសល មានឱ្យទានរក្សាសីលជាដើម ទន្ទឹងប្តូរទៅកើតក្នុងកាមាវចរទេវលោក ឯរូបារម្មណ៍មានដើមកប្បព្រឹក្សទិព្វមានជាដើម ជាសុគតិនិមិត្តដល់បុគ្គលនោះ តែតឡើងត្រាកជក្នុងមនោទ្វារជាបច្ចុប្បន្នដោយចំណែកមួយពិត ។ ក៏អារម្មណ៍ពាំង ๖ របស់សត្វពាំងខ្លាយ មានកាមាវចរបដិសន្ធិសត្វជាដើម ដែលមរណាសន្នជវនៈកាន់យកក្នុងទ្វារពាំង ๖ ប្រព្រឹត្តទៅតាមសភាពពិត ជាបច្ចុប្បន្នខ្លះ ជាអតីតខ្លះ ដែលបណ្ឌិតកំណត់ថា កម្មនិមិត្តនិងគតិនិមិត្ត ដូចន័យដែល

ចានអធ្យាយមកយ៉ាងនេះឯង ។ ចំណែកជម្មារម្មណ៍របស់សត្វទាំង
ឡាយ ជារូបាវចរបដិសន្ធិក្តី ជាបឋមារូបាវចរបដិសន្ធិនឹងតតិយារូបា-
វចរបដិសន្ធិក្តី ដែលមរណាសន្នដវនៈ កាន់យកកម្មនិមិត្ត ឬគតិនិមិត្ត
កំណត់ថា កម្មនិមិត្ត តើតតាមបញ្ញត្តិជាអតីតតែម្យ៉ាងពិត, ឯជម្ម-
រម្មណ៍របស់សត្វជារូបាវចរបដិសន្ធិ ២ ទី ៤ ជាកម្មនិមិត្ត ជាអតីតា-
រម្មណ៍ជួចតាដែរ ។ វិសជ្ជនាមកកង្ខាវម្មណសង្គហៈ ជាសេចក្តី
សន្និដ្ឋានតែប៉ុណ្ណោះ ។

៨៤- ជម្ពាវិទី ចានស្តាប់ហើយសួរគាថាទៀតថា ម្នាលអត្ត-
ចារ្យ ប្រស្នាដែលលោកវិសជ្ជនាមកនេះប្រពៃហើយ តែយើងនៅមាន
សង្ស័យអំពីវត្ថុធម៌វិញ្ញាណជាតុគាថាទៀត ចុះវត្ថុមានប៉ុន្មាន ? តើវត្ថុអ្វីខ្លះ ?
វិញ្ញាណជាតុមានប៉ុន្មាន ? តើវិញ្ញាណជាតុអ្វីខ្លះ ? វិញ្ញាណជាតុទាំងអស់
នោះទៀត តើតទៅដឹងអាស្រ័យនូវវត្ថុអ្វីខ្លះ ? គ្នា ដោយភាពទាំង ៣ ដូច
ម្តេចខ្លះ ?

អត្តវាទី វិសជ្ជនាតបថា : ចាត្រូវជម្ចាស់ តាមន័យបរមត្ថព្រះ
អភិធម្ម ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្តែងថា វត្ថុមាន ៦ គឺ ទី
កន្លែងសម្រាប់ជ្រះថ្លា ត្រូតអារម្មណ៍ដោយភ្នែកយើញរូបជាដើម ។

បានឈ្មោះថា បក្ខុវត្ត ๑ ទីកន្លែងសំរាប់ជ្រះថ្លាត្រេកអានូវសព្ទារម្មណ៍ ដោយត្រចៀកស្តាប់សំឡេងផ្សេង ។ បានឈ្មោះថា សោតវត្ត ๑ ទីកន្លែងសម្រាប់ជ្រះថ្លាត្រេកអានូវគន្ធារម្មណ៍ ដោយច្រមុះស្រង់ក្លិនផ្សេង ។ បានឈ្មោះថា ឃានវត្ត ๑ ទីកន្លែងសម្រាប់ជ្រះថ្លាត្រេកអានូវរសារម្មណ៍ ដោយអណ្តាតស្រូបភ្លក់សេទ្ធាញ់ផ្សេង ។ បានឈ្មោះថា ជិវ្ហាវត្ត ๑ ទីកន្លែងសម្រាប់ជ្រះថ្លាត្រេកអានូវផោដ្ឋព្វារម្មណ៍ ដោយកាយប៉ះពាល់នូវរូបារម្មណ៍ផ្សេង ។ បានឈ្មោះថា កាយវត្ត ๑ ទីកន្លែងសម្រាប់តើតខ្ជីឯនៃធម្មារម្មណ៍ ដោយចេវជ្ជ ជាទីលំនៅរបស់មនោធាតុ តែងទន្ទេមកាន់ធម្មារម្មណ៍ផ្សេង ។ បានឈ្មោះថា ហទយវត្ត ๑ ត្រវជ្ជវត្ត ๖ តាត ។ ធម្មជាតិ សម្រាប់ដឹងច្បាស់នូវអារម្មណ៍ផ្សេង ។ គ្រាន់តែជាធាតុទ្រទ្រង់នៅក្នុងគួហាតឺមហាភូតរូបចំណឹង ๔ មិនមែនសត្វ មិនមែនជីវិត សម្រាប់សួនឬសោះទៅវិញជាធម្មតា បានឈ្មោះថា វិញ្ញាណធាតុមាន ๗ គឺចក្ខុវិញ្ញាណធាតុ វិញ្ញាណអាស្រ័យនូវចក្ខុវត្ថុហើយប្រព្រឹត្តទៅគ្រាន់តែជាធាតុ ๑ សោតវិញ្ញាណធាតុ វិញ្ញាណអាស្រ័យនូវសោតវត្ថុ ហើយប្រព្រឹត្តទៅគ្រាន់តែជាធាតុ ๑ ឃានវិញ្ញាណធាតុ វិញ្ញាណអាស្រ័យនូវឃានវត្ថុ ហើយប្រព្រឹត្តទៅ

គ្រាន់តែជាធាតុ ๑ ជិវ្ហាវិញ្ញាណធាតុ វិញ្ញាណអាស្រ័យនូវជិវ្ហាតែហើយ
ប្រព្រឹត្តទៅគ្រាន់តែជាធាតុ ๑ កាយវិញ្ញាណធាតុ វិញ្ញាណអាស្រ័យ
នូវកាយតែហើយប្រព្រឹត្តទៅគ្រាន់តែជាធាតុ ๑ មនោធាតុ ចិត្តសម្រាប់
ទទួលដឹងច្បាស់នូវធម្មារម្មណ៍អាស្រ័យនូវហទយតែ ហើយប្រព្រឹត្ត
ទៅគ្រាន់តែជាធាតុ ๑ មនោវិញ្ញាណធាតុ ចិត្តសម្រាប់ទុនទៅកាន់
អារម្មណ៍ដឹងច្បាស់នូវអារម្មណ៍ផ្សេង ๆ អាស្រ័យនូវហទយតែ ៖ មិន
ចានអាស្រ័យនូវហទយតែ ៖ ហើយប្រព្រឹត្តទៅគ្រាន់តែជាធាតុ ๑
ត្រូវជាវិញ្ញាណធាតុទាំង ๗ ពាក្យ ๆ ឯវិញ្ញាណធាតុទាំង ๗ ដែល
អាស្រ័យនូវតែផ្សេង ๆ កន្លងមកទាំង ๓ នោះ ជួបអធិប្បាយតទៅនេះ
តែកន្លងមកនូវវិញ្ញាណធាតុទាំង ๗ នេះ តែងអាស្រ័យនូវតែទាំង ๖
ដោយពិត កន្លងមកមានតែវិញ្ញាណធាតុ ๔ គឺចក្ខុវិញ្ញាណធាតុ ๑
សោតវិញ្ញាណធាតុ ๑ ឃានធាតុ ๑ ឃានវិញ្ញាណធាតុ ๑ តែងអាស្រ័យ
នូវតែទាំង ๓ គឺចក្ខុតែ ๑ សោតតែ ๑ ឃានតែ ๑ ដោយពិត
កន្លងមកមានតែមនោវិញ្ញាណធាតុ ๑ តុំចានអាស្រ័យនូវតែអ្វីឡើយ
មានចិត្តជាអាយតនៈដោយពិត ๆ ដែលជួនាមកអំពីតែ និងវិញ្ញាណ-
ធាតុជាសេចក្តីសង្ខេបតែប៉ុណ្ណេះឯង ๆ

๘๕- ធម្មវាទី ថានស្តាប់ហើយ សួរកង្ខាវិសយប្បវត្តិសង្ខេបៈ តទៅទៀតថា; ម្នាលអត្តវាទី ចុះកង្ខាវិសយប្បវត្តិសង្ខេបៈ វិថីចិត្តដែលត្រាច់ទៅមកក្នុងទ្វារចំនួន ៦ នោះមានឈ្មោះដូចម្តេច? គឺវិថីចិត្តអ្វី? សេចក្តីអធិប្បាយ ថាដូចម្តេចខ្លះ?

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី វិថីចិត្តដែលត្រាច់ទៅមកក្នុងទ្វារចំនួន ៦ នោះមាន-៦ គឺវិថីចិត្តសម្រាប់ត្រាច់ទៅមកក្នុងចក្ខុទ្វារ ថានឈ្មោះថា ចក្ខុទ្វារវិថី ១ វិថីចិត្តសម្រាប់ត្រាច់ទៅមកក្នុងសោតទ្វារ ថានឈ្មោះថា សោតទ្វារវិថី ១ វិថីចិត្តសម្រាប់ត្រាច់ទៅមកក្នុងឃានទ្វារ ថានឈ្មោះថា ឃានទ្វារវិថី ១ វិថីចិត្តសម្រាប់ត្រាច់ទៅមកក្នុងជិវ្ហាទ្វារ ថានឈ្មោះថា ជិវ្ហាទ្វារវិថី ១ វិថីចិត្តសម្រាប់ត្រាច់ទៅមកក្នុងកាយទ្វារ ថានឈ្មោះថា កាយទ្វារវិថី ១ វិថីចិត្តសម្រាប់ត្រាច់ទៅមកក្នុងមនោទ្វារ ថានឈ្មោះថា មនោទ្វារវិថី ១ ត្រូវជា ៦ យ៉ាង ដោយពិត ។

๘๖- ធម្មវាទី ថានស្តាប់ហើយ សួរតទៅទៀតថា ម្នាលអត្តវាទី ចុះអារម្មណ៍ដែលប្រព្រឹត្តទៅក្នុងទ្វារចំនួន ៥ មានឈ្មោះផ្សេងគ្នា ប៉ុន្មាន? គឺឈ្មោះអ្វីខ្លះ? អារម្មណ៍ដែលប្រព្រឹត្តទៅក្នុងមនោទ្វារមានឈ្មោះផ្សេងគ្នា

ប៉ុន្មាន ? ឈ្មោះអ្វីខ្លះ ? ចូរលោកវិសជ្ជនាមកយើងនឹងបានស្តាប់ ចូលចិត្តផងមើល ?

អត្ថវិទី វិសជ្ជនាតបថា បពិត្រធម្មាចារ្យ អារម្មណ៍ដែលប្រព្រឹត្តទៅកន្លែងតាំង ៥ មានឈ្មោះ ៤ គឺអតិមហគ្គតារម្មណ៍ ១ មហគ្គតារម្មណ៍ ១ បរិត្តារម្មណ៍ ១ អតិបរិត្តារម្មណ៍ ១ អារម្មណ៍ដែលប្រព្រឹត្តទៅកន្លែមនោទ្វារមានឈ្មោះ ២ គឺវិភូតារម្មណ៍ ១ អវិភូតារម្មណ៍ ១ ត្រូវជាឈ្មោះ ៦ ដោយពិត ។

៨ពី- ធម្មវិទី បានស្តាប់ហើយសួរគាថាទៀតថា: ម្នាលអត្តវាទី ចុះខណចិត្តធំតាំង ១៧ គឺខណចិត្តអ្វីខ្លះ ? កន្លែខណចិត្តធំមួយ ។ មានខណចិត្តតូច ៣ ។ ដូចម្តេចខ្លះ ? ចូរលោកវិសជ្ជនាព្រមទាំងសេចក្តីឧបមាមកយើងនឹងបានស្តាប់ចូលចិត្តផងមើល ?

អត្ថវិទី វិសជ្ជនាតបថា: បពិត្រធម្មាចារ្យ ឯខណចិត្តធំតាំង ១៧ នោះគឺ: អតីតភវង្គ: ១ ភវង្គចលន: ១ ភវង្គុប្បាទ: ១ មញ្ចទ្វារាវជ្ជន: ១ បញ្ចវិញ្ញាណ: ១ សម្បដិច្ឆន: ១ សន្តីរណ: ១ វោដ្ឋព្វន: ១ ជវន: ៧ តទាលម្ពណ: ២ ត្រូវជា ១៧ ដូចមានសេចក្តីអធិប្បាយមកកន្លែអហេតុកអកុសលវិបាកតាំង ៧ នឹងអហេតុកអកុសលវិបាកតាំង ៨

ជាទាងដើមមកវិញហើយ, បណ្តាខណចិត្តធំទាំង ១៧ នេះ ខណចិត្ត
ធំមួយ ។ មានខណចិត្តតូច ៣ ។ ដូចគ្នាទាំងអស់គឺ ឧប្បាទៈ វិថីចិត្ត
កើតឡើងមួយរំពេច ១ ឋិតិ វិថីចិត្តជួបប្រទះនឹងអារម្មណ៍ដែលឋិតនឹងខ្លី
កន្លងទៅរហ័ស ។ មួយរំពេច ១ ភង្គៈ វិថីចិត្តចែកចេញអំពីអារម្មណ៍ធ្លាក់
ចុះមកកាន់ទីភវង្គៈវិញមួយរំពេច ១ ត្រូវជា ៣ ខណចិត្តតូច ឲ្យចែកយ៉ាង
នេះដូចគ្នាទាំងអស់ បូករួមខណចិត្តធំទាំង ១៧ ត្រូវជាខណចិត្តតូច
៥១ គត់ ។

ម្យ៉ាងវិញទៀត ខណចិត្តធំដែលកេញ្ចប់របូណាយ៉ាងនេះ វិថីចិត្ត
ដែលកើតឡើងទទួលនូវអារម្មណ៍មួយខណៈ ។ នេះ តែងមានខណចិត្តធំ
មួយប្រព្រឹត្តកន្លងទៅជាអតីតភវង្គ ហើយមានខណចិត្តធំ ១៦ ជាអយុ
វបស់របូបធម៌ទាំងឡាយពិត ។ រឿរលែងតែវិញ្ញត្តិរូបពីរនឹងលក្ខណៈរូប ៤
ចេញ ព្រោះវិញ្ញត្តិរូបទាំង ២ មានខណចិត្តមួយ ។ ជាអយុពិត។ ជាតិ-
រូប ២ នឹងអនិច្ចតារូប ១ មានខណចិត្តមួយកើតឡើង ស្មើគ្នាដោយឧប្បា-
ទខណៈនឹងភង្គខណៈទាំងឡាយជាអយុពិត, ចំណែកឯជរតារូប ១ មាន
ខណចិត្ត ៤៩ ជាអយុដោយពិត ។ មួយទៀត វិថីចិត្តទាំង ១៤ ដែល
នឹងកើតឡើងក៏កើតឡើងតែដោយអំណាចនៃភវង្គចិត្តទាំងអស់ ដើរភវង្គ-

ចិត្តពុំបានកើតឡើងទេ ហើយចិត្តទាំងអស់ក៏កើតឡើងពុំបានឡើយ ដូច
មានសេចក្តីពន្យល់ក្នុងរឿងយោជនា ព្រះអភិធម្មត្ថសង្គហៈថា: មានបុរស
ម្នាក់ បានយកសម្ពត់សាដកមកដណ្តប់ខ្លួនក្បាលដេកលក់ជិតគល់ស្វាយ
មានផ្លែមួយដើម លុះដល់មានផ្លែស្វាយពុំ ១ ជ្រុះមកក្នុងទីជិតខ្លួនហើយ
ភ្ញាក់ឡើង ដោយសូរសន្ធឹកផ្លែស្វាយដែលជ្រុះមកនោះ, ហើយយកដៃ
ចាប់ចកសំពត់ចេញអំពីក្បាលបើកភ្នែកសំឡឹងមើលផ្លែស្វាយ, បាន
ឃើញហើយក៏យកដៃចាប់យកផ្លែស្វាយពុំនោះមកច្របាច់មើល ហើយ
ហិតស្រង់ក្លិន បានដឹងច្បាស់ថា ផ្លែស្វាយនោះជាផ្លែស្វាយពុំពិត ហើយ
ចាត់ការលេចសាច់ស្វាយពុំ ដែលនៅក្នុងមាត់លាយជាមួយទឹកមាត់ស្រូបចូលទៅ
ក្នុងបំពង់តបិតនៅក្នុងក្រពះជាយ ស្រេចហើយក៏ដេកលក់ទៅវិញក្នុង
ទីដដែលនោះឯង ។

សេចក្តីអធិប្បាយពន្យល់ថា កាលដែលវិថីចិត្តធ្លាក់ចុះមកកាន់ទី
ភវង្គជានសិប់សួនហើយបិតនៅស្ងៀម ដូចជាកាលដែលបុរសនោះដេក
លក់សិប់សួនដែរ កាលដែលអារម្មណ៍ចូលមកប៉ះខ្លួនឯងក្តុបសាខ
ហើយញ័រដល់កវង្គចិត្តនោះ ដូចជាកាលដែលផ្លែស្វាយពុំជ្រុះចុះមកប៉ះ
ខ្លួនឯងដែរ ឮសូរសំឡេងប៉ះខ្លួនឯងក្រវៀកបុរសដែលដេកលក់នោះ

ដែរ កាលដែលគាប់ផ្ទួនវិថីចិត្តកើតឡើងដោយអំណាចនៃកវឌ្ឍៈ ហើយ
តាំងរណាមើលទូរប្អូបារម្មណ៍ ថា រូបគ្នីនេះ ដូចជាកាលដែលបុរសនោះ
ភ្ញាក់ឡើង ដោយសទ្ធឹកសំឡេងផ្លែស្វាយចំនួបន្ទឹងសោតបសាទនោះ
ដែរ កាលដែលចក្ខុវិញ្ញាណកើតឡើងប្រព្រឹត្តទៅសំឡឹងមើលដឹងច្បាស់
ទូរប្អូបារម្មណ៍ ដូចជាកាលដែលបុរសនោះបើកភ្នែកហើយក្រឡេកមើលឃើញ
ផ្លែស្វាយនោះជាក់ច្បាស់ដែរ កាលដែលសម្បដិច្ឆនវិថីចិត្តកើតឡើងហើយ
ទទួលចាប់យក ត្រមទូរប្អូបារម្មណ៍ដូចជាកាលដែលបុរសនោះយកដៃលូកទៅចាប់
ផ្លែស្វាយនោះយកមកដែរ កាលដែលសន្តីរណវិថីចិត្តកើតឡើងហើយត្រេះរិះរំពឹងគិតទូរប្អូបារម្មណ៍ ដូចជាកាល
ដែលបុរសនោះយកដៃចាប់ច្រច្បាច់ផ្លែស្វាយនោះដែរ កាលដែលវោដ្ឋព្វនវិថីចិត្តកើតឡើងហើយកំណត់កត់សំគាល់ ទូរប្អូបារម្មណ៍ជឹងច្បាស់
ទុកក្នុងចិត្ត ដូចជាកាលដែលបុរសនោះហិតស្រង់ក្លិនស្វាយនោះ ជឹង
ច្បាស់ក្នុងចិត្តថា ផ្លែស្វាយនេះជាស្វាយទុំពិតមែន កាលដែលជវនវិថីចិត្ត
កើតឡើងហើយទទួលសោយទូរសនៃអារម្មណ៍ ដូចជាកាលដែលបុរសនោះបរិភោគទូរសាច់ស្វាយទុំនោះដែរ កាលដែលតទារម្មណវិថីចិត្ត
កើតឡើង ហើយទទួលតាន់យកទូរសនៃអារម្មណ៍ដែលជវនចិត្ត

សោយហើយនោះយកមកជាអាម្នុណ៍ ដូចជាកាលដែលបុរសនោះ
លេបនូវសាច់ស្វាយខ្ទុះនៅក្នុងដើមគល់ប្រឡាក់លាយដោយស្នូសចូលទៅក្នុង
បំពង់កនោះដែរ កាលដែលវិថីចិត្តធ្លាក់ប្តូរមកកាន់ទីភវង្គវិញស៊ប់ស្ងួត
ទៀត ដូចជាកាលដែលបុរសនោះដេកលក់ទៅវិញក្នុងទីនោះដដែល
ដោយពិត ។ ឯខណចិត្តទាំង ១៧ ពេញបរិបូណ៌ដោយសេចក្តី
អធិប្បាយមានប្រមាណប៉ុណ្ណេះឯង តែថាក្នុងយោជនាព្រះអភិធម្ម-
សង្គហៈនេះ លោកសំដែងតម្រង់ថា ខណចិត្តទាំង ១៧ នេះ បើ
សំដែងវិញ្ញាកបែកជាតួភវង្គមាន ៣ គឺ អតីតភវង្គៈ ១ ភវង្គចលនៈ ១
ភវង្គបច្ឆេទៈ ១ បែកជាវីថិចិត្តមានឈ្មោះជាសរុបមាន ៧ គឺ បញ្ចទ្វារ-
វជ្ជនៈ ១ ចក្ខុវិញ្ញាណៈ ១ សម្បដិច្ឆនៈ ១ សន្តីរណៈ ១ វោដ្ឋព្វនៈ ១
ជវនៈ ១ តទារម្មណៈ ១ បើបែកជាវីថិចិត្តមានឈ្មោះកេរៅផ្សេង ។ គ្នា
មាន ១៤ គឺ បញ្ចទ្វារវជ្ជនៈ ១ ចក្ខុវិញ្ញាណ ១ សម្បដិច្ឆនៈ ១ សន្តី-
រណៈ ១ វោដ្ឋព្វនៈ ១ ជវនៈ ១ ជវនៈ ១ ជវនៈ ១ ជវនៈ ១ ជវនៈ ១ ជវនៈ ១
ជវនៈ ១ តទារម្មណៈ ១ តទារម្មណៈ ១ ត្រូវជាវីថិចិត្ត ១៤ រួមនឹង
ភវង្គចិត្ត ៣ ទៀតត្រូវជា ១៧ ហៅថាខណចិត្តធំ ១៧ មានខណចិត្ត
តួច ៥១ គត់ ជាសេចក្តីសង្ខេបតែប៉ុណ្ណេះឯង ។

๘๘- ធម្មវាទី ថានស្តាប់ហើយសួរតទៅទៀតថា: ម្នាលអគ្គ-
ភទ្ទ ចុះអតិមហគ្គារម្មណ៍ដែលប្រព្រឹត្តទៅក្នុងតថាលម្ពណាវរ: អធិប្បាយ
ថាដូចម្តេចខ្លះ? មហគ្គារម្មណ៍ដែលប្រព្រឹត្តទៅក្នុងជវនវរ: អធិប្បាយ
ថាដូចម្តេចខ្លះ? បរិត្តារម្មណ៍ដែលប្រព្រឹត្តទៅក្នុងភវង្គវរ: អធិប្បាយ
ថាដូចម្តេចខ្លះ? អតិបរិត្តារម្មណ៍ដែលប្រព្រឹត្តទៅក្នុងមោឃវរ: ប្លែក
ផ្សេងគ្នាយ៉ាងណាខ្លះ? ចូរលោកវិសជ្ជនារៀបរាប់ឲ្យសព្វគ្រប់មកយើង
ទើបថានស្តាប់ចូលចិត្តផង!មើល?

អដ្ឋកថាទី វិសជ្ជនាតបថា: បពិត្រធម្មវាទី ឯអារម្មណ៍ទាំង ៤ នោះ
ទី ១ អតិមហគ្គារម្មណ៍ អារម្មណ៍ច្រើនកៃក្រៃលែងមានកម្លាំងខ្លាំងដែល
ប្រព្រឹត្តទៅក្នុងតថាលម្ពណាវរ: មានរណចិត្ត ១៧ វិបាកជាភវង្គ ៣
ជាវិថីចិត្ត ១៤ ដូចបានអធិប្បាយមកក្នុងប្រស្នាលេខ ៨៧ មករួចហើយ
ក៏ក្នុងតថាលម្ពណាវរ:នេះ ពុំបានសួរឲ្យវិថីចិត្តអ្វីឡើយ ។ ទី ២-
មហគ្គារម្មណ៍ អារម្មណ៍ច្រើនមានកម្លាំងល្មមដែលប្រព្រឹត្តទៅក្នុង
ជវនវរ:នោះ ផ្សេងគ្នាមានពីរយ៉ាង ទី ១- រណចិត្តទាំង ១៧ នោះ
រណចិត្ត ៤ កើតជាភវង្គវិថី ៤ គឺអតីតភវង្គ: ៤ ភវង្គចលន: ១
ភវង្គុប្បាទ: ១ តទៅអំពីភវង្គវិថីទាំង ៤ នោះ រណចិត្ត ១២ កើតជា

រីថិចិត្ត ១២ គឺបញ្ចក្ខន្ធវេជ្ជនៈ ១ ចក្ខុវិញ្ញាណៈ ១ សម្បដិច្ឆនៈ ១ សន្តីរណៈ ១ ភវង្គនៈ ១ ជវនៈ ១ ជវនៈ ១ ជវនៈ ១ ជវនៈ ១ ជវនៈ ១ ជវនៈ ១ ជវនៈ ១ តទៅអំពីរីថិចិត្តទាំង ១២ នោះ កើតមានគន្ធកវង្គចិត្ត ១ ទៀត ត្រូវជាវណចិត្ត ១៧ គត់ ។ ឧ ២ - វណចិត្តទាំង ១៧ នោះ វណចិត្ត ៥ កើតជាកវង្គរីថិ ៥ គឺអតីតកវង្គៈ ៣ កវង្គុបលនៈ ១ កវង្គុប្បច្ចេទ ១ តទៅអំពីកវង្គរីថិទាំង ៥ នោះ វណចិត្ត ១២ កើតជារីថិចិត្ត ១២ គឺបញ្ចក្ខន្ធវេជ្ជនៈ ១ ។ល។ ជវនៈ ១ ត្រូវជារីថិចិត្ត ១២ គត់ សូម្បីគាគន្ធកកវង្គចិត្តពុំបានកើតទៀយ ។ ក្នុងជវនវារៈនេះ សូម្បីតាលម្ពណវារៈជាបឋមដូចបានអធិប្បាយមកនេះពិត ។

ឧ ៣ - ឋិតិវារៈ តាម្ពណ៍មានប្រមាណតិចជាងប្រព្រឹត្តទៅក្នុងវេជ្ជនវារៈនោះផ្សេងគ្នាមាន ៥ យ៉ាង ឧ ១ - វណចិត្តទាំង ១៧ នោះ វណចិត្ត ៦ កើតជាកវង្គរីថិ ៦ គឺអតីតកវង្គ ៤ កវង្គុបលន ១ កវង្គុប្បច្ចេទ ១ វណចិត្ត ៤ កើតជារីថិចិត្ត ៤ គឺ បញ្ចក្ខន្ធវេជ្ជនៈ ១ ចក្ខុវិញ្ញាណៈ ១ សម្បដិច្ឆនៈ ១ សន្តីរណៈ ១ វណចិត្ត ១ កើតជាភវង្គនរីថិចិត្ត ៣ ដង តទៅអំពីភវង្គនរីថិចិត្តនោះ កើតភៃគាគន្ធកកវង្គចិត្ត ៤ គឺ កវង្គ ១ កវង្គ ១ កវង្គ ១ កវង្គ ១ ត្រូវ

ជា ๑ ណ ចិត្ត ๑๗ គត់ ๆ ខ ๒ - ๑ ណ ចិត្ត ចាំង ๑๗ នោះ ๑ ណ ចិត្ត ๗ កើត ជា កវង្ស វិថី ๗ គឺ អតីត កវង្ស ๕ កវង្ស ចលន ๑ កវង្ស ប្បវេទ ๑ ๑ ណ ចិត្ត ๔ កើត ជា វិថី ចិត្ត ๔ គឺ បញ្ចទ្វារ ជវន ๑ បកវិញ្ញាណ ๑ សម្បដិច្ឆន ๑ សន្តីរណ ๑ ๑ ណ ចិត្ត ๑ កើត ជា ភវង្គ ចិត្ត ๓ ដង តទៅ អំពី ភវង្គ ចិត្ត នោះ សូន្យ អាគន្តុក កវង្ស ๑ កើត តែ អាគន្តុក កវង្ស ๓ គឺ កវង្ស ๑ កវង្ស ๑ កវង្ស ๑ ត្រូវ ជា ๑ ណ ចិត្ត ๑๗ គត់ ๆ ខ ๓ - ๑ ណ ចិត្ត ចាំង ๑๗ នោះ ๑ ណ ចិត្ត ๘ កើត ជា កវង្ស វិថី ចិត្ត ๘ គឺ អតីត កវង្ស ๖ កវង្ស ចលន ๑ កវង្ស ប្បវេទ ๑ ๑ ណ ចិត្ត ๔ កើត ជា វិថី ចិត្ត ๔ ដូច គ្នា ๑ ណ ចិត្ត ๑ កើត ជា ភវង្គ ចិត្ត ๓ ដង ដូច គ្នា ដែរ តទៅ អំពី ភវង្គ ចិត្ត នោះ សូន្យ អាគន្តុក កវង្ស ๑ កើត តែ អាគន្តុក កវង្ស ๒ គឺ កវង្ស ๑ កវង្ស ๑ ត្រូវ ជា ๑ ណ ចិត្ត ๑๗ គត់ ๆ ខ ๔ - ๑ ណ ចិត្ត ចាំង ๑๗ នោះ ๑ ណ ចិត្ត ๙ កើត ជា កវង្ស វិថី ๙ គឺ អតីត កវង្ស ๗ កវង្ស ចលន ๑ កវង្ស ប្បវេទ ๑ ๑ ណ ចិត្ត ๔ កើត ជា វិថី ចិត្ត ๔ ដូច គ្នា ๑ ណ ចិត្ត ๑ កើត ជា ភវង្គ ចិត្ត ๓ ដង ដូច គ្នា ដែរ តទៅ អំពី ភវង្គ ចិត្ត នោះ សូន្យ អាគន្តុក កវង្ស ๑ កើត តែ អាគន្តុក កវង្ស ๑ ត្រូវ ជា ๑ ណ ចិត្ត ๑๗ គត់ ๆ ខ ๕ - ๑ ណ ចិត្ត ចាំង ๑๗ នោះ ๑ ណ ចិត្ត ๑๐ កើត ជា កវង្ស-

រំថិ ๑๐ គឺអតីតកវគ្គ ๘ កវគ្គចលន ๑ កវគ្គុប្បន្ន ๑ រំណាចិត្ត ๘ កើតជារំថិចិត្ត ๘ ដូចគ្នា ។ ណាចិត្ត ๑ កើតជាវេជ្ជភូនរំថិចិត្ត ๓ ដង ដូចគ្នាដែរ សូន្យអាគន្តុកកវគ្គចំនួនអស់ពុំចូនកើតឡើយ ត្រូវជា ។ ណាចិត្ត ๑๗ គត់ ប្រព្រឹត្តទៅក្នុងវេជ្ជភូនវារៈនេះ សូន្យជវនៈវារៈជា តំរូវតាមដូចអធិប្បាយមកនេះពិត ។ សេចក្តីពន្យល់ថា: អតិមហន្តារម្មណ៍ប្រព្រឹត្តទៅក្នុងកវគ្គរំថិទី ๑ មហន្តារម្មណ៍ប្រព្រឹត្តទៅក្នុងកវគ្គរំថិទី ๒ មរិត្តារម្មណ៍ប្រព្រឹត្តទៅក្នុងកវគ្គរំថិទី ๙ ដោយពិត ។

ទី ๔ - អតិបរិត្តារម្មណ៍ អារម្មណ៍មានប្រមាណតិចក្រៃលែង មានកម្លាំងខ្សោយពន់ពេក តិបណ្ឌិតតម្រូវតំណាក់ដើងដោយវារៈសូន្យ តាំង ๗ ឃាំងដែលប្រព្រឹត្តទៅក្នុងរមាយវារៈ ដូចនេះ, ទី ๑ - ។ ណាចិត្ត តាំង ๑๗ នោះ ។ ណាចិត្ត ๙ កើតជាអតីតកវគ្គ ๙ គឺអតីតកវគ្គ ๑ ។ ល ។ អតីតកវគ្គ ๑ តទៅអំពីអតីតកវគ្គតាំង ๙ នោះ កើតវែកវគ្គចលន ๒ គឺកវគ្គចលន ๑ ភ្លេវគ្គចលន ๑ តទៅអំពីកវគ្គចលនតាំង ๒ នោះ កើតអាគន្តុកកវគ្គ ๒ គឺកវគ្គ ๑ ។ ល ។ កវគ្គ ๑, ត្រូវជា ។ ណាចិត្ត ๑๗ ជារមាយវារៈ ជាវារៈសូន្យទី ๑ ។ ទី ๒- ។ ណាចិត្តតាំង ๑๗ នោះ ។ ណាចិត្ត ๖๘ កើតជាអតីតកវគ្គ ๑๐ គឺអតីត-

កវង្គ ๑ ។ល។ អតីតកវង្គ ๑ គេហៅអំពីអតីតកវង្គចាំង ๑๐ នោះ
កើតតែកវង្គចលន ๒ ដូចគ្នា គេហៅអំពីកវង្គចលនចាំង ๒ នោះ សូន្យ
គាតន្តុកកវង្គ ๑ កើតតែអគន្តុកកវង្គ ๙ គឺកវង្គ ๑ ។ល។ កវង្គ ๑
ត្រូវជាខណចិត្ត ๑๗ ជាមោឃវារៈ ជាវារៈសូន្យទី ๒ ។ ខ័ ๓ - ខណ-
ចិត្តចាំង ๑๗ នោះ ខណចិត្ត ๑๑ កើតជាអតីតកវង្គ ๑๑ គឺអតីតកវង្គ ๑
។ល។ អតីតកវង្គ ๑ គេហៅអំពីអតីតកវង្គចាំង ๑๑ នោះ កើត
តែកវង្គចលន ๒ ដូចគ្នា គេហៅអំពីកវង្គចលនចាំង ๒ នោះ សូន្យ
គាតន្តុកកវង្គ ๑ កើតតែអគន្តុកកវង្គ ๔ គឺកវង្គ ๑ ។ល។ កវង្គ ๑
ត្រូវជាខណចិត្ត ๑๗ ជាមោឃវារៈ ជាវារៈសូន្យទី ๓ ។ ខ័ ๔ - ខណ-
ចិត្តចាំង ๑๗ នោះ ខណចិត្ត ๑๒ កើតជាអតីតកវង្គ ๑๒ គឺអតីត-
កវង្គ ๑ ។ល។ អតីតកវង្គ ๑ គេហៅអំពីអតីតកវង្គចាំង ๑๒ នោះ
កើតតែកវង្គចលន ๒ ដូចគ្នា គេហៅអំពីកវង្គចលនចាំង ๒ នោះ សូន្យ
គាតន្តុកកវង្គ ๑ កើតតែអគន្តុកកវង្គ ๓ គឺកវង្គ ๑ កវង្គ ๑ កវង្គ ๑
ត្រូវជាខណចិត្ត ๑๗ ជាមោឃវារៈ ជាវារៈសូន្យទី ๔ ។ ខ័ ๕ -
ខណចិត្តចាំង ๑๗ នោះ ខណចិត្ត ๑๓ កើតជាអតីតកវង្គ ๑๓ គឺអតីត-
កវង្គ ๑ ។ល។ អតីតកវង្គ ๑ គេហៅអំពីអតីតកវង្គចាំង ๑๓ នោះ

កើតវែកវង្គចលន ๒ ដូចគ្នា គេចាំអំពីកវង្គចលនចាំង ๒ នោះ សូន្យ
គាតន្តុកកវង្គ ๑ កើតវែកគាតន្តុកកវង្គ ๒ គឺកវង្គ ๑ កវង្គ ๑ ត្រូវជា
ឯណចិត្ត ๑๗ ជាមោយពាក្យ: ជាពាក្យសូន្យចំ ๘ ។ ចំ ๖ - ឯណចិត្ត
ចាំង ๑๗ នោះ ឯណចិត្ត ๑๒ កើតជាអតីតកវង្គ ๑๒ គឺអតីតកវង្គ ๑
។ ល ។ អតីតកវង្គ ๑ គេចាំអំពីអតីតកវង្គចាំង ๑๒ នោះ កើតវែកវង្គ-
ចលន ๒ ដូចគ្នា គេចាំអំពីកវង្គចលនចាំង ๒ នោះ សូន្យគាតន្តុក-
កវង្គ ๑ កើតវែកគាតន្តុកកវង្គ ๑ ត្រូវជាឯណចិត្ត ๑๗ ជាមោយពាក្យ:
ជាពាក្យសូន្យចំ ๖ ។ ចំ ๗ - ឯណចិត្តចាំង ๑๗ នោះ ឯណចិត្ត ๑๗
កើតជាអតីតកវង្គ ๑๗ គឺអតីតកវង្គ ๑ ។ ល ។ អតីតកវង្គ ๑ គេចា
អំពីអតីតកវង្គចាំង ๑๗ នោះ កើតវែកវង្គចលន: ๒ គឺកវង្គចលន: ๑
កវង្គចលន: ๑ ត្រូវជាឯណចិត្ត ๑๗ ជាមោយពាក្យ: ជាពាក្យសូន្យ
ចំ ๗ ពិត ។

ឯពាក្យសូន្យចាំង ๗ យ៉ាង ដូចបានអធិប្បាយមកនេះ គឺសូន្យវិថី-
ចិត្ត ដែលមានឈ្មោះជាសរួមចាំង ๗ គឺបញ្ចទ្វារាវជ្ជន: ๑ បញ្ច-
វិញ្ញាណ: ๑ សម្បដិច្ឆន: ๑ សន្តីរណ: ๑ វោដ្ឋព្វន: ๑ ជវន ๑ តទា-
លម្ពណ: ๑ ត្រូវជាវិថីចិត្ត ๗ ពិត តែថាតារម្មណ៍ចាំង ๔ នេះ បាន

តែអារម្មណ៍ចាំង ๕ គឺរូបារម្មណ៍ ๑ សទ្ទារម្មណ៍ ๑ គន្ធារម្មណ៍ ๑ រសារម្មណ៍ ๑ ផោដ្ឋព្វារម្មណ៍ ๑ ដែលប្រព្រឹត្តទៅក្នុងទ្វារចាំង ๕ ដោយពិត ។

វិសជ្ជនាម៉ងអំពីអារម្មណ៍ចាំង ๔ មានអតិមហគ្គារម្មណ៍ជាដើម ដែលមានសេចក្តីថ្លែកផ្សេង ។ គ្នា ជាសង្ខេបតែប៉ុណ្ណេះឯង ។

๘๙ - ធម្មវិទី ចាន់ស្តាប់ហើយពោលថា ម្នាលអត្ថវិទី ប្រស្នាដែលលោកវិសជ្ជនាមកនេះយើងស្តាប់ចាន់ហើយ តែថាយើងនឹងសួរលោកជាន់តមវេន: បញ្ជាក់សេចក្តីអំពីអារម្មណ៍ចាំង ๔ មានអតិមហគ្គារម្មណ៍ជាដើមនេះឲ្យជាក់ច្បាស់តទៅទៀត ចុះអតិមហគ្គារម្មណ៍ក្តី មហគ្គារម្មណ៍ក្តី បរិត្តារម្មណ៍ក្តី អតិបរិត្តារម្មណ៍ក្តី ចាំង ๔ នេះ កើតក្នុងអារម្មណ៍មួយ ។ មានខណចិត្តប្រព្រឹត្តកន្លងទៅប៉ុន្មាន ? ថ្លែកផ្សេងគ្នាយ៉ាងណាខ្លះ ? មានខណចិត្តប៉ុន្មានជាអាយុនៃរូបធម៌ចាំងឡាយ ថ្លែកផ្សេងគ្នាយ៉ាងណាខ្លះ ? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មកយើងនឹងចាន់ស្តាប់ចូលចិត្តផងមើល !

អត្ថវិទី វិសជ្ជនាតបថា: បពិត្រធម្មាចារ្យ ទី ๑ អតិមហគ្គារម្មណ៍ជាអារម្មណ៍មានខណចិត្ត ចាំង ๑๗ ពេញបរិបូណ៌ដោះ អារម្មណ៍

មានខណចិត្ត ១ គឺអតីតភវង្គប្រព្រឹត្តកន្លងទៅ សល់នៅអារម្មណ៍មាន
ខណចិត្ត ១៦ ជាអាយុរបស់រូបធម៌ទាំងឡាយ រឿរណែងតែវិញតិចរួម ៤
និងជាតិរូប, អនិច្ចតារូប, ជរតារូបចេញដោយពិត ។

ទី ២-មហគ្គតារម្មណ៍នោះជាអារម្មណ៍មានខណចិត្តផ្សេង ។ គឺ
មានពីរយ៉ាងគឺអារម្មណ៍មានខណចិត្ត ២ គឺអតីតភវង្គ ១ អតីតភវង្គ ១
ប្រព្រឹត្តកន្លងទៅ សល់នៅអារម្មណ៍មានខណចិត្ត ១៥ ជាអាយុរបស់រូប-
ធម៌ទាំងឡាយ ១ អារម្មណ៍មានខណចិត្ត ៣ គឺអតីតភវង្គ ១ ។ល។
អតីតភវង្គ ១ ប្រព្រឹត្តកន្លងទៅ សល់នៅអារម្មណ៍មានខណចិត្ត ១៤
ជាអាយុរបស់រូបធម៌ទាំងឡាយ ។

ទី ៣- ចិត្តារម្មណ៍នោះជាអារម្មណ៍មានខណចិត្តផ្សេង ។ គឺ
មាន ៦ យ៉ាង គឺអារម្មណ៍មានខណចិត្ត ៤ . គឺអតីតភវង្គ ១ ។ល។
អតីតភវង្គ ១ ប្រព្រឹត្តកន្លងទៅ សល់នៅអារម្មណ៍មានខណចិត្ត ១៣
ជារាយុរបស់រូបធម៌ទាំងឡាយ ១ . អារម្មណ៍មានខណចិត្ត ៥ គឺអតីត-
ភវង្គ ១ ។ល។ អតីតភវង្គ ១ ប្រព្រឹត្តកន្លងទៅ សល់នៅអា-
រម្មណ៍មានខណចិត្ត ១២ ជាអាយុរបស់រូបធម៌ទាំងឡាយ ១ អារម្មណ៍
មានខណចិត្ត ៦ គឺអតីតភវង្គ ១ ។ល។ អតីតភវង្គ ១ ប្រព្រឹត្ត

កន្ធដទៅ សល់នៅអារម្មណ៍មានខណចិត្ត ១១ ជាអាយុរបស់រូបធម៌
តាំងខ្សោយ ១ អារម្មណ៍មានខណចិត្ត ៧ គឺអតីតភវង្គ ១ ។ល។
អតីតភវង្គ ១ ប្រព្រឹត្តកន្ធដទៅ សល់នៅអារម្មណ៍មានខណចិត្ត ១០
ជាអាយុរបស់រូបធម៌តាំងខ្សោយ ១ អារម្មណ៍មានខណចិត្ត ៨ គឺអតីត-
ភវង្គ ១ ។ល។ អតីតភវង្គ ១ ប្រព្រឹត្តកន្ធដទៅ សល់នៅអា-
រម្មណ៍មានខណចិត្ត ៨ ជាអាយុរបស់រូបធម៌តាំងខ្សោយ ១ អារម្មណ៍
មានខណចិត្ត ៨ គឺអតីតភវង្គ ១ ។ល។ អតីតភវង្គ ១ ប្រព្រឹត្ត
កន្ធដទៅ សល់នៅអារម្មណ៍មានខណចិត្ត ៨ ជាអាយុរបស់រូបធម៌
តាំងខ្សោយ ១ ។

ទី ៤- អតិបរិត្តារម្មណ៍នោះ ជាអារម្មណ៍មានខណចិត្តផ្សេង ។
គ្នាមាន ៦ យ៉ាង គឺអារម្មណ៍មានខណចិត្ត ១០ គឺអតីតភវង្គ ១ ។ល។
អតីតភវង្គ ១ ប្រព្រឹត្តកន្ធដទៅ សល់នៅអារម្មណ៍មានខណចិត្ត ៧
ជាអាយុរបស់រូបធម៌តាំងខ្សោយ ១ អារម្មណ៍មានខណចិត្ត ១១ គឺអតីត-
ភវង្គ ១ ។ល។ អតីតភវង្គ ១ ប្រព្រឹត្តកន្ធដទៅ សល់នៅអារម្មណ៍
មានខណចិត្ត ៦ ជាអាយុរបស់រូបធម៌តាំងខ្សោយ ១ អារម្មណ៍មានខណ-
ចិត្ត ១២ គឺអតីតភវង្គ ១ ។ល។ អតីតភវង្គ ១ ប្រព្រឹត្តកន្ធដទៅ សល់នៅ

អារម្មណ៍មានឧណចិត្ត ៥ ជាអាយុវេស់រូបធម៌តាំងខ្សែ ១ អារម្មណ៍
មានឧណចិត្ត ១៣ គឺអតីតភវង្គ ១ ។ល។ អតីតភវង្គ ១ ប្រត្រឹត្ត
កន្ទួងទៅ ។ សល់ទៅអារម្មណ៍មានឧណចិត្ត ៤ ជាអាយុវេស់រូបធម៌
តាំងខ្សែ ១ អារម្មណ៍មានឧណចិត្ត ១៤ គឺអតីតភវង្គ ១ ។ល។
អតីតភវង្គ ១ ប្រត្រឹត្តកន្ទួងទៅ សល់ទៅអារម្មណ៍មានឧណចិត្ត ៣
ជាអាយុវេស់រូបធម៌តាំងខ្សែ ១ អារម្មណ៍មានឧណចិត្ត ១៥ គឺអតី-
តភវង្គ ១ ។ល។ អតីតភវង្គ ១ ប្រត្រឹត្តកន្ទួងទៅ សល់ទៅអារម្មណ៍
មានឧណចិត្ត ២ ជាអាយុវេស់រូបធម៌តាំងខ្សែ ១ ។

វិសជ្ជនាមកតំពីអារម្មណ៍តាំង ៤ យ៉ាង មានអតិមហគ្គតារម្មណ៍ជា-
ដើម ដែលមានឧណចិត្តប្រត្រឹត្តកន្ទួងទៅនឹងសល់ទៅជាអាយុវេស់រូប-
ធម៌តាំងខ្សែជាសង្ខេបសេចក្តីតែប៉ុណ្ណេះឯង ។

៩០.- ធម្មវិទូ ថានស្តាប់ហើយសួរតទៅទៀតថា: ម្នាលអស្តាចរ
ប្តូរចំណែកទាន់វិភូតារម្មណ៍ អារម្មណ៍ដែលតើតឡើងច្រាកដចូលមក
កាន់វង្វិលកងមនោទ្វារ តើចិត្តប៉ុន្មានឧណចិត្តដែលតើតឡើងជាភវង្គវិថី
ប៉ុន្មាន? ជាវិថីចិត្តប៉ុន្មាន? គឺចិត្តអ្វីខ្លះ? អវិភូតារម្មណ: អារម្មណ៍ដែល
ពុំបានតើតឡើងច្រាកដ ពុំបានចូលមកកាន់វង្វិលកងមនោទ្វារ តើចិត្តប៉ុន្មាន-

ទ្រណចិត្តដែលកើតខ្លឹងជាកវង្គវិថីនឹងវិថីចិត្តប្លែកផ្សេងគ្នាដូចម្តេច ?

អដ្ឋកថាថា វិសជ្ជនាតបថា: ចតុត្រជម្មាទិ ឯវំភូតារម្មណា: អារម្មណ៍ដែលកើតខ្លឹងច្រាកជនោះមាន ទ្រណចិត្ត ១៣ គឺទ្រណចិត្ត ៣ កើតជាកវង្គ ៣ គឺអតីតកវង្គ ១ កវង្គចលន ១ កវង្គបច្ចុប្បន្ន ១ ទ្រណចិត្ត ១០ កើតជាវិថីចិត្តទាំង ១០ គឺមនោទ្វារវជ្ជន ១ ជវន ៧ តទាលម្ពណ ២ ជា ១០ រួមទាំងអស់ត្រូវជា ១៣ គត់ ជាទ្រណចិត្តមាន អារម្មណ៍កើតខ្លឹងច្រាកជប្រព្រឹត្តទៅក្នុងមនោទ្វារជាយថាពិត ។

អវំភូតារម្មណា: អារម្មណ៍ដែលពុំបាន កើតខ្លឹងច្រាកជនោះ មាន ទ្រណចិត្ត ១១ គឺទ្រណចិត្ត ៣ កើតជាកវង្គ ៣ គឺអតីតកវង្គ ១ កវង្គចលន ១ កវង្គបច្ចុប្បន្ន ១ ទ្រណចិត្ត ៨ កើតជាវិថីចិត្តទាំង ៨ គឺមនោទ្វារវជ្ជន ១ ជវន ៧ ជា ៨ គត់ លុះឆ្នាតទាលម្ពណវិថីពុំបានកើតឡើយ ត្រូវជាទ្រណចិត្ត ១១ គត់ ជាទ្រណចិត្តមាន អារម្មណ៍ពុំបានកើតខ្លឹងច្រាកជក្នុងមនោទ្វារជោយពិត ។ វិសជ្ជនាមកអំពីវិភូតារម្មណ៍នឹងអវំភូតារម្មណ៍ជាសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

๙๑- ធម្មាទិ ថានស្តាប់ហើយសួរតទៅទៀតថា: ម្នាលអត្តាចារ្យប៉ុនជនេសម្តេ: បេសប៉ុប្បជ្ជនទាំងឡាយនឹងសេក្ខបុគ្គលនឹងអសេក្ខបុគ្គល

តាំងឡាយ មានទំណាចិត្តកើតខ្លឹងត្រមជាជវនៈសម្រាប់សោយនូវ
អារម្មណ៍អស់វារៈ តិចប្រើនថ្ងៃតវផ្សងគ្នាយ៉ាងណាខ្លះ? ចូរលោកវិសជ្ជនា
មកយើងនឹងបានស្តាប់ចូលចិត្តផងមើល?

អត្ថាធិប្បាយ វិសជ្ជនាតបថា: បពិត្រធម្មាភិ ឯជវនៈសម្ភវៈទី ១ បេស់
ប្បុជ្ជនតាំងឡាយ ក្នុងកាលដែលស្លាប់ក្តី កាលដែលសន្ធប់ជាតិស្មារ-
តីក្តី យ៉ាងធាប់រហ័ស តងមានទំណាចិត្តកើតខ្លឹងត្រម ជាជវនៈសោយ
នូវអារម្មណ៍ប្រព្រឹត្តទៅអស់វារៈ ៧ ដងដែរ បើយ៉ាងយ៉ីតយូរក្នុងកាល
ដែលសន្ធប់ជាតិស្មារតីក្តី កាលដែលប្បុជ្ជនតាំងឡាយបានឃើញនូវ
សរីរៈតាំងអស់បេស់ប្រែតមានរូបតាក្រក់ផ្សង ១ គួរខ្លាចតិតភ័យតក់ស្លុត
ជាតិស្មារតីក្តី តែងមានទំណាចិត្តកើតខ្លឹងត្រម ជាជវនៈសោយនូវ
អារម្មណ៍ប្រព្រឹត្តទៅអស់វារៈ ៦ ដង ក្នុងកាលដែលសេសសល់
អំពីកាលនេះ ទោះបីមានអារម្មណ៍ប្រព្រឹត្តទៅក្នុងបញ្ចទ្វារក្តី មនោទ្វារក្តី
ក៏តងមានទំណាចិត្តកើតខ្លឹងត្រម ជាជវនៈសោយនូវអារម្មណ៍ប្រព្រឹត្ត
ទៅអស់វារៈ ៧ ដងដោយតិត ។ ទី ២- ជវនៈសម្ភវៈបេស់យោគា
វចរកុលបុត្រជាប្បុជ្ជនដែលបានចំរើនបរិកម្មភាវនាព្រះកម្មដ្ឋាន បាន
សម្រេចដល់អប្បនាឈានខ្លះ តែងមានទំណាចិត្តកើតខ្លឹងត្រមជា

មហគ្គតជវនៈសោយន្ទរសៃនៃធម្មារម្មណ៍ ប្រព្រឹត្តទៅក្នុងមនោទ្វារអស់វារៈ
តែម្តងឯងបានបីតនៅសិប់សួន ក្នុងអប្បនាឈានទាំងអស់តាំងអំពីអប្បនា-
ឈានទី ១ ដកបដល់អប្បនាឈានទី ៥ ដោយចំណែកមួយដូចគ្នា
ដោយពិត តែថាអង្គជវនៈប្លែកផ្សេងមិនដូចគ្នាទេ ព្រោះកុសលា-
ភិញ្ញាកើតមកអំពីរូបាវចរកុសលចិត្តឈានទី ៥ កិរិយាភិញ្ញាកើតមកអំពី
រូបាវចរកិរិយាចិត្តឈានទី ៥ ដែរ អាចឲ្យបានសម្រេចន្ទរមគ្គទាំង ៤ ទំនុំ
ថ្កូទាំងពួងមានចំព្រួចក្នុងជាដើម មានខណចិត្តកើតខ្សែនព្រមជាអង្គភិញ្ញា-
ជវនៈសោយន្ទរអារម្មណ៍ប្រព្រឹត្តទៅអស់វារៈតែម្តងពិត តទៅអំពីអង្គភិញ្ញា-
ជវនៈនោះ រីថិចិត្តជ្រាក់ចុះមកតាន់ទីតវង្គជានវិញជាដែល ៗ ទី ៣ -
ជវនសម្ភវៈ កិរិយាដែលកើតខ្សែនៃមគ្គទាំង ៤ គឺសោតាបត្តិមគ្គ ១
សកទាគាមិមគ្គ ១ អនាគាមិមគ្គ ១ អរហត្តមគ្គ ១ ប្រកបកើតព្រមក្នុង
ខណចិត្តតែមួយ តើថាបើបុគ្គលបានកសាងអង្គភិនីហារមកច្រើនទីដង
បានសម្រេចមគ្គផលជាទិប្បាភិញ្ញា តាមវិបាកចិត្តកើតខ្សែនព្រម
ជាអង្គភិញ្ញាជវនៈសោយន្ទរអារម្មណ៍ ប្រព្រឹត្តទៅអស់វារៈមួយដងដែ មគ្គចិត្ត
តំកើតខ្សែន សោយន្ទរអារម្មណ៍ប្រព្រឹត្តទៅអស់វារៈបួនដងយ៉ាងដូចយ
ឆាប់ហ័ស អប្បនាចិត្តជាផលតំកើតខ្សែនជាលំដាប់នៃតាហាវិបាកជវន

ផលប្រព្រឹត្តទៅអស់វារៈ ๓ ដង នៃបុគ្គលជាទិដ្ឋាកញ្ញាដោយពិត ។
បើបុគ្គលបានកសាងអកុសលកម្មមកតាមពេទនាណាបានសម្រេចមគ្គ - ផល ជា
ខន្ធាកញ្ញា កាមាវចរកុសលចិត្តកើតឡើងព្រមជាអកញ្ញាផលនៃសោយនូវ
អារម្មណ៍ប្រព្រឹត្តទៅអស់វារៈមួយដង មគ្គចិត្តកំកើតឡើងសោយនូវ
អារម្មណ៍ប្រព្រឹត្តទៅអស់វារៈ ៧ ដង យ៉ាងលំបាកយឺតយូរ អប្បនាចិត្ត
ជាផលកំកើតឡើងជាលំដាប់នៃកាមាវចរជវនៈផលប្រព្រឹត្តទៅអស់វារៈ ៤
ដងនៃបុគ្គលជាខន្ធាកញ្ញាដោយពិត តទៅអំពីផលចិត្តនោះ អកញ្ញា-
ជវនវិថីក៏ធ្លាក់ចុះមកកាន់ទីតវង្គជាន់វិញជាដែល ។

ចំណែកឯព្រះអនាគាមិបុគ្គលនាំព្រះអរហត្ត កន្លងកាលដែលសោក
ចូលកាន់និរោធសមាបត្តិនោះ អប្បូរាវចរកុសលចិត្តទី ៤ របស់ព្រះ
អនាគាមិបុគ្គលកើតឡើងជាកុសលជវនៈ អប្បូរាវចរកិរិយាចិត្តរបស់ព្រះ
ខីណាស្រព កើតឡើងជាកិរិយាជវនៈសោយនូវអារម្មណ៍អស់វារៈ ២ ដង
ហើយរលត់ទៅវិញ ទើបភាល់ត្រូវនិរោធសមាបត្តិ គឺថាចូលកាន់
និរោធសមាបត្តិសិប់សូន្យពិត ក៏កាលដែលចេញចាកនិរោធសមាបត្តិកើត
ឡើងហើយរលត់ទៅវិញ អនាគាមិផលកំកើតឡើងបីតនៅក្នុងអនាគា-
មិផលវិញជាដែល ព្រះអរហត្តផលកំកើតឡើងបីតនៅក្នុងព្រះអរហត្ត-

ផលវិញ្ញាជវិដល កិរិយាជវនសោយន្ធវអារម្មណ៍តស់ពរៈមួយជវៈ តាម
សមគ្គរដល់បុគ្គលនោះ ។ ពិត ។ ខ ៤ ជវនសម្ភរៈកាមាវចរកិរិយា
ចិត្តវដលជាញាណសម្បយុត្តរបស់ព្រះដ៏មានព្រះភាគកើតឡើងជាកិរិយា-
ជវនសោយន្ធវអារម្មណ៍ ប្រព្រឹត្តទៅរស់ពរៈ ៤ ជវៈ យ៉ាងរហ័ស
បើយ៉ាងយឺតឃ្លរប្រព្រឹត្តទៅរស់ពរៈ ៥ ជវៈ ក្នុងកាលវដលព្រះអគ្គទ្រង់
សំវដងន្ធវ យមកប្បាដិហារិយ៍ ដោយពិត ។

ឯកាមាវចរជវនទាំង ៨ តិហេតុកចិត្ត ១ សហេតុកកាមាវចរកិរិយា-
ចិត្ត ៨ និងមហគ្គតជវន ៩ លោកុត្តរជវន ៨ រួមទាំងអស់ត្រូវជា ៦៦
ពុំបានកើតឡើងដល់ទុហេតុកបដិសន្ធិបុគ្គល និងអហេតុកបដិសន្ធិ-
បុគ្គលទាំងឡាយឡើយ ។ ដូចមានសេចក្តីនិច្ចយរបស់ព្រះធម្មសង្គី-
ជីកាចារ្យលោកវិនិច្ចយសម្រេចតាត់សេចក្តីថា: កាមាវចរកុសលកម្ម
អំពើវដលបុគ្គលធ្វើយ៉ាងប្រើនប្រែងក្លៀវក្លាមាំមួនជាកាមាវចរកុសល ដ៏
ខ្ពស់ខ្ពង់ខ្ពស់ជាត្រៃហេតុទុកេ្ខត្តុ រមែងឲ្យបដិសន្ធិជាត្រៃហេតុហើយ
ញុំងឱកាមាវចរវិបាកទាំង ១៦ ឲ្យ ។ ផលជាក់ឡាស់ក្នុងបវត្តិកាល តែ
អហេតុកកុសលវិបាក ៨ មហាវិបាក ៨ កើតឡើងជ្រាកជវដល់បុគ្គល
ទាំងឡាយ ជាត្រៃហេតុទុកេ្ខត្តុខ្លះឯង ។ បើកាមាវចរកុសលកម្ម

អំពើដែលបុគ្គលធ្វើដោយការខំសាលំធុញទ្រាន់ ជាកាមាវចរកុសល
ចាបចោកពន់ពេកជាវិត្រហេតុទុមតក្តី កាមាវចរកុសលកម្ម អំពើ
ដែលបុគ្គលធ្វើដោយទុស្សាហៈ ព្យាយាមប្រឹងប្រែងក្លៀវក្លា ជាកាមាវច-
កុសល ជាទុគ្គមទ្ធនីទុស់ជាទ្វិហេតុទុក្រិដ្ឋក្តី នឹងឲ្យចជាសន្ធិជាទ្វិហេតុក-
បដិសន្ធិពិត ហើយញ៉ាំនវិបាកទាំង ១២ ប្រាសចេញចាកវិត្រហេតុក-
វិបាកឲ្យ។ ផលជាកំចាស់ក្នុងបវត្តិកាលគឺវិបាកទាំង១២គឺអហេតុកកុសល
វិបាក ៨ សហេតុកកុសលវិបាកជាញាណវិប្បយុត្ត ៤ តើតឡើងប្រាកដ
ដល់បុគ្គលទាំងពួយ ជាវិត្រហេតុទុមកនឹងទ្វិហេតុទុក្រិដ្ឋនោះឯង ។
កាមាវចរកុសលកម្ម អំពើដែលបុគ្គលធ្វើប្រកបដោយសេចក្តីធុញទ្រាន់
ខ្លួលប្រអូសពន់ពេក ឃាំងចាបចោកជាទ្វិហេតុទុមកនឹងត្រូវបំឲ្យចជាសន្ធិ
ជាអហេតុកបដិសន្ធិវិញ ហើយញ៉ាំងអហេតុកកុសលវិបាកទាំង ៨ ឲ្យ។
ផលជាកំចាស់ក្នុងបវត្តិកាល (បច្ចុប្បន្ន) ក្នុងកាមសុគតិភពនេះដោយ
ពិត ព្រោះថាកវិត្តចេតសិកបុគ្គលទាំងពួយ ជាសហេតុកជាបច្ច័យ
ដោយបច្ច័យជាលំដាប់នៃកវិត្តចិត្តជាអហេតុកពិត ។ កំបណ្តាបុគ្គល
ទាំង ៨ ពួក គឺបុថុជ្ជនបុគ្គល ១ សេក្ខបុគ្គល ៧ ព្រះខីណាស្រព ១
ត្រូវជា ៨ ពួក នោះកុសលជវនចិត្តអកុសលជវនចិត្តទាំងពួយពុំបានកើត

ខ្លឹនដល់ព្រះទីណា ស្រុតចាំធ ឡាយខ្លួយ ។ គឺថាកើតខ្លឹនបានដល់តែ
បុថុជ្ជនបុគ្គលនិងសេក្ខបុគ្គលប៉ុណ្ណោះឯង ។

ឯកិរិយាជវនចាំង ១៨ គឺអហេតុកហសនកិរិយាជវន ១ កាមា-
វចរសោភណាកិរិយាជវន ៨ មហគ្គតកិរិយាជវន ៩ ពុំបាននកើតខ្លឹន
ជ្រុកដល់សេក្ខបុគ្គលចាំងពីរពួក និងបុថុជ្ជនបុគ្គលចាំងឡាយខ្លួយ
ក៏អកុសលជវនជាចិដ្ឋតសម្បយុត្ត ៤ និងវិចិកិច្ចាជវន ១ ត្រូវជា ៥
ពុំបាននកើតខ្លឹនជ្រុកដល់សេក្ខបុគ្គលចាំង ៧ ពួក ព្រោះសេក្ខបុគ្គល
ចាំងពីរ គឺសោតាបន្នបុគ្គល ១ សកទាគាមីបុគ្គល ១ លោកមាន
សំយោជនធម៌ចាំងពីរ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ចា ១ បានលះបង់ដាច
ស្រឡះហើយដោយបឋមមគ្គមែនពិត ។ ចំណែកព្រះអនាគាមីបុគ្គល
ចាំងឡាយលោកមាននោមនស្សជវន ៦ ចិដ្ឋតសម្បយុត្តជវន ៤
វិចិកិច្ចាសហគតជវន ១ ត្រូវជា ៧ បានលះបង់ដាស្រឡះហើយដោយ
តតិយមគ្គពិត ។ មួយទៀត លោកុត្តរជវនចាំងឡាយ កើតខ្លឹន
ត្រមដល់ព្រះអរិយបុគ្គលចាំងឡាយ ដោយសមគួរតាមសភាពខ្លួនពិត
គឺថាសោតាបត្តិមគ្គជវនកើតខ្លឹន ដល់ព្រះអរិយបុគ្គលសុំតាបាកនិងសោ-
តាបត្តិមគ្គពិត សោតាបត្តិផលជវនកើតខ្លឹនដល់ព្រះតរិយបុគ្គលសុំតាបា

កន្លងសោតាបត្តិផលពិត សកទាគាមិមគ្គជនកើតឡើងដល់ព្រះអរិយបុគ្គលស្ថិតនៅកន្លងសកទាគាមិមគ្គពិត សកទាគាមិផលជនកើតឡើងដល់ព្រះអរិយបុគ្គលស្ថិតនៅកន្លងសកទាគាមិផលពិត អនាគាមិមគ្គជនកើតឡើងដល់ព្រះអរិយបុគ្គលស្ថិតនៅកន្លងអនាគាមិមគ្គពិត . អនាគាមិផលជនកើតឡើងដល់ព្រះអរិយបុគ្គល ស្ថិតនៅកន្លងអនាគាមិផលពិត អរហត្តមគ្គជនកើតឡើងដល់ព្រះអរិយបុគ្គល ស្ថិតនៅកន្លងអរហត្តមគ្គពិត អរហត្តផលជនកើតឡើងដល់ព្រះអរិយបុគ្គល ស្ថិតនៅកន្លងអរហត្តផលពិត ។ វិសជ្ជនាមកអំពីជនសម្ភពនៃបុថុជ្ជនបុគ្គល ទន្លងសេក្ខបុគ្គល ទន្លងអសេក្ខបុគ្គលទាំងឡាយ ជាសេចក្តីសន្និដ្ឋានតែប៉ុណ្ណេះឯង ។

៤២ ធម្មវិទី បានស្តាប់ហើយពោលថា អើអត្តវាទី ប្រស្នាដែលលោកវិសជ្ជនាមកទាំងអស់នេះ យើងស្តាប់បានបួលចិត្តហើយ តែថាយើងនឹងសួរប្រស្នាជាច្រើនទៀត ម្នាលអត្តវាទី ចុះបដិសន្ធិចុតិប្បដិបដិសន្ធិទាំង ៤ សេចក្តីប្លែកគ្នាដូចម្តេច ? សត្វទាំងឡាយដែលកើតក្នុងកូមិទាំង ៤ កំណត់អាយុពុំបាន ទន្លងកំណត់អាយុបានតិចច្រើនប្លែកផ្សេង ។ គ្នាយ៉ាងណាខ្លះ ? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មកយើងនឹងស្តាប់បួលចិត្តផងមើល !

អដ្ឋកថាទី វិសជ្ជនាតបថា បតិត្រតមច្ចាទី ឯប្រជុំបដិសន្ធិចាំង ๔ នោះ ទី ๑- តាមទុគ្គតិបដិសន្ធិមាន ๑ គឺ ๑ បេតវិសយសហគតសន្តីរណ ជាអហេតុកអកុសលវិបាកជាជនកកម្ម ជាពួជតបដិសន្ធិត្រាច់ទៅញ៉ាំងផលរបស់ខ្លួនឲ្យកើតជានាមរូបថ្មីក្នុងអបាយភូមិ ๔ ណាមួយក្នុងបដិសន្ធិកាល គឺទៅអំពីបដិសន្ធិកាលនោះ កើតជាភវង្គចិត្តបិតនៅអស់កំណាត់កាលហូនកម្មជាអាយុតិត ហើយញ៉ាំងអហេតុកអកុសលវិបាកចំាង ๗ ឲ្យ ๆ ផលសោយទុក្ខវេទនាជាទម្ងន់ឯទុក្ខលំបាកតាមបាបត្រេះ ចំពោះអកុសលកម្មរបស់ខ្លួនក្នុងបវត្តិកាល លុះផលអកុសលកម្មរសាត់ទៅផុតបង់ណា សត្វនោះក៏អស់អាយុកើតជាជវនកិរិយាចុតសួឲ្យទៅក្នុងកាលជាទីបំផុតនៃភវង្គចិត្តផុតបានោះឯង ឆានណ្ឌោះថា អបាយបដិសន្ធិ ๑ ។ ទី ๒- តាមសុគតិបដិសន្ធិមាន ๙ គឺ ๑ បេតវិសយសហគតសន្តីរណជាអហេតុកកុសលវិបាក ជាជនកកម្ម ជាពួជតបដិសន្ធិ ត្រាច់ទៅញ៉ាំងផលរបស់ខ្លួនឲ្យកើតជានាមរូបថ្មីក្នុងតាមសុគតិភូមិ គឺថាកើត ជាមនុស្សមានភេតផ្សង ๑ មានខ្វាក់ភ្នែកអំពីកំណើតជារដ្ឋមផង កើតជាវិនិបាតិកអសុរ ចាំងឡាយប្រាសចេញចាកសេចក្តីសុខតែងអស្រ័យនូវផែនដី ប្រាថ្នាដេស្មើដោយទីជាទីលំនៅនៃភូមិទេវតាចាំងឡាយផង ប្រព្រឹត្តទៅដោយ

បដិសន្ធិ-ភវង្គ-ចុតិកង្គ ឯកាមសុគតិភូមិដោយពាក្យ បានឈ្មោះថា កុសល-
វិបាកអហេតុកបដិសន្ធិ ១ ។ ឯមហាវិបាកចាំង ៨ ជាសហេតុក-
បដិសន្ធិប្រកបដោយវិជ្ជាហេតុផង ប្រកបដោយទ្វេហេតុផង ប្រព្រឹត្ត
ទៅកង្គាមសុគតិភូមិចាំង ៧ ជាន់ តែជាន១មនុស្ស ១ ជាន១សួគ៌ ៦ ជាន់
ដោយបដិសន្ធិ-ភវង្គ-ចុតិកង្គ ជាន១មនុស្សនឹងជាន១សួគ៌ជាសហេតុកកាម-
វិបាកបដិសន្ធិមាន ៨ រួមចាំងអស់ត្រូវជាកាមវិបាកបដិសន្ធិ ១០ កង្គាមភូមិ
ចាំង ១១ ជាន់ ។ ម្យ៉ាងទៀត សត្វចាំងឡាយដែលកើតកង្គាមភូមិ
ចាំង ៤ ក្តី កើតកង្គាជម្ពូទ្វីបនេះក្តី លោកពុំបានកំណត់អាយុឡើយ
ព្រោះសត្វចាំងអស់នេះមានអាយុខ្លីខ្លះ មានអាយុវែងខ្លះសមគួរតាមកម្ម
វេរស់ខ្លួនដោយពិត ឯមនុស្សកើតកង្គាខ្ពស់ក្រុវទ្វីប មានអាយុ ១ ពាន់
ឆ្នាំមនុស្សជាកំណត់ មនុស្សកើតកង្គាអមរគោយានទ្វីប ពូវិទេហទ្វីប
មានអាយុ ៥០០ ឆ្នាំមនុស្សជាកំណត់ ចំណែកសត្វចាំងឡាយ ដែល
កើតកង្គាសួគ៌ ៦ ជាន់ លោកកំណត់អាយុបាន ដោយថ្ងៃ-ខែ ឆ្នាំ
វេរស់មនុស្សយកទៅគុណនឹងថ្ងៃ ខែ ឆ្នាំទិព្វវេរស់ទេវតាចាំងឡាយ
ដូចអធិប្បាយតទៅនេះ ឧ ១ - អាយុវេរស់មនុស្ស ៥០ ឆ្នាំ បាន ១
ឆប់ ១ ថ្ងៃកង្គាសួគ៌ចាតុម្មហារាជិកាជាថ្ងៃទិព្វមួយ ៣០ ថ្ងៃទិព្វបាន

១ ថ្ងៃទិព្យ ១៦ ថ្ងៃទិព្យបាន ១ ឆ្នាំទិព្យ អាយុវែងតាកន្លះហាន ជាមួយ
ពពជាតិ ៩០០ ឆ្នាំទិព្យ គឺតាប់ជាឆ្នាំរបស់មនុស្សបាន ៩ លានឆ្នាំគត់ ។
ទី ២ - អាយុវែងតាកន្លះហានតាវត្តឹង្ស ១ ពាន់ឆ្នាំទិព្យ គឺតាប់ជាឆ្នាំរបស់
មនុស្សបាន ៣ កោដិ ៦ លានឆ្នាំគត់ ។ ទី ៣ - អាយុវែងតាកន្លះហាន
យាមា ២ ពាន់ឆ្នាំទិព្យ គឺតាប់ជាឆ្នាំរបស់មនុស្សបាន ១៨ កោដិ ៤ លាន
ឆ្នាំគត់ ។ ទី ៤ - អាយុវែងតាកន្លះហានតុសិត ៤ ពាន់ឆ្នាំទិព្យ គឺតាប់
ជាឆ្នាំរបស់មនុស្សបាន ៥៧ កោដិ ៦ លានឆ្នាំគត់ ។ ទី ៥ - អាយុ
វែងតាកន្លះហាននិម្មានរតី ៨ ពាន់ឆ្នាំទិព្យ គឺតាប់ជាឆ្នាំរបស់មនុស្សបាន
២៣០ កោដិ ៤ លានឆ្នាំគត់ ។ ទី ៦ - អាយុវែងតាកន្លះហានបរនិម្មិត
វសវត្តី ១ ម៉ឺន ៦ ពាន់ឆ្នាំទិព្យ គឺតាប់ជាឆ្នាំរបស់មនុស្សបាន ៩២១ កោដិ
៦ លានឆ្នាំគត់ ។

ទី ៣ - រូបាវចរបដិសន្ធិមាន ៤ គឺ ១ - បឋមជ្ឈានវិបាកជាជនក-
កម្មជាពួជតបដិសន្ធិត្រាប់ទៅ ញ៉ាំងផលរបស់ខ្លួនឲ្យកើតជានាមរូបថ្នក់
កណ្តាលបឋមជ្ឈានភូមិ ៣ ជាន់ គឺព្រហ្មបារិសជ្ជា ១ ព្រហ្មបុរោហិតា ១
មហាព្រហ្ម ១ ដោយអំណាចនៃបដិសន្ធិ - ភវង្គ - ចុតិដ៏សមគួរតាម
កំឡាំងរបស់ឈាន ។ ២ - ទុតិយជ្ឈានវិបាកជាជនកកម្មជាពួជតបដិសន្ធិ

ត្រាច់ទៅញ៉ាំងផលរបស់ខ្លួនឲ្យកើតជានាមរូបថ្នឹកឆ្នុកយជ្ឈាន ៣ ជាន់ គឺបឋមាគា ១ អប្បមាណាគា ១ តាកស្សក ១ ដោយអំណាចនៃបដិសន្ធិ - ភវង្គ - ចុតិដ៏សមគួរតាមកំឡាំងរបស់ឈាន ។ ៣- តតិយជ្ឈាន វិបាកជាជនកកម្មជាពួជតបដិសន្ធិត្រាច់ទៅញ៉ាំងផលរបស់ខ្លួនឲ្យកើតជានាមរូបថ្នឹកឆ្នុកតតិយជ្ឈានភូមិ ៣ ជាន់ គឺបរិត្តសុភា ១ អប្បមាណសុភា ១ សុភកិណ្ហា ១ ដោយអំណាចនៃដិសន្ធិ - ភវង្គ - ចុតិជួចគ្នា ។ ៤ - ចតុត្ថជ្ឈានវិបាកជាជនកកម្មជាពួជតបដិសន្ធិត្រាច់ទៅញ៉ាំងផលរបស់ខ្លួនឲ្យកើតជានាមរូបថ្នឹ ក្នុងចតុត្ថជ្ឈានភូមិ ៣ ជាន់គឺវេហប្ផលា ១ អសញ្ញីសត្តា ១ សុទ្ធាវាសទាំងប្រាំ ១ ដោយអំណាចនៃបដិសន្ធិ - ភវង្គ - ចុតិជួចគ្នា តែថាសុទ្ធាវាសភូមិទាំងប្រាំបាននៅតាងត្រកេនានាមីចុគ្គលទាំងឡាយចុំណ្ហាះម្តេហ៊ានរូបត្រូវទាំងអស់ត្រូវជា ១៦ តត កើតដោយរូបាវចរវិបាកទាំង ៤ ឲ្យបដិសន្ធិដោយពិត, បាននាំឈ្មោះថា រូបាវចរបដិសន្ធិទាំង ៤ ថ្លែកនៅតែអញ្ញីសត្វ ១ បាននាំឈ្មោះថា រូបបដិសន្ធិវិញ ព្រោះថា ព្រះយោគាវចរកុលបុត្រដែលបានចំរើនបញ្ចមជ្ឈានមានកំរោកសិណជាអារម្មណ៍ ជារូបាវចរកុសលហើយមានចិត្តនឿយណាយប្រាសចេញពីសញ្ញាជាស្រេច ឬតទៅកើតកន្លងអសញ្ញីសត្វទាំង.

ឡាយនោះ ថើស្វាប់ទៅដោយឥរិយាបថឯណា កំតើតឡើងក្នុង
អសញ្ញីសត្វនោះជាជីវិតនៃរូបជារូបមានជីវិតជាតំរប់ ៩ ដោយឥរិយា-
បថនោះឯង គឺថាថើស្វាប់ទៅដេក កើតឡើងក៏ដេកដែរ ស្វាប់ទៅដើរ
កើតឡើងក៏ដើរដែរ ស្វាប់ទៅឈរ កើតឡើងក៏ឈរដែរ ស្វាប់ទៅអង្គុយ
កើតឡើងក៏អង្គុយដែរ ចានឈ្មោះថា រមៀបដំសន្ធិតែមក្រាំងដោយពិត ។
ឯអាយុរបស់ព្រហ្មទាំងអស់នោះមានទ្វីវែងផ្សេង ។ គ្នា ពុំចានកំណត់អាយុ
ដោយថ្ងៃ-ខែ-ឆ្នាំឡើយ គឺថាកំណត់ដោយកប្បជួបអធិប្បាយតទៅនេះ ។
១- កប្បមួយថែកជា ៣ ចំណែក អាយុព្រហ្មចាំវេជ្ជាចាន ១
ចំណែកកប្បជាប្រមាណ ។ ២- ព្រហ្មបុរោហិតា មានអាយុកន្លះកប្ប
ជាប្រមាណ ។ ៣- មហាព្រហ្ម មានអាយុ ១ កប្បជាប្រមាណ ។
៤- ព្រហ្មបរិត្តាភា មានអាយុ២កប្បជាប្រមាណ ។ ៥- ព្រហ្មអប្បមា-
ណាភា មានអាយុ៤កប្បជាប្រមាណ ។ ៦- ព្រហ្មអាភស្សរ មានអាយុ
៨កប្បជាប្រមាណ ។ ៧- ព្រហ្មបរិត្តសុភា មានអាយុ១៦កប្បជាប្រ-
មាណ ។ ៨- ព្រហ្មអប្បមាណសុភា មានអាយុ៣២កប្បជាប្រមាណ ។
៩- ព្រហ្មសុភកិណ្ហា មានអាយុ ៦៤ កប្បជាប្រមាណ ។ ១០- ព្រហ្ម
វេហប្ផលា មានអាយុ ៥០០ កប្បជាប្រមាណ ។ ១១- ព្រហ្មអសញ្ញីសត្វ

មានអាយុ ៩០០ កប្បជាប្រមាណដូចគ្នា ។ ១២- ព្រហ្មអរិហា មាន
អាយុ ១ ពាន់កប្បជាប្រមាណ ។ ១៣- ព្រហ្មអកនិដ្ឋា មានអាយុ ២ ពាន់
កប្បជាប្រមាណ ។ ១៤- ព្រហ្មសុទស្សាមានអាយុ ៤ពាន់កប្បជាប្រ
មាណ ។ ១៥ ព្រហ្មសុទស្សី មានអាយុ ៨ ពាន់កប្បជាប្រមាណ ។
១៦- ព្រហ្មអកនិដ្ឋាមានអាយុ ១ ម៉ឺន ៦ ពាន់កប្បជាប្រមាណ ។

ទី ៤ - អរូបាវចរបដិសន្ធិមាន ៤ គឺ: ១ - អរូបវិបាកទី ១ ប្រព្រឹត្ត
ទៅដោយអំណាចនៃបដិសន្ធិ - ភវង្គ - ចុតិកើតឡើងក្នុងអាកាសានញ្ចាយ -
តនអរូបភូមិទី ១- ។ ២- អរូបវិបាក ទី ២ ប្រព្រឹត្តទៅដោយអំណាចនៃ
បដិសន្ធិ - ភវង្គ - ចុតិកើតឡើងក្នុងវិញ្ញាណញ្ចាយតនអរូបភូមិទី ២ ។
៣ - អរូបវិបាកទី៣ប្រព្រឹត្តទៅដោយអំណាចនៃបដិសន្ធិ - ភវង្គ - ចុតិកើត
ឡើងក្នុងអកិញ្ចញ្ញាយតនអរូបភូមិ ទី ៣ ។ ៤- អរូបវិបាកទី ៤ ប្រព្រឹត្ត
ទៅដោយអំណាចនៃបដិសន្ធិ - ភវង្គ - ចុតិកើតឡើងក្នុងនេវសញ្ញា -
សញ្ញាយតនអរូបភូមិទី៤ ។ ក៏អរូបព្រហ្មទាំង ៤ នេះកើតឡើងតុំមានរូបអ្វី
បន្តិចបន្តួចមែនតិច មានតែមនោធាតុជាអាយតនៈ តុំបានអាស្រ័យ
នូវតែអ្វីឡើយ ។ ឯកំណត់អាយុអរូបព្រហ្មទាំង ៤ នេះ: អរូបព្រហ្មទី ១
មានអាយុ ៦ ម៉ឺនកប្បជាប្រមាណ, អរូបព្រហ្មទី ២ មានអាយុ ៤ ម៉ឺនកប្ប

ជាប្រមាណ, អរូបព្រហ្មទី ៣ មានអាយុ ៦ ម៉ឺនកប្បជាប្រមាណ, អរូបព្រហ្មទី ៤ មានអាយុ ៨ ម៉ឺន ៤ ពាន់កប្បជាប្រមាណ ។ វិសជ្ជនា មកអំពីបដិសន្ធិចតុក្កជាដើមសេចក្តីសង្ខេបតែប៉ុណ្ណេះឯង ។

៨៣- ធម្មវិទូ៖ បានស្តាប់ហើយពោលថា ម្នាលអគ្គវ័ ចុះកម្ម ចតុក្កប្រជុំកម្ម ៤ ដោយអាការៈតាំង ១ ប្លាយ មាន ប៉ុន្មាន ? អធិប្បាយប្លែកផ្សេង គ្នាដូចម្តេចខ្លះ ? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មកយើងនឹងបានស្តាប់ចូលចិត្តផងមើល ?

អគ្គវិទូ៖ វិសជ្ជនាតបថា: បពិត្រធម្មវ័ ឯកម្មចតុក្កប្រជុំកម្ម ៤ ដោយអាការៈតាំង ១ ប្លាយមាន ៦ នោះ ដូចមានសេចក្តីក្នុងអដ្ឋកថា មហាដីកា, អនុដីកា, ព្រមទាំងវោជនា, លោកសំដែងអធិប្បាយ ពន្យល់ថា: ប្រជុំកម្ម ៤ គឺកិច្ចកម្ម អំពើជាកុសលនឹងអកុសលអាច ញ៉ាំងកិច្ចរបស់ខ្លួន ។ មានបដិសន្ធិកិច្ចជាដើមឲ្យសម្រេច ដោយអាការៈ មានប៉ុន្មាន ? ។ ជាកទានកម្ម អំពើជាកុសលនឹងអកុសលអាចឲ្យនូវផល ផ្សេង ។ គ្នា ដោយអាការៈមានប៉ុន្មាន ? ។ ជាកសីលកម្ម អំពើជាកុសលនឹង អកុសលអាចឲ្យនូវផលផ្សេង ។ គ្នាតាមកាលដោយអាការៈមានប៉ុន្មាន ? ។ ជាកភាវនាកម្ម អំពើជាកុសលនឹងអកុសល ដែលជាហេតុបណ្តុះ

បណ្តាលឲ្យកើតខ្លឹងជាផលផ្សេង ។ ដោយអាការៈមានបួន ១ ។ គ្រប់ជា
កម្ម ៤ ដោយពិត ។

ទី១- កិច្ចកម្មដែលសោកចែកដោយអាការៈបួននោះគឺកុសលចេតនា
និងអកុសលចេតនា ដែលពុំបានកាត់ផ្តាច់បង់នូវវិបាកជាផលនៃនម្មជាតិ
ហើយញុំាងវិបាកជាផលបេសំខ្លួនឲ្យកើតខ្លឹង គឺថានាំកែងរូបជាមិឲ្យ
កើនចំរើនធំខ្លឹងពេញបរិបូណ៌ ក្នុងបដិសន្ធិកាលនិងបវត្តិកាលដោយ
ផលដែលខ្លួនបានធ្វើសន្សំទុកមកហើយ បាននាំឈ្មោះថាជនកកម្ម ១, អំពើ
ជាកុសលនិងអកុសល ដែលមិនអាចញុំាងវិបាកជាផលបេសំខ្លួនឲ្យកើត
ខ្លឹងបាន ហើយកើតជាបច្ច័យក្នុងកិរិយាចំនុកចំរុនតាំកែងវិបាកជាផល
នៃកម្មជាតិ ដែលខ្លួនបានធ្វើសន្សំទុកមកអស់កាលជាយូរអង្វែងមកហើយ
ឲ្យកើតខ្លឹង ឬថាឲ្យកើតជាបច្ច័យ នៃវិបាកជាផលប្រព្រឹត្តទៅអស់
កាលជាយូរអង្វែងក្រោកជះស្មើដោយជនកកម្ម ដើម្បីកើតខ្លឹងជាបច្ច័យ
សម្រាប់ចំនុកចំរុនកាត់ផ្តាច់បង់នូវវិបាកជាផលកើតខ្លឹង ឲ្យសោយនូវ
សេចក្តីសុខ នឹងក្នុងកន្លះបវត្តិកាល គឺថាបើកុសលវិបាកមានកម្លាំងខ្លាំង
នឹងកាត់ផ្តាច់បង់នូវសេចក្តីទុក្ខលំបាកចេញ ហើយឲ្យបានសោយនូវ
សេចក្តីសុខត្រួមក្នុងវិញ បើអកុសលវិបាកមានកម្លាំងខ្លាំងនឹងកាត់

ផ្តាច់បង់នូវសេចក្តីសុខក្នុងភព្វាន្តរបញ្ញា ហើយឲ្យបានសោយនូវសេចក្តី
ទុក្ខលំបាកវិញផង ដើម្បីកើតឡើងជាបច្ច័យឲ្យបានចូលទៅដុតចំអែនត ។
ទៅទាំងមុខផង ឈ្មោះថា ទុបត្ថម្ភកកម្ម ១ អំពើឯណាមួយដែល
ជាចំអាស្រ័យនូវវិបាកជាផលដែលខ្លួនឲ្យកើតឡើង ដោយកម្មដទៃ
ប្រព្រឹត្តទៅអស់កាលជាយូរអង្វែងមកហើយ ដោយការបៀតបៀននូវ
និមិត្តមានត្រមត្រៀងដោយព្យាធិជាតុជាដើម ឬថាបៀតបៀននូវវិបាក
ជាផលនៃកម្មដទៃអំពីចន្លោះនីឯចន្លោះ ដោយកិរិយាប្រមូលមកនូវបច្ច័យ
មានការៈបៀតបៀនច្រើនជាដើម ក៏កាត់ផ្តាច់បង់នូវអំពើហាមឃាត់នោះ
ដោយច្រកគំាងពួង ហើយឲ្យនូវឱកាសផល់កម្មដទៃឲ្យ ។ ផល
កុដិបវត្តិកាល តុំបានញុំាងផលឲ្យកើតឡើង ដោយខ្លួនឯងឡើយ
ឈ្មោះថា ទុបបីឡកកម្ម ១, អំពើជាកុសលនិងអកុសលដែលហាម
ឃាត់ផ្តាច់បង់នូវផលនៃកម្មនោះ ។ ហើយញុំាងវិបាកជាផលបេសល់ខ្លួនឲ្យ
កើតឡើងដោយខ្លួនឯង ដោយកិរិយាកើតជាបច្ច័យបៀតបៀនផ្តាច់បង់
នូវកម្មដ៏មានកំឡាំងថយមែនពិត ឈ្មោះថា ទុបឃាដកកម្ម ១ ត្រូវ
ជាកិច្ចកម្មមាន ៤ ដោយពិត ។

ឧ ៦- ឈ្មោះថាកម្ម ដែលលោកបែងដោយអាការ ៤ នោះគឺអំពើ

ជាកុសលក្តីអកុសលក្តី ដែលមានផលធ្ងន់ គឺថាមានទោសធំធ្ងន់អំពើជាអ-
កុសលបានទាំងអនន្តរិយកម្មទាំង៥ប្រាំមានសម្ភារៈមកតាជាដើម មានអានុ-
ភាពធំធ្ងន់អំពើជាកុសលបានទាំងមហគ្គតគុណទាំង ៩ មានឧបបជ្ជវេទនា
ជាដើម ជាអំពើមានផលតឹកម្មដទៃពុំគាចនឹងហាមឃាត់បានឡើយ បាន
ឈ្មោះថាគរុកម្ម ១, អំពើជាកុសលក្តីជាអកុសលក្តីដែលបុគ្គលបានធ្វើក្នុង
កាលជិតស្លាប់នឹងផ្សំផលមុនជាងកម្មទាំងពួងបានឈ្មោះថា អាសន្នកម្ម ១,
អំពើជាកុសលខ្លះ ជាអកុសលខ្លះ ដែលបុគ្គលធ្វើសន្សំរឿយៗ គឺថាធ្វើម្តង
ហើយម្តងទៀត កម្មនេះកំធ្វើកម្មនោះកំធ្វើ សេពគប់ហើយដោយច្រើនបាន
ឈ្មោះថាអាចិណ្ណកម្ម ១អំពើជាកុសលក្តី ជាអកុសលក្តីដែលបុគ្គលធ្វើពេល
ឯណាមិនច្បាស់ជាអំពើណាឡើយ ធ្វើតាមតែប្រទះដោយមិនមានចេតនា
តែថាមិនមែនជាគរុកម្ម - អាសន្នកម្ម - អាចិណ្ណកម្មឡើយ បានឈ្មោះថា
តដង្គាកម្ម ១ ត្រូវជាបាតទានកម្ម ៤ ដោយពិត ។ សេចក្តីលោកពន្យល់ថា
បើបុគ្គលម្នាក់បានធ្វើកម្មគ្រប់ទាំង ៤ គរុកម្មនឹងផ្សំផលមុន បើមិនមាន
គរុកម្មទេ អាសន្នកម្មនឹងផ្សំផល បើមិនមានអាសន្នកម្មទេ អាចិណ្ណ-
កម្មនឹងផ្សំផល បើមិនមានអាចិណ្ណកម្មទេ តដង្គាកម្មនឹងផ្សំផលដោយ
ចំណែកមួយ ។

ข้อ ๓ - ปาតិកាលកម្ម អំពើជាកុសលនិងអកុសលអាចឲ្យផ្លូវផល
ផ្សេង ๆ គ្នា តាមកាល ដោយអាការមាន ๔ នោះ គឺ អំពើជាកុសល
និងអកុសលដែលបុគ្គលធ្វើសម្រេចដោយចេតនា គឺថាកុសល-
ចេតនាក្តី អកុសលចេតនាក្តី កើតជាផលនៃវិថីសោយនូវារម្មណ៍
អស់កាលវែងឆ្ងាយ រមែងឲ្យផលជាក់ច្បាស់ដល់ក្នុងកន្លងបច្ចុប្បន្នជាតិ
នេះដោយពិត ឬនឈ្មោះថា ទិដ្ឋធម្មវេទនីយកម្ម ๑, អំពើជាកុសលក្តី
ជាអកុសលក្តី ដែលបុគ្គលធ្វើឲ្យសម្រេចដោយសត្តមផលនៃចេតនា គឺថា
កុសលចេតនាក្តី, អកុសលចេតនាក្តី កើតជាផលនៃវិថីសោយនូវារម្មណ៍
អារម្មណ៍ កើតខ្សឹងនឹងរលត់ទៅវិញអស់កាល ជាតំរប់ ๗ ជាតិ, រមែងឲ្យ
ផលជាលំដាប់អំពីបច្ចុប្បន្នជាតិនេះ គឺថាផលំជាតិទាងក្រោយនឹងឲ្យ
បដិសន្ធិកើតជាមនុស្ស ឬទេវតា ឬថាកើតក្នុងអបាយភូមិក្តី ក្នុងជាតិ
ជាបន្ទាប់ជាតិនេះតទៅទៀតនឹងកើតជាវិបាកឲ្យផលកាល ๆ ជាតិទៅ ឬន
ឈ្មោះថា អបរាបរវេទនីយកម្ម ๑, អំពើជាកុសលក្តី ជាអកុសលក្តី
ដែលបុគ្គលធ្វើឲ្យសម្រេចដោយបញ្ចមផលនៃចេតនា គឺថាកុសលចេតនាក្តី
អកុសលចេតនាក្តី កើតជាផលនៃវិថីសោយនូវារម្មណ៍អស់កាល
ជាតំរប់ប្រាំផង, រមែងរលំចាំបាននូវខណៈកាល ថើទិដ្ឋធម្មវេទនីយកម្មនិង

ទុបបជ្ជវេទនិយកម្មឈប់ឲ្យផលពេលណា ឪដឲ្យផលពេលនោះឯង ឪ
ចានឈ្មោះថា អថកបវេទនិយកម្ម ១, អំពើជាកុសលក្តី អកុសលក្តី
ដែលបុគ្គលធ្វើជាអបកបវេទនិយកម្ម បើពុំបានឱកាសឪដឲ្យផលទេ
ឪដឯចានឈ្មោះថា អហោសិកម្ម ១, ត្រូវជាចាកកាលកម្ម ៤ ដោយពិត។

ទី ៤ - ចាកជ្ឈានកម្ម អំពើជាកុសលក្តី អកុសលក្តី ដែលជា
ហេតុបណ្តុះបណ្តាលឲ្យកើតខ្លឹងជាផលផ្សេង។ ដោយអាការមាន ៤
នោះគឺ អំពើជាអកុសលដែលបុគ្គលធ្វើប្រព្រឹត្តទៅក្នុងកាយទ្វារ ១
វចីទ្វារ ១ មនោទ្វារ ១ ដោយអកុសលចិត្តចាំង ១២ ហៅថា អកុសល-
កម្ម សេចក្តីអធិប្បាយតទៅទៀតថា: អំពើដែលបុគ្គលប្រព្រឹត្តធ្វើអាក្រក់
ដោយកាយមាន ៣ យ៉ាងគឺ:

ទី ១ - សម្លាប់សត្វ ១ លួចទ្រព្យគេ ១ មិនសង្កាសប្រព្រឹត្តធ្វើ
ខុសក្នុងកាមគុណចាំងពួយ គឺសេចក្តីតម្រេកត្រេកត្រអាលខ្លាំងរួប-
សំខ្លួន · កូន · ប្រ · សម្បត្តិ ឬត្រេកអរសេពជាមួយសុភនិងមេយ
តំណាយ តំណងឆ្កប់បញ្ចូលក្នុងសេតណ្ហាកាមគុណដែរ, តំណាងដែល
ត្រេកអរហួសប្រមាណមិនប្រព្រឹត្តធម៌សង្កាសក្នុងកាមគុណចាំង ៥ នេះ
ចានឈ្មោះថា តាមេសុមិច្ឆាចារ ១, រួមអំពើចាំង ៣ នេះ ចានឈ្មោះថា

កាយទុច្ចរិត សេចក្តីប្រព្រឹត្តអាក្រក់លាមកដោយកាយមាន ៣ ពាក្យ ។

ខ្ញុំ ២- ពោលពាក្យកុហកឲ្យខូចប្រយោជន៍អ្នកដទៃ ហៅថា មុសាវាទ ១; បុគ្គលដែលមានចេតនាដ៏អាក្រក់ និយាយពាក្យញុះញង់បំបែកមិត្តអ្នកដទៃឲ្យបែកចេញពីគ្នា ហើយយកមកជាមិត្តរបស់ខ្លួនវិញ ហៅថា បិសុណាវាចា ១; បុគ្គលដែលមានចេតនាដ៏អាក្រក់ ពោលពាក្យអាក្រក់នាំឲ្យក្តៅក្រហាយដល់បុគ្គលដទៃ ហៅថា ផរុសវាចា ១, បុគ្គលដែលមានចេតនាដ៏សៅហ្មង ពោលពាក្យឥតប្រយោជន៍មានញុំាងបុគ្គលឲ្យជឿនូវរឿងកំណាច់សំគាក់ឯកមកក្តៅផ្សាដើម ដែលជារឿងពុំពិតឥតខ្លឹមសារឥតមូលដ្ឋាន ហៅថា សម្ផប្បលាប ១; រួមអំពើទាំង ៤ នេះ បានឈ្មោះថាវចីទុច្ចរិតប្រព្រឹត្តអាក្រក់ដោយវាចាមាន ៤ ពាក្យ ។

ខ្ញុំ ៣- បុគ្គលដែលមានចិត្តបង្អោនទៅកាន់ទ្រព្យអ្នកដទៃ ដើម្បីយកមកឲ្យជារបស់ខ្លួន ដោយលោភចិត្ត ហៅថា អភិជ្ឈា ១, បុគ្គលដែលមានចិត្តទឹងច្រឡូស្តអ្នកដទៃឲ្យវេទិនាស ហៅថា ព្យាបាទ ១, បុគ្គលដែលពិចារណាយល់ឃើញខុសដ៏វិបរិត្តវង្វេង ។ មិនត្រូវតាមគន្លងធម៌ពិត ហៅថា មិច្ឆាទិដ្ឋិ ១, រួមអំពើទាំង ៣ នេះ បានឈ្មោះថា មនោទុច្ចរិតប្រព្រឹត្តអាក្រក់ដោយចិត្តមាន ៣ ពាក្យ ។

រួមអំពើដែលបុគ្គលប្រព្រឹត្តតាក្រក់ដោយប្រជុំទ្វារទាំង ๓ នេះ ហៅថា អកុសលកម្មបថមាន ๑๐ ជាគន្លងផ្លូវប្រព្រឹត្តធ្វើនូវអំពើតាក្រក់ ដោយអកុសលចិត្តទាំង ๑๒ ដែលជាហេតុបណ្តុះបណ្តាលឲ្យកើតជាអហេតុកអកុសលវិបាកទាំង ๗ គឺ។ បេក្ខាសហគតសន្តីរណអហេតុកវិបាក ๗ ជាគួបជិសន្ធិកើតក្នុងអបាយភូមិទាំង ๔ គឺ នរក ๑ ប្រេត ๑ តិរច្ឆាន ๑ អសុរកាយ ๑ ដោយខុសវេទនា ដោយចំណែកមួយ ហៅថា កាមាវចរអកុសលកម្ម ๑ ។

អំពើកុសលដែលបុគ្គលប្រព្រឹត្តធ្វើទៅក្នុងកាយទ្វារ ๑ វចីទ្វារ ๑ មនោទ្វារ ๑ ដោយមហាកុសលចិត្តទាំង ๘ ហៅថា កុសលកម្ម, សេចក្តីអធិប្បាយថា បុគ្គលដែលប្រព្រឹត្តធ្វើនូវអំពើដ៏ល្អតម៉ត់ចត់ល្អ ដោយកាយទ្វារ - វចីទ្វារ - មនោទ្វារ គឺ ឧ ๑ - រៀរាលនូវអំពើប្រព្រឹត្តអាក្រក់លាមកដោយកាយទ្វារទាំង ๓ យ៉ាងជាស្រឡះ គឺ មិនសម្លាប់សត្វ ๑ មិនលួចទ្រព្យគេ ๑ ប្រព្រឹត្តធម៌សន្តោសក្នុងកាមគុណទាំងឡាយ មិនត្រេកត្រអាលហួសប្រមាណ ๑ ។ ឧ ๒ - រៀរាលនូវអំពើប្រព្រឹត្តអាក្រក់លាមកដោយវចីទ្វារទាំង ๔ យ៉ាងជាស្រឡះ មាន មិនពោលពាក្យកុហកឲ្យខូចប្រយោជន៍អ្នកដទៃជាដើម ๑ ។ ឧ ๓ រៀរ

សេចក្តីអំពើប្រព្រឹត្តអាក្រក់លាមកដោយមនោទ្វារទាំង ៣ យ៉ាង ជាស្រេចមានអន់តិចជ្រា មិនបង្អោនចិត្តទៅតាន់ត្រឡប់ក្នុងខៃដោយសោកចិត្តជាដើម ១ រួមទាំងអស់ត្រូវជា ១០ គត់ ហៅថា កុសលកម្មបថទាំង ១០ ជាគន្លងផ្លូវប្រព្រឹត្តធ្វើនូវអំពើដ៏ស្អាតម៉ត់ចត់ល្អ ដោយមហាកុសលចិត្តទាំង ៨ ដែលជាចិត្តមានឥន្ទ្រីយ៍ល្អដ៏ធ្ងៃវិទ្ធាសភាពនៃអាចលះបង់នូវអកុសលកម្មបថទាំង ១០ បានជាស្រេច ហើយចំពោះកុសលកម្មបថទាំង ១០ ទៀតក៏មានប្រែនខ្លីងក្នុងសន្ធានខ្លួន ជាហេតុបណ្តុះបណ្តាលទៀតខ្លីងជាសហេតុកកុសលវិបាកទាំង ៨ ជាគួបដំសន្ធិកើតខ្លីងសោយសុខក្នុងកាមសុគតិភពទាំង ៧ ជាន់ គឺឋានមនុស្ស ១ កាមាវចរសួគ៌ ៦ ជាន់ ដោយពិត ។ ម្យ៉ាងទៀត កុសលកម្ម អំពើដែលបុគ្គលធ្វើដោយមហាកុសលចិត្តទាំង ៨ នេះ មិនមានតែប៉ុណ្ណោះទេ អាចញ៉ាំងអំពើជាកុសលទៀតខ្លីងជាអនេកកប់តុំអស់ខ្លីយ ក៏ក្នុងមហាកុសលចិត្តមួយ ។ អាចញ៉ាំងបុញ្ញកិរិយាវត្ថុជាប់ ។ ទៀតខ្លីងបានត្រូវជាបុញ្ញកុសិតំនរបុណ្យ ៨០ គត់ ហើយយកទៅគុណនឹងអារម្មណ៍ទាំង ៦ មានរូបារម្មណ៍ជាដើម ក្នុងអារម្មណ៍មួយ ។ កើតបុញ្ញកុសិតំនរបុណ្យចែកសិបៗត្រូវជា ៤៨០ បុណ្យគត់ ដូចបានអធិប្បាយមកអំពី

មហាកុសលចិត្តចាំង ๘ ក្នុងប្រស្នាខាងដើមនោះរួចហើយ, លោកអ្នក
សិក្សាបរមត្ថត្រូវអេកិនម្ន បើចង់ដឹងសេចក្តីច្បាស់លាស់ ត្រូវពិនិត្យមើល
ក្នុងប្រស្នាខាងដើម ដែលមានពាក្យថា - ធ្វើយអំពីមហាកុសលចិត្ត
នោះចុះ អាចនឹងដឹងសេចក្តីអធិប្បាយបានដោយងាយ, តំរូមសេចក្តី
ចាំងអស់ដោយសង្ខេប បាននៅឈ្មោះថា តាមាវចរកុសលកម្ម ១ ។

អំពើដែលយោគាវចរកុលបុត្រទំព្យាយាមចំរើនសមថកម្មដ្ឋាន ឬ
វិបស្សនាកម្មដ្ឋានក្នុងមនោទ្វារសម្រេចដោយការនា ដោយរួចាវច-
កុសលចិត្តចាំង ៤ ហើយបានសម្រេចដល់អប្បនាឈានជាលំដាប់នឹង
លំដាប់ជាហេតុបណ្តុះបណ្តាលឲ្យកើតឡើងជារួចាវចរវិបាក ជាតួបដិ-
សន្ធិកើតឡើងក្នុងរូបភពចាំង ១៦ ជាន់ តាមលំដាប់នៃឈានជាន់ខាប
ជាន់ខ្ពស់ បាននៅឈ្មោះថា រួចាវចរកុសលកម្ម ១ ។

អំពើដែលយោគាវចរកុលបុត្រទំព្យាយាមចំរើនសមថកម្មដ្ឋាន ឬ
វិបស្សនាកម្មដ្ឋានក្នុងមនោទ្វារសម្រេចដោយការនា ដោយអរួចាវច-
កុសលចិត្តចាំង ៤ ហើយបានសម្រេចដល់អប្បនាឈានជាលំដាប់នឹង
លំដាប់ ជាហេតុបណ្តុះបណ្តាលឲ្យកើតឡើង ជាអរួចាវចរវិបាកជាតួ
បដិសន្ធិកើតឡើងក្នុងអរូបភពចាំង ៤ ជាន់ តាមលំដាប់នៃឈានជាន់ខាប

ជាន់ខ្ពស់ បានឈ្មោះថា អរូបភាវចរកុសលកម្ម ๑ ។

បពិត្រធម្មាចរិ ខ្ញុំអត្តាចរិបានវិសជ្ជនាមកអំពីចតុកម្មចតុក្កៈ ប្រជុំកម្មបួនៗដង គឺ កិច្ចកម្ម ๔ បាកចារនកម្ម ๔ បាកគាលកម្ម ๔ បាកដ្ឋានកម្ម ๔ ត្រូវជាកម្ម ๑๖ ដោយសេចក្តីសង្ខេបតែប៉ុណ្ណេះឯង ។

๙๔ - ធម្មាចរិ បានស្តាប់ហើយពោលថា: ម្នាលអត្តាចរិចុះ អកុសលកម្ម អំពើបាបលាមកដែលបុគ្គលបានធ្លាប់ហើយដោយអកុសលចិត្តចាំង ๑๒ ទីនត្រឡប់ឲ្យផលជាអហេតុកបដិសន្ធិវិញ គឺថា: ចក្ខុសហគតសន្តីរណា ជាអហេតុកអកុសលវិបាក ជាជនកកម្ម តាក់តែងបដិសន្ធិឲ្យកើតជានាមរូបថ្មី ។ កន្លងកាមធាតុតិភូមិណាមួយក្នុងបដិសន្ធិកាល ហើយថាញ៉ាំងអហេតុកអកុសលវិបាកចាំង ๗ ផ្សេង ។ ផលសោយធម្មារម្មណ៍ កន្លងបវត្តិកាល ចុះចំណែកខាងកុសលវិបាក ដែលកើតជាប់មកក្នុងសន្តានខ្លួនបានឲ្យផលសោយសុទារម្មណ៍ក្នុងបវត្តិកាលខ្លះដែរឬទេ ?

អត្តាចរិ វិសជ្ជនាតបថា បពិត្រធម្មាចរិ សត្វចាំងខ្សោយដែលប្រព្រឹត្តធ្វើខ្លួវអំពើបាបលាមកហើយស្លាប់ទៅនោះ ទីណមានអកុសលវេបក្កនាជាជនកកម្មតាក់តែងបដិសន្ធិឲ្យកើតជានាមរូបថ្មី ។ កន្លងកាមធាតុតិភូមិណាមួយក្នុងបដិសន្ធិកាល, តែថាកន្លងបវត្តិកាលបើអហេតុកអកុសលកម្មមាន

កំឡាំងខ្លាំងញ៉ាំងអហេតុកអកុសលវិបាកឲ្យ ។ ផលសោយទុក្ខវេទនាជាដរាបតទៅ, បើអហេតុកអកុសលកម្មមានកំឡាំងខ្សោយហើយ អហេតុកកុសលកម្មមានកំឡាំងខ្លាំងវិញ នឹងញ៉ាំងអហេតុកកុសលវិបាកឲ្យ ។ ផលសោយសុខវេទនាក្នុងបច្ចុប្បន្ននេះជាយថាពិត; រួមអហេតុកអកុសលវិបាក ៧ នឹងអហេតុកកុសលវិបាក ៨ ក្រៅជា ១៥ តែងផ្ទាស់ប្តូរគ្នាឲ្យផលសោយទុក្ខខ្លះ សុខខ្លះ ដ៏សមគួរតាមកុំឡាំងខ្លាំងនឹងកំឡាំងខ្សោយក្នុងកាមទុគ្គតិភូមិក្នុងបវត្តិកាលជាយថាំណាកមួយ, ឯមហាកុសលវិបាកទាំង ៨ តុំបានប្រព្រឹត្តទៅឲ្យផលក្នុងកាមទុគ្គតិភូមិទាំង ៤ ជាន់នោះឡើយ ។ ចំណែកខាងសត្វទាំងឡាយដែលប្រព្រឹត្តធ្វើនូវអំពើជាកុសលមានផលបុណ្យល្អហើយស្លាប់ទៅនោះ នឹងមានកុសលចេតនាណាមួយជាជនកកម្ម តាក់តែងបដិសន្ធិឲ្យកើតជាតាមរូបថ្នូ ក្នុងកាមសុគតិភូមិទាំង ៧ ជាន់ មានហានមនុស្សជាដើមក្នុងបដិសន្ធិកាលតែជាកុសលវិបាក បើអកុសលកម្មមានកំឡាំងបានឱកាសនឹងញ៉ាំងអហេតុកអកុសលវិបាកឲ្យ ។ ផលសោយទុក្ខវេទនាជាខម្លួនក្នុងបច្ចុប្បន្ននេះ បើតុំបានឱកាសទេ អហេតុកកុសលកម្មមានកម្លាំងបានឱកាសវិញនឹងញ៉ាំងអហេតុកកុសលវិបាកឲ្យ ។ ផលសោយសុខវេទនា ជាសុខយ៉ាងតិចក្នុង

បច្ចុប្បន្នេនេ បើពុំបានទុកាសទេ សហេតុកកុសលកម្មមានកម្លាំងខ្លាំង បានទុកាសវិញ ទើបញ៉ាំងសហេតុកមហាកុសលវិបាកទាំង ៨ ឲ្យ។ ផលសោយសុខវេទនា ជាសុខវេទនាដ៏ប្រសើរក្នុងបច្ចុប្បន្ននេះដោយពិត ;. ម្នេអហេតុកអកុសលវិបាក ៧ អហេតុកកុសលវិបាក ៨ សហេតុក-មហាកុសលវិបាក ៨ ត្រូវជា ២៣ សម្រាប់ឲ្យផលដល់សត្វទាំងឡាយ ដែលកើតកន្លងកាមសុគតិភូមិទាំង ៧ ជាន់ដោយចំណែកមួយពាក់ វិសជ្ជ-នាមកអំពីអកុសលកម្ម ឧទ្ធំកុសលកម្មឲ្យផលដោយសង្កត់សង្កិនតែប៉ុណ្ណោះឯង ។

๔๕ - ឯម្ហាកិច្ចិ បានស្តាប់ហើយពោលថា: សាធុ។ អើ អត្តាទ័ ប្រស្នាដែលលោកបានវិសជ្ជនាមកនេះប្រពៃណាស់ហើយ តែយើងនឹងសួរប្រស្នាដទៃតទៅទៀត ម្នាលអត្តាទ័ ចុះអំពើដែលបុគ្គលបានធ្វើជាកុសលយ៉ាងក្តុមក្តួលដ៏ខ្លាំងឈ្មោះថា ទ្រៃហេតុក្រឹដ្ឋមានប៉ុន្មានយ៉ាង? សេចក្តីផ្សងគ្នាដូចម្តេចខ្លះ? អំពើដែលបុគ្គលបានធ្វើជាកុសលយ៉ាងជាន់តាបថយចាកឈ្មោះថា ទ្រៃហេតុទុមក: មានប៉ុន្មានយ៉ាង? សេចក្តីផ្សងគ្នាដូចម្តេចខ្លះ? អំពើដែលបុគ្គលបានធ្វើជាកុសលយ៉ាងក្តុមក្តួលដ៏ខ្លាំង ឈ្មោះថា ទ្វិហេតុក្រឹដ្ឋមានប៉ុន្មានយ៉ាង? សេចក្តីផ្សងគ្នាដូច

ម្តេចខ្លះ? អំពើដែលបុគ្គលបានធ្វើជាកុសលយ៉ាងដ៏ទាបថយថោក ឈ្មោះថា ទុំហេតុទុមកៈ មានប៉ុន្មានយ៉ាង? សេចក្តីផ្សងគ្នាដូចម្តេចខ្លះ? ប៊ូរលោកវិសុទ្ធាឡេសត្ថគ្រប់មនយើងទាំងអស់បានស្តាប់ចូលចិត្តផងមើល!

អត្ថវិភាគ វិសុទ្ធាគមថា បតិត្រធម្មាទី សេចក្តីវិនិច្ឆ័យរបស់ព្រះធម្មសង្គីតិកាចារ្យ លោកបានសម្រេចតាស់សេចក្តីថា ទុក្កដកម្ម អំពើដែលបុគ្គលបានធ្វើយ៉ាងទុក្ខមន្ទឹងស់ជាទុក្រិដ្ឋក្តី អំពើដែលបុគ្គលបានធ្វើយ៉ាងដ៏ទាបថយថោកជាទុមកៈក្តី នោះយើងបានអធិប្បាយមកក្នុងប្រស្នាទី ៦០-៦១ និងទី ៨១ ជាមាងដើមមកបួសត្ថគ្រប់ហើយមិនចាប់អធិប្បាយតទៅទៀតទេ សម្បុរសទាំងឡាយ អ្នកសិក្សារៀនបរមត្ថត្រូវតេកិច្ច ត្រូវតែយកសេចក្តីអធិប្បាយក្នុងប្រស្នាទី ៦០-៦១និង៨១ នោះបុរេ តង់ជ្រាបសេចក្តីបានដោយដាយ ។ ក្នុងប្រស្នានេះ ទីងសំដែងតែត្រង់សេចក្តីដែលថ្មីកគ្នា តាមសេចក្តីវិនិច្ឆ័យដូចអធិប្បាយតទៅនេះ:

ទី ១ - ត្រៃហេតុទុក្រិដ្ឋ ចែកចេញជាពីរយ៉ាងតាមអំពើដែលបុគ្គលបានធ្វើដោយកុសលចេតនាយ៉ាងទុក្ខមន្ទឹងស់ ។ ទី ២ ត្រៃហេតុទុមកៈ ចែកចេញជាពីរយ៉ាង តាមអំពើដែលបុគ្គលបានធ្វើដោយកុសល-

- ចេតនាយ៉ាងជាន់ខាងថយជាក ។ ខ. ๓ - ទុំហេតុទ្រង់ទ្រាំដូច ចែកចេញជាតិរយ៉ាង តាមអំពើដែលបុគ្គលបានធ្វើដោយកុសលចេតនាយ៉ាងខ្ពស់ខ្ពស់ ។ ខ. ๔ - ទុំហេតុទុមក: ចែកចេញជាតិរយ៉ាង តាមអំពើដែលបុគ្គលបានធ្វើដោយកុសលចេតនា យ៉ាងជាន់ខាងថយជាក រួមមកសេចក្តីអធិប្បាយតាមគាថា អដ្ឋកថា មហាដីកា - អនុដីកា - យោជនានៃអភិធម្មត្ថសង្គហថា: ខ. ๑ - ត្រង់ហេតុទ្រង់ទ្រាំដូចចែកចេញជាតិរយ៉ាងនោះគឺអំពើដែលបុគ្គលបានធ្វើដោយកុសលចេតនាមួយ ក្នុងខណៈធ្វើបុណ្យឲ្យទានមួយលើក ។ ក្នុងជាតិនេះ ហើយមានខុសគ្នាហ៊ាំទាំងយាមប្រើងប្រែងក្លៀវក្លាចាត់ការជាកុសលពុំបានធ្លាក់ខ្វិលប្រកបសោះឡើយ . មានចាត់ចែងធ្វើការជាកុសលដដែរ ។ យ៉ាងច្រើន ជំរុញរឿងជាបរិវារចាមភេមបុណ្យជាប្រធានដែលខ្លួនបានប្រារព្ធនឹងធ្វើនោះ ដកចេញសម្រាប់បុណ្យមួយលើក ។ ហើយតែងមានចិត្តនឹករលឹកបុណ្យដែលខ្លួនបានធ្វើហើយនោះរឿយ ។ ពុំដាច់ ដោយអស់ទាំងកែមហាកុសលចិត្តទាំង ๘ រៀវលែងចាកសសង្ខារកែមហាកុសលចិត្ត ๘ ចេញតែបឋមកុសលចិត្តខ្ពស់ ๑ ដែលប្រកបដោយសោមនស្សវេទនាជាញាណសម្បយុត្តអសង្ខារិក ๑, តតិយកុសលចិត្តខ្ពស់ ๓ ដែលប្រកបដោយសោមនស្សវេទនាជាញាណ-

វិប្បយុត្តអសង្ខារិក ១ ចតុត្ថមកុសលចិត្តខ្លី ៤ ដែលប្រកបដោយឧបេក្ខា-
វេទនាជាញាណសម្បយុត្តអសង្ខារិក ១, សត្តមកុសលចិត្តខ្លី ៧ ដែល
ប្រកបដោយឧបេក្ខាវេទនាជាញាណវិប្បយុត្តអសង្ខារិក ១ ត្រូវជា ៤
ជាកុសលចិត្ត មានឧស្សាហ៍ទំព្យាយាមប្រឹងប្រែងកើតឡើងដោយខ្លួន
ឯង តុំមានបុគ្គលណាមួយមកជំរុញនាំឲ្យធ្វើឡើយ លុះដល់បុគ្គល-
ខ្លួនមរណភាពទៅនឹងមានកុសលចេតនា ណាមួយមានកម្លាំងខ្លាំងជាង
ដែលខ្លួនបានធ្វើហើយក្នុងបច្ចុប្បន្ននេះកើតជាជនកកម្ម តាក់តែងឲ្យ
ឲ្យកើតជានាមរូបថ្មីក្នុងភពតាមសុគតិភូមិទាំង ៧ ជាន់ មានហានមនុស្ស
ដើមក្នុងបដិសន្ធិកាល ហើយញាំងអសង្ខារិកមហាវិបាក ៤ និងអហេតុ-
កកុសលវិបាក ៨ ត្រូវជា ១២ ឲ្យ ។ ដល់ក្នុងបវត្តិកាល បាននាំឲ្យ
កើតហេតុទ្រឹង្គខ្លី ១ ។

អំពើដែលបុគ្គលបានធ្វើដោយកុសលចេតនាមួយក្នុង ១ ណា ធ្វើបុណ្យ
ឲ្យទានមួយលើក ។ ក្នុងជាតិនេះ ហើយមានឧស្សាហ៍ទំព្យាយាមប្រឹង
ព្រែងដាំក្តៅ ក្តា ចាត់ការជាកុសល តុំបាន់ខ្ជិល ប្រកបធុញ ច្រានឡើយ
មានចាត់ចែងធ្វើការជាកុសលដរៃ ។ យ៉ាងច្រើន ដំរុងរឿងចាមរកេម
ដាចរៀបបុណ្យជាប្រធានដែលខ្លួនបានច្រាវត្ថុនឹងធ្វើនោះ ដកចេដល់

សម្រេចបុណ្យមួយលើក ។ ហើយតែងមានចិត្តនឹកលើកបុណ្យដែលខ្លួន
បានធ្វើហើយនោះរឿយ ។ តុជាច់ ដោយសង្ឃរាកមហាកុសលចិត្ត
ទាំង ៤ រឿរលែងចាកអសង្ឃរាកមហាកុសលចិត្ត ៤ ចេញ គឺកុសល-
ចិត្ត ទី ៥.៨ ដែលប្រកបដោយសោមនស្សវេទនា ជាញាណសម្ប-
យុត្តសង្ឃរាក ១ ជាញាណវិប្បយុត្តសង្ឃរាក ១ ឧទ្ធច្ចកុសលចិត្ត
ទី ៦.៩ ដែលប្រកបដោយឧបេក្ខាវេទនា ជាញាណសម្បយុត្ត-
សង្ឃរាក ១ ជាញាណវិប្បយុត្តសង្ឃរាក ១ ត្រូវជា ៤ ជាកុសល-
ចិត្តមានបុគ្គលជាទៃដឹកនាំទើបធ្វើ លុះដល់បុគ្គលនោះខ្លួលមរណភាព
ទៅ ឧទ្ធច្ចកុសលចេតនាណាមួយដែលមានកម្លាំងជាងដែលខ្លួនបាន
ធ្វើហើយកន្លងបច្ចុប្បន្ននេះ តើតជាជនកកម្មភាក់តែងបដិសន្ធិឲ្យតើតជា
នាមរូបថ្មីកន្លងកាមសុគតិភូមិទាំង ៧ ជាន់ក្នុងបដិសន្ធិកាល ហើយញុំង
សង្ឃរាកមហាវិបាក ៤ ឧត្តរកុសលវិបាក ៨ ត្រូវជា ១២ ឲ្យ ។
ផលកន្លងបវត្តិកាល បានឈ្មោះថា វៃត្រហេតុ ក្រៃផ្នែក ទី ២ ។

ទី ២ - វៃត្រហេតុទុមកៈ បែកចេញជាពីរយ៉ាងនោះគឺ អំពើដែល
បុគ្គលបានធ្វើដោយកុសលចេតនាមួយ កន្លងណាៈធ្វើបុណ្យឲ្យទានមួយ
លើក ។ កន្លងជាតិនេះ គ្រាន់តែផ្តើមបុណ្យឲ្យតើតខ្សឹង ហើយបណ្តាក

បណ្តាយឲ្យតែអ្នកដទៃគេធ្វើ, ឥតមានទុស្សហ៍ខំព្យាយាមប្រឹងប្រែងដើរក្បៀវក្បាចាត់ការជាកុសលឡើយ មានសេចក្តីខ្ជិលច្រអូសធុញទ្រាន់ច្រើន បណ្តាយឲ្យអកុសលកម្មចាំងឡាយ ចូលមកលុកលុយរោមរោមជាបរិវារបុណ្យជាច្រើនពន់ ដែលខ្លួនបានច្រាវច្រឹងធ្វើនោះឲ្យថយផលានិសង្សតិចទៅ មានទីដែរបន្ទោសអ្នកដទៃឲ្យធ្វើជាដើម ដរាបដល់សម្រេចបុណ្យមួយលើក។ ហើយមានវិប្បដិសារី សេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយ ដោយគិតថា អំពើដែលអញបានធ្វើហើយនេះ ជាអំពើដ៏អាក្រក់ពេក, កំប្តុគ្គលធ្វើបុណ្យដោយអសង្ខារកែមហាកុសលចិត្ត ៤ រៀវលែងចាកអសង្ខារកែកុសលចិត្ត ៤ ចេញតែ កុសលចិត្តទី ១-៣ ដែលប្រកបដោយសោមនស្សវេទនា ជាញាណសម្បយុត្តអសង្ខារកែ ១ ជាញាណវិប្បយុត្តអសង្ខារកែ ១ នឹងកុសលចិត្តទី ៥-៧ ដែលប្រកបដោយឧបេក្ខាវេទនា ជាញាណសម្បយុត្តអសង្ខារកែ ១ ជាញាណវិប្បយុត្តអសង្ខារកែ ១ ត្រូវជា ៤ ជាកុសលចិត្តឥតមានបុគ្គលដទៃដឹកនាំទៀយ; ក៏អំពើដែលបុគ្គលបានធ្វើដោយអសង្ខារតែកុសលចិត្តទាំង ៤ ដែលជាត្រឹមហេតុមានកម្លាំងខ្សោយពេក យ៉ាងនេះនឹងត្រឡប់ឲ្យផលច្រាកដស្មើដោយខ្លួនហេតុឲ្យត្រឹមត្រូវវិញ គឺថានឹងមានកុសលវេទនា

ណាមួយជាជនកម្ម តាក់តែងឯបដិសន្ធិឲ្យកើតជាតាមរូបថ្នឹកឯតាមសុគតិ-
ភូមិទាំង ៧ ជាន់ក្នុងឯបដិសន្ធិកាល ហើយញ៉ាំងអសង្ខារកែមហាវិបាក
ជាញាណវិប្បយុត្ត ៦ នឹងអហេតុកកុសលវិបាក ៨ ត្រូវជា ១០
ឲ្យ។ ផលក្នុងឯបវត្តិកាល បាននាំឲ្យថា វៃក្រហេតុទុមកៈ ទី ១ ។

អំពើដែលបុគ្គលបានធ្វើដោយកុសលចេតនាមួយ ក្នុង ១ ណៈធ្វើ
បុណ្យឲ្យទានមួយលើក។ ក្នុងជាតិនេះ គ្រាន់តែចូលមកផ្តើមបុណ្យឲ្យ
កើតឡើងហើយបណ្តាបណ្តាយឲ្យតែអ្នកជាទៃគេធ្វើ ឥតមាន ១ សប្តាហ៍
ទំនាយាមប្រើងប្រែងជំរុញក្លាចាត់ការជាកុសលឡើយ មានសេចក្តី
ខ្ជិលច្រអូសធុញទ្រាន់ប្រែន បណ្តាយឲ្យអកុសលកម្មទាំងឡាយចូល
មកលុកលុយចោមរោមជាបរិវារបុណ្យជាប្រធាន ដែលខ្លួនបានប្រារព្ធ
នឹងធ្វើនោះឲ្យខាតផលានិសង្សតិចទៅ មានទំនៀមដែលបន្ទោសអ្នកជាទៃ
ជាដើម ដកបដល់សំរេចបុណ្យមួយលើក។ ហើយមានវិប្បដិសារី
ក្តៅក្រហាយក្នុងកាលជាខាងក្រោយ ដោយគិតថា: អំពើដែលុ
អញបានធ្វើហើយនេះជាអំពើដ៏អក្រក់ពេក; កំបុគ្គលបានធ្វើបុណ្យ
ដោយសសង្ខារកែមហាកុសលចិត្ត ៤ រឿរលែងចាត់តអសង្ខារកែមហា-
កុសលចិត្ត ៤ ចេញតែ កុសលចិត្ត ទី ២.៤ ដែលប្រកបដោយសោ-

មនស្សវេទនា ជាញាណសម្បយុត្តសសង្ខារកៈ ๑ ជាញាណវិប្បយុត្ត-
សសង្ខារកៈ ๑ ទំនឹងកុសលចិត្តទី ๖ ๘ ដែលប្រកបដោយ ๑ បេក្ខា-
វេទនា ជាញាណសម្បយុត្តសសង្ខារកៈ ๑ ជាញាណវិប្បយុត្តសសង្ខា-
រកៈ ๑ ត្រូវជា ๔ ជាកុសលចិត្តមានបុគ្គលដទៃជាកន្លាំងើបធ្វើ, កិរិយា
ដែលបុគ្គលបានធ្វើដោយសសង្ខារកៈមហាកុសលចិត្ត ๔ ជាវិត្រហេតុមាន
កម្លាំងខ្លាចេកយ៉ាងនេះទំនឹងត្រូវបង់ឲ្យផលប្រាកដ ស្មើដោយ ๒ ហេតុ-
ទ្រឹង្គ តែថាទំនឹងមានកុសលចេតនាណាមួយជាជនកកម្ម តាក់តែងចម្ងដ-
សន្ធិឲ្យកើតជានាមរូបថ្មីក្នុងភពមុតភូមិទាំង ๗ ជាន់ក្នុងចំងដសន្ធិកាល,
ហើយញុំាងសសង្ខារកៈមហាវិបាកជាញាណវិប្បយុត្ត ๔ ទំនឹងអហេតុក-
កុសលវិបាក ๘ ត្រូវជា ๑๐ ឲ្យ ๆ ផលក្នុងបវត្តិកាល ជានឈ្មោះថា
វិត្រហេតុទុមកៈទី ๒ ๆ

ទី ๓- ๒ ហេតុទ្រឹង្គចែកចេញជាតិរយ៉ាងនោះគឺ អំពើដែល
បុគ្គលបានធ្វើដោយកុសលចេតនាមួយ ក្នុង ๆ ណៈធ្វើបុណ្យឲ្យទានមួយ
លើក ๆ ក្នុងជាតិនេះ ហើយមាន ๆ សប្បាយំវិសាយាមប្រឹងប្រែងដ៏
ក្លៀវក្លា ចាត់ការជាកុសលតុំបានឱ្កាសប្រអូសធ្វើញឹកញាប់ឡើយ មានចាត់
ចែងធ្វើការជាកុសលដទៃ ๆ យ៉ាងច្រើនជាបន្តបន្ទាប់បុណ្យជាប្រធានដែល

ខ្ញុំនឹងធ្វើនោះ ដកបដិសន្ធិបុណ្យមួយលើក ។ ហើយ
តែងមានចិត្តនឹកលើកបុណ្យដែលខ្ញុំនឹងធ្វើហើយនោះរឿយ ។ តុំដាច់
ដោយអសង្ខារិកមហាកុសលចិត្តតាំង ៤ រៀរលែងពាក្យអសង្ខារិកមហា-
កុសលចិត្ត ៤ ចេញ គឺកុសលចិត្តខ្ចី ๓ ដែលប្រកបដោយសោមនស្ស-
វេទនា ជាញាណវិប្បយុត្តអសង្ខារិក ១ នឹងកុសលចិត្តខ្ចី ๗ ដែលប្រកប
ដោយឧបេក្ខាវេទនា ជាញាណវិប្បយុត្តអសង្ខារិក ១ ជាកុសលចិត្ត
កើតសេចក្តីថ្នាក់ថាដោយខ្ញុំនឹងនឹងគឺមានបុគ្គលជាពៃដឹងនាំទៀតឬយ ក៏ដល់
បុគ្គលនោះឧបត្ថម្ភណាគាថា ឱ នឹងមានកុសលចេតនាណាមួយមាន
កម្លាំងខ្លាំងជាង កើតជាជនកម្មតាក់តែងបដិសន្ធិឲ្យកើតជាតាមរូបថ័ក្ត
តាមសុគតិភូមិតាំង ๗ ជាន់ កន្លងបដិសន្ធិកាល, ហើយញាំងអសង្ខារិក-
មហាវិបាកជាញាណវិប្បយុត្ត ๖ នឹងអហេតុកកុសលវិបាក ๘ ត្រូវជា ๑๐
ឲ្យវិបាកកន្លងបវត្តិកាល ឬមានឈ្មោះថា ខ្ញុំហេតុឧក្រិដ្ឋខ្ចី ๑๐ ។ អំពើ
ដែលបុគ្គលបានធ្វើដោយកុសលចេតនាមួយ កន្លងណាៈធ្វើបុណ្យឲ្យទាន
មួយលើក ។ កន្លងជាតិនេះ រមែងមានឧស្សាហ៍ព្យាយាមប្រឹងព្រែង
ដើរក្បៀវក្បា បាត់ការដោកុសលពុំបានឱ្យលប្រអូសធ្លាក់ទ្រាន់ឡើយ, មាន
បាត់ចែងធ្វើការដោកុសលជាដៃ ។ យាំងប្រែនជាបរិវារបុណ្យ ជាប្រធាន

ដែលខ្លួនបានត្រាស់ដឹងធ្វើនោះ. ដរាបដល់សម្រេចបុណ្យមួយលើក ។
ហើយតែងមានចិត្តនឹករលឹកបុណ្យ ដែលខ្លួនបានធ្វើហើយនោះរឿយ ។
ពុំជាច់, ដោយសសង្ខារកម្មហាកុសលចិត្តចាំង ៤ រៀវលែងចាកអសង្ខា-
រកម្មហាកុសចិត្ត ៤ ចេញ តែកុសលចិត្តទី ៤ ដែលប្រកបដោយ
សោមនស្សវេទនា ជាញាណវិប្បយុត្តសង្ខារក ១ នឹងកុសលចិត្តទី ៨
ដែលប្រកបដោយឧបេក្ខាវេទនា ជាញាណវិប្បយុត្តសង្ខារក ១
ត្រូវជា ២ ជាកុសលចិត្តកើតដោយបុគ្គលដទៃដឹកនាំ. ទើបកើតសេចក្តី
ជ្រះថ្លា ក្លៀវក្លាឡើងហើយធ្វើ លុះដល់បុគ្គលនោះខ្លួលមរណកាល
ទៅ នឹងមានកុសលចេតនាណាមួយមានកម្លាំងខ្លាំងជាងកើតជាជនកកម្ម
តាក់តែងបដិសន្ធិឲ្យកើតជានាមរូបថ្មីក្នុងកាមសុគតិភូមិចាំង ៧ ជាន់ ក្នុង
បដិសន្ធិកាល, ហើយញាំងសសង្ខារកម្មហាវិបាកជាញាណវិប្បយុត្ត ២
នឹងអហេតុកកុសលវិបាក ៨ ត្រូវជា ១០ ឲ្យ ។ ផលកន្លងបវត្តិកាល
បានឈ្មោះថា ខ្វិហេតុទុក្ខិត ទី ៦ ។

ទី ៤- ខ្វិហេតុទុមក:ចែកចេញជាពីរយ៉ាងនោះ គឺ: អំពើដែល
បុគ្គលបានធ្វើដោយកុសលចេតនាមួយ ក្នុងខណៈធ្វើបុណ្យឲ្យទានមួយ
លើក ។ ក្នុងជាតិនេះ ជាបុគ្គលឥតមានសទ្ធាពុំបានជ្រើសមូលផល ពុំបាន

ត្រូវអប្រុះថ្លាក្នុងការជាកុសលបុន្មានឡើយ ធ្វើដោយមានសេចក្តី
រង្គៀសខ្មើសខាល់ធំឆ្ងាតមិត្រសំឡាញ់ ដែលនៅផ្ទះជិតខាងគេតែងធ្វើ
បុណ្យឲ្យទានរឿយ ៗ ហើយក៏ចាត់ចែងធ្វើទៀ ព្រោះខ្លាចគេរិះគន់
ប៉ុណ្ណោះ មានសេចក្តីខ្ជិលច្រអូសធុញច្រាន់ច្រែន ពុំបានជួយចាត់
ចែងការជាកុសលម៉ាំមួនឡើយ ធ្វើដោយអសង្ខារិកមហាកុសលចិត្ត
ចំនួន ២ គឺកុសលចិត្តលេខ ៣ ដែលប្រកបដោយសោមនស្សវេទនា ជា
ញាណវិប្បយុត្តអសង្ខារិក ១ កុសលចិត្តលេខ ៧ ដែលប្រកបដោយឧបេក្ខា
វេទនា ជាញាណវិប្បយុត្តអសង្ខារិក ១ ត្រូវជា ២ ជាកុសលចិត្តកើត
ឡើងដោយខ្លួនឯង ឥតមានអ្នកជំរុញដំកន់ឡើយ លុះបានធ្វើបុណ្យ
ឲ្យទានរួចហើយមានវិប្បដិសារី ក្តៅក្រហាយជាខាងក្រោយពុំមានសេចក្តី
ប្រុះថ្លារីករាយឡើយ ក៏អំពើបុណ្យទានដែលបុគ្គលបានធ្វើដោយអសង្ខា-
រិកកុសលចិត្តចំនួន ២ មានកម្លាំងខ្សោយគេកយ៉ាំងនេះនឹងត្រឡប់ឲ្យផល
ជាអហេតុកកំណើតវិញគឺ ឧបេក្ខាសហគតសន្តីរណអហេតុកវិបាកជា
គួបដំណើតាក់តែងនាមរូបថ្មី ឲ្យកើតឡើងក្នុងឋានមនុស្សនេះ មាន
កើតជាមនុស្សខ្វាក់ - ថ្លង់ - គគំពីកំណើតជារដើមក្នុងបដិសន្ធិកាល ហើយ
ញ៉ាំងអហេតុកកុសលវិបាកចំនួន ៨ ឲ្យ ៗ ផលក្នុងបវត្តិកាល បានល្មោះ

ជា ទ្វិហេតុទុមកៈ ទី ๑ ๗

អំពើដែលបុគ្គលបានធ្វើដោយកុសលចេតនាមួយ ក្នុងខណៈធ្វើបុណ្យឲ្យទានមួយលើក ๆ ក្នុងជាតិនេះ ជាបុគ្គលឥតមានសទ្ធាពុំបានដឿងកម្ម-ផល ពុំបានត្រេកអរជ្រះថ្លាក្នុងការជាកុសលប៉ុន្មានឡើយ ធ្វើដោយមានញាតិ - មិត្តសំឡាញ់ចូលមកនិយាយបបួលដឹកនាំឲ្យចូលធ្វើបុណ្យឲ្យទាន ក៏មានសេចក្តីខឿសពាល់ចូលធ្វើបុណ្យនឹងគេទៅ ហើយមានសេចក្តីឯលប្រអូសធុញច្រានច្រែន ពុំបានជួយចាត់ចែងការជាកុសលមាំមួនឡើយ ធ្វើដោយសសង្ខារកុសលចិត្តទាំង ๒ គឺកុសលចិត្តទី ๘ ដែលប្រកបដោយសោមនស្សវេទនា ជាញាណវិប្បយុត្ត-សសង្ខារក ๑ កុសលចិត្តទី៨ដែលប្រកបដោយឧបេក្ខាវេទនាជាញាណ-វិប្បយុត្តសសង្ខារក ๑ ត្រូវជា ๒ ជាកុសលចិត្តមានបុគ្គលដទៃចូលមកដឹកនាំទើបធ្វើ, លុះធ្វើបុណ្យឲ្យទានរួចហើយមានវិប្បដិសារៈ ក្តៅក្រហាយជាខាងក្រោយ ពុំមានសេចក្តីជ្រះថ្លារីករាយឡើយ, ក៏គំរើបុណ្យទានដែលបុគ្គលបានធ្វើដោយសសង្ខារកកុសលចិត្តទាំង ๒ មានកម្លាំងខ្សោយពេកយ៉ាងនេះនឹងត្រឡប់ឲ្យផលជាអហេតុកកំណើតវិញ គឺ ឧបេក្ខាសហ-គតសន្ធិណាអហេតុកវិបាកជាតួបដិសន្ធិតាក់តែងនាមរូបថ្មី ឲ្យកើតឡើង

ក្នុងឋានមនុស្សនេះ ក្នុងបដិសន្ធិកាល, ហើយញុំងអហេតុកកុសលចិត្តទាំង ៨ ឲ្យ ។ ផលក្នុងបវត្តិកាល ឋានឈ្មោះថា ទ្វិហេតុទមក: ទី ២ ។ សំដែងចំណែកខាងកាមាវចរកុសលកម្ម អំពើដែលបុគ្គលធ្វើដោយកាមាវចរកុសលចិត្តប្រព្រឹត្តទៅដោយទ្វារទាំង ៣ មានកាយទ្វារជាដើម ចប់ដោយសង្ខេប ។

ឯបុថុជ្ជនាវចរកុសលកម្ម អំពើដែលយោគាវចរកុលបុត្រទំហាក់ចិត្តចំរើនសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ដោយការនាប្រព្រឹត្តទៅក្នុងមនោទ្វារនោះ លោកសំដែងចែកជា ៣ យ៉ាង គឺ ប្បរិត្ត យ៉ាងតិចស្តើង ១ មជ្ឈិម យ៉ាងមធ្យមជាកណ្តាល ១ បណីត យ៉ាងឧត្តមខ្ពង់ខ្ពស់ ១; សេចក្តីថា បើយោគាវចរកុលបុត្រចំរើនបានឧបចារជ្ឈានយ៉ាងតិចស្តើងប្រកបទៅកើតក្នុងជាន់ព្រហ្មបារិសជ្ជា, យ៉ាងមធ្យមជាកណ្តាលប្រកបទៅកើតក្នុងជាន់ព្រហ្មបុរោហិតា, យ៉ាងឧត្តមខ្ពង់ខ្ពស់ប្រកបទៅកើតក្នុងជាន់មហាព្រហ្ម, កើតតាមលំដាប់ឈានជាន់ខាង-កណ្តាល-ខ្ពង់ខ្ពស់ គ្រប់ឋានព្រហ្មទាំង ១០ ជាន់ រៀរលែងតែអសញ្ញីសត្វនិងសុទ្ធាវាសភូមិទាំង ៥ ជាន់ចេញ ។ ចំណែកឯអបុថុជ្ជនាវចរកុសលកម្ម គឺអំពើដែលយោគាវចរកុលបុត្រឋានចំរើនឋានអរូបជ្ឈានទាំង ៤ ហើយ និងប្រកបទៅ

កើតក្នុងហានអរូបព្រហ្មទាំង ๔ ជាន់តាមលំដាប់ឈាន ដោយពិត ๆ ចំណែកឯព្រះអនាគាមីបុគ្គលទាំង ๕ ពួក ដែលលោកបានចំរើនបញ្ចមជ្ឈានកើតខ្ពស់ហើយ តែលោកឬតភៀតឯកើតក្នុងសុទ្ធាវាសភូមិទាំង ๕ ជាន់ដោយចំណែកមួយពិត ๆ បពិត្រធម្មាធិបតីទ្ធី ខ្ញុំអត្តាធិបានវិសជ្ជនាមកអំពីទុក្ខដកម្មនិងទុមកកម្ម អំពើដែលបុគ្គលបានធ្វើយ៉ាងទុត្តមន្តដ៏ខ្ពស់និងអំពើដែលបុគ្គលបានធ្វើយ៉ាងជាន់ទាបថយថោក, តែងឲ្យផលផ្សេង ៗ គ្នាជាសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

๙๖-ធម្មាធិទ្ធី បានស្តាប់ហើយសួរតទៅទៀតថា ម្នាលអត្តាធិបុះចំណែកខាងលោកុត្តរធម៌ ๙ ដែលមានឈ្មោះថា ព្រះនិព្វាន ๑ នោះសម្តែងដោយសភាវៈមាន ๑ សំដែងដោយហេតុមាន ๒ សម្តែងដោយអាការៈមាន ๓ មានសេចក្តីផ្សេងគ្នាដូចម្តេច ខ្ញុំ? បពិត្រលោកវិសជ្ជនាឲ្យតិស្តាសេតុត្រប់មកយើងខ្ញុំនឹងបានស្តាប់ចូលចិត្តផងមើល !

អត្តាធិទ្ធី វិសជ្ជនាតបថា បពិត្រធម្មាធិទ្ធី ๑ ព្រះនិព្វានសម្តែងដោយសភាវៈមាន ๑ នោះអធិប្បាយថា មគ្គញ្ញាណ ត្រាស់ដឹងច្បាស់នូវព្រះនិព្វានកើតរលត់ប្រព្រឹត្តទៅជាមួយនឹងមគ្គទាំង ๔ ឯណា ផលញ្ញាណ ត្រាស់ដឹងច្បាស់នូវព្រះនិព្វានកើតរលត់ប្រព្រឹត្តទៅជាមួយនឹង

ផលចំនួន ៤ ឯណា មគ្គញ្ញាណផលញ្ញាណចំនួនពីរនោះ ។ តែដូច
ហើរជ្រុលទៅជ្រកសិប់ស្មូនក្នុងសន្តិលក្ខណាដ្ឋាន ទីកន្លែងដែលស្ងប់រម្ងាប់
ចាកកងទុក្ខចំនួនជាលក្ខណៈរបស់ផលញ្ញាណ ហើយចាប់ថ្កត់តោងជាប់នូវសន្តិលក្ខណាដ្ឋានរបស់ខ្លួននោះមកជាអារម្មណ៍ ជាទីត្រេកអរពុំដាច់ ឬថា មគ្គញ្ញាណនិងផលញ្ញាណចូលទៅចាកព្រៃតិកណ្ឌា ១០៨ ទំព័រ ៦៤ មាន: ៩ ជាស្រេច តុំចូលជាប់ជំពាក់សោះឡើយ ឬថា ផលញ្ញាណរំលត់រលាស់គាត់ចាលទៅចូលព្រៃសព្វាត តិ តណ្ហា . ទំព័រ- មាន: ជាស្រេចតុំចូលឲ្យសេសសល់ឡើយ ចូលឈ្មោះថា ព្រះនិព្វានតិត ។ មួយវិញទៀត សម្តេចព្រះសព្វញ្ញុសម្ពុទ្ធជាអម្ចាស់ទ្រង់ត្រាស់សម្តែងសរសើរថា ប្រពុំ ចំណែកបរមត្ថធម៌ដ៏ខ្ពង់ខ្ពស់ប្រសើរឯក ប្លែកជាងលោកិយធម៌ទាំងអស់ អ្នកប្លុំ មានគុណវិសេសជាងទីកន្លែងមាំមួននៅពុំចូលកក្រើកឃ្លាតចេញតើមិនចូលស្ងាប់សោះ អ្នកប្លុំ មានគុណគួរប្រព្រឹត្តកន្លងបង់នូវទីបំផុត ចាកកិលេសជាតិទាំងអស់មានពន: ដើមជាស្រេច អ្នសំខ្លាំ ជាគុណជាតតិមច្ចយប្រជុំគាក់តែងពុំចូលឡើយ អ្នធ្លាំ រកតែជាទៃប្រសើរលើសលុបពុំមាន ធ្ងៃធំ ព្រះអង្គទ្រង់ផ្សា

ឈ្មោះថា ព្រះនិព្វានដោយពិត ។ ទី ២- សម្តែងដោយហេតុមាន ២ នោះ
គឺ សឧប្បាទិសេសានិញ្ជនជាតុ ព្រះនិព្វានជាតុដែលប្រព្រឹត្តទៅ
ជាមួយនឹងបញ្ចក្ខន្ធជាគ្រឿងសៅហ្មង តិតណ្ហា · ទិដ្ឋ · មាន: តែងប្រកាន់
មាំដ៏សល់នៅដោយកិរិយាធ្វើឲ្យជាអារម្មណ៍ ១ អនុប្បាទិសេសានិ-
ញ្ជនជាតុ ព្រះនិព្វានជាតុដែលប្រព្រឹត្តទៅជាមួយនឹងបញ្ចក្ខន្ធជាគ្រឿង
សៅហ្មងដែលតណ្ហា - ទិដ្ឋ - មាន: តែងប្រកាន់មាំសល់នៅពុំមានសោះ
ឡើយ. គឺថាព្រះទើណាស្រេចដែលលោកបានលះកន្ធទាំង ៥ ចាំដែលជា
គ្រឿងប្រកាន់មាំនៃតណ្ហា - ទិដ្ឋ - មាន:ឲ្យសូន្យអស់ពុំឲ្យមានសេសសល់
ឡើយ ហើយលោកចូលកាន់ព្រះនិព្វាន ១ ។ ទី ៣- សម្តែងដោយ
អាការ:មាន ៣ នោះគឺ ១ - សុន្ទរដ្ឋាន ទីតាំងយាំងល្អប្រពៃជាឋាន
សូន្យស្ងាត់ ចាកសម្បយោគធម៌ ដែលជាគ្រឿងប្រកបព្រមនៃកង
កិលេសតើតឡើងជាអារម្មណ៍ផង សូន្យស្ងាត់ចាកពន: ទោស: មោហ:
ទាំង ៣ យ៉ាងផង សូន្យស្ងាត់ចាកសង្ខារធម៌ទាំង ៣ យ៉ាងផង ឋាននេះឈ្មោះថា
សុញ្ញតនិព្វានពិត ។ ២ - សុន្ទរដ្ឋាន ទីតាំងយាំងល្អប្រពៃប្រាសចេញ
ចាកនិមិត្ត គឺថាពន: ទោស: មោហ: ទាំងសង្ខារធម៌ទាំង ៣ យ៉ាងជានិមិត្ត
តាក់តែងនាមរូបថ្មីឲ្យកើតទៀតពុំបានឡើយ ឋាននេះឈ្មោះថា អនិមិត-

និព្វានតិត ៧ ៣ - សុន្ទរវាន ទីតាំងយ៉ាងល្អប្រៀពវតទីតាំង
ទីជំកល់នៃពត: ទោស: មោហ: និង តណ្ហា - ទិដ្ឋ - មាន: សោះឡើយ
ជាសិវាន ជាឋានដ៏ខ្ពង់ខ្ពស់សម្រាប់សោយសុខក្សេមក្សាន្តជាយូចំណែក
មួយតិត ឋានឈ្មោះថាអប្បណិហិតនិព្វានតិត ៧ មួយទៀត តាមន័យ
ក្នុងព្រះសូត្រលោកសង្គីតសរសើរគុណនាមព្រះនិព្វានមាន ៨ យ៉ាង
គឺ: មទ្ទនិមទ្ទនដ្ឋានំ ទីឋានដែលញាំញីលំអិតនូវគ្រឿងស្រវឹង គឺ:
រាយ: អរោគ: ជីវិត: ជាដើមឲ្យវិនាសអស់ទៅជាស្រឡះ ១, បិបាសវិនា-
យដ្ឋានំ ទីឋានសម្រាប់ឋានូ្ឋបង់នូវសេចក្តីសម្រេកស្រេកឃ្លានក្នុងតាម-
គុណទាំងច្រុំជាស្រឡះ ១, អាលយសមុគ្ឃាតដ្ឋានំ ទីឋានសម្រាប់
ដកតាស់រំលើងឡើង នូវសេចក្តីតណ្ហាជំពាក់ជាប់នៅក្នុងតាមគុណទាំង
ច្រុំជាស្រឡះ ១, វដ្តុប្បច្ឆេទដ្ឋានំ ទីឋានសម្រាប់កាត់ផ្តាច់ផ្តង់នូវចក្រ
វដ្តវិលត្រឡប់ទៅមកក្នុងតតទាំង ៣ ជាស្រឡះ ១, តណ្ហាក្ខយដ្ឋានំ
ទីឋានសម្រាប់ក្សយអស់នៅនៃតណ្ហាទាំងអស់ជាស្រឡះ ១, វិរាគដ្ឋានំ
ទីឋានសម្រាប់ដល់នូវសេចក្តីខ្សឿយណាយ ចាកតណ្ហាទាំងអស់ជាស្រឡះ
១, និរោធដ្ឋានំ ទីឋានសម្រាប់រលត់ឋានូ្ឋនូវកងទុក្ខទាំងអស់ដែលប្រជុំកើត

ខ្សែដ៏អំពីតណ្ហាជាស្រឡះ ១; ឆិន្នាឆិន្នាំ ទីហានសម្រាប់បញ្ជាក់ពីកាលបរមេសគឺ: តណ្ហាជាស្រឡះ ១, កំពីរនៃឆន្ទៈទាំងអស់ ៨ ហានេះបានឈ្មោះថា ព្រះនិព្វានដោយពិត ។ រីសជ្ឈនាមកអំពីរឿងព្រះនិព្វាន មាន ១ ២-៣ ជាសេចក្តីពិស្តារខ្លះ សង្ខេបខ្លះ តែប៉ុណ្ណោះឯង ។

๔๓- ធម្មវិទូ បានស្តាប់ហើយសួរគេទៀតថា ម្នាលអត្តវាទី បុរេទីហានព្រះនិព្វាននោះបាននៅក្នុងហានមនុស្សឬហានទេវតាហានព្រហ្ម ឬព្រះនិព្វាននោះបានដាច់ពីហានទាំងនេះទៅឬជួបម្តេច ? ចូរលោកវីសជ្ឈនាឲ្យច្បាស់លាស់មក យើងនឹងស្តាប់ចូលចិត្តអស់សង្ឃឹមដែរមែល !

អត្តវាទី វីសជ្ឈនាតបថា បពិត្រធម្មវាទី ឯទីហានព្រះនិព្វាននោះបាននៅក្នុងលោកទាំង ៣ ឬថាក្នុងភពទាំង ៣ ក៏មាន បាននៅក្នុងទីបំផុតលោកទាំង ៣ ឬថាទីបំផុតភពទាំង ៣ ក៏មាន, ព្រោះព្រះនិព្វាននោះមានឈ្មោះ ៤ យ៉ាង គឺ ១ កិលេសនិព្វាន ជានាងព្រះអរិយបុគ្គលទាំង ៨ ពួក ដែលលោកជានពិចារណាឃើញនូវទោសក្នុងលោកឬភពទាំង ៣ ជាក់ច្បាស់ហើយទំព្យាយាមចំរើនកាន្តាសមថកម្មដ្ឋាន ឬវិបស្សនាកម្មដ្ឋាន ហើយជានយកនូវចិត្តជាកាន-

វិបរក្តី រួចាវិបរក្តី អរួចាវិបរក្តី ឲ្យបែរជាកម្មកាន់ត្រអែរយោគត្រ
កើតរលត់ត្រមជាមួយនឹងមគ្គផលប្រកបដោយអង្គ៨ មានសម្មាទិដ្ឋិ
ជាដើម ចានឈ្មោះថា សោតាបត្តិមគ្គចិត្ត ហៅថា លោកុត្តរកុសល-
ចិត្តទី១, វិចាកជាផលកើតមកអំពីលោកុត្តរកុសលចិត្តទី.១ នោះ ចាន
ឈ្មោះថា សោតាបត្តិផលចិត្ត ហៅថា លោកុត្តរវិចាកចិត្តទី២, ក៏ព្រះ
អរិយបុគ្គលដែលលោកចានសម្រេចមគ្គ-ផលតាំងពីសោតាបត្តិមគ្គជាដើម
ទៅនិងទៅជាលំដាប់ៗ ហើយលោកលះបង់នូវកិលេសតាំងពួង តាំង
ពីកងកិលេសយ៉ាងគួចតិចជាលំដាប់ទៅនិងទៅ, លុះដល់លោកចាន
សម្រេចត្រអរហត្តផលញ្ញាណគេញ្ញាទី ទើបលោកអាចកាត់ផ្តាច់
នូវកងកិលេសតាំងឡាយ ដោយសម្បុច្ចេទប្បហានអស់ពុំមានសេស-
សល់ក្នុងសន្តានលោកឡើយ, ចានឈ្មោះថា កិលេសនិព្វាន រំលត់
កិលេសអស់ជាអង្គព្រះនិណាស្រេចពិត បិតនៅក្នុងលោកនេះ-ភពនេះ
ព្រោះអាយុសង្ខារបស់លោកពុំទាន់អស់នៅឡើយ បើលោកចាន
សម្រេចកិលេសនិព្វាននាហានមនុស្ស ក៏លោកបិតនៅក្នុងហានមនុស្សដែរ
បើលោកចានសម្រេចកិលេសនិព្វាននាហានសួគ៌ ឬហានព្រហ្ម ក៏លោក
បិតនៅក្នុងហានសួគ៌ ឬហានព្រហ្មនោះដែរ, តាមកំណត់អាយុសង្ខារបស់

លោកដោយពិត ។ ๒ ។ ឧទ្ធច្ចនិព្វាន ចានន័យថា ព្រះឧណាស្រេច
ដល់លោកមានអាយុសង្ខារដល់កំណត់អស់ហើយ។ លោកលះឧទ្ធច្ចាំង
ច្រាំងលោភៈអស់ពុំមានសេសសល់ឡើយ, នៅមានតែផលញាណ
ជាថ្នាស្អាតបរិសុទ្ធក្នុងសន្តានរឿង ជាសារធម៌ដ៏មានទ្វីមសារស្អិតវិសេស
ក្រៃលែង ចូរគាន់មហាជនតែកែ គឺព្រះនិព្វាន មានផលជានៃសោយទូ
សនៃព្រះនិព្វានជាអារម្មណ៍ ជាអព្យាកតធម៌ ជាសុខក្សេមក្សាន្តពុំបាន
លាយប្រឡំទៅដោយកងទុក្ខឡើយ, ចានឈ្មោះថាឧទ្ធច្ចនិព្វាន បានន័យក៏
ខ្ពស់បំផុតលោកបំផុតកត ដោយចំណែកតែមួយពិត. ។

វិសជ្ជនាមកអំពីខ្លឹមព្រះនិព្វានបានន័យក៏ខ្ពស់លោត - កន្លងកតនឹងបាត
នន័យក៏ខ្ពស់បំផុតលោក - បំផុតកត ដោយសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

๙๘ - ធម្មវិទូ ចានស្តាប់ហើយសួរទៀតថា: ម្នាលអត្ថវិទូ
ពុះពាក្យថា ខ្ពស់បំផុតលោកមាន ๓ នឹងខ្ពស់បំផុតកតមាន ๓ សេចក្តីដូច
គ្នាទេ ឬផ្សេងគ្នាយ៉ាងណាខ្លះ? ចូរលោកវិសជ្ជនាមកយើងនឹងចាន
ស្តាប់ផងមើល!

អត្ថវិទូ វិសជ្ជនាតបថា បពិត្រធម្មវិទូ ឯពាក្យថា ខ្ពស់បំផុត
លោកមាន ๓ នឹងខ្ពស់បំផុតកតមាន ๓ នោះ មានអត្ថសដូចគ្នាខ្លះ ផ្សេង

ត្រង់ៈ ដូចអធិប្បាយតទៅនេះ។ កំពីរបំផុតលោក-ចំផុតកំពែកជា៣ យ៉ាង
គឺ តាមភូមិតាំង ១១ ជាន់ ពប់តាំងពីហានន១កន្ទី ១ ជរាបទៅដល់ហាន
បរនិម្មិតវសវត្តីទី ១១ ត្រូវជា ១១ ជាន់ ហានឈ្មោះថា ពីរបំផុតកាម-
លោក តាមកំពស់ ១ ជាខាងក្រោម រូបភូមិតាំង ១៦ ជាន់ ពប់តាំង
ពីហានព្រហ្មបារិសជ្ជាទី ១ ជរាបទៅដល់ហានអកនិដ្ឋព្រហ្មទី ១៦ ត្រូវជា
១៦ ជាន់ ហានឈ្មោះថា ពីរបំផុតរូបលោក-រូបកំពស់ ៤ ជាកណ្តាល ។
អរូបភូមិតាំង ៤ ជាន់ ពប់តាំងពីហានអាកាសានញ្ចាយតនអរូបព្រហ្មទី ១
ជរាបទៅដល់ហាននេវសញ្ញានាសញ្ញាយតនអរូបព្រហ្ម ទី ៤ ត្រូវជា ៤
ជាន់ ហានឈ្មោះថា ពីរបំផុតអរូបលោក ។ អរូបកំពស់ ៣ ជាខាង
លើបំផុតគ្មានលោតគ្មានកំពស់ទៀតឡើយ ។ កំពាក្យថា ពីរបំផុត
លោកមាន ៣ សេចក្តីអធិប្បាយដូចគ្នាពិត, ប៉ុន្តែគួរតែត្រង់លោកស័ព្ទ
ខ្ញុំឯកវិស័ព្ទមានអត្ថរសផ្សេងគ្នាដូច្នេះ លោកស័ព្ទ ប្រែថា កើតឡើង
ហើយតែងវិនាសរលាយទៅវិញ ឬថាលិចអស្តង្គត។ គ្មានទៀង
ទេរៈឡើយ, កវិស័ព្ទ ប្រែថា ញុំាងនាមរូបឲ្យកើតឡើង គឺថាអំពើ
ដែលសត្វតាំងខ្លួយបានធ្វើល្អក្តី អាក្រក់ក្តី ដោយចេតនាឯណា,
ចេតនានោះកើតជា ជនកកម្ម ញុំាងផលរបស់ខ្លួនឲ្យតាក់តែងនាមរូបឲ្យ

តើតទៅដ៏កន្លងហាននោះៗ ឋាននឈ្មោះថា តតិយកម្មភព ដោយពិត ។

វិសជ្ជនាមកអំពីតាក្យថា លោក ៣ ភព ៣ ដោយសេចក្តីសង្ខេបតែប៉ុណ្ណេះឯង ។

๙๙- ធម្មរាជ៏ ឋានស្តាប់ហើយសួរតទៅទៀតថា: ម្នាលអគ្គវាទី ចុះទីបំផុត លោក-បំផុតភព មាន ៣ នោះ តើឋានព្រះនិព្វាន ឋិតនៅកន្លែងបំផុត លោក-បំផុតភពណា ? មានចម្ងាយអំពីឋានមនុស្សប៉ុន្មាន ? វាស់ឋានដែរឬទេ ? បើវាស់តុំឋានទេ តើមានសេចក្តីឧបមាដូចម្តេច ? ចូរលោកវិសជ្ជនាឲ្យច្បាស់លាស់មក យើងនឹងស្តាប់ចូលចិត្តឋានជ្រះថ្លាយ៉ាងក្រៃលែង !

អគ្គវាទី វិសជ្ជនាតបថា: មតិត្រង់ម្ចាស់ អ្នកប្រាជ្ញទាំងឡាយ លោកតែងសម្តែងប្រាប់តៗស្រេចថា លោកធ្លុំ និព្វានំ ភវធ្លុំ និព្វានំ សេចក្តីថា ព្រះនិព្វានឋិតនៅកន្លែងបំផុតលោក បំផុតភព ទី ៣ ដាច់ឆ្ងាយលើឋានទេវសញ្ញានាសញ្ញាយតនអរូបព្រហ្មទី ៤, ដូចមានឋាលីបទវិគ្គហ:កន្លងជាតអនុជាតព្រះអភិធម្មត្ថសង្គហ:ជាដើមថា: " កាមរូបារូបសំខាត. លោកតោ ខុត្តរតិ គតោ វិ សត្តេ ទុទ្ធំ និព្វានំ តារេតីតិ

លោកុត្តរំ" សេចក្តីថា អគ្គមគ្គញ្ញាណឯណា ចានធ្វើនផុត ចាកកាម
លោក-រូបលោក-អរូបលោក ជាស្រេឡះអគ្គមគ្គញ្ញាណនោះចានឈ្មោះថា
លោកុត្តរៈធ្វើនផុតចាកលោកទាំង ៣ ជាស្រេឡះពិត, ម្យ៉ាងទៀតទៅ អគ្គ-
ផលញ្ញាណឯណា ញ៉ាំងសត្វទាំងឡាយឲ្យធ្វើនផុតទៅ កាន់ហានព្រះនិព្វាន
ជាទានលើចំផុត ចាកលោកទាំង ៣ ជាស្រេឡះ អគ្គផលញ្ញាណនោះចាន
ឈ្មោះថា លោកុត្តរៈ ញ៉ាំងសត្វទាំងឡាយឲ្យធ្វើនផុតទៅកាន់ហាននិព្វាន
ជាទានលើចាកលោកទាំង ៣ ជាស្រេឡះពិត ។ ចានសេចក្តីថា ហានព្រះ
និព្វាននោះ ស្ថិតនៅកន្លែចំផុតលោកទាំង ៣ ដ៏ធ្ងាយក្រៃលែងណាស់អំពី
ហានមនុស្សលោកយើងនេះ រាស់កប់យោជនពុំចានស្មានតីពុំត្រូវឡើយ,
តែថាចានសេចក្តីផ្សៃទុបមាកន្លងគម្ពីរលោកចំបកកថា លោកចានសម្តែង
ផ្សៃចពន្យល់ ល្មមស្តាប់ចានដោយចាលំទុបមាថា សព្វភារៈត្តេ បិត្វាន
ភារំ នាទាយ នាវហេ តណ្ហាន វិស្សហិ ទ្វីមាសេហិ
ប អដ្ឋហិ រតិន្ទិវេហិ អរហត្តំ ។ល។ ដាវិន្ទ តីហិ វិស្សេហិ ទ្វេ-
មាសដ្ឋទិនេហិ តុ បត្តុំសតិនាទីហិ ភូមិតលមុបាបុណិ ។
អធិប្បាយថា ផែនដីយាងធំប៉ុនផ្ទះកំពូលផែលខេវតាវិសេស ចានមហិទ្ធានុ-
ភាពប្រើន បិតនៅកន្លែចំផុតភពហើយលើកឡើងទ្រាំកំប៉ុះមកកាន់ហាន

មនុស្សលោកយើងនេះភ្លាត់មកយ៉ាងរហ័សអស់កាលយូរបំផុត ៣ ខ្នាំ ២ ខែ ក្រៃលែងដោយយប់នឹងថ្ងៃ ៨ ថែមទៀត ។ល។ លុះដល់ផែនថ្មនោះ ភ្លាត់ចុះមកជាយូរអង្វែងណាស់ ចំនួន ៣ ខ្នាំ ២ ខែ ៨ ថ្ងៃ ២៤ នាទី ទើបដល់ផ្ទៃនៃផែនដីមនុស្សលោកយើងនេះ គ្រាន់តែស៊ីកដោយខ្សល់សល់នៅប៉ុនផ្ទៃក្រួចស៊ើចប៉ុណ្ណោះ ឃើញថាភ្លាយណាស់ ឧបមាយ៉ាងណា ទីឋានព្រះនិព្វានដែលបិតនៅក្នុងទីបំផុតកតកំភ្លាយណាស់ ឧបមាយ៉ាងនោះដែរ ។ រីសជ្ឈនាមកអំពីឋានព្រះនិព្វាន បិតនៅក្នុងទីបំផុតលោកបំផុតកត នឹងសេចក្តីឧបមា ដោយសង្ខេបតែប៉ុណ្ណេះឯង ។

១០០- ធម្មវិទី ឋានស្តាប់ហើយពោលថា: អើអត្ថាទី បើឋានព្រះនិព្វាន បិតនៅក្នុងទីភ្លាយគេកយ៉ាងនេះ តើព្រះទីណាស្រុតដែលលោកលែងខ្លាំងជ្រុំជាស្រឡះហើយ ទៀងទៅកាន់ឋានព្រះនិព្វានចំនួនប៉ុន្មានខ្នាំ-ខែ ថ្ងៃទៅ ទើបដល់ឋានព្រះនិព្វាន ឬទៅដល់មួយរំពេចទេ? ចូរលោកវីសជ្ឈនាមកយើងនឹងឋានស្តាប់ចូលចិត្តផងមើល!

អត្ថវិទី វីសជ្ឈនាតបថា បពិត្រធម្មាទី ឋានព្រះនិព្វាននៅឆ្ងាយពិតមែនហើយ តែថាព្រះទីណាស្រុតដែលលោកឋានលែងខ្លាំងចូលកាន់ឋានព្រះនិព្វានមិនយឺតយូរទេ ដល់មួយរំពេច ព្រោះព្រះទីណាស្រុត

ចាំងអស់លោកមានផលញាណ ទន្ទហូរជ្រួលទៅជ្រកសិប់សួនកន្លឹ
ព្រះនិព្វាន ចាប់ផ្តក់តោងយកព្រះនិព្វានមកជាអារម្មណ៍ជាប់ជាន់ខ្ជួ តែ
លោកបានរំលត់ខន្ធចាំងជ្រុំជាស្រឡះហើយ លោកចូលកាន់ឋានព្រះនិព្វាន
មួយរំពេច តុំបានយឺតយូរឡើយ ដូចបុរសឈរលើកាំជណ្តើរទាំងលើ
បំផុត តែឈានដើងឡើងផុតពីកាំជណ្តើរហើយ បានឈ្មោះថា បុរស
នោះចូលកន្លឹជ្រុំសាទសិប់សួនមួយរំពេចពិត មានឧបមាយ៉ាងណា ព្រះ
ខីណាស្រពចាំងអស់ តែរលោកបានរំលត់ខន្ធចាំងជ្រុំជាស្រឡះហើយ
លោកចូលកាន់ជ្រុំសាទតែវ គឺឋានព្រះនិព្វានមួយរំពេចពិត មានឧប-
មេយ្យដូច្នោះឯង ។ មួយវិញទៀត បុគ្គលដែលមានជម្ងឺឈឺជា
ខ្លាំនដ៏តស្លាប់ បើជាវេទនាទន្ទហូរជ្រួលទៅជ្រកសិប់សួនកន្លឹកពណ្ណ តែ
ប្រតទៅហើយកើតឡើងកន្លឹកតនោះមួយរំពេច តុំបានយឺតយូរឡើយ
មានឧបមាយ៉ាងណា ព្រះអរហន្តចាំងឡាយ លោកតែងមានផល-
ញាណទន្ទហូរជ្រួលទៅជ្រកសិប់សួនកន្លឹព្រះនិព្វានជាអារម្មណ៍ ជាប់
មិនជាប់ តែរលោកបានរំលត់ខន្ធចាំងជ្រុំជាស្រឡះហើយ លោក
កើតឡើងកន្លឹមហានគរគឺព្រះនិព្វានមួយរំពេចតុំបានយឺតយូរឡើយ មាន
ឧបមេយ្យយ៉ាងនោះឯង ។ វិសជ្ជនាមកអំពីព្រះខីណាស្រពរំលត់ខន្ធ

ចូលកាន់ព្រះនិព្វានយ៉ូរឆាប់ ដោយសេចក្តីសង្វេបតែប៉ុណ្ណោះឯង ។

๑๐๑ - ធម្មវាទី . បានស្តាប់ហើយសួរគេថៅខ្ញុំតថា ម្នាលអគ្គវាទី បុគ្គលថា មហានគរ គឺព្រះនិព្វាន និងពាក្យថា មហានគរក្នុងលោកយេនេះ គ្រឿងប្រដាប់សម្រាប់លំអក្នុងមហានគរទាំងពីរនេះ មានផ្សេងគ្នា ឬដូចគ្នាទេ? ធម្មតាមហានគរក្នុងលោកនេះតែងមានគ្រឿងប្រដាប់សម្រាប់លំអព្រះនគរ មានផ្លូវថ្នល់តូច - ធំ ខ្វាត់ខ្វែងជាដើមជាទីលំអព្រះនគរ, បុគ្គលថាមហានគរគឺព្រះនិព្វាន មានគ្រឿងប្រដាប់សម្រាប់លំអព្រះនិព្វានដូចគ្នាដែរ ឬផ្សេងគ្នាដូចម្តេចខ្លះ? ចូរលោកវិសជ្ជនាមកយើងនឹងបានស្តាប់ចូលចិត្តផងមើល !

អគ្គវាទី វិសជ្ជនាតបថា : បពិត្រធម្មវាទី ព្រះមហានគរគឺព្រះនិព្វាន និងមហានគរក្នុងលោកយេនេះ មានគ្រឿងប្រដាប់សម្រាប់លំអដ៏រុងរឿងវិសេសវិសាលដូចគ្នាដែរ តែថាអត្ថន័យសេចក្តីគ្នា ដូចមានក្នុងគម្ពីរនិព្វានសូត្រ អធិប្បាយថៅនេះថា លោកយមហានគរក្រុងដែលធំទូលាយជាលោកយ មានរបូបមិ គឺ ๔ ចាតុទ្វីបនិងអនុចាតុទ្វីប គឺរបូបមនុស្សទាំងឡាយនិងសត្វទាំងឡាយប្រែកុះករនិងផ្លូវថ្នល់តូច - ធំ ស្ពាន ប្រាសាទ រមាន ខាស ប្រាត់ កែវកងជាដើមគេញ្ញាសបរិបូណ៌

កើតដោយកំឡាំងសង្សារ ចេតនាភាក់ផែងឲ្យកើតឡើងជាទីលំអដ៏រុងរឿង
វិសេសផ្សេង ។ ក្នុងលោកយមហានគរ មានសេចក្តីឧបមាយ៉ាងណា
លោកុត្តរមហានគរក្រែងកែវ គឺព្រះនិព្វាន ដ៏ខ្ពស់ខ្ពស់ប្រសើរវិសេស
វិសាលធ្ងន់ផុតចាកលោកទាំង ៣ ជាស្រេច្បះ មានអរូបធម៌ជាបរមត្ថធម៌
ឥតរូបមានខ្លឹមសារដ៏ល្អឥតខ្ចោះ គឺផលញាណ ដោយសុខក្សេមក្សាន្ត
ចេតនាភាក់ផែងយកផលសីល ធ្វើជាកំពែង, យកផលបញ្ញា ធ្វើជាកូនទ្វារ, យកផលសមាធិ ធ្វើជាសើន, យកផលមេត្តា ធ្វើជាស្នាមក្លោះ, យក
ផលព្រះកម្មដ្ឋានទាំង ៤០ ធ្វើជាផ្លូវថ្នល់កែវខ្ចាត់ខ្ចែងជាក្រឡាចត្រង្គ,
យកផលពោធិបក្ខិយធម៌ទាំង ៣៧ ធ្វើជាពន្លឺរុះរាំ ៣៧, យកផល
សម្មប្បធានទាំង ៤ ធ្វើជាសសរ, យកផលព្រះអភិធម្មទាំង ៧ គម្ពីរ ធ្វើជា
ស្ទូងក្រាសាទកែវវិចិត្រ, យកផលខន្ធកម្មៈ ធ្វើជាទីជំរំណោក, យកផល
វិមុត្តិញាណ ធ្វើជាបល្ល័ង្ក, យកផលវិមុត្តិញាណទស្សនៈ ធ្វើជាប្រទីប
ផ្កាលាដ៏ភ្លឺរុងរឿងគ្រោងគ្រាត, យកផលភាវនា ធ្វើជាស្រះមង្គល-
ទោក្ខរណី, យកផលករុណា ធ្វើជាទឹកថ្លាស្អាតដ៏តេញចរបូណិ, យកផល
អង្គារសញ្ញាណទាំង ១៨ ធ្វើជាដីខ្សាច់តេត្រ, មានពួកភមរជាតិនិនហ្មឹង
សក្កណជាតិ គឺព្រះសង្ឃសម្ភទ្ធ ព្រះបច្ចេកពុទ្ធ ព្រះទីណាស្រពាំងខ្សាយ

តែងសេពគប់ដោយច្រើនជាទីបូ ជាគ្រឿងប្រដាប់សម្រាប់លំអដ៏ភ្លឺស្វាង រុងរឿងវិសេសផ្សេង ។ ក្នុងលោកុត្តរមហានគរក្រុងតែវដ៏ធំទូលាយបរិសុទ្ធ ធ្វើផុតចាកលោកទាំង ៣ គឺព្រះនិព្វាន មានសេចក្តីឧបមេយ្យដូចលោកិយ-មហានគរនោះឯង។ មួយទៀតព្រះអរហំសម្មាសម្ពុទ្ធទ្រង់សំដែងបុព្វាវិសជ្ជ-នាដោយព្រះអង្គឯងថា ពោធត្តែធ ធំញ្ជំ បវ្ជ្ជតិ សុន្ទរដ្ឋានដែលតថាគតនោលឲ្យឈ្មោះថាព្រះនិព្វានដោយអត្ថសូចម្តេច? ហើយវិសជ្ជ-នាដោយព្រះអង្គឯង សីតលនត្តែធ បង្អោ វិយ ធំញ្ជំ ។ល។ សុមោជនត្តែធ សុធម្មោ វិយធំញ្ជំ, ព្រះនិព្វានដូចជាព្រះបន្ទូ ដោយអត្ថសូចថាត្រជាក់សប្បាយ, ព្រះនិព្វានដូចជាព្រះអាទិត្យ ដោយ អត្ថសូចថា ញ៉ាំងកងកំលេសទាំងអស់ឲ្យរលត់សូន្យឲ្យសោះ ព្រះនិព្វានដូច ជាផែនដី ដោយអត្ថសូចថា ជាទីតាំងចំពោះនៃព្រះទឹណាស្រេតទាំងឡាយ, ព្រះនិព្វានដូចជាថ្មកែវ ដោយអត្ថសូចថា មិនចេះកក្រើកញាប់ញ័រដោយ កងកំលេស, ព្រះនិព្វានដូចជាមហាសមុទ្រសាគរ ដោយអត្ថសូចថា ញ៉ាំងនៃវិសេសទាំង ៣ គឺពុទ្ធរតន: ១ ធម្មរតន: ១ សង្ឃរតន: ១ ឲ្យ កើតឡើងត្រមក្នុងលោក, ព្រះនិព្វានដូចជាធម្មជ្រលក់ដែល ដោយអត្ថសូ ចថាជាទីប្រជុំត្រមដែលព្រះទឹណាស្រេត ទាំងឡាយមានព្រះសព្វញ្ញុសម្ពុ-

ជាដើមតែងសេពគប់, តែថាព្រះនិព្វានគោរជាផែនដីពិតមែន តំណែវែរ, ជាទឹកពិតមែនតំណែវែរ, ជាភ្លើងពិតមែនតំណែវែរ, ជាខ្យល់ពិតមែនតំណែវែរ, ព្រះនិព្វានគោះជាគុណជាតមិនត្រជាក់ពេកមិនក្តៅពេកឡើយ គឺចំណែកបរមត្ថធម៌យ៉ាងឯកដ៏ខ្ពង់ខ្ពស់ប្រសើរ ថ្វែកឥតគួមិនចេះចាស់ជាកមិនចេះឈឺចាប់មិនចេះស្លាប់កើត ជាសុខយ៉ាងល្អិតដ៏សំខាន់ស្ងប់រម្ងាប់ ចាកកងទុក្ខទាំងអស់ជាទីក្សេមក្សាន្តមិនបានប្រឡំជាមួយកងទុក្ខណាមួយឡើយ បានឈ្មោះថា មហានគរក្រុងកែវដ៏ប្រសើរ គឺព្រះនិព្វានជាយចំណែកនានែតមួយស្ថាននេះឯង ។ វិសជ្ជនាមកអំពីលោកុត្តរមហានគរនោះ លោកិយមហានគរ ជាយសេចក្តីសង្ខេបតែប៉ុណ្ណេះឯង ។

๑๐๒ - ធម្មរាជី បានស្តាប់ហើយពោលថា ម្នាលអគ្គទាទីលោកបាននិយាយមកនេះប្រពៃហើយ, តែថាយើងនៅមានសង្ស័យតទៅទៀត, ចុះផលញ្ញាណជារូបធម៌គ្មានរូប ជាធម៌ឯកតែមួយគ្មានគូខ្សោយសុខដូចម្តេចបាន ឬមានវេទនាសម្រាប់សោយសុខដែរឬដូចម្តេច? ពួកបុគ្គលជាប៉ុប្បជនច្រើនចូលចិត្តថា បើព្រះនិព្វានគ្មានរូបសោះទេ បានអ្វីសោយសុខ លុះតែមានរូបប្រុស ស្ត្រី ប្តីប្រពន្ធ កូនចៅ ទ្រព្យសម្បត្តិ ពេញបរិបូណ៌ជាដើម ទើបនឹងសោយសុខសប្បាយបាន បើព្រះនិព្វាន

មានតែផលញ្ញាណមួយគ្មានប្រយោជន៍សោះទេ ធំធំសោយសុខសប្បាយដូចម្តេចបាន? ចូរលោកវិសជ្ជនាប្រស្នានេះឲ្យប្លាស់ស្រឡះមក យើងនឹងបានស្តាប់ចូលចិត្តផងមើល!

អ្នកវិទ្យាទី វិសជ្ជនាតបថា បពិត្រធម្មាចរ្យ ផលញ្ញាណគ្មានប្រយោជន៍ឯក មានតែមួយវត្ថុកំពិតមែនហើយ តែថានឹងមានផលជាច្រើន ១ជាអញ្ញាតកតវេទនាយ៉ាងវិសេស ផ្សេងគំពីវេទនាជាលោកិយ.ចាំងអស់តែគំពីព្រះអរហត្តផលសម្រាប់សោយសុខក្សេមក្សាន្តដោយចំណែកមួយពិត។

ឯពួកបុគ្គលជាបុថុជ្ជនច្រើនចូលចិត្តថា បើព្រះនិព្វានគ្មានប្រយោជន៍សោះទេ បានអ្នកធំធំសោយសុខនោះ ព្រោះតែបុគ្គលជាបុថុជ្ជនតែងគ្រាស់ទៅដោយកងកិលេសមានអវិជ្ជាជាដើម តែងត្រូបសង្កត់បិទបាំងក្រាជាប់ឆ្អឹងភាន់ប្រឡំតាមួយ សំគាល់អនិដ្ឋារម្មណ៍ថាជាឥដ្ឋារម្មណ៍វិញ ចូលចិត្តតាប់ចិត្ត ស្រឡាញ់ពាក់ព័ន្ធមានប្រយោជន៍ជាដើម គឺបុរស ស្ត្រី មានប្តីប្រពន្ធកូនចៅធំធំទ្រព្យសម្បត្តិជាដើម ដែលព្រះអរិយបុគ្គលចាំងឡាយ លោកមិនក្រាថ្នាមិនស្រឡាញ់តាប់ចិត្តសោះ លោកបានពិចារណាឃើញទោសជាក់ប្លាស់ថា ជាគ្រឿងប្រជុំកងទុក្ខចាំងពួងឲ្យកើតខ្លឹងដោយពិត, ហើយបុគ្គលជាបុថុជ្ជននោះតាំងយកអនិដ្ឋារម្មណ៍

នោះមកជាឥដ្ឋារម្មណ៍ ចូលចិត្តស្រឡាញ់កប់អានគាប់ចិត្តនឹងបញ្ចកន្ធ
អានរូបក្ខន្ធជាដើមនោះថាជាសុខសប្បាយស្រួលល្អវិញ ព្រោះតែកង
កំលេសមានរវៃផ្សាងៗដើម បកគ្រប់សង្កត់សន្ធានខ្លួនឲ្យឆងឆិតសូន្យឈឹង
រវើរវាយកាន់ប្រឡំអារម្មណ៍មិនសមគួរតាមសភាពតែឡើយ ។ ចំណែក
ឯព្រះនិណាស្រេតទាំងឡាយលោកបានពិចារណាឃើញទោស ទុប្បាទ -
ធម៌ដាក់បញ្ចាស់ថា សត្វទាំងឡាយតែមានបញ្ចកន្ធមានរូបក្ខន្ធជាដើម
តើតែឡើងហើយ តែងប្រជុំសោយទុក្ខវេទនាជាខ្លួនយ៉ាងច្រើនបំផុត
ដ៏ទុក្ខតើតអំពីភស្ដុបំភ្លើមដ៏តែបានដោយលំបាកខ្លាំងផង ទុក្ខតើតអំពី
កំឡុងបំភ្លើមរក្សាខ្លួន នឹងបំភ្លើមរក្សាប្រពន្ធកូនទៀតជាដើម តុំពេញ
លេញផង, ទុក្ខតើតអំពីសេចក្ដីចាស់ជរាតែងចៀតបៀនឲ្យជាប់ជានិច្ចផង,
ទុក្ខតើតអំពីមានជម្ងឺឈឺចាប់ខ្លួនឯងនឹងប្រពន្ធកូនទៀតជាដើមផង, ទុក្ខ
តើតអំពីការត្រាត់ត្រាសគ្នានឹងស្លាប់ប្រពន្ធកូនទៀតជាដើមផង, ទុក្ខតើត
អំពីបុគ្គលពាលនឹងអ្នកដទៃបៀតបៀនឲ្យរបស់ខ្លួនជាដើមផង, ក៏ព្រះ
និណាស្រេតទាំងឡាយ លោកបានពិចារណាឃើញទោស ទុប្បាទធម៌
នេះជាក់ច្បាស់ហើយ ទើបលោកបានពិចារណាឃើញផលានិសង្ស
នៃទុប្បាទធម៌គឺធម៌ដែលពុំបានតើតបញ្ចកន្ធទៀតពុំបានស្លាប់រឿងជាធម៌មាន

ទ្វីមសារបរិសុទ្ធទំនងតំណល់ដទៀត តែអមតមហានិព្វានពិត, ហើយ
លោកមានទស្សហ៍ទំព្យាយាមប្រឹងប្រែងចំរើនភាវនាទូរសមថកម្មដ្ឋានពីន
វិបស្សនាកម្មដ្ឋានជាបថមសំបូនសម្រេច ព្រះអរហត្តផលញ្ញាណដោយពិត
លុះដល់តាយុសង្ខារបស់លោកអស់ហើយ ទើបលោកំលត់ខន្ធទាំងទ្រុំ
ជាលោកិយទ្រេះស្រឡះហើយលោកចូលកាន់ព្រះបរមនិព្វាន ជាសិវដ្ឋាន
បានសោយសុខក្សេមក្សាន្តមិនច្រឡំដោយភាងទុក្ខទាំងពួងឡើយ ។

វិសជ្ជនាមកអំពីសោយសុខក្នុងព្រះនិព្វានយ៉ាងណាក្តីមជាងសុខទាំងអស់
ជាលោកិយ ដោយសេចក្តីសង្ខេបតែប៉ុណ្ណេះឯង ។

๑๐๓- ជម្ពុរាជ្ញី បានស្តាប់ហើយសួរតទៅទៀតថា ម្នាល
អត្តវាទី បុព្រះនិព្វានបានឈ្មោះថាចិត្តដែរ ឬថាពុំបានឈ្មោះថាចិត្តទេ ?
បើពុំបានឈ្មោះថាចិត្តទេ បានឈ្មោះដទៃអំពីចិត្តវិញ តើអធិប្បាយ
ដូចម្តេចខ្លះ? បពិត្រលោកវិសជ្ជនាមកឲ្យសព្វគ្រប់យើងខ្ញុំបានស្តាប់ចូល-
ចិត្តផងមើល !

អ្នកវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ព្រះនិព្វាននោះកើតមក
អំពីចិត្តពិតមែន តែថាព្រះមេត្រូជាម្ចាស់ព្រះអង្គពុំបានត្រាស់សំដែង
ឲ្យឈ្មោះថាចិត្តឡើយ ព្រះអង្គទ្រង់ត្រាស់សំដែងឲ្យឈ្មោះថាផល-

ញាណមានឈ្មោះផ្សងអំពីចិត្តវិញដូចអធិប្បាយតទៅនេះ សេចក្តីថា ព្រះនិព្វានឱ្យកើតមកអំពីចិត្តកំពុងតែមានហើយ តែពុំបានឈ្មោះថាចិត្តទេ បានឈ្មោះថាផលញាណវិញ ព្រោះផ្លែកអំពីចិត្តជាលោកិយតែ, ចំណែកឯចិត្តជាលោកិយតែងលាយប្រឡំទៅដោយលោភៈ ទោសៈ មោហៈជាអកុសលខ្លះ លាយប្រឡំទៅដោយអលោភៈអទោសៈអមោហៈជាកុសលខ្លះ ជាចិត្តត្រូវតាសនៃទូវតាអម្មណ៍ល្អក៏យក តាអម្មណ៍តាក្រក់ក៏យកពុំបានរើសតាអម្មណ៍ទេ ឪថាបុណ្យក៏ធ្វើបាបក៏ធ្វើ ជាចិត្តអាប់អកតខ្លីស្មើដំរីសៅហ្មងដោយ ១បក្ខលេសទាំងឡាយ តែងបួលមកជ្រៀតជ្រែកអប់រំជាប់ជាទិច្ចដ៏ល្អក៏ពុំបានជ្រះថ្លាស្អាតផូរផង់ទេ បានឈ្មោះថាលោកិយចិត្តដ៏គ្រោតគ្រាត ព្រោះជំពាក់ដោយកិច្ចទាំង ១៦ ពុំទាន់បានធ្វើឲ្យសម្រេចស្រេច, ចំណែកឯព្រះនិព្វានកើតមកអំពីញាណដ៏ល្អិតផូរផង់ជាផលរបស់ព្រះអរហត្ត បានឈ្មោះថា ផលញាណប្រាជ្ញាដ៏ថ្លាស្អាតផូរផង់ ភ្លឺស្វាងរុងរឿងវិសេសបំផុត ប្លែកស្រឡះចាកកងកិលេសធម៌ទាំងអស់ពុំមានសេសសល់សោះ បានឈ្មោះថា ផលញាណវិញនឹងហៅថាចិត្តពុំបានទេ, ព្រោះព្រះអរិយបុគ្គលទាំងឡាយលោកបានសំចម្រាញ់ បណ្តេញចេញនូវគ្រឿងសៅហ្មងទាំងចិត្តរបស់លោក

ដោយមគ្គទាំង ៤ ក្នុងព្រះអរិយសច្ចទាំង ៤ ដោយកិច្ចបួន ។ គឺ៖
ខ ១- ព្រះអរិយបុគ្គលដែលលោកចាន់តិចារណាក្នុងព្រះអរិយសច្ចទាំង ៤ សម្រេចដោយកិច្ច ៤ គឺ បរិញ្ញាកិច្ច អំពើធ្វើកំណត់កត់សំគាល់ដឹងច្បាស់នូវកងទុក្ខសច្ច ១, បហានកិច្ច អំពើធ្វើឲ្យលះបង់នូវសមុទយសច្ច គឺ តណ្ហា ជាហេតុប្រជុំតាក់តែងកងទុក្ខទាំងពួងឲ្យកើតឡើង ១, សច្ឆិកិរិយា អំពើធ្វើឲ្យច្បាស់ជាក់ច្បាស់នូវនិរោធសច្ចដែលជាគ្រឿងរំលត់បង់នូវតណ្ហា ១ ភាវនាកិច្ច អំពើធ្វើឲ្យចម្រើនប្រែចំរើននូវមគ្គសច្ច ដែលជាផ្លូវដំណើរទៅកាន់ទីរំលត់នូវកងទុក្ខទាំងពួង ១ ហើយញុំាងកិច្ចទាំង ៤ ឲ្យសម្រេចស្រេចដោយសោតាបត្តិមគ្គចិត្តតែ ។
ខ ២ - ព្រះអរិយបុគ្គលដែលលោកចាន់តិចារណាក្នុងព្រះអរិយសច្ចទាំង ៤ សម្រេចដោយកិច្ចទាំង ៤ ដូចគ្នាដែរ ហើយញុំាងកិច្ចទាំង ៤ ឲ្យសម្រេចស្រេចដោយសកិទាគាមិមគ្គចិត្តតែ ។ ខ ៣ - ព្រះអរិយបុគ្គលដែលលោកចាន់តិចារណាក្នុងព្រះអរិយសច្ចទាំង ៤ សម្រេចដោយកិច្ចទាំង ៤ ដូចគ្នា ហើយញុំាងកិច្ចទាំង ៤ ឲ្យសម្រេចស្រេចដោយអនាគាមិមគ្គចិត្តតែ ។ ខ ៤ - ព្រះអរិយបុគ្គលដែលលោកចាន់តិចារណាក្នុងព្រះអរិយសច្ចទាំង ៤ សម្រេចដោយកិច្ចទាំង ៤ ដូចគ្នា

ហើយញ៉ាំងកិច្ចទាំង ៤ ឲ្យសម្រេចស្រេចដោយព្រះអរហត្តមគ្គចិត្តពិត ។
កំព្រះអរិយបុគ្គលទាំងឡាយ ដែលលោកបានបរិស្ពាញបង់នូវគ្រឿង
សៅហ្មងគឺកិលេសតណ្ហាទាំងអស់ ក្នុងព្រះអរិយសច្ចទាំង ៤ សម្រេច
ដោយកិច្ចទាំង ៤ ធ្វើឲ្យហើយស្រេចដោយមគ្គចិត្តទាំង ៤ គឺសោតាបត្តិ-
មគ្គចិត្តមានកិច្ច ៤ សកិទាគាមិមគ្គចិត្តមានកិច្ច ៤ អនាគាមិមគ្គចិត្តមាន
កិច្ច ៤ ព្រះអរហត្តមគ្គចិត្តមានកិច្ច ៤ ត្រូវជាសោឡសកិច្ចទាំង ១៦
សម្រេចស្រេចពិត ភាលបើព្រះអរិយបុគ្គលទាំងឡាយ លោកបាន
ញ៉ាំងកិច្ចទាំង ១៦ នេះឲ្យសម្រេចស្រេចហើយតើបលោកបានសម្រេច
ដល់ព្រះអរហត្តផលចិត្តពេញទី តែថាព្រះសម្ងាសម្ពុទ្ធជាអម្ចាស់ព្រះអង្គ
ពុំបានត្រាស់ឲ្យឈ្មោះថា ផលចិត្តទេ ព្រះអង្គត្រឡប់ឲ្យឈ្មោះថា ផល-
ញ្ញាណវិញ. គឺប្រាជ្ញាដ៏ក្លៀវថាស្អាតចាប់តោងយកព្រះនិព្វានមកជាអារម្មណ៍
ជាប់ពុំដាច់ដែលជាផលរបស់សន្តានលោក ដែលថាស្អាតផ្សេងពីបរិសុទ្ធ
ផុតស្រឡះចាកកងកិលេសធម៌ទាំងអស់ពុំមានសេសសល់ ហើយព្រះ
អង្គឲ្យឈ្មោះថាព្រះនិព្វានគឺផលញ្ញាណពិត ព្រះអង្គពុំបានឲ្យឈ្មោះថាចិត្ត
ទេឡើយ, មានសេចក្តីឧបមាដូចបុគ្គលយកស្រូវមកហាលថ្ងៃហើយកំនត់ធីង
ស្ទាល់កំនត់ស្រូវ ធ្វើឲ្យអស់សមក្រៃត្រាស់ទាបញ្ជាអស់ ហៅថា អង្គរសំរូប

វិញ គេតុំបាននៅថាស្រូវខ្លីយ ទើបគេយកអង្កាំរបោះទៅជាក់
ក្តឹតស្លាល់ជាន់ប្តូរស្លាល់បុក ហើយគេជាន់ប្តូរបុកធ្វើឲ្យអស់សម្បកស្តើង ។
បេញអស់ហៅថាអង្កាំតែវិញ គេតុំបាននៅថាអង្កាំរបោះខ្លីយ ទើប
គេយកអង្កាំតែនោះ ទៅគ្រាំទឹកហើយស្រង់ខ្លឹងសំដីលហាលឲ្យស្ងួត
ខន់ជ្រាយស្រេចហើយ យកទៅកិនឱនឹងស្លាល់កិនមេរ៉ាធ្វើឲ្យល្អិតផងដឹមត៌
បត់អស់ហៅថាមេរ៉ាវិញ គេតុំបាននៅថាអង្កាំតែខ្លីយ , ទើបគេ
យកមេរ៉ានោះទៅខាក់ប្តូរនៃនឹងបង្អែរប្តូរគ្រែទៅជាដើម ធ្វើឲ្យអស់មេរ៉ា
ដែលហាយដោយដុំធំគ្រែតគ្រែតចេញ ឲ្យសល់នៅតែមេរ៉ាដែលល្អិត
មឹតផ្សេងៗហៅថាមេរ៉ាផងសុទ្ធវិញ គេតុំបាននៅថាមេរ៉ាគ្រែតគ្រែត
ខ្លីយ , មានសេចក្តីឧបមាយ៉ាងណា ព្រះអរិយបុគ្គលចាំងឡាយលោក
បានពិចារណាឃើញពោសធ្មប្បាទធម៌ជាក់ច្បាស់ថា សត្វចាំងឡាយ
តែមានបញ្ចក្ខន្ធមានរូបក្ខន្ធជាដើមកើតឡើងហើយ តែងប្រជុំសោយ
ទុក្ខវេទនាជាខម្ចន់ដោយក្រៃលែង ទើបលោកបានពិចារណាឃើញផល-
និសង្សអនុប្បាទធម៌តធម៌ដែលតុំបាននៅកើតបញ្ចក្ខន្ធទៀត តុំបាននស្ងាប់វិញ
ថាជាធម៌មានខ្លឹមសារបរិសុទ្ធម៌ត់បត់ល្អដ៏ទៀង តែព្រះនិព្វានជាក់ច្បាស់
ហើយ ទើបលោកចំព្យាយាមប្រឹងប្រែងចំរើនភាវនាទូរសមថកម្មដ្ឋាន

ឧដ្ឋិតវិបស្សនាកម្មដ្ឋាន ដើម្បីតបតំណាងយកសោតាយចិត្តជាដើម ៣ គឺកាមាវចរចិត្ត ១ រូបាវចរចិត្ត ១ អរូបាវចរចិត្ត ១ ជួបជាស្រេវគ្នា ទើបសោតាទិត្តាយមកំណៅចិត្តទាំងនោះ ឲ្យក្តៅសព្វជួបជាយកស្រេវមកហាលកំណៅថ្ងៃ សោតបានតិចារណាកងព្រះអរិយសច្ចទាំង ៤ ជួបជាយកស្រេវមកចាក់ចុះក្នុងភ្លាល់កំនស្រេវ សោតបានធ្វើកិច្ចទាំង ៤ មានបរិញ្ញាកិច្ចជាដើមឲ្យសម្រេចហើយបានលះបង់នូវសញ្ញោជន: ទាំង ៣ ឧដ្ឋិតអកុសលចិត្តទាំង ៤ ជាស្រេឡះ ជួបជាកំនស្រេវធ្វើសម្បកគ្រាស់ ឲ្យអស់ចេញ ។ សម្រេចដោយមគ្គចិត្តទី ១ ជួបជាដៃភ្លាល់កំនសម្រាប់ចាប់កំនស្រេវ សោតបានធ្វើកិច្ចទាំង ៤ ឲ្យហើយស្រេចសម្រេចផលផលចិត្តទី ១ ដែលជាផលកើតមកអំពីមគ្គចិត្តទី ១ ហៅថា សោតាបត្តិផល ដូចជាពាក្យហៅថាអង្ករសំរូប ដែលជាផលកើតមកអំពីស្រេវនោះដែរ ព្រះអរិយបុគ្គលទាំងឡាយ ដែលសោតបានទំត្តាយមចំរើនកំណៅសោតាយចិត្តដែលសល់នៅទាំងអស់ឲ្យក្តៅសព្វហើយ សោតបានតិចារណាកងព្រះអរិយសច្ចទាំង ៤ ជួបជាយកអង្ករសំរូបមកជាក់កងភ្លាល់ជានំប្លុកភ្លាល់ប្លុក សោតបានធ្វើកិច្ចទាំង ៤ មានបរិញ្ញាកិច្ចជាដើម ឲ្យសម្រេចស្រេចហើយបានលះបង់នូវសញ្ញោជន: ជាចំណែកនៃតាមជាតុទាំងប្រាំតី ៣ ខាងដើមលះបង់អស់

๒ ខាងបុណ្ណគ្រាន់តែស្តើងតិចប៉ុណ្ណោះ ឧទ្ធច្ចៈជាអកុសលចិត្តចាំង ๗ គឺ ๕ ខាងដើមជាចំជាស្រឡះ ๒ ខាងបុណ្ណ គឺបដិឃចិត្តចាំង ๒ គ្រាន់តែស្តើងតិចប៉ុណ្ណោះ ដូចជាជាន់ឬបុកអង្កាំសំរូប ឧទ្ធច្ចៈជាន់ឬត្បាល់បុកធ្វើសម្បកអង្កាំសំរូបយ៉ាងស្តើង ។ ឲ្យអស់ចេញ ។ សម្រេចដោយមគ្គចិត្តទី ๒ ដូចជាអង្រែសម្រាប់ជាន់ឬសម្រាប់បុក លោកបានធ្វើកិច្ចចាំង ๔ ឲ្យរហ័យស្រេចសម្រេចដល់ផលចិត្តទី ๒ ដែលជាផលកើតមកអំពីមគ្គចិត្តទី ๒ ហៅថា សកិទាគាមិផល ដូចពាក្យហៅថាអង្កាំសំរែតជាផលកើតមកអំពីអង្កាំសំរូបនោះដែរ ព្រះអរិយបុគ្គលចាំងឡាយដែលលោកបានទំលាយចោមចំរើនកំដៅលោភៈចិត្ត ដែលនៅសល់ចាំងអស់ឲ្យក្តៅសព្វ, លោកបានតិចារណាក្នុងព្រះអរិយសច្ចចាំង ๔ ដូចជាយកអង្កាំសំរែតដែលគ្រាំទឹករហ័យស្រង់ខ្សឺងហាលសំដៅ ឲ្យស្ងួតខន់ជ្រាយជាក់ក្នុងត្បាល់តន្ទេម្ប៉ា លោកបានធ្វើកិច្ចចាំង ๔ មានបរិញ្ញាកិច្ចជាដើមឲ្យសម្រេចស្រេចរហ័យបានលះបង់ទូសៈញ្ញោជនៈជាចំណែកនៃកាមធាតុជាខាងក្រោមចាំង ๕ ជាស្រឡះ ឧទ្ធច្ចៈជាអកុសលចិត្តចាំង ๗ ជាស្រឡះ ដូចជាកន្ទុយអង្កាំសំរែតដែលជាក់ក្នុងត្បាល់តន្ទេម្ប៉ា កន្ទុយធ្វើឲ្យល្អិតម៉ត់ជាមេម្ប៉ា សម្រេចដោយមគ្គចិត្តទី ๓ ដូចជាដៃត្បាល់តន្ទេម្ប៉ា, លោកបានធ្វើកិច្ច

តាំង ๔ ឲ្យហើយស្រេចសម្រេចផលផលចិត្តទី ๓ ដែលជាផលកើតមក
អំពីមគ្គចិត្តទី ๓ ហៅថាអនាគាមិផលដូចជាពាក្យហៅថាមេក្តាដែលជាផល
កើតមកអំពីអង្គសំរែតោះដែរ; ព្រះអរិយបុគ្គលតាំនឡាយដែលលោក
បានរំលាយដោយចំរើនកំណៅលោភៈចិត្ត ដែលសល់នៅតាំនអស់ឲ្យក្តៅ
សព្វ លោភៈបានតិចតួចណាក្នុងព្រះអរិយសច្ចតាំង ๔ ដូចជាបុគ្គលយក
មេក្តាជាក់ក្នុងចង្អេរ ឬ ក្រតៅជាដើមសម្រាប់ខាក់ ឬដែរមេក្តា លោក
បានធ្វើកិច្ចតាំង ๔ មានបរិញ្ញាកិច្ចជាដើម ឲ្យសម្រេចស្រេចហើយ
បានលះបង់នូវសញ្ញោជនៈតាំង ๑๐ នីវរណកុសលចិត្តតាំង ๑๒ បហា-
កុសលចិត្តតាំង ๘ ជាស្រេឡះ ដូចជាខាក់ ឬដែរមេក្តាធ្វើឲ្យមានដុំធំគ្រោត
គ្រាតអស់ចេញ ឲ្យសល់នៅតែមេក្តាផង់សុទ្ធ សម្រេចដោយមគ្គចិត្តទី ๔
ដូចជាចង្អេរ ឬក្រតៅជាដើម សម្រាប់ខាក់ ឬដែរ, លោកបានធ្វើកិច្ច
តាំង ๔ ឲ្យហើយស្រេចសម្រេចផលផលចិត្តទី ๔ ដែលជាផលកើតមក
អំពីមគ្គចិត្ត ๔ ហៅថា ព្រះអរហត្តផល ដូចជាមេក្តាផង់សុទ្ធជាផលកើត
មកអំពីមេក្តាលាយដោយដុំធំគ្រោតគ្រាតនោះដែរ កិសន្តិលក្ខណាជ្ឈាន
ទីពីរនៃដែលស្ងប់រម្ងាប់ចាកកាមកិលេសធម៌តាំងអស់ជាលក្ខណៈ តីព្រះ
រមតមហាឱឡាន កើតមកអំពីចិត្តពិតមែន តែព្រះសម្ពាសម្ពុទ្ធជារម្ងាស់

តុំបាននហៅថា ចិត្តទេ ព្រះអង្គហៅថា ផលញ្ញាណវិញ ។បមេយ្យដូច
មេឃ្លាផង់សុទ្ធនោះឯង ។

๑๐๔- ធម្មវិទូ បានស្តាប់ហើយពោលថា សាធុ។ ម្នាលអត្តវាទី
ប្រស្នានេះពីរកេរប្រពៃណាស៎ាហើយ តែយើងនឹងសួរប្រស្នា ๑ តទៅទៀត
ចុះបុគ្គលចាំងឡាយដែលមានប្រាថ្នានឹងត្រេចទៅកាន់មហានគរ តើព្រះ
និព្វាន ដែលជាទីពឹងជ្រកគោនស្ងប់រម្ងាប់ចាកកងកិលេសទាំងពួងជា
គុណធម៌មានជំណើរដំណើរទៀងប្រព្រឹត្តទៅខាងមុខ ជាសុខក្សេមក្សាន្តយ៉ាង
នេះ តើនឹងត្រាច់ទៅដោយយានជំនិះអ្វី ដែលគាបនឹងធ្វើដំណើរឲ្យ
បានដល់មហានគរ តើព្រះនិព្វានយ៉ាងធាប់រហ័សបាន? ចូរលោកវិសជ្ជនា
ឲ្យមានភាក្យឧបមាឧបមេយ្យប្រៀបសេចក្តីឲ្យដាយស្តាប់ យើងនឹងបាន
ស្តាប់ចូលចិត្តដោយសព្វគ្រប់ជាមិលរ ។

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី បុគ្គលចាំងឡាយដែលមាន
សេចក្តីប្រាថ្នានឹងដោះរើខ្លួនឲ្យរួចផុតស្រឡះ ចាកសង្សារទុក្ខទាំងពួង
នឹងដោះខ្លួនគេចវេះចៀសចេញទៅកាន់មហានគរ តើព្រះនិព្វាន ដែល
ជាសុខក្សេមក្សាន្តឲ្យបានដល់ធាប់រហ័សនោះ នឹងត្រាច់ទៅដោយ
យានជំនិះតុំបាន, ដោយយានសេះតុំបាន, ដោយយានថ៎កតុំបាន,

ដោយយាន មានវាសអង្រឹងសែនជាដើមក៏ពុំបាន, ដោយយានសេះ
ដើងក៏ពុំបាន, ដោយដំណើរដើរទៅដោយដើងក៏ពុំបាន, លុះតែត្រាច់
ទៅដោយពុទ្ធយាន គឺបុគ្គលមានសទ្ធាជឿជាក់ក្នុងព្រះពុទ្ធសាសនា បាន
បង្អែរកាយថ្វាយជីវិតខ្លួនចំពោះព្រះពុទ្ធជាទីពឹងទីរឭកមាំមួនមិនកក្រើកជា
យាន ១, ដោយធម្មយាន គឺបុគ្គលមានសទ្ធាជឿជាក់ក្នុងព្រះពុទ្ធសាសនា
បានបង្អែរកាយថ្វាយជីវិតខ្លួនចំពោះព្រះធម៌ជាទីពឹងទីរលឹកមាំមួន មិន
កក្រើកជាយាន ១, ដោយសង្ឃយាន គឺបុគ្គលមានសទ្ធាជឿជាក់ក្នុងព្រះ
ពុទ្ធសាសនា បានបង្អែរកាយថ្វាយជីវិតខ្លួនចំពោះព្រះសង្ឃជាទីពឹងទី
រលឹកមាំមួនមិនកក្រើកជាយាន ១, ដោយធម្មស្សវនយាន គឺបុគ្គលមាន
សទ្ធាជឿជាក់ក្នុងផលានិសង្សស្តាប់ព្រះធម៌ទំនាយមស្តាប់ព្រះធម៌ហើយ
បដិបត្តិតាមសក្ការៈតាមកក្រើកជាយាន ១, ទើបអាចនឹងត្រាច់ទៅកាន់
មហានគរ គឺព្រះនិព្វានយ៉ាងធាប់រហ័សបាន ក៏បុគ្គលទាំងឡាយដែល
មានទ្រឹង្ឋានឹងត្រូចទៅមហានគរ គឺព្រះនិព្វាននោះ រឿរលែងតែ
យានទាំង ៤ នេះបេញ្ញាហើយ ក៏មិនអាចនឹងត្រូចទៅកាន់មហានគរគឺព្រះ
និព្វាននោះបានឡើយ ។ ឯមហានគរជារលោកិយ ដែលធំទូលាយជាទី
មនោរម្យសុខក្សេមក្សាន្តសប្បាយស្ងៀតនៅគ្មានទីទ្វាយជាដរាបនាន់យោជន៍ បើ

បុគ្គលចាំងឡាយមានទ្រង់ថានឹងត្រេចទៅកាន់មហានគរនោះ ហើយឡើង
ជិះយានជំនិះផែនដី មានកំឡាំងឡាយមានយានរទេះចាស់ទីមនោចាស់
ជាដើម មានអានុភាពតិចមិនអាចញាំងកិច្ចដំណើរនោះ ឲ្យដល់មហា-
នគរបានឡើយ មុខជានឹងដល់នូវសេចក្តីអន្តរាយជាវិតក្កនិទាក់កណ្តាល
ផ្លូវនោះពុំខាន, លុះតែបានស្វែងរកយានជំនិះយ៉ាងលឿនភ្លាំង
ភ្លែក មានកំឡាំងអានុភាពច្រើន មានអាកាសយន្តឬវេហាយន្តជាដើមជិះ
ត្រេចទៅ ទើបអាចនឹងធ្វើដំណើរដែលនឹងត្រេចនោះទៅឲ្យបានដល់នូវមហា-
នគរនោះ តាមទ្រង់ថាយ៉ាងនោះហើយបានដោយពិត មានសេចក្តី
ឧបមាដូចម្តេច?

ចំណែកខាងមហានគរគឺព្រះនិព្វានដ៏ប្រសើរក្តៅក្តន់ក្តៅធំដូចជា
ជាទីអភិរម្យស្ងប់រម្ងាប់ចាកកិលេសធម៌ទាំងពួង ជាសុខក្សេមក្សាន្ត
ស្ថិតនៅក្នុងទីបំផុតសោក បំផុតភពទាំងពួងបើបុគ្គលចាំងឡាយមានទ្រង់ថា
នឹងត្រេចទៅកាន់មហានគរគឺព្រះនិព្វាននោះ ហើយវៀរឆ្ងាយផ្សឹងសាន់ឃាត
វត្តជាខាងក្រៅព្រះពុទ្ធសាសនាមកជាទីពឹងទីពួកមាំ ដែលជាយាន
ជំនិះគឺសីលប្រព្រឹត្តទុសំខន់ឯសភាវធម៌ពិត, បុគ្គលចាំងនោះមិនអាច
នឹងត្រេចទៅកាន់មហានគរ គឺព្រះនិព្វាននោះបានឡើយ; មុខជានឹងដល់

ន្លូវសេចក្តីអន្តរាយសោយទុក្ខលំបាកគោកយ៉ាកជាទម្ងន់កន្លងទីពាក់កណ្តាលផ្លូវសង្សារវដ្តនោះពុំមាន លុះបានសូន្យរសៃសរសេរសរណាត្តដ៏ខ្ពង់ខ្ពស់ដែលខ្ពាំងពួកគ មានមហិទ្ធានុភាពច្រើនជាយានតឹមានសទ្ធាផ្សឿជាក់កន្លង់គុណព្រះពុទ្ធសាសនាហើយ បានបង្វែរកាយ ថ្វាយជីវិតទ្វេនចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទន់ស្តាប់ព្រះធម៌ជាខ័ពន់ខ័រលើកមាំមួនមិនកក្រើក ជាយានដ៏ខ្ពង់ខ្ពស់ទៅបានឈ្មោះជាគ្រប់ទៅកាន់មហានគរកែវ គឺព្រះនិព្វានរោងយ៉ាងធាប់ចាស់បានដោយពិត មានសេចក្តីឧបមេយ្យដូច្នោះឯង ។

សេចក្តីនេះ សមតាមពុទ្ធភាសិតក្នុងព្រះសូត្រថា: យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ អាបទំ សោ ន គច្ឆេយ្យ អបាយគច្ឆេយ្យ បទំ សព្ភិ ។ អធិប្បាយថា: បុគ្គលឯណាមួយឱោះបុរសក្តី ស្ត្រីក្តី មានសទ្ធាផ្សឿមាំជាក់ច្បាស់ក្នុងគុណព្រះរតនត្រ័យមិនកក្រើកញាប់ញ័រឡើយហើយបានបង្វែរកាយថ្វាយជីវិតទ្វេន ចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាខ័ពន់ខ័រលើកមាំជាខ្ពង់ខ្ពស់ហើយ បុគ្គលពាលនោះពុំបានដល់នូវសេចក្តីអន្តរាយក្នុងសង្សារវដ្តឡើយ ទៀងតែនឹងត្រាស់ដឹងនូវព្រះអមតមហានិព្វានជាចំណែកលោកុត្តរធម៌ មានទ្វីមយ៉ាងខ្ពង់ខ្ពស់ ជា

ស្តុះកម្រមកប្តូនដោយចំណែកមួយតិត ។

បពិត្រធម្មាទិ ខ្ញុំអត្តាទិ ជានវិសជ្ជនាប្រស្នាជាគំរប់ ១០៤ នេះ ដោយសេចក្តីសង្ខេបតែប៉ុណ្ណេះឯង ។

សម្តែងប្តូនា - វិសជ្ជនា នូវសេចក្តីអធិប្បាយអត្ថសំខាន់បរមត្ថ ព្រះអភិធម្មសង្គ្រោះ អំពីរឿងនិទាន-ចិត្ត-ចេតសិក-រូប-និព្វាន ជានបាន ក្រងជាពាក្យ ប្តូនា វិសជ្ជនា ចំនួន ១០៤ បញ្ចប់ រៀបរៀងសេចក្តីតាំង ព្រះពុទ្ធសកាជ ២៤៨៣ មកដល់ ព. ស. ២៤៨៤ ថ្ងៃសុក្រ ១១ កេច ខែកត្តិក ឆ្នាំម្សាញ់ត្រីស័ក ទើបចប់ស្រេចបរិបូណ៌ហាន ។

អភិធម្មត្ថាធិប្បាយកថា និដ្ឋិតា ។

បញ្ជីសៀវភៅដែលផ្សាយចេញ

ពីបណ្ណាគារ ជីន - ខេង - ហួត

๑ - បទានុក្រមធម្មបទ ភាគ ๑		๑๐๐
๒ - ,, ភាគ ๒		๑๐๐
๓ - ,, ភាគ ๓		๑๐๐
๔ - និរយកថា	(ទិមណាត្រី)	๑๕
๕ - អវិដ្ឋាកថា	(កោ-សុំម)	๒๒
๖ - ខរវែកវិទ	(អ៊ុម-ទិម)	๑๕
๗ - សត្តកថា		๑๕
๘ - ភេសជ្ជក្ខន្ធក:	(ឈិម-ទួច)	๒๐
๙ - បដិចាចប្រវត្តិ	(ហែម-ហួន)	๙๐
๑๐ - ព្រះស្នាតិហ៊ិបដិចត្តិតិស្ការ	(ឈិម-ទួច និង សុង-ស៊ីវ)	๒๘
๑๑ - ទានវិនិច្ឆ័យ	(កឹម-ភ្ញ)	๒๐
๑๒ - បញ្ជាប់ក្រមសាមណេរ		๘
๑๓ - រឿងដំយប្រាជ្ញ ខ្សែ ๑	(គែ-ជុំន)	๗
๑๔ - ,, ខ្សែ ๒	(,,)	๑๒
๑๕ - សេចក្តីសំរ៉ាង	(ប ឈុំ)	๓๐
๑๖ - ប្រស្នាអធិប្បាយសាសនសុភាសិត ទី ๑	(ខួត-ទិម)	๓๐
๑๗ - ,, ទី ๒	(,,)	๒๕
๑๘ - ព្រៃព្រួនធម៌	(សុង-ស៊ីវ)	๑๒
๑๙ - ល្បើកប្រែត ទី ๑	(សុង-ស៊ីវ)	๘

๒๐ - លើកប្រែត ទី ๒	(សុង-ស៊ី)	๔๑
๒๑ - ប្រជុំនិទានជាតក ទី ๑	(,,)	๒๔๑
๒๒ - ,, ទី ๒	(,,)	๒๔๑
๒๓ - ,, ទី ๓	(,,)	๒๔๑
๒๔ - ប្រជុំនិទានជាតក ទី ๔	(សុង-ស៊ី)	๒๔๑
๒๕ - ,, ទី ๕	(,,)	๒๔๑
๒๖ - ទូរេនិទានបញ្ញា	(,,)	๑๒๑
๒๗ - កប្បកថា	(,,)	๑๒๑
๒๘ - ទាយកចរិហារ	(សុង-ស៊ី)	๑๒๑
๒๙ - ប្រស្នាបញ្ហាវិសុទ្ធិសីល	(,,)	๒๐๑
๓๐ - ព្រៃលក្ខណប្រទីប	(,,)	๑๐๑
๓๑ - កម្មប្រទីប	(,,)	๑๔๑
๓๒ - ប្រជុំកងវិន័យ	(,,)	๒๒๑
๓๓ - ប្រស្នាអនុពុទ្ធប្រវត្តិ	(ជបសុធម្មោ)	๒๐๑
๓๔ - អនាបត្តិនិទេស	(ន សមិទ្ធិ)	๒๒๑
๓๕ - សុធីវិធម៌ប្រចាំសង្គមគ្រួសារ	(សុង-ស៊ី)	๓๐๑
๓๖ - ប្រជុំវិញ្ញាសា ភ្ជាប់ទី ๖		๔๐๑
๓๗ - ភាណភិរតិសេស		๕๐๑
๓๘ - ប្រជុំបុញ្ញប្រវត្តិ	(យ៉ន វ៉ែ ន៉ង សុង-ស៊ី)	๓๐๑
๓๙ - ពចនបរិយាយ	(ព្រះយោសធម្ម កៅ-ស៊ុម)	๑๘๑

๔๐ - ព្រះរស់	(សុង-ស៊ីវ)	๑๕
๔๑ - ឧធុរសទេសនា	(សុង-ស៊ីវ)	๑๓
๔๒ - បញ្ចាវុឌ្ឍិធម៌	(ជាច់-ប្រាំង)	๘
๔๓ - ជីវិតធម្មកថា	(ព្រះមុនីកោសម្ម សូ-ហាយ)	๑๓
๔๔ - ប្រជុំពុទ្ធបញ្ញត្ត និង ពុទ្ធានុញ្ញាត្ត	(សុង-ស៊ីវ)	๑๒
๔๕ - លោកធម៌បការណ៍		๑๕
๔๖ - វិជ្ជាទេមភាសាកុហរដ្ឋាន	(រ-ក)	๑๕
๔๗ - ចរិយាណដ្ឋាន	(រ-ក)	๑๕
๔๘ - សុន្ទរកថាពិសេស		๑๐
๔๙ - នានាធម្មសំវែងពិសេស		๑๕
๕๐ - បំភ្លឺធម្មទេសនា	(ស្វាយ-សុធីរ)	๒๐
๕๑ - អត្ថាធិប្បាយទេសនាគាថ	(ឧម-ណាត្រ)	๓๐